# បណ្ឌិត្យសភានគរបាលកម្ពុជា

## កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ

# នីតិវិធី
# នៃការស៊ើបអង្កេត
# បទល្មើសជួញដូរមនុស្ស

## ភាគទី៣

២០១៧

សូមរក្សាសិទ្ធិ

# មាតិកា

**Logo and Disclaimer**
**អារម្ភកថាស្តីពីការរៀបចំសៀវភៅគោល**
**អារម្ភកថារបស់អង្គការ IJM**
**លិខិតបង្គាប់ការ**
**លិខិតថ្លែងអំណរគុណ**

**មេរៀន ៖ ការកំណត់អត្តសញ្ញាណជនសង្ស័យ និងការចាប់ខ្លួនជនសង្ស័យ**

**ជំពូកទី១ ការកំណត់អត្តសញ្ញាណជនសង្ស័យ**
**I. ការប្រមូលព័ត៌មាន** ..........១
**១. ព័ត៌មានពីប្រភពចំហ** ..........១
**២. ព័ត៌មានពីប្រភពសម្ងាត់** ..........២
**៣. ប្រភពព័ត៌មានផ្សេងទៀត** ..........២
**៤. ប្រភពព័ត៌មានរបស់មន្ត្រីនគរបាល** ..........៣
**II. ការវិភាគ និងផ្ទៀងផ្ទាត់ព័ត៌មាន** ..........៣
**១. ការវិភាគព័ត៌មាន** ..........៣
**២. ផ្ទៀងផ្ទាត់ព័ត៌មាន** ..........៣

**ជំពូកទី២ ការចាប់ខ្លួន និងឃាត់ខ្លួនជនសង្ស័យ** ..........៤
**សេចក្តីផ្តើម** ..........៤
**I. ការចាប់ខ្លួន និងឃាត់ខ្លួន** ..........៤
**១. និយមន័យ** ..........៤
**២. គោលបំណង** ..........៤
**៣. ច្បាប់អន្តរជាតិទាក់ទងនឹងការចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួន** ..........៥
**៤. ច្បាប់ជាតិ** ..........១០
**II. ការរៀបចំផែនការចាប់ខ្លួន** ..........១៤
**១. ការធ្វើផែនការចាប់ខ្លួន** ..........១៤
**២. កត្តាពិចារណាមុនការចាប់ខ្លួន** ..........២២

៣. ប្រតិបត្តិការចាប់ខ្លួន ...............................................២៣
ឯកសារយោង

**មេរៀន៖ វិធីសាស្ត្រក្នុងការស៊ើបអង្កេតករណីជួញដូរមនុស្ស**

I. សេចក្ដីផ្ដើម ...............................................១
១. ការស៊ើបអង្កេតបែបប្រតិកម្ម ...............................................១
២. ការស៊ើបអង្កេតបែបសកម្មជាមុន ...............................................៣
II. ការកសាងព័ត៌មានសម្ងាត់ ...............................................៨
១. ឱកាស ...............................................៩
២. ការគំរាមកំហែង ...............................................៩
៣. ការឆ្លើយតបចំពោះការគំរាមកំហែង ...............................................៩
III. បច្ចេកទេសបង្ក្រាបសកម្មភាព ...............................................៩
១. គោលការណ៍ណែនាំអនុវត្ត ...............................................១០
២. ដំណាក់កាលនៃការកេងប្រវ័ញ្ច ...............................................១០
ឯកសារយោង

**មេរៀន៖ ការកសាង ប្រើប្រាស់អ្នកផ្ដល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់**

សេចក្ដីផ្ដើម ...............................................១
I. អ្នកផ្ដល់ព័ត៌មាន ...............................................១
១. តើអ្នកផ្ដល់ព័ត៌មានគឺជានរណា? ...............................................១
២. ហេតុអ្វីបានជាមន្ត្រីស៊ើបអង្កេតជ្រើសរើសអ្នកផ្ដល់ព័ត៌មាន? ...............................................១
II. បណ្ដាញសម្ងាត់ ...............................................២
១. មូលដ្ឋានសម្ងាត់ ...............................................២
២. មូលដ្ឋានទុកចិត្ត (សហការីកិត្តិយស) ...............................................២
៣. ទំនាក់ទំនងប្រយោល ឬធម្មតា ...............................................៣
III. ប្រភេទនៃអ្នកផ្ដល់ព័ត៌មាន ...............................................៣

១. អ្នកផ្តល់ព័ត៌មានជាសាក្សី ....................... ៣
២. អ្នកផ្តល់ព័ត៌មានសកម្ម ....................... ៣
៣. អ្នកផ្តល់ព័ត៌មានក្នុងពន្ធនាគារ ....................... ៣
IV. ការជំរុញឱ្យមានការផ្តល់ព័ត៌មាន ....................... ៦
១. ភាពភ័យខ្លាច ....................... ៦
២. ការទិញព័ត៌មាន ....................... ៧
៣. ការសងសឹក ....................... ៧
៤. អត្តទត្ថបុគ្គល ....................... ៧
៥. គោលបំណងលាក់កំបាំង ....................... ៧
៦. ការសោរភាព ឬពលរដ្ឋល្អ ....................... ៨
V. កត្តាដែលមានឥទ្ធិពលទៅលើការសម្រេចចិត្តក្នុងការផ្តល់ព័ត៌មាន ....................... ៨
១. ការលើកទឹកចិត្ត ....................... ៨
២. ការទុកចិត្ត ....................... ៨
៣. មនសិការ ....................... ៩
VI. បុគ្គលដែលអាចក្លាយជាអ្នកផ្តល់ព័ត៌មាន ....................... ១០
១. ទំនុកចិត្ត និងជឿជាក់ ....................... ១០
២. បុគ្គលិកលក្ខណ: ....................... ១១
VII. ការកសាងអ្នកផ្តល់ព័ត៌មាន ....................... ១១
១. វិធីសាស្ត្រ ....................... ១១
២. ការរៀបចំ ....................... ១១
៣. ការឆ្លើយតប(កង្វល់) ....................... ១២
៤. បញ្ចប់នូវដំណើរការជ្រើសរើស ....................... ១២
VIII. ការគ្រប់គ្រងអ្នកផ្តល់ព័ត៌មាន ....................... ១២
១. ការសម្រេចចិត្ត ....................... ១២
២. ការទទួលខុសត្រូវ ....................... ១២
៣. ការគ្រប់គ្រងអ្នកផ្តល់ព័ត៌មាន ....................... ១៣
៤. ការទំនាក់ទំនងជាអចិន្ត្រៃយ៍ ....................... ១៣
៥. ការបណ្តុះបណ្តាល និងការណែនាំ ....................... ១៣
៦. រក្សាទំនាក់ទំនងបែបវិជ្ជាជីវៈ ....................... ១៣
៧. ការចងក្រងឯកសារអំពីសកម្មភាពការងាររបស់អ្នកផ្តល់ព័ត៌មាន ....................... ១៣

៨. ការផ្តល់ទ្រនាប់ ……………………………………………១៣
៩. ការរក្សាការសម្ងាត់ ……………………………………………១៤
១០. ការប្រុងប្រយ័ត្ន ……………………………………………១៤
១១. ការបញ្ជាក់ព័ត៌មាន ……………………………………………១៤
១២. ការផ្តល់ប្រាក់ដល់អ្នកផ្តល់ព័ត៌មាន ……………………………………………១៤
IX. ភ្នាក់ងារសម្ងាត់ ……………………………………………១៤
១. ដូចម្តេចដែលហៅថា ភ្នាក់ងារសម្ងាត់? ……………………………………………១៤
២. ការជ្រើសរើសភ្នាក់ងារសម្ងាត់ ……………………………………………១៥
៣. ការគ្រប់គ្រងលើភ្នាក់ងារសម្ងាត់ ……………………………………………១៦
សេចក្តីសង្ខេប ……………………………………………១៦
ឯកសារយោង


## មេរៀនៈ ការគ្រប់គ្រងសាក្សី និងដំណើរការសវនាការ


I. សេចក្តីផ្តើម ……………………………………………១
១. ការគ្រប់គ្រង និងការការពារសាក្សី……………………………………………១
២. ដំណើរការសវនាការ ……………………………………………២
II. សង្ខេបពីកាតព្វកិច្ចអន្តរជាតិ ស្តីពីសុវត្ថិភាព និងសុខុមាលភាពរបស់សាក្សី …………២
១. គោលការណ៍សង្ខេបពីកាតព្វកិច្ចអន្តរជាតិ ……………………………………………២
២. ស្តង់ដារអាស៊ាន-គោលការណ៍ណែនាំអាស៊ានសម្រាប់អ្នកអនុវត្តផ្ទាល់ …………៣
៣. ការការពារសាក្សី ……………………………………………៤
៤. ការពិនិត្យវាយតម្លៃពីហានិភ័យដែលអាចកើតឡើង……………………………………………៥
៥. កិច្ចដំណើរការសវនាការ ……………………………………………៩
៦. វិធានការជួយដល់ជនរងគ្រោះដទៃទៀត……………………………………………១២
៧. ការវាយតម្លៃអំពីហានិភ័យដែលអាចកើតឡើង ក្រោយពេលសវនាការ ……១៥
៨. គោលការណ៍ណែនាំនៃអនុស្សរណៈយោគយល់គ្នារវាងកម្ពុជា-ថៃ……………១៦
III. សេចក្តីសង្ខេប ……………………………………………១៧
ឯកសារយោង

## មេរៀន ៖ ការរៀបចំឡើងសវនាការ


I. សេចក្តីផ្តើម ……………………………………………………១
  ១. តួនាទីរបស់សាក្សីជានគរបាលយុត្តិធម៌ ……………………………១
  ២. ភាពគួរជឿបាន ……………………………………………………២
  ៣. អត្តចរិតរបស់សាក្សី ………………………………………………២
II. ការរៀបចំដើម្បីធ្វើបន្ទាល់ ………………………………………………៣
  ១. ការគំរាមកំហែង ឬឧបសគ្គ ……………………………………………៣
  ២. ការរៀបចំរឿងក្តី ……………………………………………………៣
  ៣. ការហាត់សម ………………………………………………………៤
  ៤. មុនដំណាក់កាលជំនុំជម្រះ …………………………………………៤
  ៥. ដំណាក់កាលជំនុំជម្រះ ………………………………………………៥
  ៦. សន្និដ្ឋាន …………………………………………………………៥
III. ដំណើរការនៃកិច្ចពិភាក្សាដេញដោល ……………………………………៦
  ១. ឥរិយាបថខាងក្រៅ …………………………………………………៦
  ២. ការឆ្លើយសំណួរ ……………………………………………………៦
  ៣. ការដើរចេញពីកន្លែងឈររបស់សាក្សី ……………………………………៧
IV. ការប្រើប្រាស់សម្លៀកបំពាក់នៅតុលាការ ………………………………៧
  ១. ទិដ្ឋភាពទូទៅ ………………………………………………………៧
  ២. អ្វីដែលមិនគួរស្លៀកពាក់ ……………………………………………៨
  ៣. ការត្រួតពិនិត្យសន្តិសុខ ……………………………………………៨
V. លំហាត់អនុវត្ត ………………………………………………………៨
VI. របៀបរៀបចំសាក្សីធ្វើបន្ទាល់ ……………………………………………៩
  ១. ដំណាក់កាលទី ១ …………………………………………………៩
  ២. ដំណាក់កាលទី ២ …………………………………………………៩
  ៣. ដំណាក់កាលទី ៣ …………………………………………………៩
VII. ការស្តាប់ចម្លើយសាក្សីនៅក្នុងសវនាការ …………………………………១០
  ១. ការសាកសួរដោយចៅក្រម និងតំណាងអយ្យការ ………………………១០
  ២. ការសាកសួរដោយមេធាវី ……………………………………………១១
VIII. ការកំណត់អត្តសញ្ញាណសាក្សី ………………………………………១១

១. ភាពជឿជាក់របស់សាក្សី ..........១១
២. ការវាយតម្លៃរបស់អ្នកស៊ើបអង្កេត ទៅលើសុក្រិតភាពរបស់សាក្សី ..........១២
IX. ការការពារសាក្សីនៅបន្ទប់សវនាការ ..........១២
១. តើសាក្សីគឺជានរណា? ..........១២
២. តួនាទីជាសាក្សី ..........១២
៣. សារសំខាន់របស់សាក្សី ..........១៣
៤. ការដាក់សាក្សីឱ្យនៅដោយឡែក ..........១៣
X. ការត្រៀមឯកសារមុនឡើងតុលាការ ..........១៤
១. ការរៀបចំនៅកន្លែងកើតហេតុ ..........១៤
២. សាក្សី ..........១៤
៣. ការរៀបចំសាក្សី ..........១៤
៤. ការរៀបចំសំណុំរឿងនៅអង្គភាពនគរបាល ..........១៤
៥. ការសម្ភាសសាក្សីនៅអង្គភាពនគរបាល ..........១៤
៦. មុនពេលជំនុំជម្រះក្តី ..........១៥
៧. កត្តាលើកទឹកចិត្ត ..........១៥
៨. ការរៀបចំនៅបន្ទប់សវនាការ ..........១៥
៩. ការឆ្លើយតបទៅសំណួររបស់មេធាវី ..........១៥
១០. ទំនាក់ទំនងរវាងសាក្សី និងមេធាវី ..........១៥
១១. មូលហេតុបណ្តាលឱ្យសក្ខីកម្មបរាជ័យ ..........១៥
XI. ទិដ្ឋភាពទូទៅលើអាចារៈនៅបន្ទប់សវនាការ ..........១៥
១. អត្ថប្រយោជន៍នៃវិជ្ជាជីវៈនៅក្នុងបន្ទប់សវនាការ ..........១៦
២. ឥរិយាបថ និងអាចារៈ ក្នុងបន្ទប់សវនាការ ..........១៦
៣. សមាសធាតុរៀបចំបន្ទាល់ ..........១៦
៤. ការប្រើប្រាស់ទម្រង់គំរូកំណត់ហេតុនៅអំឡុងពេលធ្វើបន្ទាល់ ..........១៦
៥. គោលការណ៍នៃភាពជាសាក្សី ..........១៧
៦. វិចារណ៍ទូទៅ ..........១៨
៧. ការផ្តល់អនុសាសន៍លើការធ្វើបន្ទាល់ ..........១៨
XII. លំហាត់ជាក្រុម ៖ ការសាកល្បងធ្វើបន្ទាល់នៅតុលាការ ..........២០
ឯកសារយោង

## មេរៀន ៖ ការស៊ើបអង្កេតបណ្តាញឧក្រិដ្ឋជន


I. ឧក្រិដ្ឋជនមានអង្គការចាត់តាំងនៅលើពិភពលោក ..... ១

១. និដ្ឋភាពទូទៅ ..... ១

២. សកម្មភាព ..... ១

II. ឧក្រិដ្ឋជនមានអង្គការចាត់តាំងអាស៊ី ..... ៣

III. រចនាសម្ព័ន្ធនៃឧក្រិដ្ឋជនមានអង្គការចាត់តាំង ..... ៤

IV. កម្រិតនៃការរៀបចំសម្រាប់ឧក្រិដ្ឋជនមានអង្គការចាត់តាំង ..... ៧

V. ឧក្រិដ្ឋកម្មឆ្លងដែន ៖ ការគំរាមកំហែងចំពោះសន្តិសុខ និងសន្តិភាពអន្តរជាតិ ..... ១០

១. ការកំណត់ឧក្រិដ្ឋកម្មឆ្លងដែន ..... ១០

២. ឧក្រិដ្ឋកម្មតាមតំបន់ ..... ១០

៣. ការវិវត្តនៃឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ..... ១១

៤. ភាពសំខាន់ៗនៃឧក្រិដ្ឋកម្មឆ្លងដែននៅអាស៊ីប៉ាស៊ីហ្វិក ..... ១២

៥. ផលប៉ះពាល់នៃឧក្រិដ្ឋកម្មមានអង្គការចាត់តាំងឆ្លងដែន ..... ១៣

៦. តួនាទីមន្ត្រីអនុវត្តច្បាប់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ..... ១៥

៧. កិច្ចសហប្រតិបត្តិការតាមតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ..... ១៥

៨. កិច្ចសហប្រតិបត្តិការអន្តរជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ..... ១៨

៩. ទស្សនវិស័យ ..... ១៩

១០. ឧក្រិដ្ឋជនមានអង្គការចាត់តាំង និងគ្រឿងញៀននៅកម្ពុជា ..... ២០

VI. ការគ្រប់គ្រងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងអំពើពុករលួយ ..... ២១

១. កត្តាសេដ្ឋកិច្ច-សង្គម ..... ២២

២. បរិយាកាសនយោបាយ ..... ២២

៣. ប្រព័ន្ធយុត្តិធម៌ ..... ២២

៤. អភិបាលកិច្ចផ្នែកឯកជន ..... ២៣

៥. អភិបាលកិច្ចផ្នែកសាធារណៈ ..... ២៣

៦. ឯករាជ្យភាព និងសុចរិតភាពរបស់តុលាការ ..... ២៣

៧. បញ្ហានីតិបញ្ញត្តិ និងឧបករណ៍ស៊ើបអង្កេត ..... ២៣

VII. ការចោទប្រកាន់ចំពោះក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ..... ២៥

១. ការចោទប្រកាន់ ..... ២៥

២. កិច្ចសហប្រតិបត្តិការអន្តរជាតិ ..... ២៦

៣. វិធីសាស្ត្រជាក់លាក់នៃកិច្ចសហប្រតិបត្តិការ……………………………………………២៦
VIII. ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ……………………………………………………………២៧
IX. ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងក្នុងការជួញដូរមនុស្ស…………………………………២៩
១. ទិដ្ឋភាពទូទៅ ……………………………………………………………២៩
២. ការជាប់ទាក់ទងនឹងទេសន្តរប្រវេសន៍ខុសច្បាប់…………………………………………៣០
៣. ភាពលំបាកដែលប្រឈមនឹងមន្ត្រីអនុវត្តច្បាប់…………………………………………៣១
X. ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងភេរវកម្ម…………………………………………………៣២
១. និន្នាការ ……………………………………………………………៣២
២. ភេរវកម្ម ……………………………………………………………៣៣
XI. ការឆ្លើយតបចំពោះការគំរាមកំហែងនៃឧក្រិដ្ឋកម្មអន្តរជាតិ……………………………………៣៣
១. គោលបំណង ……………………………………………………………៣៤
២. កម្មវិធី និងការផ្តួចផ្តើម ……………………………………………………………៣៤
៣. ការស៊ើបការណ៍ ……………………………………………………………៣៥
៤. ការកាត់បន្ថយអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មលើកុមារ……………………………៣៥
៥. កិច្ចខិតខំប្រឹងប្រែងប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា…………………………៣៦
៦. ការស្រាវជ្រាវបញ្ហាដែលកំពុងកើតឡើង………………………………………………៣៧
XII. គោលការណ៍ផ្សេងៗដើម្បីប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង………៣៧
ឯកសារយោង

This curriculum has been prepared by the Police Academy of Cambodia along with the Anti-Human Trafficking and Juvenile Protection Department (AHTJPD) of the Cambodian National Police and International Justice Mission (IJM), with contributions from the Australia-Asia-Program-to-Combat-Trafficking-in-Persons (AAPTIP) and is part of the Cambodia Countering Trafficking-in-Persons program funded by the United States Agency for International Development (USAID) and implemented by Winrock International.

*Disclaimer: This curriculum is made possible by the generous support of the American people through USAID. The contents are the responsibility of the Police Academy of Cambodia, the AHTJPD and IJM and do not necessarily reflect the views of USAID or the United States Government.*

# អារម្ភកថា

នៅចុងទសវត្សរ៍នេះ អំពើជួញដូរមនុស្សបានប្រែក្លាយជាបញ្ហាសកល ហើយកំពុងគំរាមកំហែង និងបន្តធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សេដ្ឋកិច្ច បុគ្គល គ្រួសារ និងសង្គម ។ ជនល្មើសនៃអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងរត់ពន្ធមនុស្ស បាននឹងកំពុងធ្វើសកម្មភាពលាក់កំបាំង ដែលជាការព្រួយបារម្ភ របស់សហគមន៍ សមត្ថកិច្ច និងរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាប្រទេសក្នុងតំបន់ និងនៅលើពិភពលោក ។

ក្រសួងមហាផ្ទៃបានបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីធ្វើការស្រាវជ្រាវតាក់តែងរៀបចំជាគោលការណ៍ជាតិដ៏មានសារសំខាន់ ជាពិសេសសម្របសម្រួលកែលម្អនូវលិខិតបទដ្ឋានគតិយុត្តិ បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ។

នាយកដ្ឋានប្រឆាំងការជួញមនុស្ស និងការពារអនីតិជន ត្រូវបានបង្កើតឡើងជាសេនាធិការឱ្យក្រសួងមហាផ្ទៃ ដើម្បីសហការជាមួយក្រសួងពាក់ព័ន្ធ ភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការដៃគូក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើរត់ពន្ធមនុស្ស ។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងយោងតាមអនុសាសន៍ដ៏មានតម្លៃរបស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តមនាយឧត្តមសេនីយ៍ **សេខ ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា បានចាត់ទុកអំពើជួញដូរមនុស្ស គឺជាបទឧក្រិដ្ឋដែលមិនអាចមើលរំលងបាន ហើយក៏ជាការងារអាទិភាពមួយ ក្នុងចំណោមការងារអាទិភាពដទៃទៀតសម្រាប់បណ្ឌិត្យសភានគរបាលកម្ពុជា ធ្វើការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិ លើមុខវិជ្ជាស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

បណ្ឌិត្យសភានគរបាលកម្ពុជា បាលរួមសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ក្រោមការឧបត្ថម្ភគាំទ្រថវិកា របស់ទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាម៉េរិក (USAID) តាមរយៈអង្គការវីនរ៉ក់អន្តរជាតិ (WINROCK) ក្នុងការរៀបចំសៀវភៅគោលស្តីពី **នីតិវិធីនៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស** មាន៖

**ភាគទី១**

១. ក្រមសីលធម៌មន្ត្រីអនុវត្តច្បាប់

២. ទិដ្ឋភាពទូទៅស្តីពីក្របខណ្ឌគតិយុត្តិពាក់ព័ន្ធអំពើជួញដូរមនុស្សនៅកម្ពុជា

៣. ការប្រមូលព័ត៌មានព្រហ្មទណ្ឌ

៤. ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ និងការសរសេររបាយការណ៍

៥. ការប្រមូល និងថែរក្សារូបកស្តុតាង

**ភាគទី២**

៦. បច្ចេកទេសសម្ភាស

៧. ការសម្ភាសជនរងគ្រោះជាសាក្សី

៨. ការសម្ភាសជនសង្ស័យ

៩. ការកំណត់អត្តសញ្ញាណ និងការប្រព្រឹត្តលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស

**ភាគទី៣**

១០. ការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួនជនសង្ស័យ

១១. វិធីសាស្ត្រក្នុងការស៊ើបអង្កេតករណីជួញដូរមនុស្ស

១២. ការកសាង ប្រើប្រាស់អ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់

១៣. ការគ្រប់គ្រងសាក្សី និងដំណើរការសវនាការ

១៤. ការរៀបចំឡើងសវនាការ

១៥. ការស៊ើបអង្កេតបណ្តាញឧក្រិដ្ឋជន

ការរៀបចំសៀវភៅគោលនេះ គឺសម្រាប់បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងអភិវឌ្ឍសមត្ថភាព អំពីនីតិវិធីក្នុងការស៊ើបអង្កេតបទល្មើស ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយសង្គ្រោះជនរងគ្រោះ ។

IJM

# Preface

International Justice Mission has been honoured to collaborate with the Police Academy of Cambodia and Anti-Human Trafficking and Juvenile Protection Department in the creation of this comprehensive manual on Human Trafficking Investigations.

The publication of this series of training modules marks a significant step forward in the effort to eradicate human trafficking in Cambodia. It is unique in its depth and breadth on the topic, and it carries considerable weight because it is a curriculum created *by* the experts of the Cambodian National Police *for* the benefit of all Cambodian law enforcement officers. It is our hope that this curriculum will equip and empower *every* Cambodian police officer to address human trafficking when they see it, from the newest recruit to the most seasoned officer. It has been carefully designed to be adaptable for use at recruit-level right through to honing the skills of experienced Anti-Trafficking experts.

IJM would like to extend special thanks and congratulations to His Excellency General Seng Phally and His Excellency Lieutenant General Pol Phie They for their support of this work, and to PAC Trainers, Lt. Gen. Khim Sovannavuth, Lt. Gen. Ros Sarith, Maj. Gen. Sen Sathya, Maj. Gen. Uon Sokhon, Brig. Gen. Be Sahor, Brig. Gen. Chan Sophea and AHTJPD Trainer, Maj. Gen. Kim Pheap for their painstaking effort in compiling and refining this curriculum. IJM also wishes to appreciate the great efforts of the International Organisation for Migration (IOM) and Australia-Asia-Program-to-Combat-Trafficking-in-Persons (AAPTIP) to counter trafficking in Cambodia, who have been valued collaborators and partners in this effort, and the support of USAID's Cambodia Counter-Trafficking in Persons program implemented by Winrock International.

IJM continues to be inspired by the commitment of the officers of the CNP, and grateful for the ongoing collaboration, trust and partnership we enjoy. We hope and trust this curriculum will be of value to you all for many years to come.

Phnom Penh, April 20th, 2017

Director

P. Williams

ភីធ័រ វីល្លៀម

IJM

# Preface

International Justice Mission has been honoured to collaborate with the Police Academy of Cambodia and Anti-Human Trafficking and Juvenile Protection Department in the creation of this comprehensive manual on Human Trafficking Investigations.

The publication of this series of training modules marks a significant step forward in the effort to eradicate human trafficking in Cambodia. It is unique in its depth and breadth on the topic, and it carries considerable weight because it is a curriculum created *by* the experts of the Cambodian National Police *for* the benefit of all Cambodian law enforcement officers. It is our hope that this curriculum will equip and empower *every* Cambodian police officer to address human trafficking when they see it, from the newest recruit to the most seasoned officer. It has been carefully designed to be adaptable for use at recruit-level right through to honing the skills of experienced Anti-Trafficking experts.

IJM would like to extend special thanks and congratulations to His Excellency General Seng Phally and His Excellency Lieutenant General Pol Phie They for their support of this work, and to PAC Trainers, Lt. Gen. Khim Sovannavuth, Lt. Gen. Ros Sarith, Maj. Gen. Sen Sathya, Maj. Gen. Uon Sokhon, Brig. Gen. Be Sahor, Brig. Gen. Chan Sophea and AHTJPD Trainer, Maj. Gen. Kim Pheap for their painstaking effort in compiling and refining this curriculum. IJM also wishes to appreciate the great efforts of the International Organisation for Migration (IOM) and Australia-Asia-Program-to-Combat-Trafficking-in-Persons (AAPTIP) to counter trafficking in Cambodia, who have been valued collaborators and partners in this effort, and the support of USAID's Cambodia Counter-Trafficking in Persons program implemented by Winrock International.

IJM continues to be inspired by the commitment of the officers of the CNP, and grateful for the ongoing collaboration, trust and partnership we enjoy. We hope and trust this curriculum will be of value to you all for many years to come.

Phnom Penh, April 20th, 2017

Director

គីធ័រ វីល្លៀម

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
**បណ្ឌិត្យសភានគរបាលកម្ពុជា**

លេខ :..០១៥......ណ.ប៥

# លិខិតបង្គាប់ការ

- យោងតាមសំណូមពររបស់អង្គការអន្តរជាតិទេសន្តប្រវេសន៍ប្រចាំកម្ពុជា
- យោងតាមសំណូមពររបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិប្រចាំកម្ពុជា
- យោងតាមភាពចាំបាច់របស់បណ្ឌិត្យសភានគរបាលកម្ពុជា

ត្រូវបានបង្កើតក្រុមការងាររបស់បណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីសហការនិងសម្របសម្រួលជាមួយ អង្គការអន្តរជាតិទេសន្តប្រវេសន៍ប្រចាំកម្ពុជា និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិប្រចាំកម្ពុជា ក្នុងការរៀបចំផែនការ កម្មវិធីបណ្តុះបណ្តាល និង ខ្លឹមសារបង្ហាត់បង្រៀន ពាក់ព័ន្ធនឹងជំនាញ ទេសន្តប្រវេសន៍ អំពើរត់ពន្ធជនទេសន្តប្រវេសន៍ អំពើជួញដូរមនុស្ស និង ការគ្រប់គ្រងព្រំដែន ដែលមានសមាសភាព និង ភារកិច្ច ដូចខាងក្រោម ៖

**ក.សមាសភាព**

ក្រុមការងាររបស់បណ្ឌិត្យសភានគរបាលកម្ពុជា រួមមាន ៖

១. លោកឧត្តមសេនីយ៍ទោ យឹម សុវណ្ណារ៉ុង អត្តលេខ ០៩៥៥ គ្រូនគរបាលជាតិ ប្រធាន
២. លោកឧត្តមសេនីយ៍ទោ រស់ សារិទ្ធ អត្តលេខ ០៨០១ គ្រូនគរបាលជាតិ អនុប្រធាន
៣. លោកឧត្តមសេនីយ៍ទោ អ៊ួន សុខន អត្តលេខ ០៤៨៩០ គ្រូនគរបាលជាតិ សមាជិក
៤. លោកឧត្តមសេនីយ៍ទោ សេន សត្យា អត្តលេខ ០៥៨៥៤ គ្រូនគរបាលជាតិ សមាជិក
៥. លោកវរសេនីយ៍ឯក បេ សាហោ អត្តលេខ ៣០៥២៣ គ្រូនគរបាលជាតិ សមាជិក
៦. លោកវរសេនីយ៍ឯក ចាន់ សុភា អត្តលេខ ០៥៨៨៤ គ្រូនគរបាលជាតិ សមាជិក

ក្រុមការងាររបស់អង្គការអន្តរជាតិទេសន្តប្រវេសន៍ប្រចាំកម្ពុជា IOM រួមមាន ៖

១. លោក ប្រិដ ឌិកសិន (Mr. Brett Dickson) ប្រធានគម្រោង
២. លោក កេង ម៉េងឡាង មន្រ្តីគម្រោង
៣. លោក នុត សំអុល ជំនួយការគម្រោង

ក្រុមការងាររបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិប្រចាំកម្ពុជា IJM រួមមាន ៖

១. លោកស្រី ម៉ារី ហេល័រ (Mrs. Mary Heller) នាយិកាផ្នែកស៊ើបអង្កេត
២. លោក កែ ហុកស៊្រុន អ្នកសម្របសម្រួលនិងត្រួតពិនិត្យការបណ្តុះបណ្តាល

ខ. ភារកិច្ច

- សហការ សម្របសម្រួល រៀបចំ ផែនការ កម្មវិធីការងារ សម្រាប់ដំណើរការ

-រៀបចំខ្លឹមសារមេរៀន និង ពិនិត្យពិភាក្សា លើខ្លឹមសារមេរៀន ដើម្បីរៀបចំ បោះពុម្ព ជាសៀវភៅគោល សម្រាប់ប្រើប្រាស់ក្នុងកម្មវិធីបណ្តុះបណ្តាល

-រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល សម្រាប់ដំណើរការបង្ហាត់បង្រៀន តាមកម្មវិធីអប់រំរបស់បណ្ឌិត្យសភានគរបាលកម្ពុជា

-រាយការណ៍អំពីសកម្មភាពនិងលទ្ធផលការងារ ជាបន្តបន្ទាប់ ជូនឯកឧត្តមប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍគ្រូនគរបាលជាតិ

ក្រុមការងារមានសិទ្ធិប្រើប្រាស់ មន្ត្រី ឬ បុគ្គលិកក្រោមឱវាទរបស់ខ្លួន សម្រាប់ជួយបំពេញការងារ ដើម្បីសម្រេចភារកិច្ច ដោយជោគជ័យ ។

ឯកឧត្តម អស់លោក លោកស្រី ដែលមានរាយនាមក្នុងលិខិតបង្គាប់ការនេះ ត្រូវអនុវត្តភារកិច្ចរបស់ខ្លួន ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

ជីតជូ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

**នាយឧត្តមសេនីយ៍ សេង ផល្លី**

កន្លែងទទួលៈ

- ថ្នាក់ដឹកនាំបណ្ឌិត្យសភានគរបាលកម្ពុជា
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
បណ្ឌិត្យសភានគរបាលកម្ពុជា

លេខ: ៤០៩ ល.ឧ.ក

# លិខិតថ្លែងអំណរគុណ

ការគាំទ្រលើកម្មវិធីកាត់បន្ថយអំពើជួញដូរមនុស្ស រត់ពន្ធមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ កំពុងតែកើតមាននៅជុំវិញពិភពលោក ។ ឯកសារសម្រាប់បណ្តុះបណ្តាលមន្រ្តីអនុវត្តច្បាប់ ស្តីពី នីតិវិធីនៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស ត្រូវបានរៀបចំតាក់តែងឡើងតាមលិខិតបង្គាប់ការលេខ០១៨ ល.ប.ក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ របស់បណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីឱ្យក្រុមការងាររៀបចំផែនការ កម្មវិធីបណ្តុះបណ្តាល និងខ្លឹមសារមេរៀនរវាងបណ្ឌិត្យសភានគរបាលកម្ពុជា សហការជាមួយ អង្គការបេសកកម្មយុត្តធម៌អន្តរជាតិ ។

ឆ្លងតាមការពិនិត្យ ពិភាក្សានិងកែសម្រួល របស់ក្រុមប្រឹក្សាអភិវឌ្ឍគ្រូនគរបាលជាតិ នៃបណ្ឌិត្យសភានគរបាលកម្ពុជា សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ដោយមានតំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងក្រុមមេធាវីរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ជាអ្នកពិគ្រោះយោបល់ ទើបបានបញ្ចប់ការពិនិត្យ ពិភាក្សានិងកែសម្រួលនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧។

បណ្ឌិត្យសភានគរបាលកម្ពុជាសង្ឃឹមថា សៀវភៅគោល ស្តីពីនីតិវិធីនៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស ជាមូលដ្ឋានគ្រឹះក្នុងការបណ្តុះបណ្តាលមន្រ្តីអនុវត្តច្បាប់ ឱ្យយល់ដឹងកាន់តែច្បាស់ ដើម្បីអនុវត្ត ភារកិច្ច មានប្រសិទ្ធភាពខ្ពស់ក្នុងស្មារតីទទួលខុសត្រូវ គោរពច្បាប់ គោរពសិទ្ធិមនុស្ស និងជួយឱ្យប្រជាពលរដ្ឋទទួលបាននូវផលប្រយោជន៍ដោយមិនមានការរើសអើង ។

ក្នុងនាមប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ក្រុមការងាររបស់បណ្ឌិត្យសភានគរបាលកម្ពុជា អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ( IJM) តំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រុមមេធាវីរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងក្រោមការឧបត្ថម្ភថវិកាពី អង្គការ USAID និង WINROCK ដែលបានរួមចំណែកយ៉ាងសកម្មយកអស់កម្លាំងកាយចិត្ត ផ្តល់នូវបច្ចេកទេស និងថវិកាក្នុងការរៀបចំ កែសម្រួលសៀវភៅគោលខាងលើ ។

ធ្វើនៅដីឥដ្ឋថ្ងៃទី១៧ ខែ មេសា ឆ្នាំ២០១៧

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ **សេង ផល្លី**

USAID
WINROCK INTERNATIONAL
IJM

# បណ្ឌិត្យសភាគរបាលកម្ពុជា

## កម្មវិធីបណ្ដុះបណ្ដាលនគរបាលជាតិ

# ការកំណត់អត្តសញ្ញាណ
# និងការចាប់ខ្លួនជនសង្ស័យ

២០១៧

សូមរក្សាសិទ្ធិ

មេរៀននេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការវីនរ៉ក់ ឬរដ្ឋាភិបាលអាមេរិក

# ការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួនជនសង្ស័យ

## ជំពូកទី១
## ការកំណត់អត្តសញ្ញាណជនសង្ស័យ

ការកំណត់អត្តសញ្ញាណជាវិធានការស្រាវជ្រាវមួយដែលត្រូវបានដំណើរការដោយមន្ត្រីនគរបាលយុត្តិធម៌ សំដៅបំភ្លឺភាពដូចគ្នា ឬផ្សេងគ្នារវាងជនសង្ស័យ ដែលត្រូវកំណត់អត្តសញ្ញាណ ជាមួយនឹងជនសង្ស័យផ្សេងទៀតពាក់ព័ន្ធដល់បទល្មើស ដែលអ្នកកំណត់ភិនភាគបានសង្កេតឃើញ ហើយប្រៀបធៀបអំពីលក្ខណៈពិសេសនៃស្លាកស្នាមរបស់ជនសង្ស័យ ដើម្បីកំណត់ថាតើដូចគ្នា ឬខុសគ្នា ។

ការកំណត់អត្តសញ្ញាណ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ក្នុងការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ សំខាន់សម្រាប់បទល្មើស ដែលមិនទាន់ជាក់លាក់អំពីជនល្មើស ។ ការកំណត់អត្តសញ្ញាណអាចជួយឱ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រមូលបាននូវឯកសារដើម្បីពង្រឹងភស្តុតាងបំភ្លឺការពិតនៃបទល្មើស ។

គោលបំណងនៃការកំណត់អត្តសញ្ញាណ គឺដើម្បីកំណត់ភាពដូចគ្នា ឬខុសគ្នារវាងជនសង្ស័យចំពោះមុខ ជាមួយនឹងជនសង្ស័យដែលបានជួបប្រទះនាពេលកន្លងមក ។

### I. ការប្រមូលព័ត៌មាន

ការប្រមូលព័ត៌មាន គឺពាក់ពន្ធ័នឹងការប្រមូល ការវិភាគ ការបញ្ជូន និងការរក្សាទុកព័ត៌មានដែលទាក់ទងដល់ការស៊ើបអង្កេត ។ ការប្រមូលព័ត៌មានរួមមាន ៖

- ព័ត៌មានពីប្រភពចំហ
- ព័ត៌មានពីប្រភពសម្ងាត់
- ប្រភពព័ត៌មានផ្សេងទៀត
- ប្រភពព័ត៌មានរបស់មន្ត្រីនគរបាល ។

#### ១. ព័ត៌មានពីប្រភពចំហ

ព័ត៌មានពីប្រភពចំហ គឺជាព័ត៌មានដែលទទួលបានមកពីសាធារណជន ស្តែងចេញមកតាមតាមរយៈ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី រូបភាព ឬប្រព័ន្ធអេឡិចត្រូនិក ។ អត្ថប្រយោជន៍នៃព័ត៌មានពីប្រភពចំហ អាចងាយរកបាន ហើយប្រមូលផ្តុំនូវព័ត៌មានជាច្រើនដែលធ្វើឱ្យអ្នកប្រមូលព័ត៌មាន មានការងាយស្រួលក្នុងការស្វែងរក ។ ក្នុងករណីភាគច្រើន ការប្រមូលព័ត៌មានពីប្រភពចំហគឺស្របច្បាប់ ហើយអ្នកប្រមូលមិនទទួលរងនូវគ្រោះថ្នាក់ ចំពោះការបញ្ជូនឱ្យស៊ើបអង្កេត និងត្រូវចោទប្រកាន់ ។ គេអាចទាញយកព័ត៌មានដែលងាយនឹងប្រែប្រួលនេះតាមរយៈការវិភាគ និងវាយតម្លៃទិន្នន័យដែលទាក់ទងដល់មនុស្ស សកម្មភាព ឬទីកន្លែងជាក់លាក់ណាមួយ ។

### ២. ព័ត៌មានពីប្រភពសម្ងាត់

អ្នកផ្តល់ព័ត៌មាន ជាជនដែលមិនមែនជាមន្ត្រីអនុវត្តច្បាប់ ប៉ុន្តែដោយសារបានស្គាល់ច្បាស់ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងជនល្មើស បានផ្តល់ព័ត៌មានអំពីសកម្មភាពបទល្មើស សម្រាប់ការស៊ើបអង្កេត ដល់មន្ត្រីអនុវត្តច្បាប់ ។ មានកត្តាមួយចំនួនដែលគួរត្រូវពិចារណា ក្នុងពេលសម្ភាសអ្នកផ្តល់ព័ត៌មាន ។ ជាទូទៅអ្នកផ្តល់ព័ត៌មាន ៖

- អាចមានអារម្មណ៍ភ័យខ្លាច និងប្រយ័ត្នប្រយែង
- អាចបង្កើនកម្រិតនៃការភ័យខ្លាច ដែលបណ្តាលឱ្យពួកគេមិនព្រមផ្តល់ព័ត៌មាន
- អាចសាកល្បងអំពីបុគ្គលិកលក្ខណៈរបស់អ្នកស៊ើបអង្កេត

អ្នកផ្តល់ព័ត៌មានសម្ងាត់ អាចជាអ្នកផ្តល់ព័ត៌មានដែលគួរឱ្យជឿទុកចិត្ត អ្នកផ្តល់ព័ត៌មានអនាមិក អ្នកផ្តល់ព័ត៌មានម្តងម្កាល និងអ្នកផ្តល់ព័ត៌មានទៀងទាត់ ។

### ៣. ប្រភពព័ត៌មានផ្សេងទៀត

ប្រភពព័ត៌មានផ្សេងទៀត ដែលមន្ត្រីអនុវត្តច្បាប់អាចរកបាន ទាក់ទងនឹងប្រភពផ្លូវការ និងក្រៅផ្លូវការ ។

#### ក. ប្រភពព័ត៌មានផ្លូវការ

- របាយការណ៍បទល្មើស
- របាយការណ៍ស៊ើបអង្កេត
- របាយការណ៍ចាប់ខ្លួន ។

ក្រៅពីប្រភពទាំងនេះ កិច្ចសហប្រតិបត្តិការជាមួយនឹងមន្ត្រីអនុវត្តច្បាប់ជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល អាចនាំមកនូវប្រភព និងតម្រុយដ៏សំខាន់នៃព័ត៌មាន ។ ដោយសារតែការស៊ើបអង្កេតការរត់ពន្ធមនុស្ស និងទាសភាពផ្លូវភេទ ពាក់ព័ន្ធដល់អង្គការ ស្ថាប័នរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលជាច្រើន ទើបកិច្ចសហប្រតិបត្តិការបានក្លាយជាសមាសធាតុសំខាន់ចំពោះការស៊ើបអង្កេត ។

#### ខ. ប្រភពព័ត៌មានក្រៅផ្លូវការ

- ទីភ្នាក់ងារលក់សំបុត្រយន្តហោះ
- ឯកសារចុះឈ្មោះនៅសណ្ឋាគារ និងភោជនីយដ្ឋាន
- ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ
- ក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណេត
- ស្ថាប័នធនាគារ
- អ្នកបើកបររថយន្តឈ្នួល ។

### ៤. ប្រភពព័ត៌មានរបស់មន្ត្រីនគរបាល

- ការសម្ភាស
- ពាក្យបណ្តឹង
- អត្តសញ្ញាណកម្មតាមរយៈការតម្រង់ជួរ
- អត្តសញ្ញាណកម្មតាមរយៈរូបថត ។

## II. ការវិភាគ និងផ្ទៀងផ្ទាត់ព័ត៌មាន

### ១. ការវិភាគព័ត៌មាន

ការវិភាគនូវបណ្តុំព័ត៌មានដែលប្រមូលបានពីប្រភពនានា គឺដើម្បីធ្វើការកំណត់អត្តសញ្ញាណ និងនិន្នាការរបស់ជនដែលបានប្រព្រឹត្តបទល្មើស ។ ការវិភាគព័ត៌មានធ្វើចំណាត់ថ្នាក់ពីបរិមាណទិន្នន័យដើមដ៏ច្រើនចេញពីមូលដ្ឋានទិន្នន័យដែលត្រូវបានប្រើប្រាស់ ។

- វិភាគគ្រប់ព័ត៌មានដែលពាក់ព័ន្ធដល់រឿងហេតុ
- ពិចារណាឱ្យបានល្អិតល្អន់ តាមលំដាប់លំដោយនៃខ្លឹមសារព័ត៌មាន
- ធ្វើការសន្និដ្ឋាន វាយតម្លៃ និងផ្ទៀងផ្ទាត់ទៅលើខ្លឹមសារព័ត៌មាន ។

### ២. ផ្ទៀងផ្ទាត់ព័ត៌មាន

មន្ត្រីស៊ើបអង្កេតត្រូវផ្ទៀងផ្ទាត់ព័ត៌មានដែលពួកគេទទួលបានមកពីប្រភពផ្សេងៗគ្នា រួមទាំងការសម្ភាសជនសង្ស័យ សាក្សី និងជនរងគ្រោះ ។ ការផ្ទៀងផ្ទាត់ព័ត៌មានមានសារៈសំខាន់ សម្រាប់ហេតុផលមួយចំនួន ៖

- ការកំណត់ភាពចាំបាច់សម្រាប់ការស៊ើបអង្កេតបន្ថែម
- ការកំណត់គោលបំណងនៃការស៊ើបអង្កេត
- បញ្ជាក់ពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃព័ត៌មាន
- ទទួលបានភស្តុតាងជាក់លាក់សម្រាប់ការស៊ើបអង្កេត និងការបញ្ជូនសំណុំរឿង
- ធានាពីបច្ចុប្បន្នភាពនៃព័ត៌មាន ។

ដំណើរការនៃការផ្ទៀងផ្ទាត់អាចទាក់ទងដល់ការកំណត់អត្តសញ្ញាណជនសង្ស័យ ។

# ជំពូកទី២
# ការចាប់ខ្លួន និងឃាត់ខ្លួនជនសង្ស័យ

## សេចក្តីផ្តើម

ការចាប់ខ្លួន គឺបង្ហាញពីការរំលោភដ៏ធ្ងន់ធ្ងរមួយទៅលើសិទ្ធិរបស់បុគ្គលណាម្នាក់។ គោលការណ៍នៃនីត្យានុកូល និងភាពចាំបាច់ ស្របជាមួយនឹងការហាមឃាត់ទៅលើការប្រើប្រាស់អំណាចដោយបំពាន បានតម្រូវឱ្យការអនុវត្តរបស់មន្ត្រីអនុវត្តច្បាប់ ឆ្លើយតបទៅនឹងតម្រូវការមួយចំនួននៅក្នុងស្ថានភាពនៃការចាប់ខ្លួន ។ សេចក្តីតម្រូវទាំងនោះ គឺទាក់ទងទៅនឹងចំណេះដឹងខាងផ្នែកច្បាប់ និងនីតិវិធីដែលត្រូវធ្វើទៅតាមស្ថានភាពជាក់លាក់ណាមួយ ដែលនាំឱ្យមានការដកសិទ្ធិសេរីភាព ។ ដូចនេះ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន ឬដាក់ពន្ធនាគារ តម្រូវឱ្យធ្វើទៅតាមច្បាប់យ៉ាងតឹងរ៉ឹង និងអនុវត្តដោយមន្ត្រីមានសមត្ថកិច្ច ឬបុគ្គលដែលមានការអនុញ្ញាតឱ្យធ្វើដូចនេះ ។

ច្បាប់ជាតិ ច្បាប់អន្តរជាតិ និងស្តង់ដានានា គឺបានកំណត់លក្ខខណ្ឌ និងផ្តល់បញ្ញត្តិទាក់ទងនឹងការចាប់ខ្លួន ។ វាគឺជាកាតព្វកិច្ចរបស់មន្ត្រីអនុវត្តច្បាប់ ក្នុងការអនុវត្តទៅតាមលក្ខខណ្ឌទាំងអស់នេះ ដើម្បីធានាថា ពួកគេមិនបានធ្វើការចាប់ខ្លួនដោយខុសច្បាប់ នៅពេលពួកគេតម្រូវឱ្យធ្វើការចាប់ខ្លួន ជនសង្ស័យប្រព្រឹត្តអំពើជួញដូរមនុស្ស ។

## I. ការចាប់ខ្លួន និងឃាត់ខ្លួន

### ១. និយមន័យ

ការចាប់ខ្លួន គឺជាវិធីសាស្ត្រដើម្បីធានាថា ជនជាប់ចោទមានវត្តមាននៅចំពោះមុខតុលាការក្នុងពេលសវនាការរឿងក្តី ។ ការចាប់ខ្លួន មិនមានន័យថា ជាការផ្តន្ទាទោសឡើយ ។ គោលការណ៍សច្ចធារណ៍នៃនិរទោសកំណត់ថា ជនជាប់ចោទត្រូវចាត់ទុកជាជនគ្មានទោស រហូតដល់មានការផ្តន្ទាទោសជាស្ថាពរ ។

### ២. គោលបំណង

មន្ត្រីអនុវត្តច្បាប់ គួរកត់សម្គាល់ថា ការចាប់ខ្លួនជនណាម្នាក់ គួរតែធ្វើឡើង នៅពេលមានការអនុញ្ញាតដោយច្បាប់ ។ នៅពេលការអនុញ្ញាតឱ្យចាប់ខ្លួនដោយគ្មានដីកា មន្ត្រីអនុវត្តច្បាប់ដែលពាក់ព័ន្ធត្រូវបានគេផ្តល់អំណាចឆន្ទានុសិទ្ធក្នុងការចាប់ខ្លួនបុគ្គលណាម្នាក់ ។ ដូចនេះ មន្ត្រីអនុវត្តច្បាប់មិនត្រូវបានបង្ខំឱ្យប្រើប្រាស់អំណាចរបស់ខ្លួន ក្នុងការចាប់ខ្លួនបុគ្គលណាមួយឡើយ ។ នៅក្នុងការអនុវត្តឆន្ទានុសិទ្ធនេះ មន្ត្រីអនុវត្តច្បាប់ត្រូវពិចារណាទៅលើទង្វើផ្សេងៗ និងត្រូវពិចារណាដោយប្រុងប្រយ័ត្នពីអ្វីដែលពួកគេចង់បំពេញភារកិច្ច តាមរយៈការចាប់ខ្លួនបុគ្គលណាម្នាក់ ។

ជនសង្ស័យ អាចត្រូវបានចាប់ខ្លួនផងដែរ នៅក្នុងពេលដំណើរការស៊ើបអង្កេត ។ ជួនកាលការស៊ើបអង្កេតជាច្រើនតម្រូវឱ្យបង្ហាញភស្តុតាងពីភាពមានទោសនៅចំពោះមុខតុលាការ ហើយមន្ត្រីអនុវត្តច្បាប់ត្រូវការពេលវេលាច្រើន ដើម្បីធ្វើការស៊ើបអង្កេតលើរឿងក្តីនោះ ។ ដោយហេតុនេះ ជនសង្ស័យត្រូវតែបានគេដោះលែង នៅពេលគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ។

ជនសង្ស័យអាចត្រូវបានចាប់ខ្លួនផងដែរ បើមានការសង្ស័យសមហេតុផលថា គាត់នឹងមានការប៉ុនប៉ងរត់គេចខ្លួន ឬជននោះនឹងប្រព្រឹត្តបទល្មើសផ្សេងទៀត ។

**៣. ច្បាប់អន្តរជាតិទាក់ទងនឹងការចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួន**

ការចាប់ខ្លួនជនសង្ស័យនៅក្នុងរឿងក្តីព្រហ្មទណ្ឌ គឺជាការសម្រេចចិត្តយ៉ាងសំខាន់របស់មន្ត្រីអនុវត្តច្បាប់ ។ ការចាប់ខ្លួន គឺជាការរឹតត្បិតទាំងស្រុងទៅលើសិទ្ធិដើរហើរ របស់បុគ្គលណាម្នាក់ ទោះបីជារយៈពេលខ្លី យ៉ាងណាក៏ដោយ ហើយការចាប់ខ្លួននេះ គឺបង្កឱ្យមានភាពស្មុគស្មាញដល់មន្ត្រីចាប់ខ្លួន និងជនដែលត្រូវចាប់ខ្លួន ប្រសិនបើការសម្រេចចិត្តចាប់ខ្លួន មិនមានលក្ខណៈសមស្រប ។ ច្បាប់អន្តរជាតិ បានចែងពីស្តង់ដានានា ដោយឈរលើមូលដ្ឋានសិទ្ធិមនុស្ស ហើយបានផ្តល់ដល់មន្ត្រីអនុវត្តច្បាប់ នូវគោលការណ៍តុល្យភាពនៅពេលពិចារណា ក្នុងការប្រើប្រាស់វិធីចាប់ខ្លួន ។ ចំណុចជាមូលដ្ឋាន ទាំងអស់នៃការចាប់ខ្លួន គឺថាសិទ្ធិរបស់បុគ្គលណាម្នាក់ មិនត្រូវបានគេឃុំខ្លួន ដោយបំពាន ហើយក៏ជាសិទ្ធិរបស់ជនគ្រប់រូប ទទួលបានសវនាការកាត់ក្តីដ៏ត្រឹមត្រូវមួយ ។ ការចាប់ខ្លួនដោយគ្មានដីកា ឬការចាប់ខ្លួនដោយមិនមានលក្ខណៈត្រឹមត្រូវ ឬខុសច្បាប់ នឹងមានផលប៉ះពាល់ជាអវិជ្ជមានផ្សេងៗ ទៅលើសិទ្ធិសំខាន់ទាំងពីរនេះ ។

**តារាងទី ១**

| ច្បាប់អន្តរជាតិ | នីតិវិធីសម្រាប់ការអនុវត្តទៅលើសិទ្ធិ ដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិទាក់ទងនឹងការចាប់ខ្លួន ឃាត់ខ្លួន និងការឃុំខ្លួន |
|---|---|
| | ច្បាប់អន្តរជាតិចែងថា ៖<br>" ជនគ្រប់រូបមានសិទ្ធិមានជីវិតជាប់ពីកំណើត ។ សិទ្ធិនេះត្រូវការពារដោយច្បាប់ ។ គ្មានជនណាម្នាក់ ត្រូវប្រហារជីវិតដោយបំពានឡើយ។"<br>(កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ៦)<br>" គ្មានជនណាម្នាក់ ត្រូវរងទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬថោកទាបឡើយ ។ ជាពិសេស ហាមយកជនណាម្នាក់ មកធ្វើការពិសោធខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ" ។<br>(កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ៧)<br>"គ្មានជនណាម្នាក់ ត្រូវដាក់ជាទាសភាពឡើយ ។ ទាសភាព និងការជួញដូរទាសករតាមគ្រប់រូបភាព ត្រូវហាមឃាត់"។<br>(កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ៨)<br>"ជនគ្រប់រូបមានសិទ្ធិ សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយបំពានបានឡើយ ។ គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធី មានចែងនៅក្នុងច្បាប់ " ។<br>(កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ៩) |

| | |
|---|---|
| | "ជនណា ដែលត្រូវបានចាប់ខ្លួន ត្រូវប្រាប់ឱ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាម អំពីការចោទប្រកាន់។"<br>" បុគ្គលណា ដែលបានចាប់ខ្លួន ឬឃុំខ្លួន ពីបទព្រហ្មទណ្ឌ នឹងត្រូវនាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ ដើម្បីបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង ។ ការឃុំខ្លួនមនុស្សដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម" ។<br>" ជនណា ដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យារពេល អំពីនីត្យានុកូលភាព នៃការឃុំខ្លួន និងបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់"។<br>"ជនណា ដែលបានរងគ្រោះដោយសារការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់ មានសិទ្ធិទាមទារសំណង"។<br>(កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ៩)<br>"ជនណា ដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការគិតគូរតាមលក្ខណៈមនុស្សធម៌ និងការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សពីកំណើត" ។<br>" ជនជាប់ចោទ ត្រូវដាក់ឱ្យនៅផ្សេងពីទណ្ឌិត លើកលែងតែក្នុងកាលៈទេសៈពិសេស។ ជនជាប់ចោទ ត្រូវស្ថិតនៅក្រោមរបបដាច់ដោយឡែក ដែលសមស្របទៅតាមល័ក្ខខ័ណ្ឌរបស់ជនពុំទាន់មានទោស" ។<br>"ជនជាប់ចោទជាអនីតិជន ត្រូវដាក់ផ្សេងពីនីតិជន ហើយត្រូវសម្រេចសេចក្តីឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន" ។<br>"ប្រព័ន្ធគ្រប់គ្រងពន្ធនាគារ ត្រូវគិតគូរដល់ទណ្ឌិត ក្នុងគោលបំណងជាសារវ័ន្ត ដើម្បីស្តារនីតិសម្បទា និងបញ្ចូលពួកគេទៅក្នុងសង្គមវិញ។ ទណ្ឌិតជាអនីតិជន ត្រូវបំបែកចេញពីនីតិជន ហើយត្រូវស្ថិតនៅក្នុងការគ្រប់គ្រងសមស្របតាមអាយុ និងស្ថានភាពនីត្យានុកូលភាពរបស់គេ" ។<br>(កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ១០)<br>"ជនគ្រប់រូប ត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ សវនាការរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន" ។<br>"ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថា ជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានបង្ហាញស្របតាមច្បាប់" ។<br>"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជន |

គ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម ៖

- ត្រូវទទួលបានព័ត៌មានលម្អិតភ្លាមៗ អំពីលក្ខណៈ និងមូលហេតុពីការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ
- ត្រូវមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវី តាមការជ្រើសរើសរបស់ខ្លួន
- ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលហួសកំណត់
- ត្រូវបានជំនុំជម្រះ នៅពេលមានវត្តមាន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលប្រព័ន្ធតុលាការតម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះ បើជនជាប់ចោទ គ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ
- ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយ ទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុក ចូលខ្លួនដើម្បីសួរចម្លើយ ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក
- ត្រូវទទួលបានអ្នកបកប្រែភាសា ដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិននិយាយភាសាដែលប្រើប្រាស់ក្នុងសវនាការ
- មិនត្រូវបានបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធភាព។

"នីតិវិធីអនុវត្តចំពោះកុមារដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ" ។

"ជនគ្រប់រូប ដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ ពិនិត្យតាមច្បាប់ឡើងវិញ ទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោស" ។

"នៅពេលជនណាម្នាក់ ត្រូវបានប្រកាសឱ្យជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមក ការប្រកាសឱ្យជាប់ពិរុទ្ធនេះ ត្រូវបានបដិសេធ ឬត្រូវបានលើកលែងទោស ដោយហេតុថា អង្គហេតុថ្មី ឬដែលបានរកឃើញថ្មី បញ្ជាក់យ៉ាងច្បាស់ថា មានការខុសឆ្គងមកពីតុលាការ ជនដែលទទួលរងគ្រោះដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លុះត្រាតែមានភស្តុតាងបង្ហាញនូវការលាតត្រដាងបានទាន់ពេលនូវអង្គហេតុដែលគេបានដឹង" ។

"គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មី ចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសរួចហើយ ស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗ" ។

(កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ១៤)

| | |
|---|---|
| | **សម្គាល់៖** សិទ្ធិទាំងអស់នេះ បានទទួលស្គាល់យ៉ាងទូលំទូលាយ ដោយសហគមន៍អន្តរជាតិ ដោយហេតុថា រដ្ឋទាំងអស់មានកាតព្វកិច្ចគោរពទៅលើសិទ្ធិទាំងអស់នេះ ទោះបីជារដ្ឋទាំងអស់នោះ បាន ឬមិនបានឱ្យសច្ចាប័នទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយក៏ដោយ ។ ដូចនេះ គ្មានរដ្ឋណាមួយអាចគេចផុតពីកាតព្វកិច្ចក្នុងការអនុវត្តទៅលើសិទ្ធិទាំងអស់នេះ ដោយសំអាងថា សិទ្ធិទាំងអស់នេះមិនត្រូវបានការពារដោយប្រព័ន្ធច្បាប់ជាតិ។ |

**តារាងទី ២**

| ការអនុវត្តដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិដែលទាក់ទងទៅនឹងការចាប់ខ្លួន និងការឃុំខ្លួន | **កាតព្វកិច្ច និងការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់មន្ត្រីអនុវត្តច្បាប់** |
|---|---|
| | អាកប្បកិរិយារបស់មន្ត្រីអនុវត្តច្បាប់ម្នាក់ៗ នៅក្នុងស្ថានភាពនៃការចាប់ខ្លួន ត្រូវកំណត់ពីស្ថានភាពនីមួយៗ ដែលទំហំនៃអាកប្បកិរិយា ត្រូវបានគេវិនិច្ឆ័យថា ជាការបំពាន ។ ការកិច្ចក្នុងការធានាឱ្យមានភាពស្មើគ្នា និងកិច្ចការពារពីអាកប្បកិរិយាខុសច្បាប់ គឺស្ថិតនៅលើមន្ត្រីអនុវត្តច្បាប់ម្នាក់ៗ ព្រោះកាតព្វកិច្ចរបស់មន្ត្រីអនុវត្តច្បាប់ ត្រូវធានាថា សិទ្ធិរបស់ជនត្រូវចាប់ខ្លួន ត្រូវបានគោរពដោយយោងទៅតាមច្បាប់ ។<br>មន្ត្រីអនុវត្តច្បាប់ មានកាតព្វកិច្ចមួយចំនួនទាក់ទងនឹងសិទ្ធិរបស់ជនត្រូវចាប់ខ្លួន ៖<br>• អនុវត្តតែការចាប់ខ្លួនណា ដែលមានលក្ខណៈស្របច្បាប់ និងចាំបាច់<br>• ប្រើប្រាស់តែអំណាចណា ដែលច្បាប់បានផ្តល់មកឱ្យខ្លួន<br>• នៅពេលចាប់ខ្លួន ផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវអំពីមូលហេតុនៃការចាប់ខ្លួន<br>• ផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ អំពីការចោទប្រកាន់ទៅលើជនត្រូវចាប់ខ្លួន<br>• ផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ ដល់ជនត្រូវចាប់ខ្លួន អំពីសិទ្ធិរបស់ពួកគេ<br>• ត្រូវធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវ ចំពោះជនដែលត្រូវចាប់ខ្លួន ៖<br>  ○ មូលហេតុនៃការចាប់ខ្លួន<br>  ○ ពេលវេលានៃការចាប់ខ្លួន<br>  ○ ការបញ្ជូនទៅកន្លែងឃុំឃាំង<br>  ○ វត្តមានលើកទី១របស់ជននោះនៅចំពោះមុខតុលាការ ឬអាជ្ញាធរដទៃទៀត<br>  ○ អត្តសញ្ញាណរបស់មន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ<br>  ○ បញ្ជាក់ព័ត៌មានឱ្យបានច្បាស់លាស់ ពីទីកន្លែងឃុំឃាំង<br>• ផ្តល់ព័ត៌មានពីកំណត់ហេតុនេះ ទៅដល់ជនដែលត្រូវចាប់ខ្លួន ឬទៅដល់មេធាវីរបស់ពួកគេ នៅក្នុងទម្រង់ដែលបានបញ្ជាក់ដោយច្បាប់<br>• បញ្ជូនជនដែលត្រូវចាប់ខ្លួន តាមនីតិវិធីទៅតុលាការ ឬអាជ្ញាធរដទៃទៀត<br>• ផ្តល់មេធាវីដល់ជនដែលត្រូវចាប់ខ្លួន និងអនុញ្ញាតឱ្យមានការទាក់ទងគ្នា<br>• ហាមឃាត់ការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អមនុស្សធម៌ ឬការបន្ទាបបន្ថោក |

| | |
|---|---|
| | ឬផ្តន្ទាទោស នៅក្នុងអំឡុងពេល និងបន្ទាប់ពីពេលចាប់ខ្លួន<br>• ធានាដល់ជនដែលត្រូវចាប់ខ្លួន នូវសិទ្ធិក្នុងឋានៈជាជនជាប់ឃុំឃាំង<br>• អនុវត្តឱ្យបានតឹងរ៉ឹង ទៅលើវិធាននៃកិច្ចការពារ ជាពិសេសដល់ស្ត្រី និងកុមារដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ។ |

**តារាងទី ៣**

| ច្បាប់អន្តរជាតិ | នីតិវិធីសម្រាប់ការអនុវត្តសិទ្ធិដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ទាក់ទងទៅនឹងការឃាត់ខ្លួន និងការឃុំខ្លួន |
|---|---|
| | នីតិវិធីសម្រាប់ការអនុវត្តសិទ្ធិ ទទួលស្គាល់ជាលក្ខណៈអន្តរជាតិទាក់ទងនឹងការឃាត់ខ្លួន ឃុំខ្លួន មានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ នៅក្នុងតារាងទី១ នៃមេរៀននេះ ។ ការទទួលស្គាល់សេចក្តីត្រូវការនៃការរក្សាសិទ្ធិមនុស្ស របស់ជនដែលស្ថិតនៅក្រោមទម្រង់នៃការឃុំឃាំង បានធ្វើឱ្យអង្គការសហប្រជាជាតិបង្កើតនូវឯកសារផ្សេងៗ ដែលបន្ថែមទៅនឹងបញ្ញត្តិដែលពាក់ព័ន្ធនឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។ វិធាននៃស្តង់ដាអប្បបរមា សម្រាប់ទង្វើទៅលើអ្នកជាប់ពន្ធនាគារ ត្រូវបានបង្កើតឡើងជាគោលការណ៍ណែនាំសម្រាប់ស្ថាប័នអនុវត្តច្បាប់នៅលើពិភពលោក ដើម្បីធានាថា ជនជាប់ឃុំឃាំង និងទណ្ឌិត ត្រូវបានប្រព្រឹត្ត នៅក្នុងលក្ខណៈជាមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ ។<br>គោលការណ៍ណែនាំនៃវិធានស្តង់ដាអប្បបរមា បានកំណត់នូវវិធានស្តីពីទង្វើទៅលើបុគ្គល ដែលបានដកសិទ្ធិសេរីភាព ដោយផ្តោតអារម្មណ៍ជាពិសេសទៅលើការចាប់ខ្លួន និងការឃុំខ្លួនជាបណ្តោះអាសន្ន ។ វិធាននៃស្តង់ដាអប្បបរមា បានតម្រូវដាក់លាក់ទៅលើ ៖<br>• ទង្វើជាលក្ខណៈមនុស្សធម៌ ដោយមានការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សដែលមានពីកំណើត<br>• ការហាមឃាត់អំពើទារុណកម្ម<br>• ការត្រួតពិនិត្យពីតុលាការ លើស្ថានភាពរបស់ជនជាប់ឃុំឃាំង<br>• សិទ្ធិទទួលបានការប្រឹក្សាពីមេធាវី<br>• សិទ្ធិក្នុងការប្រាស្រ័យទាក់ទង និងសិទ្ធិបន្តទំនាក់ទំនងជាមួយក្រុមគ្រួសារ ឬជនដែលគេបានជ្រើសរើស<br>• ការពិនិត្យខាងផ្នែកវេជ្ជសាស្ត្រត្រឹមត្រូវ<br>• កំណត់ហេតុត្រឹមត្រូវនៃអង្គហេតុទាក់ទងការចាប់ខ្លួន ឃាត់ខ្លួន និងការឃុំខ្លួន<br>• កំណត់ហេតុលើអង្គហេតុមួយចំនួន ទាក់ទងទៅនឹងការសម្ភាសជនសង្ស័យ |

| | |
|---|---|
| | ផ្នែក "គ" នៃវិធានស្តង់ដាអប្បបរមា ៖ អ្នកទោសដែលស្ថិតនៅក្រោមការចាប់ខ្លួន ឬរង់ចាំសវនាការរឿងក្តី<br>**វិធាន ៨៤**<br>(១) ជនត្រូវបានចាប់ខ្លួន ឬត្រូវបានឃុំឃាំង ដោយមូលហេតុនៃការចោទប្រកាន់បទល្មើស ហើយត្រូវបានឃាត់ខ្លួននៅប៉ុស្តិ៍នគរបាល ឬឃុំខ្លួននៅពន្ធនាគារ ប៉ុន្តែមិនទាន់បានកាត់ទោស ឬផ្តន្ទាទោស ត្រូវបានចាត់ទុកថា "អ្នកជាប់ពន្ធនាគារដែលមិនទាន់បានកាត់ក្តី" ។<br>(២) ជនជាប់ឃុំឃាំងដែលមិនទាន់បានផ្តន្ទាទោស (ពិរុទ្ធជន) ត្រូវបានគេសន្មតជាមុនថា ជាជនគ្មានទោស ហើយត្រូវបានគេប្រព្រឹត្តទៅលើក្នុងឋានៈជាជនគ្មានទោស ។<br>(៣) ដោយគ្មានការប៉ះពាល់ទៅលើវិធានខាងផ្នែកច្បាប់ ស្តីពីកិច្ចការពារសេរីភាពរបស់បុគ្គល ឬដោយចែងពីនីតិវិធីដែលតម្រូវឱ្យមានការពិនិត្យទៅលើជនជាប់ឃុំឃាំង មិនទាន់បានកាត់ក្តី ជនជាប់ឃុំឃាំងទាំងអស់នេះ ត្រូវទទួលបានរបបពិសេសមួយ ដែលមានចែងនៅក្នុងវិធានខាងក្រោម ដែលជាការតម្រូវពិសេសតែប៉ុណ្ណោះ ។<br>**វិធាន ៨៥**<br>(១) ជនជាប់ឃុំឃាំងដែលមិនទាន់បានកាត់ក្តី ត្រូវដាក់ដោយឡែកពីទណ្ឌិត<br>(២) ពិរុទ្ធជនវ័យក្មេង ត្រូវដាក់ដោយឡែកពីពិរុទ្ធជនពេញវ័យ ហើយជាគោលការណ៍ ត្រូវបានឃុំឃាំងនៅកន្លែងដាច់ដោយឡែក ។<br>**វិធាន ៨៦ ៖** ពិរុទ្ធជនត្រូវមានបន្ទប់ដោយឡែកតែឯង សមស្របអាកាសធាតុ ។<br>**វិធាន ៨៧ ៖** ត្រូវមានការកម្រិតដែលទាក់ទងទៅនឹងសណ្តាប់ធ្នាប់ល្អនៃកន្លែងស្នាក់នៅរបស់ពិរុទ្ធជន ប្រសិនបើគេពេញចិត្ត អាចមានម្ហូបអាហារពីខាងក្រៅតាមការចំណាយរបស់ខ្លួន តាមរយៈរដ្ឋបាល ឬតាមរយៈគ្រួសារ ឬមិត្តភក្តិ ។ បើមិនដូច្នោះទេ រដ្ឋបាលរបស់ស្ថាប័នត្រូវផ្តល់ម្ហូបដល់ពួកគេ ។ |

## ៤. ច្បាប់ជាតិ

### ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣)

មាត្រា ៣៨ ចែងពីសិទ្ធិជាមូលដ្ឋាន នៃសិទ្ធិមនុស្សទាក់ទងទៅនឹងការចាប់ខ្លួន និងការឃុំខ្លួនប្រជាពលរដ្ឋ ។

ច្បាប់ហាមឃាត់ មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែ អនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះ ជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**ខ. ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧**

ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័ត នៅឆ្នាំ២០០៧ ។ ក្រមនេះ មិនមានការកែប្រែ ទៅលើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទេ ។ លើសពីនេះទៀត ក្រមនេះ បានកំណត់ពីវិធានសម្រាប់នគរបាល ព្រះរាជអាជ្ញា និងចៅក្រម ត្រូវអនុវត្តតាម ក្នុងការស៊ើបអង្កេត និងការកាត់ក្តីចំពោះបទល្មើសណាមួយ ។ ជាលទ្ធផល មានមាត្រាសំខាន់ៗនៅក្នុងក្រមនេះ បានចែងពីការងាររបស់នគរបាល រួមមាន នគរបាលប្រឆាំងអំពើជួញដូរមនុស្ស និងនគរបាលនៅថ្នាក់មូលដ្ឋាន ។ មាត្រាសំខាន់របស់ក្រមនេះ ពាក់ព័ន្ធនឹងការអនុវត្តរបស់នគរបាល មានដូចតទៅ ៖

មាត្រា ៨៦ ៖ និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ ៖

- បទល្មើសដែលកំពុងប្រព្រឹត្ត
- បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ។

ត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ៖

- ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រផាប់ចាប់ប្រភីង
- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីចង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

មាត្រា ៨៧ ៖ ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់ អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

មាត្រា ៩៦ ៖ ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ ៖

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

- មានការយល់ព្រមជាលាយលក្ខអក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី)ម៉ោង ។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព(ហេតុផលសមស្របទៅតាមពេលវេលា) ។ ការអនុញ្ញាតឱ្យពន្យារពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខអក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ការពន្យារគឺជាវិធានការពិសេស ។ ការពន្យារនេះ មិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោងឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន ។

ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៣៦ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ២៤ ម៉ោងឡើយ ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៤៨ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៣៦ ម៉ោងឡើយ ។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។

មាត្រា ៩៨ ៖ ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្ដើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះតាម គ្រប់មធ្យោបាយ និងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប)នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនា ជននេះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខអក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។

គោលការណ៍ណែនាំអន្តរជាតិ បានចែងដោយផ្តល់ឱ្យមន្ត្រីអនុវត្តច្បាប់ ចំពោះការអនុវត្តនានាដែលទទួលស្គាល់បន្ថែមទៀតទាក់ទងនឹងវិធីគ្រប់គ្រងទៅលើកុមារ បន្ទាប់ពីការចាប់ខ្លួនកុមារ ។ ចំពោះអនុសញ្ញា "កុមារមានន័យថា ជនគ្រប់រូប ដែលមានអាយុតិចជាង១៨ឆ្នាំ អាស្រ័យទៅតាមច្បាប់ ដែលអនុវត្តទៅលើកុមារ នីតិភាពអាចមានមុន១៨ឆ្នាំ " (អនុសញ្ញាស្តីពី សិទ្ធិកុមារ មាត្រា១)។

តារាងទី៥ ៖ មន្ត្រីអនុវត្តច្បាប់ មានកាតព្វកិច្ចគោរពច្បាប់អន្តរជាតិ

| ច្បាប់ | មន្ត្រីអនុវត្តច្បាប់ មានកាតព្វកិច្ចគោរពច្បាប់អន្តរជាតិ |
|---|---|
| អន្តរជាតិ | នៅក្នុងករណីចាប់ខ្លួន និងឃុំខ្លួនកុមារ ក្របខណ្ឌច្បាប់អន្តរជាតិតម្រូវឱ្យជ្ឍគោរព ទាក់ទងនឹងសិទ្ធិរបស់ជនដែលត្រូវចាប់ខ្លួន បានចែងថា ៖ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារកំណត់អំពីនីតិភាពទាបជាងនេះ ។ (មាត្រា១ នៃអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ)<br>ការផ្តោតអារម្មណ៍ជាចម្បងនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ គឺ "អត្ថប្រយោជន៍ល្អបំផុតរបស់កុមារ"។ រាល់វិធានការទាំងអស់ ដែលមានចែងនៅក្នុងអនុសញ្ញានេះ បានយកគោលការណ៍នេះជាចំណុចចាប់ផ្តើម ។ អនុសញ្ញាស្តីពីសិទ្ធិកុមារ បានបង្ហាញនូវភាពគ្មានសង្ស័យថាកុមារមានសិទ្ធិ និងសេរីភាពដូចមនុស្សពេញវ័យដែរ។ សិទ្ធិជាមូលដ្ឋានមួយចំនួន ដូចជា សិទ្ធិរស់រានមានជីវិត សេរីភាព និងសុវត្ថិភាពរបស់បុគ្គល សិទ្ធិទទួលបាននូវសេរីភាពក្នុងការបញ្ចេញគំនិតយោបល់ និងសិទ្ធិប្រមូលផ្តុំ និងបង្កើតសមាគមន៍ដោយសន្តិវិធី បានបញ្ចូលទៅក្នុងអនុសញ្ញានេះយ៉ាងច្បាស់លាស់។ លើសពីនេះទៀត អនុសញ្ញាបានផ្តល់នូវកិច្ចការពារបន្ថែមទៀតពីការបំពារបំពាន ការធ្វេសប្រហែស ការកេងប្រវ័ញ្ចលើកុមារ (អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣២-៣៦)។<br>គោលបំណងនៃប្រព័ន្ធយុត្តិធម៌សម្រាប់កុមារ ត្រូវបានពង្រឹងសុខុមាលភាពរបស់កុមារ និងធានា ថាប្រតិកម្មណាមួយទៅលើជនល្មើសជាកុមារ គឺត្រូវឱ្យមានលក្ខណៈសមស្របទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស ។ ជនល្មើសជាកុមារគួរតែបង្វែរពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ទៅសេវាគាំទ្រសហគមន៍ដែលមាន ។<br>មាត្រា ៣៧ ចែងថា ៖ គ្មានកុមារណាម្នាក់ ត្រូវទទួលរងទារុណកម្ម ឬប្រព្រឹត្តកម្ម ឬការផ្តន្ទាទោសឃោរឃៅ អមនុស្សធម៌ ឬថោកទាបឡើយ (ព្រមទាំងទោសប្រហារជីវិត ឬដាក់គុកអស់មួយជីវិត ) ។ ការដកហូតសេរីភាពកុមារដោយខុសច្បាប់ ឬដោយបំពាន ត្រូវហាមឃាត់ ។ កុមារណាដែលត្រូវបានដកហូតសេរីភាពត្រូវទទួលបានការគិតគូរប្រកបដោយមនុស្សធម៌ ដោយការគោរពចំពោះសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស និងគិតដល់សេចក្តីត្រូវការក្នុងវ័យកុមារ ។ កុមារទាំងអស់ដែលត្រូវបានដកហូតសេរីភាព ត្រូវដាក់ឱ្យនៅដោយឡែកពីមនុស្សពេញវ័យ ។ កុមារទាំងនេះ ត្រូវមានសិទ្ធិទាក់ទងជាមួយគ្រួសារខ្លួន មានសិទ្ធិទទួលបានភ្លាមៗនូវជំនួយផ្នែកច្បាប់ និងជំនួយសមស្របផ្សេងៗទៀត និងមានសិទ្ធិជំទាស់នីត្យានុកូលភាព នៃការដកហូតសេរីភាពខ្លួន ចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ។<br>ច្បាប់អន្តរជាតិ បានចែងជាពិសេសដល់ ៖ |

| | |
|---|---|
| | • ការពារសិទ្ធិរបស់កុមារ<br>• ការពារសុខុមាលភាពរបស់កុមារ ដែលមានការពាក់ព័ន្ធនឹងច្បាប់<br>• ការពារកុមារពីការបំពារបំពាន ធ្វេសប្រហែសនិងការកេងប្រវ័ញ្ចនិង<br>• បង្ហាញវិធានការពិសេស ដើម្បីទប់ស្កាត់កុំឱ្យមានបទល្មើសដែលកើតចេញពីកុមារ ។ |

## II. ការរៀបចំផែនការចាប់ខ្លួន

### ១. ការធ្វើផែនការចាប់ខ្លួន

ការរៀបចំផែនការ និងការអនុវត្តកិច្ចប្រតិបត្តិការចាប់ខ្លួន នៅក្នុងរឿងក្តីជួញដូរមនុស្សជានិច្ចកាល គឺជាបញ្ហាប្រឈម ។ ផែនការចាប់ខ្លួនតម្រូវឱ្យពិចារណាក្នុងកិច្ចប្រតិបត្តិការចាប់ខ្លួន ៖

- ច្បាប់
- ទីតាំង
- កម្លាំង
- វាយតម្លៃពីហានិភ័យ
- ឧបករណ៍ សម្ភារៈ
- ការបែងចែកភារកិច្ច ។

កិច្ចប្រតិបត្តិការចាប់ខ្លួន អាចតម្រូវឱ្យមានចំនួនមន្ត្រីច្រើន និងឧបករណ៍ធនធាន ដើម្បីគ្រប់គ្រងប្រភេទផ្សេងៗនៃកត្តានានា ដែលបានកំណត់ខាងលើ ហើយភារកិច្ចចម្បងរបស់មន្ត្រីទទួលបន្ទុកស៊ើបអង្កេត នឹងតម្រូវឱ្យរៀបចំផែនការប្រតិបត្តិការឱ្យបានលម្អិត ដើម្បីពន្យល់ ផ្តល់ភារកិច្ច និងដាក់កម្លាំងមន្ត្រី និងធនធាន នៅក្នុងលក្ខណៈប្រកបដោយប្រសិទ្ធភាព ។

គំរូ PEACE ត្រូវបានយកមកប្រើប្រាស់នៅក្នុងគោលបំណងនៃការចាប់ខ្លួន ៖

- P -ការធ្វើគម្រោងផែនការ និងការរៀបចំ
- E -ការចូល និងអនុវត្ត
- A -ការចាប់ខ្លួនជនសង្ស័យគោលដៅ
- C -ការគ្រប់គ្រងកន្លែងកើតហេតុ
- E -ការរឹបអូសវត្ថុតាង ។

# គោលការណ៍ PEACE - ប្រតិបត្តិការចាប់ខ្លួនជនសង្ស័យ និងការជួយសង្គ្រោះជនរងគ្រោះ

**ភារកិច្ច ៖** អ្នកបានទទួលព័ត៌មាននិយាយពីទីតាំងជនសង្ស័យ និងទីតាំងជនរងគ្រោះផ្សេងទៀតដែលកំពុងត្រូវបានគេធ្វើការកេងប្រវ័ញ្ច ។ ប្រសិនបើចាំបាច់ក្នុងការធ្វើអន្តរាគមន៍ ត្រូវរៀបចំគម្រោងផែនការ និងបើកប្រតិបត្តិការចាប់ខ្លួនជនសង្ស័យ និងជួយសង្គ្រោះជនរងគ្រោះ ។

**P ៖ គម្រោងផែនការ**
តើមានមូលហេតុគ្រប់គ្រាន់ទេ? តើមានអំណាចស្របច្បាប់ទេ? បញ្ជាក់ពីទីតាំង កំណត់ពីហានិភ័យ និង វាយតម្លៃហានិភ័យ គ្រប់គ្រងភាពគ្រោះថ្នាក់ សម្រេចពីពេលវេលា ត្រូវមានកម្លាំងគ្រប់គ្រាន់ អ្នកបកប្រែ-អ្នកពិគ្រោះយោបល់ ឧបករណ៍ - បង្កើតក្រុមពន្យល់ពីការងារត្រូវធ្វើ

→ **E ៖ ការអនុវត្ត**
ចូលដោយសុវត្ថិភាព គ្រប់គ្រងកន្លែងកើតហេតុ ធ្វើយ៉ាងណា ឱ្យអ្នកនៅទីនោះ មានសុវត្ថិភាពទាំងអស់គ្នា កំណត់ទីតាំងជនរងគ្រោះ និងពិនិត្យពីសុវត្ថិភាពរបស់គេ - តើមានការភ័យតក់ស្លុត ឬអត់ កំណត់ទីតាំងជនសង្ស័យ និងចាប់ខ្លួន - ដាក់ជនរងគ្រោះ ឱ្យនៅដាច់ពីជនសង្ស័យ យកជនរងគ្រោះ និងទ្រព្យសម្បត្តិ របស់ពួកគេ ទៅដាក់កន្លែង ដែលមានសុវត្ថិភាព

→ **A ៖ ការចាប់ខ្លួន**
ធ្វើយ៉ាងណា ឱ្យមានសុវត្ថិភាព មានសន្តិសុខល្អ យកចិត្តទុកដាក់ដល់ជនរងគ្រោះ ឬជនសង្ស័យឱ្យបានត្រឹមត្រូវ ធ្វើការណែនាំខ្លួន ប្រាប់ជនសង្ស័យ ពីមូលហេតុនៃការចាប់ខ្លួន ដាក់ជនរងគ្រោះ និងជនសង្ស័យ ឱ្យនៅដាច់ពីគ្នា ទប់ស្កាត់ជនសង្ស័យ មិនឱ្យគំរាមជននរងគ្រោះ ដោយផ្ទាល់មាត់ ឬដោយក្រសែភ្នែក

→ **C ៖ កន្លែងកើតហេតុ**
សន្តិសុខ និងការគ្រប់គ្រង កំណត់ត្រាការចេញចូល ថតរូបកន្លែងកើតហេតុមុនពេលឆែកឆេរ រៀបចំគំនូសប្លង់ រៀបចំគម្រោងឆែកឆេរ ធ្វើការងារជាក្រុមតាមវិធីសាស្ត្រ ប្រាប់ជនសង្ស័យពីអំណាចស្របច្បាប់ ពីសិទ្ធិ និងមូលហេតុ នៃការឆែកឆេរ

→ **E៖ការរឹបអូសភស្តុតាង**
ត្រូវរឹបអូស ឯកសារធនាគារ អត្តសញ្ញាណប័ណ្ណ ឯកសារធ្វើដំណើរ អត្ថបទផ្សាយពាណិជ្ជកម្ម កុំព្យូទ័រ មធ្យោបាយទំនាក់ទំនង ឯកសារការងារ កូនសោ ប្រវ៉ាក់ម្ហូបអាហារ និងសម្ភារៈផ្ទះបាយ រថយន្ត-សម្ភារៈធ្វើការកេងប្រវ័ញ្ច ធ្វើរបាយការណ៍ ឱ្យបានពេញលេញ

**កំណត់ចំណាំ៖** ទោះជាប្រញាប់ក៏ដោយ ត្រូវធ្វើគម្រោងផែនការសិន ជួយសង្គ្រោះជនរងគ្រោះ ចាប់ខ្លួនជនសង្ស័យ គិតពីសុវត្ថិភាព និងសិទ្ធិរបស់អ្នកទាំងអស់គ្នា ។ ប្រសិនបើអាចធ្វើទៅបាន ត្រូវជូនដំណឹង និងធ្វើតាមការណែនាំពីអង្គភាពជំនាញមុនពេលធ្វើអន្តរាគមន៍ ។ ប្រសិនបើមិនអាចធ្វើទៅបាន ត្រូវជូនដំណឹងទៅអង្គភាពជំនាញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីការធ្វើអន្តរាគមន៍ហើយ ។

- គម្រោងផែនការ និងការរៀបចំ

| **P – គម្រោងផែនការ និងការរៀបចំ**<br>**មានទិដ្ឋភាពជាច្រើនក្នុងប្រតិបត្តិការទាំងនេះ ហើយវាមិនមែនជាការងាយស្រួលទេ ។ មិនថា យើងមានការប្រញាប់ប៉ុណ្ណាទេ ត្រូវទុកពេលធ្វើផែនការ និងការរៀបចំ ។** | |
|---|---|
| **ផែនការ** | ចូរពិចារណានូវចំណុចដូចតទៅនេះ ៖<br>១. ច្បាប់<br>• តើព័ត៌មានដែលមានស្រាប់ មានមូលហេតុគ្រប់គ្រាន់ក្នុងការប្រើប្រាស់អំណាចស្របច្បាប់ ដើម្បីចូលឆែកឆេរទីតាំង និងចាប់ខ្លួនជនសង្ស័យបានដែរឬទេ?<br>• ត្រូវបញ្ជាក់ថា យើងទទួលបានអំណាចស្របច្បាប់ និងមានដីកាតុលាការ ហើយឯកសារ ឬដីកាទាំងនោះ មាននៅក្នុងដៃរបស់អ្នក ។<br>២. ទីតាំង |

- បញ្ជាក់ទីកន្លែងដែលជនរងគ្រោះកំពុងត្រូវបានគេធ្វើការជួញដូរឱ្យបានច្បាស់
- ត្រូវព្យាយាមយកប្លង់អាគារទាំងក្នុង និងខាងក្រៅឱ្យបាន
- តើផ្លូវមួយណាជាផ្លូវសុវត្ថិភាព សម្រាប់ចូលទៅក្នុងកន្លែងនោះ ។

៣. កម្លាំង

- តើចំនួនជនរងគ្រោះប៉ុន្មាននាក់ដែលត្រូវជួយសង្គ្រោះ បន្ទាប់មកតើត្រូវយកជនរងគ្រោះទៅដាក់នៅឯណា?
- តើអ្នកគិតថាមានជនសង្ស័យនៅទីនោះប៉ុន្មាននាក់? តើអ្នកត្រូវការមន្ត្រីប៉ុន្មាននាក់ដើម្បីគ្រប់គ្រង និងចាត់ចែងជនសង្ស័យឱ្យមានសុវត្ថិភាព ហើយតើអ្នកត្រូវយកជនសង្ស័យទាំងនោះទៅដាក់នៅកន្លែងណា ក្រោយពីធ្វើការចាប់ខ្លួន?
- តើនៅមានជនផ្សេងទៀតនៅទីនោះដែរឬទេ ដូចជា ភ្ញៀវនៅក្នុងផ្ទះបន អ្នកបម្រើស្របច្បាប់នៅតាមផ្ទះ ម្ចាស់ផ្ទះ ។ល។ បើសិនជាមានការណ៍បែបនេះ តើត្រូវចាត់ចែងពួកគេដោយរបៀបណា?
- ការថែទាំសុខភាព តើមានព័ត៌មានប្រាប់ថា មានជនណាម្នាក់ ឬច្រើននាក់ឈឺ ឬមានរបួសដែរឬទេ? តើវាជាការចាំបាច់ដែរទេ ក្នុងការយកគ្រូពេទ្យទៅទីនោះ?
- យកអ្នកបកប្រែភាសា បើសិនជាជនរងគ្រោះ និយាយភាសាបរទេស
- អ្នកពិគ្រោះយោបល់ ត្រូវបញ្ជាក់សុខភាពផ្លូវចិត្តរបស់ជនរងគ្រោះ ។

៤. វាយតម្លៃពីហានិភ័យ

- តើព័ត៌មាននេះប្រាប់អ្នកពីគ្រោះថ្នាក់ដែលអាចកើតមានដែរឬទេ?
- ជនសង្ស័យ តើមានជនសង្ស័យនៅទីនោះប៉ុន្មាននាក់? តើពួកគេជាមនុស្សបែបណា មានអាវុធដែរឬទេ?
- ជនរងគ្រោះ តើមានជនរងគ្រោះនៅទីនោះប៉ុន្មាននាក់ ហើយតើពួកគេមានការភ័យតក់ស្លុតដែរឬទេ?
- កន្លែង តើនៅកន្លែងនោះអាចនឹងមានគ្រោះថ្នាក់ដែរឬទេ? ដូចជា អាគារមានបន្ទប់ច្រើនជាន់ ការដាក់ខ្សែភ្លើងឱ្យឆក់ សារជាតុចំហេះ និងសារជាតុផ្សេងៗទៀត
- តើអ្នកអាចគ្រប់គ្រងហានិភ័យទាំងនេះដោយរបៀបណា?

៥. ឧបករណ៍ សម្ភារៈ

- ត្រូវគិតពីឧបករណ៍ការពារសុវត្ថិភាព ដូចជា អាវុធរបស់កម្លាំងនគរបាល អាវក្រោះ ខ្នោះដៃ
- តើមន្ត្រីរបស់អ្នកធ្វើដំណើរទៅកាន់កន្លែងនោះដោយមធ្យោបាយអ្វី?
- តើមានម៉ាស៊ីនថតរូប ម៉ាស៊ីនថតវីដេអូដែរឬទេ?
- ឧបករណ៍ផែកធេរ មានពិល ឡូណឺវិស ឯកសារសម្រាប់ធ្វើកំណត់ហេតុ ប៊ិច
- មធ្យោបាយទំនាក់ទំនង តើមន្ត្រីរបស់អ្នកប្រើអ្វីសម្រាប់ធ្វើការទាក់ទងគ្នា?

៦. ការបែងចែកភារកិច្ច

| | |
|---|---|
| | • ត្រូវចែកមន្ត្រីជាក្រុម និងភារកិច្ចឱ្យបានជាក់លាក់ ដល់ក្រុមនីមួយៗ<br>• ត្រូវមានការពន្យល់ត្រួសៗ ៖<br>○ តើហេតុអ្វីបានជាយើងត្រូវបើកប្រតិបត្តិការនេះ ?<br>○ លិខិតស្នាមដែលជាអំណាចស្របច្បាប់ដែលត្រូវប្រើ<br>○ គោលដៅទូទៅនៃប្រតិបត្តិការ<br>○ ព័ត៌មានលម្អិតអំពីជនរងគ្រោះដែលត្រូវធ្វើការជួយសង្គ្រោះ<br>○ ព័ត៌មានលម្អិតអំពីជនសង្ស័យដែលត្រូវធ្វើការចាប់ខ្លួន<br>○ ព័ត៌មានលម្អិតអំពីវត្ថុតាង ឬភស្តុតាងដែលត្រូវស្វែងរក ។<br>• មន្ត្រីនីមួយៗ ត្រូវអនុវត្តតាមតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានច្បាស់លាស់ ។ |

• ការចូលទីតាំង និងការអនុវត្ត

| **E – ចូលទីតាំង និងការអនុវត្ត**<br>**ប្រតិបត្តិការនេះទទួលជោគជ័យទៅបាន អាស្រ័យទៅលើការចាត់វិធានការ ក្នុងដំណាក់កាលនៃការចូលទៅក្នុងទីតាំងនោះជាដំបូង** | |
|---|---|
| **ការចូលក្នុងទីតាំង និងការអនុវត្ត** | ចូរគិតពិចារណាពីចំណុចខាងក្រោម ៖<br>១. ការចូលទៅក្នុងទីតាំង<br>• តើវិធីមួយណាដែលជាវិធីល្អបំផុតសម្រាប់ចូលទៅក្នុងទីតាំងនោះ ?<br>• តើវាជាការចាំបាច់ដែរឬទេ ដែលអ្នកត្រូវចូលដោយបង្ខំ ឬតាមវិធីផ្សេងៗ ?<br>• ត្រូវពង្រាយកម្លាំងតាមក្រុមទាំងនោះនៅតាមច្រកចូលនីមួយៗ និងនៅជុំវិញបរិវេណអាគារក្នុងពេលដំណាលគ្នា<br>• បើសិនជាអាចធ្វើទៅបាន ត្រូវធ្វើយ៉ាងណាឱ្យក្រុមដែលចូលទីតាំង មានម៉ាស៊ីនថតវីដេអូ ឬម៉ាស៊ីនថតរូប និងការធ្វើកំណត់ហេតុ<br>• ពេលប្រតិបត្តិការចូល ត្រូវស្លៀកពាក់ឯកសណ្ឋាន<br>• ត្រូវគ្រប់គ្រងកន្លែងកើតហេតុឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។<br>២. ជនសង្ស័យ<br>• ត្រូវកំណត់ទីតាំងជនសង្ស័យ និងឃាត់ខ្លួនពួកគេ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីទប់ស្កាត់កុំឱ្យជនសង្ស័យបង្កគ្រោះថ្នាក់ដល់អ្នកផ្សេងទៀត<br>• ទប់ស្កាត់កុំឱ្យជនសង្ស័យបំផ្លាញភស្តុតាង<br>• នៅពេលដែលអ្នកគ្រប់គ្រងជនសង្ស័យបានហើយ ត្រូវដាក់ជនសង្ស័យឱ្យនៅដាច់ពីជនរងគ្រោះ ដើម្បីកុំឱ្យជនសង្ស័យអាចធ្វើការបំភិតបំភ័យជនរងគ្រោះបាន<br>• ត្រូវដាក់ជនសង្ស័យឱ្យនៅដាច់ពីគ្នា ។<br>៣. ជនរងគ្រោះ<br>• ត្រូវកំណត់ទីតាំងជនរងគ្រោះ និងធ្វើយ៉ាងណាឱ្យជនរងគ្រោះមានសុវត្ថិភាព |

| | |
|---|---|
| | • ត្រូវដឹងថា តើជនរងគ្រោះអាចនឹងមានការភ័យតក់ស្លុត ឬជនរងគ្រោះចាត់ទុកអ្នកដូចជាសត្រូវ មុនពេលពួកគេយល់ពីហេតុការណ៍ដែលបានកើតឡើង ។<br>• នៅពេលដែលរក្សាសុវត្ថិភាពបានហើយ ត្រូវមានអ្នកបកប្រែ និងអ្នកពិគ្រោះយោបល់ (បើសិនចាំបាច់) ដើម្បីពន្យល់ពីស្ថានភាពនេះ ជូនជនរងគ្រោះ<br>• ត្រូវអនុញ្ញាតឱ្យជនរងគ្រោះចង្អុលបង្ហាញពីទ្រព្យផ្ទាល់ខ្លួនរបស់ពួកគេ ប៉ុន្តែត្រូវទុករបស់របរនោះនៅកន្លែងកើតហេតុសិន<br>• ត្រូវយកជនរងគ្រោះចេញពីកន្លែងនោះ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយត្រូវយកពួកគេទៅដាក់នៅកន្លែង ដែលមានសុវត្ថិភាព ដូចជា ប៉ុស្តិ៍នគរបាល មណ្ឌលថែទាំ មន្ទីរពេទ្យ... ។<br>៤. ជនផ្សេងទៀត<br>បើសិនជាមានជនផ្សេងទៀតនៅទីនោះ ដូចជា ភ្ញៀវមកក្នុងផ្ទះបន ឬអ្នកបម្រើស្របច្បាប់ដែលធ្វើការនៅតាមផ្ទះ ត្រូវស្រង់យកព័ត៌មានពីពួកគេ ហើយត្រូវយកពួកគេចេញពីកន្លែងកើតហេតុនោះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។<br>៥. ជំនួយផ្នែកពេទ្យ<br>បើសិនជាមានជនណាម្នាក់ ដូចជា ជនរងគ្រោះ ជនសង្ស័យ ឬមន្ត្រីមានរបួសក្នុងដំណាក់កាលណាមួយ នៃប្រតិបត្តិការ ឬមានជំងឺ ហើយត្រូវការជំនួយផ្នែកពេទ្យជាបន្ទាន់ ត្រូវរៀបចំឱ្យមានការពិនិត្យព្យាបាល ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ទោះតាមវិធីយកគ្រូពេទ្យមកទីនេះ ឬក៏ត្រូវយកគេទៅមន្ទីរពេទ្យក៏ដោយ ។ |

• ការចាប់ខ្លួន

| **A – ការចាប់ខ្លួន<br>ត្រូវធានាសុវត្ថិភាពដល់ជនសង្ស័យ និងធ្វើយ៉ាងណាឱ្យការចាប់ខ្លួនស្របតាមច្បាប់ និងយកចិត្តទុកដាក់ដល់ពួកគេឱ្យបានត្រឹមត្រូវ** | |
|---|---|
| **ការចាប់ខ្លួន** | ចូរពិចារណានូវចំណុចខាងក្រោម ៖<br>១. សុវត្ថិភាព និងការប្រើប្រាស់កម្លាំង<br>• ត្រូវកំណត់ទីតាំងជនសង្ស័យ និងចាប់ខ្លួនជនសង្ស័យ<br>• ត្រូវប្រើប្រាស់កម្លាំង សមស្របសម្រាប់ការចាប់ខ្លួនជនសង្ស័យ និងទប់ស្កាត់កុំឱ្យជនសង្ស័យអាចបង្កគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃ<br>• ដាក់ខ្នោះជនសង្ស័យដើម្បីធានាសុវត្ថិភាពដល់អ្នកទាំងអស់គ្នា<br>• មិនត្រូវអនុញ្ញាតឱ្យជនសង្ស័យទាក់ទងជាមួយជនរងគ្រោះ ទោះដោយផ្ទាល់មាត់ ឬតាមក្រសែភ្នែក<br>• មិនត្រូវអនុញ្ញាតឱ្យជនសង្ស័យទាក់ទងគ្នាទេ |

| | |
|---|---|
| | • មិនត្រូវអនុញ្ញាតឱ្យជនសង្ស័យប្រើទូរស័ព្ទ ក្នុងដំណាក់កាលនេះ ។<br>២. ព័ត៌មានដែលត្រូវប្រាប់ជនសង្ស័យ<br>ត្រូវប្រាប់ជនសង្ស័យឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ៖<br>• ប្រាប់ឈ្មោះ និងឋានន្តរស័ក្តិរបស់មន្ត្រីដែលជាអ្នកធ្វើការចាប់ខ្លួន<br>• ប្រាប់ពីហេតុការណ៍ដែលជនសង្ស័យត្រូវចាប់ខ្លួន<br>• ប្រាប់ពីបទល្មើសជាក់លាក់ដែលជនសង្ស័យត្រូវចាប់ខ្លួន<br>• ប្រាប់ត្រួសៗពីមូលហេតុនៃការចាប់ខ្លួន<br>• ប្រាប់ពីសិទ្ធិរបស់ជនសង្ស័យដែលមានចែងក្នុងច្បាប់<br>• ប្រាប់ពីការកត់ត្រានូវចម្លើយដែលជនសង្ស័យបានឆ្លើយ<br>• បើសិនជាជនសង្ស័យត្រូវចាប់ខ្លួនតាមអំណាចដីកា ត្រូវបង្ហាញដីកានោះឱ្យជនសង្ស័យមើល ។ |

• ការគ្រប់គ្រងកន្លែងកើតហេតុ

| **C - កន្លែងកើតហេតុ**<br>**ការត្រួតពិនិត្យ និងការគ្រប់គ្រងកន្លែងកើតហេតុឱ្យបានត្រឹមត្រូវ គឺជាការសំខាន់ណាស់ ។** | |
|---|---|
| **កន្លែងកើតហេតុ** | ត្រូវពិចារណានូវចំណុចដូចខាងក្រោម ៖<br>១. សន្តិសុខ<br>• ត្រូវគ្រប់គ្រងកន្លែងកើតហេតុ ពេលចូលទៅដល់កន្លែងធ្វើការកេងប្រវ័ញ្ច<br>• ត្រូវគ្រប់គ្រងភស្តុតាងឱ្យមានសុវត្ថិភាព<br>• បន្ទាប់ពីគ្រប់គ្រងជនសង្ស័យហើយ ត្រូវពង្រាយកម្លាំងជុំវិញបរិវេណនោះ<br>• ត្រូវត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់ កុំឱ្យអ្នកគ្មានភារកិច្ចចេញចូល ។<br>២. កន្លែងកើតហេតុដែលត្រូវធ្វើការឆែកឆេរ<br>• កន្លែងធ្វើការកេងប្រវ័ញ្ច និងកន្លែងចាប់ខ្លួន<br>• អាសយដ្ឋានរបស់ជនសង្ស័យ<br>• មធ្យោបាយធ្វើដំណើររបស់ជនសង្ស័យ ។<br>៣. រៀបចំធ្វើការឆែកឆេរ<br>• ត្រូវធ្វើតាមលំដាប់លំដោយ ដោយប្រុងប្រយ័ត្ន<br>• ត្រូវឆែកឆេររកភស្តុតាង បន្ទាប់ពី ៖<br>○ យកជនរងគ្រោះ និងជនដទៃទៀតចេញពីកន្លែងកើតហេតុ<br>○ គូសគំនូសប្លង់ ថតកន្លែងកើតហេតុ ថតជាខ្សែវីដេអូ<br>○ ថតសោទ្វារ មេសោ ច្រវ៉ាក់ និងចម្រឹង ឬគន្លឹះបង្គច ។<br>៤. វិធីសាស្ត្រ |

| | |
|---|---|
| | • ត្រូវមានថង់ដាក់វត្ថុតាង និងសម្ភារៈសម្រាប់ការឆែកឆេរ<br>• ត្រូវធ្វើតាមលំដាប់លំដោយ ឱ្យបានសព្វគ្រប់<br>• ត្រូវបែងចែកតួនាទីភារកិច្ចទទួលខុសត្រូវរបស់ក្រុមនីមួយៗ ។<br>៥. សិទ្ធិជនសង្ស័យ<br>• មុនពេលចាប់ផ្តើមការឆែកឆេរ ត្រូវប្រាប់ជនសង្ស័យនូវចំណុចដូចខាងក្រោម ៖<br>○ អំណាចស្របច្បាប់ក្នុងការអនុញ្ញាតឱ្យធ្វើការឆែកឆេរ<br>○ បើសិនការឆែកឆេរធ្វើឡើងតាមអំណាចដីកាតុលាការ ត្រូវបង្ហាញដីកានោះឱ្យជនសង្ស័យមើល<br>○ សិទ្ធិជនសង្ស័យចូលរួមក្នុងពេលធ្វើការឆែកឆេរ ។<br>• ពេលឆែកឆេរ ត្រូវប្រាប់ជនសង្ស័យពីសិទ្ធិត្រូវមានជនឯករាជ្យម្នាក់ចូលរួម ។ |

- ការរឹបអូសភស្តុតាង

| **E- ភស្តុតាង<br>ភស្តុតាងដែលប្រមូលបាន ត្រូវជានាថា មានការពាក់ព័ន្ធនឹងបណ្តឹងបរិហារនៃករណីជួញដូរមនុស្ស** | |
|---|---|
| **ភស្តុតាង** | ត្រូវពិចារណាចំណុចដូចខាងក្រោម ៖<br>១. ការវាយតម្លៃព័ត៌មានគ្រប់ជ្រុងជ្រោយ ដោយមានសំអាងហេតុផលក្នុងការប្រើប្រាស់អំណាចស្របច្បាប់ ដើម្បីចាត់វិធានការប្រតិបត្តិការសង្គ្រោះ និងចាប់ខ្លួនដែលទាក់ទងនឹងបណ្តឹងបរិហារនៃករណីជួញដូរមនុស្ស ៖<br>• តើភស្តុតាងអ្វី ដែលគួរមាន ដើម្បីគាំទ្រ ឬបដិសេធទៅនឹងបណ្តឹងបរិហារនេះ?<br>• ធ្វើបញ្ជីបញ្ជាក់ពីវត្ថុតាងទូទៅ ឬជាក់លាក់ ដែលត្រូវពិនិត្យ និងជានាថា មន្ត្រីទាំងអស់ដឹងពីបញ្ជីនេះ ។<br>២. វិធីសាស្ត្រស្វែងរកទីកន្លែងកេងប្រវ័ញ្ច អាសយដ្ឋានជនសង្ស័យ និងមធ្យោបាយធ្វើដំណើររបស់ជនសង្ស័យ<br>• អាស្រ័យទៅតាមច្បាប់ ធ្វើការឆែកឆេរចំណុចភស្តុតាងនីមួយៗ ដែលអ្នកគិតថាមានការពាក់ព័ន្ធ<br>• ប្រសិនបើមានការសង្ស័យទៅលើវត្ថុណាមួយ ត្រូវចាប់យក<br>• ការឆែកឆេរ ត្រូវមានវត្តមានជនសង្ស័យ ជាម្ចាស់ ឬជាអ្នកគ្រប់គ្រងទីកន្លែងនោះ ឬមធ្យោបាយធ្វើដំណើរ<br>• ធ្វើការតាមលំដាប់លំដោយ និងតាមជំនាញ<br>• ទាក់ទងនឹងវត្ថុតាងនីមួយៗ ត្រូវធ្វើកំណត់ហេតុជាលាយលក្ខអក្សរ ៖ |

- ការពិពណ៌នាពីវត្ថុតាង
- ទីតាំងរកឃើញវត្ថុតាង
- ពេលវេលានៃការរកឃើញ
- ព័ត៌មានលម្អិតពីមន្ត្រីដែលបានរកឃើញ និងចាប់យក
- ព័ត៌មានលម្អិតពីរបៀបវេចខ្ចប់ បោះត្រា ស្រោមសំបុត្រ... ។

• បញ្ចប់នៃការឆែកឆេរ ត្រូវអានកំណត់ហេតុនៃការចាប់យក ឱ្យជនសង្ស័យស្តាប់ និងចុះហត្ថលេខាទទួលស្គាល់ ។

៣. វត្ថុតាង

• វត្ថុតាងជាក់លាក់ ៖ ចាប់យកវត្ថុតាងណាមួយ ដែលបានបញ្ជាក់យ៉ាងច្បាស់លាស់ នៅក្នុងព័ត៌មានដែលយើងទទួលបាន ដូចជា ៖

- អាវុធ ឬឧបករណ៍ ដែលបានប្រើប្រាស់ក្នុងការវាយធ្វើបាបជនរងគ្រោះ
- សម្ភារៈប្រើប្រាស់ក្នុងការរឹតត្បិតសេរីភាពរបស់ជនរងគ្រោះ
- សម្ភារៈរបស់ជនរងគ្រោះ
- ឯកសាររបស់ជនរងគ្រោះ ដូចជា អត្តសញ្ញាណប័ណ្ណ ឯកសារធ្វើដំណើរ សៀវភៅកំណត់ហេតុផ្ទាល់ខ្លួន... ។

• វត្ថុតាងផ្សេងៗទៀត ៖ មានការពាក់ព័ន្ធនឹងវត្ថុតាងផ្សេងៗទៀត ក្នុងការស៊ើបអង្កេតរឿងក្តីជួញដូរមនុស្ស

- ចំនួនសាច់ប្រាក់ ប័ណ្ណឥណទាន មូលប្បទានបត្រ
- ឯកសារដទៃទៀតទាក់ទងទៅនឹងការផ្ទេរហិរញ្ញវត្ថុ ដូចជា កិច្ចព្រមព្រៀងជួលអាគារ យានជំនិះ លិខិតរាយមុខទំនិញ វិក្កយបត្រ ប័ណ្ណឥណទាន...
- ឯកសារទាក់ទងនឹងការចំណាយប្រាក់ខែទៅលើបុគ្គលណាមួយ
- ឯកសារអត្តសញ្ញាណប័ណ្ណ ឬលិខិតធ្វើដំណើរ
- ឯកសារទាក់ទងនឹងការផ្សាយពាណិជ្ជកម្ម ការជ្រើសរើស ឬការកេងប្រវ័ញ្ចជនរងគ្រោះ...
- នៅក្នុងករណីជួញដូរសរីរាង្គ ការផ្សាយពាណិជ្ជកម្ម ការផ្តល់អំណោយ កំណត់ហេតុធ្វើដំណើរ កំណត់ហេតុវេជ្ជសាស្ត្រ របាយការណ៍ពិសោធន៍ទៅលើឈាម កោសិកា ឱសថ និងបរិក្ខារវេជ្ជសាស្ត្រពាក់ព័ន្ធ
- ឯកសារទាក់ទងនឹងការប្រើប្រាស់យានជំនិះ ឧបករណ៍ទំនាក់ទំនង
- ឧបករណ៍ដែលជនជួញដូរប្រើប្រាស់ក្នុងការកេងប្រវ័ញ្ចជនរងគ្រោះ មានកូនសោ ទូរស័ព្ទ កុំព្យូទ័រ ឧបករណ៍សម្ភារៈ យានជំនិះ... ។

៤. បញ្ចប់នៃការឆែកឆេរនៅកន្លែងកើតហេតុនីមួយៗ ត្រូវផ្ទៀងផ្ទាត់ថា មិនមានអ្វី បន្សល់ទុកនៅទីនោះទេ ហើយវត្ថុដែលបានចាប់យកទាំងអស់ត្រូវបានរក្សាទុក ។

សេចក្ដីសម្រេចរបស់មន្ត្រីអនុវត្តច្បាប់ក្នុងការចាប់ខ្លួនជនណាម្នាក់ ត្រូវឱ្យស្របនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលពាក់ព័ន្ធ គឺជាប្រភពនៃអំណាចចាប់ខ្លួន ។ ជាធម្មតា ការចាប់ខ្លួនអាចត្រូវបានបែងចែកជាពីរប្រភេទ ការចាប់ខ្លួនដោយមានរៀបចំផែនការ និងដោយគ្មានផែនការ ។ ជាធម្មតា ការចាប់ខ្លួនដោយគ្មានផែនការ កើតឡើងជាញឹកញាប់ដោយសារសកម្មភាពជាទូទៅរបស់នគរបាល ចំណែកឯការចាប់ខ្លួនដោយមានរៀបចំជាផែនការ ជាញឹកញាប់ កើតមកពីការស៊ើបអង្កេត ដោយមានរចនាសម្ព័ន្ធ របស់នគរបាល ។

## ២. កត្តាពិចារណាមុនការចាប់ខ្លួន

ការចាប់ខ្លួនដោយមានផែនការ គឺជាការចាប់ខ្លួន កើតចេញមកពីការស៊ើបអង្កេតរកអង្គហេតុ ការវិភាគ ទៅលើហានិភ័យ និងការកំណត់ថាតើការចាប់ខ្លួនជនសង្ស័យ គឺធ្វើឡើងដោយស្របច្បាប់ និងជាការសម្រេចចិត្តប្រកបទៅដោយភាពត្រឹមត្រូវដែរឬទេ ។

ការចាប់ខ្លួនដោយមានផែនការ គួរតែធ្វើឡើងបន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតណាមួយ ។ នោះមិនមានន័យថា ការស៊ើបអង្កេតដោយមានផែនការ តម្រូវឱ្យមានការស៊ើបអង្កេតទូលំទូលាយជាមុននោះទេ ។ ការចាប់ខ្លួនដោយមានផែនការ មានសកម្មភាពមួយចំនួន ៖

- ការវាយតម្លៃអង្គហេតុ
    - តើបទល្មើសបានកើតឡើងឬទេ ?
    - តើបទល្មើសកើតឡើងនៅពេលណា ?
    - តើវាជាបទល្មើសអ្វី ?
    - តើបទល្មើសដែលបានបញ្ជាក់នោះ ជាសមត្ថកិច្ចរបស់អ្នកឬទេ ?
    - តើអំណាចចាប់ខ្លួន ឆែកឆេរ និងរឹបអូស អាចអនុវត្តបានដែរឬទេ ?
    - តើអាចកំណត់អត្តសញ្ញាណជនសង្ស័យបានដែរឬទេ ?
    - តើត្រូវគិតពីសុវត្ថិភាពនៃសហគមន៍ ក្នុងការចាប់ខ្លួនជន ?
    - តើជនសង្ស័យអាចរត់គេចខ្លួនដែរឬទេ ?
    - តើជនសង្ស័យអាចសហការជាមួយសមត្ថកិច្ចដែរឬទេ ?
    - តើមានភស្តុតាងគ្រប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់ឬទេ ?
    - តើការចាប់ខ្លួនចាត់ទុកថាជាមធ្យោបាយ ដើម្បីទទួលបានការសារភាពដែរឬទេ ?
    - តើការប្រើប្រាស់អំណាចចាប់ខ្លួននេះ ជាការបំពានច្បាប់ដែរឬទេ ?
- រៀបចំផែនការ
    - តើអ្នកណាខ្លះជាជនសង្ស័យ ?
    - តើជនសង្ស័យមានចរិតបែបណា ?
    - តើអ្នកណាខ្លះ ជាបក្ខពួករបស់ជនសង្ស័យ ?
    - ការចាប់ខ្លួនដោយមានដីកា ឬដោយគ្មានដីកា
    - ពេលវេលានៃការចាប់ខ្លួន
    - តើមានកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធក្នុងការចាប់ខ្លួនដែរឬទេ ?

   ○ ចំនួនកម្លាំងប្រតិបត្តិការ និងតួនាទីភារកិច្ចទទួលខុសត្រូវ
   ○ ផែនទីនៃកិច្ចប្រតិបត្តិការចាប់ខ្លួន ។
- សេចក្តីពន្យល់សង្ខេប
  មន្ត្រីមានភារកិច្ចអនុវត្តផែនការចាប់ខ្លួន ត្រូវយល់ពីកិច្ចប្រតិបត្តិការឱ្យបានច្បាស់ ៖
   ○ គោលបំណង ៖ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ និងប្រើប្រាស់ពាក្យសាមញ្ញ
   ○ បេសកកម្ម ៖ បញ្ជាក់ចំណុចសំខាន់ៗ ពីការស៊ើបអង្កេត រហូតដល់ការចាប់ខ្លួន
   ○ ការអនុវត្ត ៖ មន្ត្រីត្រូវអនុវត្តតាមតួនាទី និងភារកិច្ចរបស់ខ្លួន ។

### ៣. ប្រតិបត្តិការចាប់ខ្លួន

ប្រសិទ្ធភាពនៃភាពជោគជ័យក្នុងការចាប់ខ្លួន គឺត្រូវកម្រិតនូវការប្រើប្រាស់កម្លាំងជាអប្បបរមា ។ កិច្ចប្រតិបត្តិការចាប់ខ្លួន ជាពិសេសការចាប់ខ្លួនដោយមានផែនការ គួរតែរកមធ្យោបាយ ដើម្បីកាត់បន្ថយនូវការប្រើប្រាស់កម្លាំង ឬអាវុធ តាមរយៈការវាយតម្លៃពីហានិភ័យឱ្យបានលម្អិត និងធានាថាមន្ត្រីដែលបានជ្រើសរើស ក្នុងកិច្ចប្រតិបត្តិការចាប់ខ្លួន បានទទួលនូវការបណ្តុះបណ្តាលត្រឹមត្រូវ និងមានសមត្ថភាពក្នុងការចរចា សម្របសម្រួល និងដោះស្រាយវិវាទ ។

បញ្ហានានាដែលអាចប្រឈម នៅក្នុងអំឡុងពេលនៃការចាប់ខ្លួន ក្នុងប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងប្រទេសគោលដៅ ត្រូវអនុវត្តតាមដំណាក់កាលនៃការចាប់ខ្លួន នៅពេលជនសង្ស័យសំខាន់ៗមានវត្តមាននៅកន្លែងកេងប្រវ័ញ្ច ដូចជា រោងចក្រ ការបម្រើតាមផ្ទះ ផ្ទះបន... ។

- នៅក្នុងអំឡុងពេលនៃការសម្ភាស ជនជាមេខ្យល់ "អ្នកជ្រើសរើស ជនរងគ្រោះ" ដែលទាក់ទងទៅនឹងការជ្រើសរើសជនរគ្រោះ ឬនៅពេលប្រមូល និងដឹកជញ្ជូនជនរងគ្រោះទៅកន្លែងកេងប្រវ័ញ្ច អាចត្រូវបានចាប់ខ្លួន នៅក្នុងប្រទេសប្រភពនៃការជួញដូរមនុស្ស
- គោលដៅចាប់ខ្លួនជនជួញដូរមនុស្ស គឺនៅពេលជនល្មើសមានវត្តមានជាមួយជនរងគ្រោះ នៅកន្លែងកេងប្រវ័ញ្ច ។ ការធ្វើដូចនេះ ជនជួញដូរមនុស្សមិនអាចប្រកែកបានពីអំពើ ឬប្រភេទនៃការកេងប្រវ័ញ្ចរបស់ខ្លួន
- ទោះបីរឿងក្តីជួញដូរមនុស្សមានកម្រិតទាបក៏ដោយ ក៏រឿងក្តីនោះមានភាពស្មុគស្មាញ ហើយរាល់កិច្ចប្រតិបត្តិការចាប់ខ្លួន ត្រូវរៀបចំឱ្យមានផែនការប្រតិបត្តិការចាប់ខ្លួន និងមានការពន្យល់ដោយសង្ខេបពីផែនការនោះ
- នៅកន្លែងកេងប្រវ័ញ្ច មន្ត្រីប្រតិបត្តិការ អាចត្រូវប្រឈមជាមួយមុខសញ្ញាពីរប្រភេទ គឺជនសង្ស័យ និងជនរងគ្រោះ ។ ប្រសិនបើរឿងក្តីទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការចាប់ខ្លួនកើតមានឡើងនៅកន្លែងផ្ទះបន ក្នុងករណីនេះ មន្ត្រីអនុវត្តច្បាប់អាចត្រូវប្រឈមជាមួយបុគ្គលទីបី
- ជនរងគ្រោះបរទេស អាចត្រូវចាប់ខ្លួន ដោយសារស្នាក់នៅ ឬធ្វើការខុសច្បាប់នៅក្នុងប្រទេសនោះ ។ នៅក្នុងដំណាក់កាលនេះ ជនរងគ្រោះបរទេស គឺជាជនរងគ្រោះធ្ងន់ធ្ងរនៃបទល្មើស និងជាសាក្សីសំខាន់ ក្នុងការប្រឆាំងជនជួញដូរមនុស្ស ដូចនេះ ជនរងគ្រោះត្រូវបានគេយកចិត្តទុកដាក់ជាខ្លាំង និងមិនត្រូវបានដាក់ឱ្យនៅកន្លែងឃុំឃាំង ជាមួយជនជួញដូរមនុស្ស ហើយជនរងគ្រោះជាស្ត្រីភេទ ត្រូវដាក់ដាច់ដោយឡែកពីជនរងគ្រោះ ជាបុរស

- ក្រុមចាប់ខ្លួន ត្រូវបែងចែកជាពីរក្រុម- ក្រុមមួយទទួលបន្ទុកលើជនរងគ្រោះ ហើយក្រុមមួយទៀត ត្រូវទទួលខុសត្រូវលើការចាប់ខ្លួនជនសង្ស័យ
- បុគ្គលិករបស់ទីភ្នាក់ងារគាំពារជនរងគ្រោះ ត្រូវអនុញ្ញាតឱ្យប្រាស្រ័យទាក់ទង និងពិគ្រោះយោបល់ដល់ជនរងគ្រោះថា មិនមែនជាជនល្មើសនោះទេ
- ក្នុងករណីជនរងគ្រោះជាជនបរទេស ត្រូវមានអ្នកបកប្រែដើម្បីគាំទ្រជនរងគ្រោះ
- ជនរងគ្រោះ ត្រូវនាំចេញពីកន្លែងកើតហេតុ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីកុំឱ្យជនជួញដូរមនុស្ស មានឱកាសគំរាមកំហែងជនរងគ្រោះ
- ជនរងគ្រោះ ត្រូវអនុញ្ញាតឱ្យប្រមូលទ្រព្យសម្បត្តិ និងសម្ភារៈរបស់ខ្លួន
- ជនរងគ្រោះត្រូវសហការជាមួយមន្ត្រីអនុវត្តច្បាប់ ក្នុងការស្វែងរកឯកសារពាក់ព័ន្ធ
- មន្ត្រីត្រូវមានឧបករណ៍ថតរូប ឬវីដេអូ ក្នុងដំណាក់កាលប្រតិបត្តិការចាប់ខ្លួន ។

**សំណួររំលឹកមេរៀន**

- តើគោលបំណងអ្វីខ្លះ នៅក្នុងការចាប់ខ្លួនជនសង្ស័យ នៅក្នុងរឿងក្តីជួញដូរមនុស្ស?
- កំណត់ពីការចាប់ខ្លួនដោយបំពាន ដោយប្រើប្រាស់គំនិតរបស់លោកអ្នក
- មន្ត្រីនគរបាលអាចចាប់ខ្លួនជនណាម្នាក់ដោយគ្មានដីកា ក្នុងករណីអ្វីខ្លះ?
- រៀបរាប់ពីកាតព្វកិច្ចរបស់មន្ត្រីអនុវត្តច្បាប់ ទាក់ទងទៅនឹងសិទ្ធិរបស់ជនដែលត្រូវចាប់ខ្លួន
- រៀបរាប់ពីតម្រូវការរបស់ច្បាប់អន្តរជាតិ ទាក់ទងទៅនឹងទង្វើទៅលើជនល្មើសជាកុមារ
- រៀបចំផែនការឱ្យបានលម្អិត ពីប្រតិបត្តិការចាប់ខ្លួន
- រៀបចំឯកសារពីការពន្យល់ដោយសង្ខេប ចំពោះកិច្ចប្រតិបត្តិការចាប់ខ្លួន
- ពន្យល់ពីការអនុវត្តកិច្ចប្រតិបត្តិការចាប់ខ្លួន និងពីរបៀបត្រួតពិនិត្យកន្លែងកើតហេតុ ៕

៚៚៚ ✸ ៙៙៙

# ឯកសារយោង


- ឯកសារមេរៀនរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ២០០៣
  - Bourg, Wendy et al; *A Child Interviewer's Guidebook*, Thousand Oaks, CA: Sage Publications, 1999
  - Goodman, Gail; Bottoms, Bette; *Child Victims, Child Witnesses: Understanding and Improving Testimony*, New York, NY: The Guilford Press, 1993
  - Mapes, Bruce; *Child Eyewitness Testimony in Sexual Abuse Investigations*, Brandon, VT: Clinical Psychology Publishing Co., 1995
  - Milne, Rebecca; Bull, Ray; *Investigative Interviewing: Psychology and Practice*, Chichester, West Sussex, UK: John Wiley & Sons Press, 1999
  - Morgan, Marcia; *How to Interview Sexual Abuse Victims Including the Use Of Anatomical Dolls*, Thousand Oaks, CA: Sage Publications, 1995
  - Poole, Debra A; *Investigative Interviews of Children: A Guide for Helping Professionals*, Washington, DC: American Psychological Association, 1998
  - Schafer, John; Navarro, Joe; *Advanced Interviewing Techniques: Proven Strategies for Law Enforcement, Military, and Security Personnel*, Springfield. IL: Thomas Books, 2003
  - Shuy, Roger W.; *The Language of Confession, Interrogation, and Deception*, Thousand Oaks, CA: Sage Publications, 1998
  - Swanson, Charles R. et al; *Criminal Investigation*, Boston, MA: McGraw Hill Publications, 2003, 8th edition
  - Yeschke, Charles; *The Art of Investigative Interviewing: A Human Approach to Testimonial Evidence*, Boston, MA: Butterworth-Heinemann Press, 1997

  **MANUALS USED**

  - Faller, Kathleen C.; *Child Sexual Abuse: Intervention and Treatment Issues*, U.S. Department of Health and Human Services Administration for Children and Families, McLean, VA: The Circle, Inc, 1993
  - Ministry of Interior, General Director of National Police, Kingdom of Cambodia; *Understanding and Investigating Child Sexual Exploitation*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2000
  - Ministry of Interior, General Director of National Police, Kingdom of Cambodia; *Training Document on Child Victim Sensitivity*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2003
  - Sas, Louise; *The Interaction Between Children's Developmental Capabilities and the Courtroom Environment: The Impact on Testimonial Competency*, Report prepared for the Department of Justice Canada, 2002

  **OTHER MATERIALS USED**

  - U. S. Department of State Trafficking in Persons Report, 2004

  **WEB SITES USED**

  - HTTP://www.childdevelopmentinfo.com/development/language_development.shtml
  - HTTP://www.families.qld.gov.au/projectaxis/orgbooklet/development.html
  - HTTP://danenet.wicip.org/dcccrsa/saissues/parent/1.html
  - HTTP://www.aacap.org/publications/factsfam/develop.htm
  - HTTP://www.secasa.com.au/index.php/family/12/120
  - HTTP://www.earlychildhoodbehavioralhealth.com/ChildDev/sexdevelop.htl
  - HTTP://www.ces.perdue.edu/providerparent/Child%20Growth-Development/SexualDEV.htm
  - HTTP://www.state.gov/g/tip/rls/tiprpt/2004/34021pf.htm
- ឯកសារមេរៀនរបស់ ARTIP ២០០៩ ។

# បណ្ឌិត្យសភានគរបាលកម្ពុជា

## កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ

# វិធីសាស្ត្រ ក្នុងការស៊ើបអង្កេត ករណីជួញដូរមនុស្ស

២០១៧

សូមរក្សាសិទ្ធិ

មេរៀននេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការវីនរ៉ក់ ឬរដ្ឋាភិបាលអាមេរិក

# វិធីសាស្ត្រក្នុងការស៊ើបអង្កេតករណីជួញដូរមនុស្ស

## I. សេចក្តីផ្តើម

ការគ្រប់គ្រងករណីជួញដូរមនុស្ស គឺជាបញ្ហាស្មុគស្មាញ ដែលទាមទារឱ្យមានការប្រើប្រាស់ការរួមបញ្ចូលគ្នានៃវិធីសាស្ត្របែបស៊ើបអង្កេត និងបច្ចេកទេស ។ ការស៊ើបអង្កេតនឹងមិនដំណើរការរលូនតាមការរំពឹងទុកទាំងស្រុងនោះទេ ។ ជំនាញរបស់មន្ត្រីស៊ើបអង្កេត គឺត្រូវស្វែងរកចំណុចរួមនេះ ដែលទាមទារឱ្យមានការសាកសួរ និងពិចារណាអំពីឱកាសក្នុងការស៊ើបអង្កេត តាមរយៈព័ត៌មានដែលទទួលបាន ។ ការស៊ើបអង្កេតបែបប្រតិកម្ម និងសកម្មជាមុន (តាមគំនិតផ្តួចផ្តើមរបស់មន្ត្រីនគរបាលយុត្តិធម៌) អាចជាជម្រើសតែមួយ ក្នុងការបង្ការទប់ស្កាត់សកម្មភាពរបស់ជនល្មើសជួញដូរមនុស្ស ។ ការស៊ើបអង្កេតមួយចំនួនមិនមានភស្តុតាងរឹងមាំ ដើម្បីឈានទៅដល់ការផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស ហើយអាចធ្វើឱ្យជនរងគ្រោះ ឬសាក្សី ប្រឈមនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

### ១. ការស៊ើបអង្កេតបែបប្រតិកម្ម

ការស៊ើបអង្កេតបែបប្រតិកម្ម ធ្វើឡើងនៅពេលទទួលព័ត៌មានអំពីបទល្មើស ដែលត្រូវបានប្រព្រឹត្ត និងទាមទារនូវការឆ្លើយតបភ្លាមៗ ។ បទល្មើសបានកើតឡើង ហើយការស៊ើបអង្កេតត្រូវបានធ្វើឡើងដើម្បីកំណត់អំពីអង្គហេតុនៃករណី ។ ទោះបីជាបទល្មើសបានកើតឡើងហើយក៏ដោយ ក៏គួរតែប្រើបច្ចេកទេសស៊ើបអង្កេតបែបសកម្មជាមុន ដើម្បីជួយដល់កិច្ចការស៊ើបអង្កេត ។

ឧទាហរណ៍៖ មន្ត្រីនគរបាលទទួលព័ត៌មានថា ជនរងគ្រោះនៃការជួញដូរពលកម្មដោយបង្ខំ ដែលជាជនជាតិខ្មែរ នៅក្នុងប្រទេសថៃ ត្រូវបានធ្វើមាតុភូមិនិវត្តន៍មកវិញ ។ ជនរងគ្រោះនិយាយថា ខ្លួនត្រូវបានអ្នកជ្រើសរើសពលករទំនាក់ទំនង នៅក្នុងស្រុកកំណើតរបស់គាត់ក្នុងខេត្តកំពង់ចាម ដើម្បីធ្វើការងារនៅលើទូកនេសាទក្នុងប្រទេសថៃ ដែលគាត់នឹងទទួលបានប្រាក់ខែ ៤៥០ ដុល្លារ ក្នុងមួយខែ និងមានឱកាសមកលេងផ្ទះបន្ទាប់ពីធ្វើការបានមួយឆ្នាំ ។ មេខ្យល់បានរៀបចំឱ្យជនរងគ្រោះឆ្លងកាត់ព្រំដែនខ្មែរថៃនៅក្បែរក្រុងប៉ោយប៉ែត ដោយគ្មានឯកសារធ្វើដំណើរត្រឹមត្រូវ និងបានអមដំណើរគាត់ទៅផែប្រាក់ណាម មឿងសាមុតប្រាកាន ក្នុងប្រទេសថៃ ។ នៅពេលទៅដល់កំពង់ផែនោះ មេខ្យល់បានលក់ជនរងគ្រោះទៅឱ្យម្ចាស់ទូកនេសាទក្នុងតម្លៃ ១៥០០ ដុល្លារ ។ អ្នកនេសាទ រូបនោះ ត្រូវបានបង្ខំឱ្យធ្វើការនៅលើទូកនេសាទអស់រយៈពេល ៥ ឆ្នាំ ដោយទទួលប្រាក់ឈ្នួលតិចតួច និងរងការរំលោភបំពានរាងកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ។ ទូកនេសាទនោះ ត្រូវបានឃាត់ដោយរដ្ឋាភិបាលឥណ្ឌូនេស៊ី ពីបទនេសាទខុសច្បាប់ក្នុងដែនសមុទ្រ ។ បន្ទាប់ពីមានការឃុំខ្លួន រយៈពេល ៦ ខែ ជនរងគ្រោះក៏ត្រូវបានធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ ដោយមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ។ មន្ត្រីអនុវត្តច្បាប់ត្រូវបានទំនាក់ទំនងដើម្បីសម្ភាសជនរងគ្រោះ ។

ដូចជាបានបញ្ជាក់ពីមុនរួចហើយ នៅក្នុងការស៊ើបអង្កេតបែបប្រតិកម្ម បទល្មើសបានកើតឡើងរួចហើយ ហើយការស៊ើបអង្កេតត្រូវបានធ្វើឡើងដើម្បីកំណត់អង្គហេតុនៃករណី ។ នៅក្នុងករណីនៃការជួញដូរមនុស្ស ជាញឹកញាប់ ជនរងគ្រោះត្រូវបានធ្វើមាតុភូមិនិវត្តន៍ ឬបានរត់គេចចេញពីកាលៈទេសៈរបស់ពួកគេ ។

**ក. វិធីសាស្ត្របែបប្រតិកម្មមានលក្ខណៈទូលំទូលាយ**

- ធ្វើការសម្ភាស និងទទួលសក្ខីកម្មពីជនសង្ស័យ និងសាក្សី
- ការប្រមូលភស្តុតាងដើម្បីគាំទ្រសក្ខីកម្មរបស់ជនរងគ្រោះ និងសាក្សី
- ការកំណត់អត្តសញ្ញាណ ការឃុំខ្លួន/ការចាប់ខ្លួន និងសម្ភាសជនសង្ស័យ
- ការអនុវត្តដីកាឆែកឆេរទៅលើបរិវេណគេហដ្ឋាន ឬទីតាំងរបស់ជនសង្ស័យ ដើម្បីប្រមូលភ័ស្តុតាង
- វិភាគភស្តុតាងដែលទទួលបាន ។

**ខ. ឱកាស**

- ជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណរួចហើយ មន្ត្រីស៊ើបអង្កេតអាចនឹងស្វែងយល់អំពីអ្វីដែលបានកើតឡើង
- ការកំណត់អត្តសញ្ញាណជនរងគ្រោះ ផ្តល់ឱកាសធ្វើការស៊ើបអង្កេតកន្លែងកើតហេតុ
- ជនរងគ្រោះមិនស្ថិតនៅក្នុងគ្រោះថ្នាក់ភ្លាមៗទេ ឬអាចនឹងត្រូវយកចេញ ពីស្ថានភាពគ្រោះថ្នាក់ភ្លាមៗ
- សញ្ជាតិរបស់ជនរងគ្រោះ និងលក្ខណៈនៃអំពើជួញដូរ អាចនាំទៅរកឱកាសជាច្រើនទៀត ដើម្បីកសាងព័ត៌មានអំពីជនដែលអាចរងគ្រោះផ្សេងទៀត និងបណ្តាញជនល្មើស ។

**គ. ការគំរាមកំហែង**

- មន្ត្រីខ្វះបទពិសោធន៍ធ្វើការលើករណីជួញដូរមនុស្ស
- មន្ត្រីស៊ើបអង្កេតសម្រេចចិត្តដោយប្រញាប់ប្រញាល់
- ជនរងគ្រោះស្ថិតនៅជាមួយក្រុមជនល្មើស
- ជនរងគ្រោះអាចនឹងត្រូវបានឃុំខ្លួនក្នុងមណ្ឌល មុនពេលត្រូវធ្វើមាតុភូមិនិវត្តន៍
- ជនរងគ្រោះគ្មានការទុកចិត្តលើមន្ត្រីអនុវត្តច្បាប់ ឬស្ទាក់ស្ទើរក្នុងការផ្តល់ព័ត៌មាន
- ជនរងគ្រោះអាចនឹងទទួលការប៉ះទង្គិចផ្លូវចិត្ត
- ជនរងគ្រោះអាចប្រឈមនឹងបញ្ហាអន្តោប្រវេសន៍ខុសច្បាប់
- បញ្ហាទំនាក់ទំនងការទូតពាក់ព័ន្ធនឹងជនសង្ស័យ ឬជនរងគ្រោះ
- ទីកន្លែងស្នាក់នៅ និងសេវាថែទាំជនរងគ្រោះត្រូវរៀបចំភ្លាមៗក្នុងរយៈពេលខ្លី
- បញ្ហាភាសា អ្នកបកប្រែ និងការកត់ត្រាសក្ខីកម្មត្រូវរៀបចំភ្លាមៗក្នុងរយៈពេលខ្លី
- ពេលវេលាមិនគ្រប់គ្រាន់ក្នុងដំណើរការស៊ើបអង្កេត ដើម្បីប្រមូលភស្តុតាង
- ពឹងផ្អែកតែលើបន្ទាល់របស់ជនរងគ្រោះ និងសាក្សី
- បញ្ហាលំបាកក្នុងការទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ជនរងគ្រោះ
- ការសម្រេចចិត្តដ៏តក់ក្រហល់របស់មន្ត្រីស៊ើបអង្កេត អាចនឹងធ្វើឱ្យជនរងគ្រោះជួបគ្រោះថ្នាក់ និងមិនមានភស្តុតាងគ្រប់គ្រាន់ ក្នុងការដាក់បន្ទុកជនសង្ស័យ ។

### ឃ. ការឆ្លើយតប

- ការរៀបគម្រោងបន្ទាន់ ដើម្បីឆ្លើយតបចំពោះការស៊ើបអង្កេតទទួលបានជោគជ័យ
- ការរៀបចំដំណើរការ ដើម្បីឆ្លើយតបចំពោះអ្នកដែលធ្វើមាតុភូមិនិវត្តន៍
- អនុវត្តផែនការដោយប្រើប្រាស់ធនធាន និងវិធីសាស្រ្តសមស្រប
- រៀបចំផែនការតាមស្ថានភាព
- បណ្តុះបណ្តាលសមត្ថភាពជំនាញដើម្បីធ្វើការស៊ើបអង្កេតលើអំពើជួញដូរមនុស្ស
- បញ្ជីឈ្មោះអ្នកបកប្រែ
- ត្រូវយល់ដឹងអំពីគោលនយោបាយ និងទំនាក់ទំនងជាមួយអង្គភាពអន្តោប្រវេសន៍
- ត្រូវរកជំនួយសមស្របសម្រាប់ជនរងគ្រោះ ក្នុងកម្រិតថ្នាក់ជាតិ និងអន្តរជាតិ
- កំណត់អំពីទីកន្លែងស្នាក់នៅ ឬមណ្ឌលរបស់អង្គការជំនួយសម្រាប់ជនរងគ្រោះ
- ជំនួយការផ្លូវច្បាប់
- ពិចារណាអំពីតម្រូវការនៃវិធានការការពារសាក្សី ដើម្បីលើកទឹកចិត្តជនរងគ្រោះ និងសាក្សីដទៃទៀត ឱ្យមានទំនុកចិត្តក្នុងការផ្តល់សក្ខីកម្ម ។

## ២. ការស៊ើបអង្កេតបែបសកម្មជាមុន

ការស៊ើបអង្កេតបែបសកម្មជាមុន ត្រូវបានធ្វើឡើងដោយមន្រ្តីស៊ើបអង្កេត ជាញឹកញាប់តាមរយៈព័ត៌មានដែលប្រមូលបាន ។ ការស៊ើបអង្កេតបែបសកម្មជាមុន ប្រើនូវវិធីសាស្រ្តឯកទេស (ដូចជា ការប្រើភ្នាក់ងារផ្តល់ព័ត៌មាន ប្រតិបត្តិការស៊ើបការណ៍សម្ងាត់ និងទម្រង់ផ្សេងៗនៃការឈ្លបយកការណ៍)ដើម្បីប្រមូលភស្តុតាង មុនពេលចាត់វិធានការ ដូចជាការចាប់ខ្លួនជនសង្ស័យ និងសង្គ្រោះជនរងគ្រោះ ។

ឧទាហរណ៍ ៖ មន្រ្តីនគរបាលទទួលព័ត៌មានតាមរយៈអ្នកផ្តល់ព័ត៌មានម្នាក់ថា កុមារីទាំងនោះនឹងមកដល់កន្លែងកម្សាន្តមួយ ដែលមន្រ្តីនគរបាលបានដឹងថា មានអំពើពេស្យាចារ កើតឡើង ។ នៅថ្ងៃស្អែក នឹងមានក្មេងស្រីជាច្រើនមកដល់ ហើយត្រូវបានរំពឹងថា នឹងធ្វើការនៅក្នុងកន្លែងកម្សាន្តនោះតែមួយសប្តាហ៍ទេ មុនពេលត្រូវផ្លាស់ប្តូរទីតាំងម្តងទៀត ។ អ្នកផ្តល់ព័ត៌មាននេះ ធ្លាប់ផ្តល់ព័ត៌មានដែលគួរឱ្យទុកចិត្តកន្លងមក ហើយតាមរយៈតួនាទីរបស់គាត់ជាបុគ្គលិក សន្តិសុខនៅកន្លែងកម្សាន្តនោះ គាត់អាចទទួលបាននូវព័ត៌មានល្អៗ ។ មន្រ្តីនគរបាលបានរៀបចំការឃ្លាំមើលសម្ងាត់អំពីគ្រឹះស្ថានកម្សាន្តនោះ ដើម្បីឃ្លាំមើលការមកដល់របស់ក្មេងស្រី និងធ្វើអន្តរាគមន៍ភ្លាមៗប្រសិនបើចាំបាច់ ។

ការស៊ើបអង្កេតបែបសកម្មជាមុន ត្រូវបានចាប់ផ្តើមដោយមន្រ្តីស៊ើបអង្កេត ដោយខ្លួនឯងដោយសារទទួលបាននូវព័ត៌មានសម្ងាត់ ។ ជាញឹកញាប់ ការស៊ើបអង្កេតបែបសកម្មជាមុន ប្រើបច្ចេកទេសជំនាញ ( ការប្រើអ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់ ការឃ្លាំមើល និងការប្រមូលព័ត៌មានសម្ងាត់) ដើម្បីកសាងភស្តុតាងមុនពេលចាត់វិធានការ ដូចជាចាប់ខ្លួនជនសង្ស័យ និងការរំដោះជនរងគ្រោះ ។

- បច្ចេកទេសក្នុងការស៊ើបអង្កេត

វិធីសាស្ត្របូរាណ មិនអាចដោះស្រាយជាមួយក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងបានឡើយ ដោយសារក្រុមឧក្រិដ្ឋជនជាមនុស្សមួយជីវិតរបស់ពួកគេពាក់ព័ន្ធនឹងបទល្មើស ។ ពួកគេអាចជាមនុស្សសំបូរធនធាន ចេះបត់បែន និងគ្មានមេត្តាធម៌ ហើយចំណាយពេលវេលា និងកម្លាំងភាគច្រើនទៅលើអំពើល្មើស និងមិនឈប់ធ្វើសកម្មភាពរបស់ពួកគេ ។

ទោះបីជាប្រភេទ "បច្ចេកទេសជំនាញ" និងរបៀបអនុវត្តត្រូវបានគ្រប់គ្រងដោយច្បាប់របស់ប្រទេសជាក់លាក់ណាមួយក៏ដោយ ជំនាញបច្ចេកទេសទាំងនេះនឹងពង្រឹងសមត្ថភាពរបស់អ្នកស៊ើបអង្កេត ឱ្យធ្វើការស៊ើបអង្កេតទៅលើបទល្មើសជួញដូរមនុស្ស ។

- តើបច្ចេកទេសទាំងនេះមានអ្វីខ្លះ ?
  - បច្ចេកទេស គឺជាជំនាញដែលមិនត្រូវបានប្រើក្នុងការគ្រប់គ្រងប្រចាំថ្ងៃនោះទេ
  - បច្ចេកទេសទាំងនេះជាទូទៅមានលក្ខណៈសម្ងាត់
  - វិធីសាស្ត្រនេះ បំពានចូលទៅក្នុងជីវិតឯកជនរបស់បុគ្គល ដូច្នេះការប្រើប្រាស់បច្ចេកទេសនេះ ត្រូវបានគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្ននៅក្នុងយុត្តាធិការជាច្រើន ។

អំពើជួញដូរមនុស្សពាក់ព័ន្ធនឹងបណ្តាញឧក្រិដ្ឋកម្ម ដែលពឹងផ្អែកទាំងស្រុងទៅលើការប្រើប្រាស់ការបង្ខំ ការបោកប្រាស់ និងការសម្លុតបំភ័យ ។ ជំនាញឯកទេសទាំងនេះអាចជួយកាត់បន្ថយការពឹងផ្អែកលើសក្ខីកម្មរបស់ជនរងគ្រោះ និងអនុញ្ញាតឱ្យមន្ត្រីអនុវត្តច្បាប់ជ្រៀតចូលទៅក្នុងក្រុមឧក្រិដ្ឋជនទាំងនេះ ។

- ជំនាញឯកទេសទាំងនេះមាន ៖
  - ការប្រើអ្នកផ្តល់ព័ត៌មាន
  - ភ្នាក់ងារស៊ើបការណ៍សម្ងាត់
  - ការឃ្លាំមើល
  - ការពិនិត្យមើលការប្រាស្រ័យទាក់ទង និងការបង្អាក់សកម្មភាព
  - ការវិភាគ និងការប្រើទិន្នន័យប្រាស្រ័យទាក់ទង ។

ជំនាញឯកទេសទាមទារនូវការបណ្តុះបណ្តាលឯកទេស និងបទពិសោធន៍ ដើម្បីប្រើក្នុងពេលស៊ើបអង្កេតសកម្មជាមុន ។ បច្ចេកទេសគួរតែត្រូវបានអនុវត្តដោយអ្នកឯកទេស ដែលទទួលបាននូវការបណ្តុះបណ្តាល និងបទពិសោធន៍ក្នុងបច្ចេកទេសជាក់លាក់ ។

- គោលបំណងនៃបច្ចេកទេសក្នុងការស៊ើបអង្កេតកំណត់អំពី៖
  - ជនជួញដូរ
  - ជនរងគ្រោះ
  - ទីតាំង
  - អ្នកពាក់ព័ន្ធ
  - បណ្តាញទំនាក់ទំនង

- មធ្យោបាយ និងហិរញ្ញវត្ថុ
- ការផ្សព្វផ្សាយ
- ភស្តុតាង និងព័ត៌មានសម្ងាត់
- ប្រើវិធានការជំនាញក្នុងការស៊ើបអង្កេត ។

• ការអនុវត្ត

- ប្រមូលព័ត៌មានទាក់ទងនឹងជនជួញដូរ បរិវេណអគារ ជនរងគ្រោះ ឬអ្នកពាក់ព័ន្ធផ្សេងទៀត តាមរយៈការឃ្លាំមើល ការពិនិត្យតាមដានការប្រាស្រ័យទាក់ទង និងការលបចូលដោយអ្នកផ្តល់ព័ត៌មាន ឬភ្នាក់ងារសម្ងាត់
- ប្រើវិធីសាស្ត្រផ្សេងៗដើម្បីកំណត់អំពីបណ្តាញទំនាក់ទំនងដែលជនជួញដូរប្រើ
- កំណត់អត្តសញ្ញាណមធ្យោបាយប្រើប្រាស់ ក្នុងដំណើរការជួញដូរ
- កំណត់អំពីបែបផែន វិធីសាស្ត្រដែលជនជួញដូរប្រើ ដើម្បី "សម្អាត" ប្រាក់ ។

ការស៊ើបអង្កេតទទួលបានប្រសិទ្ធភាព លុះត្រាមានការបញ្ចូលជាមួយជំនាញឯកទេស នៅក្នុងបច្ចេកទេសស៊ើបអង្កេត ដូចជា ការស៊ើបអង្កេតបែបប្រតិកម្ម ការស៊ើបអង្កេតសកម្មជាមុន ការស៊ើបអង្កេតលើហិរញ្ញវត្ថុ និងការប្រមូលវិភាគទិន្នន័យផ្សេងៗ...។

• លទ្ធផល ៖ គឺជាព័ត៌មាន ឬព័ត៌មានសម្ងាត់ដែលប្រមូលបាន ដោយការប្រើបច្ចេកទេសណាមួយ ។ ការ ប្រើប្រាស់បច្ចេកទេសនេះមានភាពស្មុគស្មាញក្នុងការរៀបចំផែនការ និងប្រើប្រាស់នូវធនធានសំខាន់ៗ ហើយជាញឹកញាប់ ត្រូវការពេលវេលាច្រើន

• នីតិវិធី

- បច្ចេកទេសជំនាញអនុវត្តតាមនីតិវិធី និងដែនសមត្ថកិច្ច
- ត្រូវពិចារណាទៅលើច្បាប់អន្តរជាតិ ព្រោះទាមទារនូវកិច្ចសហប្រតិបត្តិការរួម
- ត្រូវមានកិច្ចព្រមព្រៀងក្នុងកិច្ចសហប្រតិបត្តិការ ដែលត្រូវសហការជាមួយនគរបាលអន្តរជាតិ ។

• ការបណ្តុះបណ្តាល ៖ ការប្រើបច្ចេកទេសទាមទារនូវចំណេះដឹង និងជំនាញ ហេតុនេះមន្ត្រីស៊ើបអង្កេតត្រូវទទួលការបណ្តុះបណ្តាល និងមិនគួរប្រើបច្ចេកទេសនេះដោយខ្លួនឯងទេ ពួកគេគួរតែប្រឹក្សាយោបល់ជាមួយមន្ត្រីជំនាញ និងមានបទពិសោធន៍

• ការគ្រប់គ្រង

- ការប្រើបច្ចេកទេសជំនាញ ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង ដើម្បីផ្តល់នូវជំនួយ និងធានាសុវត្ថិភាពសម្រាប់មន្ត្រីអនុវត្តច្បាប់ និងបង្កើតយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការស៊ើបអង្កេត
- ប្រតិបត្តិការត្រូវមានការសម្របសម្រួលជាមួយមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ
- មន្ត្រីស៊ើបអង្កេតត្រូវតែផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់មន្ត្រីជំនាញឯកទេស
- ទោះបីជាមានការប្រើប្រាស់បច្ចេកទេសអ្វីក៏ដោយ កិច្ចសហប្រតិបត្តិការត្រូវមានការកត់ត្រាទុក និងមានអនុស្សរណៈនៃការយោគយល់ជាមួយគ្នា

- ត្រូវវាយតម្លៃពីហានិភ័យ និងកំណត់នូវឱកាសស៊ើបអង្កេតបន្ថែម ។

- សុវត្ថិភាព ៖ ត្រូវការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រជាពលរដ្ឋ រួមទាំងអ្នកផ្តល់ព័ត៌មាន និងមន្ត្រីប្រតិបត្តិការ
- ការបកប្រែភាសា ៖ អាស្រ័យទៅលើករណីជួញដូរមនុស្សឆ្លងដែន សេវាបកប្រែអាចជាតម្រូវការចាំបាច់ក្នុងការស៊ើបអង្កេត ។ មន្ត្រីស៊ើបអង្កេតត្រូវការអ្នកបកប្រែ មានភាពស្អាតស្អំ មានចំណេះដឹងបឋម អំពីជំនាញបច្ចេកទេស និងយល់ដឹងអំពីអង្គហេតុនៅក្នុងករណី
- ការវាយតម្លៃពីហានិភ័យ ៖ ការប្រើជំនាញឯកទេសបង្កើននូវឱកាស ក្នុងការកំណត់អំពីសកម្មភាពបទល្មើស នៅពេលវាកើតឡើង (ពេលខ្លះត្រូវបានស្គាល់ថា "ជនល្មើសកំពុងប្រព្រឹត្ត")។ នៅក្នុងការស៊ើបអង្កេតករណីជួញដូរមនុស្ស ជាញឹកញាប់ សកម្មភាពបទល្មើសពាក់ព័ន្ធនឹងហានិភ័យ និងគ្រោះថ្នាក់ចំពោះជនរងគ្រោះ ដូច្នេះវាទាមទារនូវអន្តរាគមន៍ ដើម្បីស្តារនីតិសម្បទាជនរងគ្រោះ ។
  - ត្រូវបន្តវាយតម្លៃហានិភ័យក្នុងករណីជួញដូរមនុស្ស
  - រក្សាភាពសម្ងាត់នៃការប្រើបច្ចេកទេសជំនាញ និងមនុស្សពាក់ព័ន្ធ ។
- ផែនការសង្គ្រោះ
  - ត្រូវការពារជនរងគ្រោះប្រកបដោយប្រសិទ្ធភាព
  - ត្រូវគិតពីសុវត្ថិភាពជាចម្បង ទោះបីប្រើជំនាញបច្ចេកទេសតាមរូបភាពណាក៏ដោយ
  - អាចប្រើដើម្បីលាក់បាំងការប្រើជំនាញឯកទេស បង្វែរទៅជាករណីផ្សេង ។
- អន្តរាគមន៍
  - កំណត់អំពីមន្ត្រីមានក្រមសីលធម៌ និងជំនាញ អំពីកិច្ចប្រតិបត្តិការសង្គ្រោះ និងបង្ក្រាប
  - ផ្តល់ព័ត៌មានដល់មន្ត្រីដែលត្រូវបានជ្រើសរើសសម្រាប់តួនាទីនីមួយៗក្នុងប្រតិបត្តិការ
  - ត្រូវធានាថា មានជំនួយ និងការការពារជនរងគ្រោះ
  - ទាក់ទងជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាដទៃទៀតមុនពេលបង្ក្រាប
  - ត្រូវធានាថា មានការថែទាំផ្នែកវេជ្ជសាស្ត្រ និងសេវាសង្គមកិច្ច
  - ផ្តល់ព័ត៌មានទៅដល់ជនរងគ្រោះអំពីសិទ្ធិរបស់ពួកគេ និងអំពីសេវាជំនួយផ្សេងៗ ។
- ចំណុចមិនគួរអនុវត្តមួយចំនួនក្នុងពេលអន្តរាគមន៍៖
  - កុំនាំជនរងគ្រោះ និងជនសង្ស័យទៅជាមួយគ្នា
  - កុំធ្វើប្រតិបត្តិការបង្ក្រាប/សង្គ្រោះ ដោយគ្មាន៖
    - ការរៀបផែនការ និងការវាយតម្លៃហានិភ័យ
    - កំណត់ការប្រុងប្រយ័ត្នផ្នែកសុវត្ថិភាព
    - ព័ត៌មានត្រឹមត្រូវទាក់ទងនឹងចំនួនជនរងគ្រោះ ជនល្មើស និងមនុស្សផ្សេងទៀតដែលអាចនឹងទទួលការប៉ះពាល់ដោយការបង្ក្រាប
    - រៀបចំសេវាជំនួយ ដូចជា ការប្រឹក្សាយោបល់ ជម្រកស្នាក់នៅ អាហារ និងការថែទាំវេជ្ជសាស្ត្រ

- រថយន្ត និងសម្ភារៈចាំបាច់ដទៃទៀតមានគ្រប់គ្រាន់ ។

- ប្រតិកម្មរបស់ជនជួញដូរ ៖ ការប្រើបច្ចេកទេសជំនាញ គឺជាការអនុវត្តដ៏ល្អ ដើម្បីត្រួតពិនិត្យ លើប្រតិកម្មរបស់ជនជួញដូរ ចំពោះសកម្មភាពអនុវត្តច្បាប់ ។ ការធ្វើបែបនេះជួយឱ្យមន្ត្រីស៊ើបអង្កេតដឹងនៅពេលជនជួញដូរសង្ស័យថា មានការស៊ើបអង្កេតកំពុងដំណើរការ និងប្រើវិធីសាស្ត្រអន្តរាគមន៍ដែលមានប្រសិទ្ធភាព តបតមកលើសមត្ថកិច្ចវិញ
- ការប្រឆាំងតប
    - យុត្តាធិការមួយចំនួន មានភស្តុតាងបង្ហាញថា ជនល្មើសធ្លាប់ធ្វើការប្រឆាំងតបវិញ ។ វិធានការនេះអាចមានមនុស្ស ដែលត្រូវបានគេបញ្ជូនឱ្យធ្វើការតាមដាន ប្រឆាំងតបនឹងសមត្ថកិច្ច
    - យើងមិនអាចផ្តល់ការណែនាំទៅលើគ្រប់ទម្រង់នៃវិធីសាស្ត្រប្រឆាំងតប ដែលអ្នកអាចជួបប្រទះនោះទេ ប៉ុន្តែយ៉ាងហោចណាស់ អ្នកត្រូវមានភាពប្រុងប្រយ័ត្ន ព្រោះវិធីសាស្ត្រទាំងនេះអាចនឹងកើតមាន
    - ការប្រើបច្ចេកទេសជំនាញរួមគ្នា អាចជួយកាត់បន្ថយប្រសិទ្ធភាពនៃវិធីសាស្ត្រប្រឆាំងតប របស់ជនជួញដូរមនុស្ស និងអាចជួយឱ្យយើងកំណត់អំពីវិធីសាស្ត្រដែលពួកគេកំពុងប្រើ ។
- ការប្រើបច្ចេកទេសជំនាញនៅក្នុងការស៊ើបអង្កេតលើអំពើជួញដូរមនុស្ស ៖ ទាមទារនូវការវាយតម្លៃលើហានិភ័យ ឱ្យបានជាប់លាប់ និងមានប្រសិទ្ធភាព
- ប្រើវិធីសាស្ត្របែបច្នៃប្រឌិត ស្របច្បាប់ និងមានប្រសិទ្ធភាព ដើម្បីធ្វើអន្តរាគមន៍
- ឱកាស
    - រៀបចំផែនការចាំបាច់ក្នុងការសម្របសម្រួលការស៊ើបអង្កេតបែបសកម្មជាមុន ៖
        - ធនធានត្រូវបានកំណត់
        - ការរៀបផែនការធនធាន អាចពិចារណាទៅលើដំណាក់កាលនៃការស៊ើបអង្កេតតម្រូវការជំនាញ ឧទា. ការចាប់ខ្លួន និងការសម្ភាស
        - ទីកន្លែងស្នាក់នៅអាចត្រូវបានរៀបផែនការ និងវាយតម្លៃអំពីហានិភ័យ
        - ទីតាំងរបស់ជនសង្ស័យអាចត្រូវបានកំណត់ និងត្រួតពិនិត្យដើម្បីបង្កើនប្រសិទ្ធភាពនៃឱកាសក្នុងការកំណត់ទីតាំង នៅពេលធ្វើប្រតិបត្តិការចាប់ខ្លួន
        - ត្រៀមអ្នកបកប្រែ ករណីចាំបាច់
        - បច្ចេកទេសផ្សេងអាចនឹងត្រូវបានប្រើ អ្នកផ្តល់ព័ត៌មាន អន្តរាគមន៍បច្ចេកទេសប្រតិបត្តិការសម្ងាត់
        - ការស៊ើបអង្កេតអាចធ្វើឡើងនៅក្នុងប្រទេសកំណើត ឆ្លងកាត់ និងគោលដៅ
        - សកម្មភាពរបស់បណ្តាញឧក្រិដ្ឋជនអាចត្រូវបានកំណត់តាមរយៈដំណើរការនេះ ។
- ការគំរាមកំហែង
    - ការពន្យាពេលក្នុងការអនុវត្តផែនការ អាចធ្វើឱ្យជនរងគ្រោះប្រឈមនឹងគ្រោះថ្នាក់
    - កង្វះខាតធនធានចាំបាច់ ក្នុងការស៊ើបអង្កេតបែបសកម្មជាមុន ។

- ការឆ្លើយតបចំពោះការគំរាមកំហែង
  - រៀបផែនការ និងធក់ឱកាសដើម្បីបន្តពិនិត្យមើលទៅលើការវិវត្តថ្មីៗ
  - ផ្តល់ដំណឹងដល់មន្ត្រីអំពីសញ្ញា ដែលត្រូវស្វែងរកជនរងគ្រោះនៃអំពើជួញដូរមនុស្ស (ឬបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងការស៊ើបអង្កេត)អាចប្រឈមនឹងគ្រោះថ្នាក់
  - រាយការណ៍ជូនថ្នាក់ដឹកនាំអំពីហានិភ័យ ។ ថ្នាក់ដឹកនាំលើកទឹកចិត្តដល់មន្ត្រីក្រោមឱវាទឱ្យផ្តល់ព័ត៌មានអំពីហានិភ័យ
  - ត្រូវមានផែនការប្រកាសអាសន្ន ដើម្បីធ្វើការឆ្លើយតបបែបប្រតិកម្ម
  - ប្រតិបត្តិការត្រូវគិតពីសន្តិសុខ សុវត្ថិភាព និងភាពបត់បែន ។

## II. ការកសាងព័ត៌មានសម្ងាត់

ការកសាងព័ត៌មានសម្ងាត់ គឺជាដំណើរការនៃការប្រមូល វិភាគ វាយតម្លៃ និងបកស្រាយព័ត៌មានសម្ងាត់អំពីបទឧក្រិដ្ឋ ដើម្បីស្វែងយល់អំពីសកម្មភាព និងគោលបំណងសម្រាប់ប្រតិបត្តិការ ឬគោលដៅនៃការស៊ើបអង្កេត ដែលកំពុងតែធ្វើ ឬនឹងធ្វើ និងការអនុវត្តផែនការ ការសម្រេចចិត្ត និងសកម្មភាព ។

ឧទាហរណ៍ ៖ មន្ត្រីស៊ើបអង្កេតធ្វើការឃ្លាំមើលអំពី "អគារA" មួយកន្លែង ដែល សង្ស័យថាមានស្ត្រីនៅទីនោះមកពីខេត្តនានា និងត្រូវធ្វើដំណើរទៅប្រទេស C ក្នុងរូបភាពអាពាហ៍ ពិពាហ៍ក្លែងក្លាយ ។ មន្ត្រីនគរបាលថតរូបមនុស្សផ្សេងៗដែលចេញចូលអគារនោះ ព្រមទាំង ស្លាក លេខរថយន្ត ។ ទោះបីជាអ្នកបើកបររថយន្ត គឺជាមនុស្សដដែលក៏ដោយ ប៉ុន្តែ អ្នកជិះក្នុងរថយន្តខុសៗគ្នា និងមានមុខមាត់ដូចជាជនជាតិចិន ។ នៅពេលដែលរថយន្តមួយ កំពុងចាកចេញ ពីអគារនោះ មន្ត្រីស៊ើបអង្កេតបានស្វែងរកជំនួយពីមន្ត្រីនគរបាលចរាចរ ដើម្បីបញ្ឈប់រថយន្តនោះ ក្នុងការត្រួតពិនិត្យកំណត់អត្តសញ្ញាណអ្នកបើកបរ និងអ្នកធ្វើដំណើរ ។ អ្នកបើកបរជាជនជាតិខ្មែរ និងអ្នកជិះរថយន្តគឺជាជនជាតិចិន ហើយចូលមកប្រទេសកម្ពុជាដោយប្រើទិដ្ឋាការទេសចរណ៍ ។ លិខិតឆ្លងដែននោះបង្ហាញថា ជនជាតិចិនម្នាក់នេះធ្វើដំណើរពីប្រទេសកម្ពុជាទៅប្រទេស C ជាប្រចាំ ។ ការស្រាវជ្រាវរកព័ត៌មានក្នុងប្រព័ន្ធបណ្តាញសង្គមអំពីអ្នកបើកបរ និងអ្នកធ្វើដំណើរជនជាតិចិនម្នាក់នោះ ផ្តល់នូវព័ត៌មានយ៉ាងសំខាន់ អំពីបក្ខពួក ព្រមទាំងរូបថតដែលពួកគេបង្ហោះ ដែលប្រាប់ឱ្យដឹងអំពីមធ្យោបាយធ្វើដំណើរដែលសង្ស័យថា ត្រូវបានប្រើក្នុងការនាំយកស្ត្រីខ្មែរទៅប្រទេស C ។ ការពិនិត្យមើលកំណត់ត្រាបន្ថែមលើវិក្កយបត្រទឹក ភ្លើង និងភាពជាម្ចាស់កម្មសិទ្ធិគេហដ្ឋាន ផ្តល់នូវឈ្មោះមនុស្សបន្ថែមទៀត ដើម្បីស្រាវជ្រាវជនសង្ស័យ និងបក្ខពួក ។ នៅពេលដែលមន្ត្រីស៊ើបអង្កេតប្រមូលព័ត៌មានទំនាក់ទំនងនឹងអគារនោះ ពួកគេបានកសាងឯកសារអំពីបណ្តាញជនជួញដូរមនុស្ស ផ្លូវធ្វើដំណើរ មធ្យោបាយ វិធីសាស្ត្រ និងជាចុងក្រោយនៅពេលដែលស្ត្រីទាំងនោះ មានវត្តមាននៅក្នុងអគារ ។

ការកសាងព័ត៌មានសម្ងាត់ គឺជាមធ្យោបាយដ៏សំខាន់មួយ ក្នុងការស៊ើបអង្កេតលើករណីជួញដូរមនុស្ស និងការប្រើវិធីសាស្ត្របង្ការ ដើម្បីប្រឆាំងអំពើជួញដូរមនុស្ស ។ ឱកាស ការគំរាមកំហែង

និងវិធីសាស្ត្រតបតខាងក្រោម គួរត្រូវពិចារណាអំពីការកសាងព័ត៌មានសម្ងាត់ នៅក្នុងការស៊ើបអង្កេតលើករណីនៃអំពើជួញដូរមនុស្ស ៖

**១. ឱកាស**

ការកសាងព័ត៌មានសម្ងាត់មាននូវអត្ថប្រយោជន៍ច្រើន៖

- ផ្តល់នូវមូលដ្ឋានដ៏រឹងមាំក្នុងការរៀបចំទម្រង់បែបសកម្មជាច្រើននៃការស៊ើបអង្កេត
- អាចកំណត់ជម្រើសនៃការស៊ើបអង្កេត
- កំណត់ពីសកម្មភាពរបស់ជនជួញដូរមនុស្ស
- កំណត់បញ្ហាប្រឈមរបស់មន្ត្រីអនុវត្តច្បាប់ បង្កើតឱកាសពង្រឹងផ្នែកទាំងនេះ មុនពេលប្រើទម្រង់នៃការស៊ើបអង្កេតបែបសកម្ម ។

**២. ការគំរាមកំហែង**

- គ្រោះថ្នាក់ភ្លាមៗចំពោះជនរងគ្រោះ គ្រួសាររបស់ពួកគេ ឬជនរងគ្រោះដទៃទៀត
- មន្ត្រីអនុវត្តច្បាប់អាចខ្វះសមត្ថភាពក្នុងការប្រមូល និងវិភាគព័ត៌មាន
- ការទាមទារនូវពេលវេលា និងធនធានជាច្រើន ដើម្បីអភិវឌ្ឍព័ត៌មានសម្ងាត់
- អាចបែកធ្លាយព័ត៌មាននៃវិធានការប្រមូលព័ត៌មានសម្ងាត់ ។

**៣. ការឆ្លើយតបចំពោះការគំរាមកំហែង**

- ប្រើប្រាស់វិធីក្នុងការប្រមូលព័ត៌មានសម្ងាត់អំពីបទល្មើស
- កិច្ចសហប្រតិបត្តិការពីស្ថាប័នជាតិ និងអន្តរជាតិ
- ទទួលយកនូវចំណេះដឹង ជំនាញ និងបទពិសោធន៍ពីស្ថាប័នផ្សេងៗ
- ប្រមូលព័ត៌មានពីគ្រប់ប្រភពផ្សេងៗ ។

## III. បច្ចេកទេសបង្អាក់សកម្មភាព

បច្ចេកទេសបង្អាក់សកម្មភាព គឺជាវិធីសាស្ត្របណ្តោះអាសន្នដែលត្រូវបានប្រើ ដើម្បីបង្អាក់សកម្មភាពល្មើស ក្នុងការធ្វើឱ្យជនជួញដូរមនុស្ស លំបាកបន្តសកម្មភាពរបស់ខ្លួន ។ នៅក្នុងកាលៈទេសៈដែលការស៊ើបអង្កេតបែបប្រតិកម្ម និងការចោទប្រកាន់មិនអាចធ្វើបាន នោះបច្ចេកទេសបង្អាក់សកម្មភាព គឺជាវិធីសាស្ត្រដែលអាចប្រើសម្រាប់ប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស ។

ឧទាហរណ៍៖ មន្ត្រីនគរបាលមានការសង្ស័យទៅលើឡឥដ្ឋមួយនៅជាយទីក្រុងភ្នំពេញ ដែលអាចនឹងមានការប្រើប្រាស់ពលកម្មជាប់បំណុល ដើម្បីបង្ខំគ្រួសារជាច្រើនឱ្យធ្វើការដោយទទួលប្រាក់ឈ្នួលទាបបំផុត ។ គ្រួសារទាំងនោះបានខ្ចីលុយមុន រស់នៅក្នុងកន្លែងឡឥដ្ឋ គ្មានទឹកស្អាត អគ្គីសនីប្រើប្រាស់ ហើយត្រូវបានហាមឃាត់មិនឱ្យចាកចេញពីឡឥដ្ឋ ដោយគ្មានការអនុញ្ញាតពីថៅកែ ។ គ្រួសារទាំងមូល រួមទាំងកុមារផងដែរ ត្រូវធ្វើការដើម្បីដោះបំណុល ។ ដោយសារថៅកែរូបនោះ ជាមនុស្សមានអំណាច និងឃោរឃៅ ដូច្នេះកម្មករទាំងអស់មានភាពភ័យខ្លាច មិនហ៊ានផ្តល់ព័ត៌មានអំពីស្ថានភាពការងារដែលគ្រោះថ្នាក់ និងការធ្វើបាបផ្នែករាងកាយ និងផ្លូវចិត្តទេ ។ មន្ត្រីនគរបាល

ទទួលបានជំនួយពីក្រសួងការងារ ដើម្បីធ្វើការត្រួតពិនិត្យទៅលើទីតាំងឡូតដ្ឋ កិច្ចសន្យាការងារ កំណត់ត្រាការងារ លក្ខខណ្ឌការងារ អាជ្ញាប័ណ្ណ និងពលកម្មកុមារ ។ ក្រសួងការងារដាក់ទណ្ឌកម្មទៅលើថៅកែ និងទីតាំងឡូតដ្ឋនោះ រហូតទាល់តែលក្ខខណ្ឌការងារត្រូវបានរៀបចំឡើង ហើយក្រសួងបានដាក់ឡូតដ្ឋនេះនៅក្នុងបញ្ជីត្រួតពិនិត្យជាប្រចាំ ។

បច្ចេកទេសបង្អាក់សកម្មភាពជាច្រើន អាចយកមកប្រើដោយមានប្រសិទ្ធភាព ក្នុងករណីប្រឆាំងអំពើជួញដូរមនុស្ស ។ បច្ចេកទេសទាំងនេះអាចត្រូវបានប្រើជា ការបិទបាំង សម្រាប់ការស៊ើបអង្កេត បង្កើនឥទ្ធិពលនៃការស៊ើបអង្កេត សកម្មភាពអនុវត្តច្បាប់ដទៃទៀត ឬអាចជាបច្ចេកទេសមួយដ៏មានប្រសិទ្ធភាព ដើម្បីបំផ្លាញសកម្មភាពឧក្រិដ្ឋជន ។ វិធីសាស្ត្របង្អាក់សកម្មភាពរបស់ឧក្រិដ្ឋជនអាចមានលក្ខណៈខុសៗគ្នា ទៅតាមស្ថានភាព និងច្បាប់ក្នុងប្រទេសនីមួយៗ ។ បច្ចេកទេសទាំងនេះរួមបញ្ចូល ៖

- មន្ត្រីអនុវត្តច្បាប់ស្លៀកពាក់ឯកសណ្ឋានអាចល្បាតនៅជុំវិញបរិវេណផ្ទះបន ដើម្បីបង្អាក់ទឹកចិត្តភ្ញៀវមិនឱ្យចូលក្នុងផ្ទះបន
- មន្ត្រីអនុវត្តច្បាប់ធ្វើការត្រួតពិនិត្យយានយន្ត ដែលសង្ស័យក្នុងការកេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មនានា ដែលល្មើសច្បាប់
- ការត្រួតពិនិត្យសុខភាពសាធារណៈ អគ្គីភ័យ សុខភាព និងសុវត្ថិភាពនៅលើទីតាំង ។ ការត្រួតពិនិត្យអាចនឹងនាំទៅដល់ការបិទទីតាំង ដែលបំពានលើប័ណ្ណអនុញ្ញាត ក្រមសីលធម៌ និងបទប្បញ្ញត្តិនានា
- ការត្រួតពិនិត្យឯកសារនៅច្រកឆ្លងកាត់ព្រំដែន
- ការរឹបអូសសម្ភារៈពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សរបស់ជនជួញដូរ ។

**១. គោលការណ៍ណែនាំអនុវត្ត**

នៅក្នុងកាលៈទេសៈខ្លះ យើងមិនអាចប្រតិបត្តិការបានទេ ក្រៅពីការបង្អាក់សកម្មភាពរបស់ជនជួញដូរមនុស្ស ។ នៅកាលៈទេសៈណាដែលអាចធ្វើបាន ការបង្អាក់សកម្មភាពត្រូវរួមផ្សំជាមួយសកម្មភាពដទៃទៀត ។ សកម្មភាពនេះអាចរួមបញ្ចូលការប្រមូល និងកសាងព័ត៌មានសម្ងាត់ ក៏ប៉ុន្តែអ្វីដែលល្អ ការបង្អាក់សកម្មភាពគួរតែជាផ្នែកមួយនៃការស៊ើបអង្កេតបែបប្រតិកម្ម ឬសកម្មជាមុន ។

**២. ដំណាក់កាលនៃការកេងប្រវ័ញ្ច**

ជនជួញដូរមនុស្សប្រើដំណាក់កាល ៥ ដើម្បីធ្វើសកម្មភាពរបស់ពួកគេៈ

- ការផ្សព្វផ្សាយពាណិជ្ជកម្ម
- ទីតាំងអាជីវកម្ម
- ការដឹកជញ្ជូន
- ហិរញ្ញវត្ថុ
- ការប្រាស្រ័យទាក់ទង ។

អំពើជួញដូរមនុស្ស គឺជាអាជីវកម្មកេងប្រវ័ញ្ច ដែលជាសកម្មភាពឧក្រិដ្ឋ ។ ពួកគេត្រូវ

ផ្សព្វផ្សាយ "ផលិតផល" របស់ខ្លួន ទីតាំងដើម្បីធ្វើសកម្មភាព មធ្យោបាយដឹកជញ្ជូន ការបណ្ដាក់ទុន ការចំណាយផ្សេងៗ និងបណ្ដាញទំនាក់ទំនង ។ ដូច្នេះ ការយល់ដឹងអំពីដំណាក់កាលទាំង ៥ នេះ អាចមានប្រយោជន៍ ក្នុងការរៀបចំផែនការស៊ើបអង្កេត ដើម្បី៖

- ធានាថា រាល់ភស្តុតាងទាំងអស់ត្រូវបានប្រមូល
- កសាង និងចែករំលែកព័ត៌មានសម្ងាត់អំពីអំពើជួញដូរមនុស្ស
- កំណត់ពីដំណើរការអាជីវកម្មកេងប្រវ័ញ្ច ដើម្បីបញ្ឈប់សកម្មភាពរបស់ជនល្មើស ។

### ក. ការផ្សព្វផ្សាយពាណិជ្ជកម្ម

ការផ្សព្វផ្សាយពាណិជ្ជកម្មជាផ្លូវការរួមមាន ការផ្សព្វផ្សាយនៅក្នុងកាសែត នាមប័ណ្ណ ផ្ទាំងរូបភាព និងខិត្តបណ្ណតូចៗ ។ ការផ្សព្វផ្សាយក្រៅផ្លូវការរួមមាន ពាក្យសម្ដី និងខ្សែបណ្ដាញ ។ ការផ្សព្វផ្សាយ អាចត្រូវបានប្រើនៅក្នុងគ្រប់ដំណាក់កាលណាមួយ ឬគ្រប់ដំណាក់កាលទាំងអស់នៃអំពើជួញដូរមនុស្ស ។ ជនជួញដូរមនុស្ស អាចប្រើការផ្សព្វផ្សាយ ដើម្បីចូលទៅដល់ជនរងគ្រោះនៅក្នុងតំបន់ប្រភព ប្រើប្រាស់ទីតាំងបណ្ដោះអាសន្ន ដើម្បីស្វែងរកអតិថិជន ។

- ព័ត៌មានជាក់លាក់
    - នរណាជាអ្នកធ្វើការផ្សព្វផ្សាយ? តើធ្វើការផ្សព្វផ្សាយដោយរបៀបណា?
    - តើពួកគេមានផ្ដល់ឈ្មោះ អាសយដ្ឋាន ឬលេខទំនាក់ទំនងដែលខុសពីព័ត៌មានដែលអ្នកបានដឹងរួចហើយនៅក្នុងការផ្សព្វផ្សាយនោះឬទេ? តើពួកគេ មានភិនភាគដូចម្ដេច?
    - ប្រសិនបើពាក់ព័ន្ធ តើពួកគេចំណាយសម្រាប់ការផ្សព្វផ្សាយដោយរបៀបណា? ប្រសិនបើចេញដោយមូលប្បទានបត្រ តើបានដកប្រាក់ហើយឬនៅ?
    - តើអាចយកមូលប្បទានបត្រ មកពិនិត្យស្នាមក្រយៅដៃបានឬទេ?
    - តើការផ្សព្វផ្សាយនោះត្រូវបានបង់ដោយអាណត្តិធនាគារ?
    - តើពួកគេចំណាយលើការផ្សព្វផ្សាយញឹកញាប់ដែរឬទេ នៅពេលណា និងដោយរបៀបណា?
    - តើព័ត៌មាននៅក្នុងការផ្សព្វផ្សាយនោះត្រូវបានបញ្ជូនតាមរយៈសារ អ៊ីម៉េល ...?
    - ប្រសិនបើការផ្សព្វផ្សាយគឺជាផ្ទាំងរូបភាពតូច ឬនាមប័ណ្ណ អាចយកមកវិញបានឬទេ? ប្រសិនបើអ្នកមិនអាចប្រមូលយកបណ្ណផ្សព្វផ្សាយមកវិញទេ ត្រូវកត់ត្រាពាក្យសម្ដី និងតួលេខជាក់លាក់ ឬបើអាចធ្វើបាន ថតបណ្ណផ្សព្វផ្សាយនោះ ។
    - តើការបង្ហាក់ការប្រាស្រ័យទាក់ទងអាចជាការសមរម្យ ឬទេ? អ្នកអាចនឹងទទួលបានលេខទូរស័ព្ទ ពីការសួរសំណួរផ្សេងទៀតរបស់អ្នក ។ នេះអាចជាផ្នែកមួយនៃការសួរសំណួរបែបប្រតិកម្ម ឬការផ្ដួចផ្ដើមបែបសកម្មជាមុន ។
- ការផ្សព្វផ្សាយ

ការផ្សព្វផ្សាយផ្លូវការ និងក្រៅផ្លូវការ ជាទូទៅផ្ដោតទៅលើការទទួលបានជនរងគ្រោះតាមរយៈវិធីសាស្ត្របោកបញ្ឆោតណាមួយ ។ ដូច្នេះ ការផ្សព្វផ្សាយអាច នឹងជួយបង្ហាញអំពីការបោក

បញ្ឆោត (នៅក្នុងករណីតុលាការ) និង/ឬ ត្រូវបានប្រើជាផ្នែកមួយនៃបណ្តាញ និងភស្តុតាងដែលឈានដល់ការកេងប្រវ័ញ្ច ។

◦ ការផ្សព្វផ្សាយផ្លូវការ ៖ ជាលាយលក្ខអក្សរ ជាខិត្តបណ្ណ កាសែត និងទស្សនាវដ្ដីជាលក្ខណៈបុគ្គល ឬសាធារណៈ... ។ ជាញឹកញាប់ ការផ្សព្វផ្សាយបែបនេះស្វែងរកមនុស្សមកធ្វើការពីក្រៅប្រទេស និងការសន្យាផ្តល់ប្រាក់ខែខ្ពស់ ។ ពេលខ្លះ ការផ្សព្វផ្សាយនេះនឹងបញ្ជាក់អំពីប្រភេទការងារដែលត្រូវធ្វើ ដូចជា ការរត់តុ ជាដើម ។ ប្រសិនបើវាបញ្ជាក់អំពីការងារដែលត្រូវធ្វើ ហើយមនុស្សដែលទទួលការងារនេះត្រូវបានកេងប្រវ័ញ្ច ដូច្នេះវាអាចជាភស្តុតាងផ្ទាល់អំពីការបោកបញ្ឆោត ឬអាចជួយ បញ្ជាក់បន្ថែមទៅលើសក្ខីកម្មរបស់ជនរងគ្រោះ ។ ព័ត៌មានទាក់ទងមានដូចជា លេខទូរស័ព្ទ... ។ ពេលខ្លះ លេខប្រអប់ប្រៃសណីយ៍នឹងត្រូវបានផ្តល់ឱ្យ ប៉ុន្តែកម្រផ្តល់អាសយដ្ឋានលំនៅដ្ឋាន ។

◦ ការផ្សព្វផ្សាយក្រៅផ្លូវការ

▪ មន្ត្រីធ្វើការស៊ើបអង្កេត ដើម្បីបញ្ជាក់ថាមានការផ្សព្វផ្សាយក្រៅផ្លូវការដែរ ឬទេ ?

▪ តើមានមនុស្សធ្វើចំណាកស្រុកដោយឥតរំពឹងទុក ឬទេ ? ទៅណា ? ជាមួយនរណា ? បានប្រាក់មកពីណាដើម្បីធ្វើដំណើរ ? បានព័ត៌មានពីណា ?

▪ ហេតុអ្វីបានជាពួកគេធ្វើចំណាកស្រុក ? តើពួកគេមានទំនាក់ទំនងទៅគ្រួសាររបស់ខ្លួនឬទេ តើមានផ្ញើប្រាក់ទៅផ្ទះដែរឬទេ ? តើជនចំណាកស្រុកធ្វើអ្វីនៅបរទេស ?

▪ តើមានពាក្យចចាមអារាមអ្វីខ្លះ នៅក្នុងសហគមន៍ ? តើមាននរណាចាកចេញទៅ ហើយមិនដែលឮដំណឹង ? តើពួកគេបាននិយាយអ្វីខ្លះអំពីផែនការរបស់ខ្លួន មុនពេលចាកចេញទៅ ? តើពួកគេសុខសប្បាយទេ ? តើពួកគេសហការនិយាយការពិតដែរឬទេ ? តើពួកគេអាចត្រឡប់មកវិញឬទេ ? ហើយនៅកន្លែងណា ?

▪ ប្រសិនបើពួកគេត្រូវបានជួញដូរ សំណួរបន្ទាប់ត្រូវសួរថា៖

- តើពួកគេដឹងអំពីព័ត៌មាន ពីការផ្សព្វផ្សាយដោយរបៀបណា ? តើពួកគេជួបជាមួយនរណា មុនពេលចាកចេញ ?

- តើធ្លាប់ឃើញបុគ្គលប្លែកមុខចេញចូលក្នុងស្រុករបស់ខ្លួនដែរឬទេ ? តើមិត្តភ័ក្តរបស់ពួកគេជានរណា ? រស់នៅឯណា ? នាំគ្នាទៅណាខ្លះ ?

• ការផ្សព្វផ្សាយអំពីគោលដៅ

◦ ផ្លូវការ ៖ នៅក្នុងករណីនៃសេវាកម្សាន្ត ឬអាជីវកម្មស្រដៀងគ្នា សំណួរទាំងនេះ ត្រូវរួមបញ្ចូលអ្វីដែលពួកគេផ្សព្វផ្សាយ ហើយផ្សព្វផ្សាយដោយរបៀបណា ដូចជា ការផ្សព្វផ្សាយតាមកាសែត ទស្សនាវដ្ដី ផ្ទាំងរូបភាព ស្ទីកឃ័រ ឬខិត្តប័ណ្ណ ។

◦ ក្រៅផ្លូវការ៖

▪ សេវាអ៊ីនធើណិតសម្រាប់អ្នកដែលទិញសេវាផ្លូវភេទញឹកញាប់ អាចមានពាក្យសម្ងីណាមួយដែលបង្ហាញថា ស្ត្រីនៅក្នុងផ្ទះបនណាមួយ មកពីតំបន់ក្រៅគោលដៅ ដែលបង្ហាញថាស្ត្រីទាំងនោះ គឺជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ។ សៀវភៅណែនាំ "អ្នករកសេវាផ្លូវភេទ"

តាមអ៊ីនធើណិតអាចផ្សព្វផ្សាយ អំពីសេវាកម្មផ្លូវភេទ

▪ ការជួញដូរសម្រាប់បម្រើការងារតាមផ្ទះ គឺជាផ្នែកមួយទៀត ដែលការផ្សព្វផ្សាយ ឬការធ្វើទីផ្សារក្រៅផ្លូវការអាចសំខាន់ជាងវិធីសាស្ត្រផ្លូវការ ។ ព័ត៌មានលម្អិតអំពីអ្នកបម្រើការតាមផ្ទះ អាចនឹងត្រូវចែកចាយបន្តទៅកាន់ជនល្មើសដទៃទៀត ។ ក្នុងករណីខ្លះ ជនល្មើសដែលមកពីគ្រួសារ ឬស្រុកកំណើតជាមួយជនរងគ្រោះ មិនចាំបាច់ត្រូវការផ្សព្វផ្សាយជាផ្លូវការទេ ។

**ខ. ទីតាំងអាជីវកម្ម**

• ការយល់ដឹងអំពីប្រភេទទីតាំងដែលជនជួញដូរប្រើ ធ្វើឱ្យមន្ត្រីស៊ើបអង្កេតអាចចាត់វិធានការ និងធ្វើការស៊ើបអង្កេតទៅលើទីតាំងនោះ ។ ជាទូទៅ ជនជួញដូរមនុស្សចង់ចំណាយប្រាក់តិចតួចបំផុតតាមដែលអាចធ្វើបាន ដើម្បីជួលផ្ទះល្វែង ឬបន្ទប់ជួលថោកៗ ។ លក្ខណៈជាប់លាប់នៃការជួលបន្ទប់ អាចផ្តល់នូវចំណុចចាប់ផ្តើមល្អក្នុងការឃ្លាំមើល នៅក្នុងការស៊ើបអង្កេតបែបសកម្មជាមុន និងការស៊ើបអង្កេតប្រមូលព័ត៌មានសម្ងាត់ ។

○ ព័ត៌មានអំពីទីតាំង

▪ មន្ត្រីស៊ើបអង្កេត ត្រូវស្វែងរកព័ត៌មានអំពីការបង់ប្រាក់ ទៅលើការជួលបន្ទប់ ។ ប្រសិនបើមានលិខិតប្រគល់សិទ្ធិ ឬកិច្ចសន្យាជួល តើម្ចាស់ទីតាំងមានការពាក់ព័ន្ធ ដោយផ្ទាល់ក្នុងអំពើជួញដូរឬទេ ?

▪ តើមានអ្នកចេញចូល មធ្យោបាយអ្វី?

▪ តើនរណាជាអ្នកផ្តល់ព័ត៌មាន ?

○ តើមន្ត្រីអនុវត្តច្បាប់មានចុះត្រួតពិនិត្យរដ្ឋបាលនៅទីតាំងនោះដែរឬទេ ?

○ តើមានកិច្ចសហការជាមួយអ្នកពាក់ព័ន្ធណាខ្លះ ?

○ តើមន្ត្រីស៊ើបអង្កេតបែបសកម្មជាមុន ប្រើសកម្មភាពត្រួតពិនិត្យរដ្ឋបាល ដើម្បីបិទបាំងទៅលើសកម្មភាពស៊ើបអង្កេតដែរឬទេ ?

○ មន្ត្រីមូលដ្ឋានគឺជាប្រភពព័ត៌មានដ៏សំខាន់អំពីទីតាំង ម្ចាស់ទីតាំង...

○ មន្ត្រីអាចប្រើបច្ចេកទេសបង្អាក់សកម្មភាព ដូចជា ការត្រួតពិនិត្យលើបរិដ្ឋានអគ្គីភ័យ សុខាភិបាល សន្តិសុខសណ្តាប់ធ្នាប់...។

• ព័ត៌មានទាក់ទងជាក់លាក់ទៅនឹងទីកន្លែង ៖ ទីតាំងជួបដំបូង

○ ទីតាំងជ្រើសរើសជនរងគ្រោះ និងការជួបគ្នារវាងជនជួញដូរមនុស្ស និងជនរងគ្រោះ ដូចជា បារ ហាងកាហ្វេ ភោជនីយដ្ឋាន ក្លឹប...

○ ទីកន្លែងណាត់ជួប ដូចជា ផ្ទះល្វែង ខុនដូ បន្ទប់សណ្ឋាគារ...

• ព័ត៌មានជាក់លាក់ទៅនឹងទីតាំងឆ្លងកាត់

○ ទីតាំងធ្វើដំណើរសាធារណៈ ដូចជា ស្ថានីយ៍ឡានក្រុង និងរថភ្លើង...

○ ទីតាំងសំចត ដូចជា ហាងកាហ្វេ ផ្ទះសំណាក់...

○ ទីកន្លែងលក់សំបុត្រ និងភ្នាក់ងារធ្វើដំណើរ

- ទីតាំងដែលត្រូវបានប្រើដើម្បីរក្សាទុកជនរងគ្រោះ ។

- ព័ត៌មានទាក់ទងនឹងទីតាំងគោលដៅ
  - ទីតាំងដែលជនរងគ្រោះត្រូវបានកេងប្រវ័ញ្ចកម្លាំងពលកម្ម ដូចជា ចម្ការ រោងចក្រ សិប្បកម្ម ផ្ទះបន ភោជនីយដ្ឋាន ហាងកាហ្វេ និងសណ្ឋាគារ...
  - ទីតាំងផ្ទះដែលជនរងគ្រោះរស់នៅ
  - ទីកន្លែងដែលជនល្មើសធ្វើប្រតិបត្តិការ
  - ហាងកាហ្វេ និងទីតាំងសាធារណៈ...ដែលជនជួញដូរជួបជុំគ្នា ប្រាស្រ័យទាក់ទង ។

### គ. ការដឹកជញ្ជូន

- ការជួញដូរមនុស្សត្រូវប្រើមធ្យោបាយដឹកជញ្ជូន មិនថានៅទីតាំងប្រភព ឆ្លងកាត់ ឬទីតាំងគោលដៅ ។ គ្រប់ទម្រង់នៃការដឹកជញ្ជូនត្រូវបានប្រើដោយ ថ្មើរជើង កង់ ម៉ូតូ រថយន្ត ទូក កប៉ាល់ និងយន្តហោះ

- ប្រភេទនៃការដឹកជញ្ជូនដែលត្រូវបានប្រើ អាស្រ័យលើកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងទីតាំងនោះ ដែលជាប់ព្រំដែន មិនជាប់ព្រំដែន ឬប៉ុស្តិ៍ត្រួតពិនិត្យផ្សេងទៀត ភាពខុសគ្នានៃតម្លៃ និងល្បឿននៃមធ្យោបាយដឹកជញ្ជូន និងចំនួនជនរងគ្រោះដែលត្រូវដឹកជញ្ជូន ៖
  - នៅពេលធ្វើដំណើរតាមយានជំនិះឯកជន ត្រូវពិនិត្យបណ្ណបើកបរ និងកំណត់ត្រានៃការឆែកឆេរបស់មន្ត្រីនគរបាល ។ មធ្យោបាយដឹកជញ្ជូនអាចមានស្លាកសញ្ញា ស្លាកលេខ ពណ៌ ម៉ាក និងផ្នែកខាងក្នុង ដែលផ្តល់ព័ត៌មានលម្អិតអំពីម្ចាស់ និងអាចជួយកំណត់អត្តសញ្ញាណផងដែរ ។ បន្ទាប់ពីមធ្យោបាយដឹកជញ្ជូនត្រូវបានកំណត់អត្តសញ្ញាណរួចហើយ មន្ត្រីស៊ើបអង្កេតអាចពិចារណាលើការឃ្លាំមើល ។ ជាញឹកញាប់ មន្ត្រីអនុវត្តច្បាប់ត្រូវធ្វើការជាមួយមធ្យោបាយដឹកជញ្ជូន ឯកជនសម្រាប់ហេតុផលមួយចំនួន ។ ការអន្តរាគមទាំងនេះអាចនឹងនាំឱ្យជនជួញដូរមនុស្សដែលជាប់សង្ស័យ ត្រូវបានកំណត់អត្តសញ្ញាណ ផ្តល់ការការពារសម្រាប់ប្រតិបត្តិការប្រមូលព័ត៌មានសម្ងាត់បែបសកម្មជាមុន និងបង្អាក់ការធ្វើដំណើរ
  - សេវាដឹកជញ្ជូនសាធារណៈទាមទារនូវការទិញសំបុត្រ ដូច្នេះវិធីនេះផ្តល់លទ្ធភាពមួយចំនួនសម្រាប់មន្ត្រីស៊ើបអង្កេត ។ ការស៊ើបអង្កេតប្រមូលព័ត៌មានតាមរយៈភ្នាក់ងារលក់សំបុត្រ ឬមន្ត្រីមានសមត្ថកិច្ច អាចផ្តល់ព័ត៌មានកិនភាគអំពីជនជួញដូរ និងជនរងគ្រោះបាន ។

- ព័ត៌មានទាក់ទងនឹងទីតាំងប្រភព ៖ ជនរងគ្រោះភាគច្រើនធ្វើដំណើរម្នាក់ឯង ពីទីតាំងប្រភព ដោយសារជនជួញដូរអាចនឹងព្យាយាមបង្ហាញថា សកម្មភាពរបស់ពួកគេ ត្រឹមត្រូវ ប៉ុន្តែនេះមិនមែនជាការពិតនោះទេ នៅពេលណាដែលជនរងគ្រោះត្រូវចាប់ពង្រត់ ឬបង្ខំ

- ព័ត៌មានទាក់ទងនឹងទីតាំងឆ្លងកាត់
  - មធ្យោបាយធ្វើដំណើរ ដែលត្រូវបានប្រើនៅដំណាក់កាលឆ្លងកាត់ មានលក្ខណៈខុសៗគ្នា អាស្រ័យទៅលើកាលៈទេសៈក្នុងតំបន់ ដូចជា រថយន្តក្រុង រថភ្លើង...
  - នៅក្នុងដំណាក់កាលឆ្លងកាត់ ជនជួញដូរមនុស្សអាចនឹងអមដំណើរជនរងគ្រោះ ។

លក្ខណៈទូទៅនៃការជួញដូរតាមផ្លូវអាកាសគឺថា ជនជួញដូរមនុស្សអាច នឹងអមដំណើរជនរងគ្រោះទៅចំណុចដែលឆ្លងកាត់ច្រកចេញដំណើរ ។ អ្នកអមដំណើរអាចនឹងរកលេសមិនធ្វើដំណើរទៅមុខទៀត ជនរងគ្រោះនឹងធ្វើដំណើរបន្តម្នាក់ឯង ហើយត្រូវជួបជាមួយបណ្តាញរបស់ជនល្មើស

- ជនជួញដូរមនុស្សអាចប្រើវិធីសាស្ត្រផ្សេងទៀត ដូចជា ធ្វើដំណើរតាមផ្លូវគោក ផ្លូវទឹក ដើម្បីឆ្លងដែន ។

- ព័ត៌មានទាក់ទងនឹងទីតាំងគោលដៅ
  - ជនជួញដូរមនុស្ស និងអ្នកទិញ ធ្វើដំណើរទៅកន្លែងណាត់ជួបគ្នា ដើម្បីពិភាក្សាអំពីការទិញលក់ជនរងគ្រោះ ក្នុងនាមជាអ្នកអមដំណើរ
  - ជនរងគ្រោះនៃអំពើជួញដូរមនុស្ស កម្រធ្វើដំណើរទៅទីតាំងគោលដៅ តែម្នាក់ឯងណាស់ ព្រោះនៅទីតាំងគោលដៅ ជនរងគ្រោះផ្តល់ផលចំណេញដល់ជនជួញដូរមនុស្ស
  - នៅក្នុងករណីមួយចំនួន ជនរងគ្រោះអាចនឹងត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរម្នាក់ឯង ដោយជនល្មើសមិនប្រើអំពើហិង្សា ធ្វើបាបទៅជនរងគ្រោះ គ្រួសារ និងមនុស្សជាទីស្រឡាញ់ទេ
  - លក្ខណៈរួមមួយសម្រាប់ក្រុមជនរងគ្រោះដែលធ្វើដំណើរឆ្លងដែន គឺថាពួកគេមិនចេះភាសាបរទេស ឬចេះតិចតួច ។

### ឃ. ហិរញ្ញវត្ថុ

- ឱកាសស៊ើបអង្កេតចរន្តសាច់ប្រាក់
  - ប្រាក់ចំណេញដែលបានមកពីអាជីវកម្មជួញដូរមនុស្ស
  - ជនជួញដូរមនុស្សធ្វើប្រតិបត្តិការហិរញ្ញវត្ថុគ្រប់ទម្រង់ ដូចជា ផ្លូវការ (ធនាគារ ប៉ុស្តិ៍ប្រៃសណីយ៍កាតក្រេឌីដ) និងការផ្ទេរប្រាក់ក្រៅផ្លូវការ ដូចជា ប្រាក់សុទ្ធ...
  - រាល់ព័ត៌មានហិរញ្ញវត្ថុដែលប្រមូលបានក្នុងអំឡុងពេលស៊ើបអង្កេត ៖
    - វិក្កយបត្របង់ប្រាក់សម្រាប់អគារ
    - ការត្រួតពិនិត្យទៅលើប្រតិបត្តិការធនាគារ និងកាតក្រេឌីដ ។
- ប្រតិបត្តិការហិរញ្ញវត្ថុនៅទីតាំងប្រភព
  - ការចំណាយទៅលើការផ្សព្វផ្សាយ
  - ការទិញសំបុត្រធ្វើដំណើរ
  - ការចំណាយទៅលើអគារ ដូចជា សណ្ឋាគារ ផ្ទះ លំនៅដ្ឋានសុវត្ថិភាព
  - គណនេយ្យដែលជនរងគ្រោះមាន អាចបង្ហាញអំពីការដកសាច់ប្រាក់សម្រាប់ការចំណាយទៅលើ ប្រាក់ធានា...
  - គណនេយ្យដែលប្រើដោយអ្នកពាក់ព័ន្ធជាមួយជនល្មើស បង្ហាញប្រាក់កក់
  - ស្រដៀងគ្នានេះដែរ អាចនឹងមានដាននៃសាច់ប្រាក់ ដែលបង្ហាញពីការបង់ប្រាក់ទៅលើផ្ទះ ឬទ្រព្យ សម្បត្តិដទៃទៀត ពីជនជួញដូរមនុស្សដែលជាប់សង្ស័យ
  - ការផ្ញើប្រាក់រវាងជនរងគ្រោះ និងជនជួញដូរ ។

- ប្រតិបត្តិការហិរញ្ញវត្ថុនៅទីតាំងឆ្លងកាត់
    - សំបុត្រធ្វើដំណើរ
    - វិក្កយបត្រសណ្ឋាគារ ឬកន្លែងស្នាក់នៅ
    - ទិដ្ឋាការ ។
- ប្រតិបត្តិការហិរញ្ញវត្ថុនៅទីតាំងគោលដៅ
    - ការចំណាយលើការផ្សព្វផ្សាយ រួមមាន វិបសាយ ឬសេវាអ៊ិនធើណិត...
    - ការចំណាយលើមធ្យោបាយធ្វើដំណើរ
    - ការបង់ប្រាក់សម្រាប់សណ្ឋាគារ ផ្ទះល្វែង
    - ការបើកប្រាក់ឈ្នួលដល់ជនរងគ្រោះ
    - ប្រាក់ឈ្នួល ដែលត្រូវបានចំណាយ
    - ការបង់ប្រាក់សម្រាប់ទំនិញ ឬសេវាកម្មពីភ្ញៀវ ។

**ង. ការប្រាស្រ័យទាក់ទង**

ការប្រាស្រ័យទាក់ទងមានសារសំខាន់សម្រាប់អាជីវកម្មគ្រប់ប្រភេទ ។ អំពើជួញដូរមនុស្ស ក៏មិនខុសគ្នាដែរ ។ ភាពជឿនលឿននៃផ្នែកបច្ចេកទេសក្នុងការប្រាស្រ័យទាក់ទងបានជួយឱ្យជនជួញដូរមនុស្សបំពេញសកម្មភាពរបស់ពួកគេ ។ ប្រព័ន្ធទូរស័ព្ទដៃ និងអ៊ីម៉េលមានភាពងាយស្រួល ក្នុងការប្រាស្រ័យទាក់ទងគ្នា ។ ការប្រាស្រ័យទាក់ទងទាំងនេះផ្តល់ឱកាសឱ្យអ្នកស៊ើបអង្កេតអាចចាប់ការហៅចូល កំណត់ទីតាំងនៃការហៅចូល បង្ហាញបណ្តាញពាក់ព័ន្ធរវាងអ្នកហៅ និងអ្នកទទួលទូរស័ព្ទ ។

- ឱកាសនៃការស៊ើបដែលត្រូវបានប្រើសម្រាប់ទីតាំងទាំងអស់

    - នៅក្នុងករណីមួយចំនួន ការហៅទូរស័ព្ទពីជនរងគ្រោះអាចជាការចាប់ផ្តើមការស៊ើបអង្កេត ។ បញ្ហាស្មុគស្មាញក្នុងករណីនៃអំពើជួញដូរមនុស្ស គឺការប្រើសេវាទូរស័ព្ទ ចល័ត ទាក់ទងពីប្រទេសមួយ ទៅប្រទេសមួយតាមរយៈសេវាក្រៅប្រទេស ។ បញ្ហាអាចត្រូវបានមើលឃើញនៅក្នុងគ្រប់ដំណាក់កាលនៃដំណើរការជួញដូរមនុស្ស និងអាចធ្វើឱ្យមានភាពស្មុគស្មាញដល់ការស៊ើបអង្កេត ព្រោះត្រូវការសិទ្ធិឆែកឆេរពីក្រុមហ៊ុនសេវាទូរស័ព្ទ

    - ការវិភាគលើការប្រើទូរស័ព្ទដៃ អាចកំណត់ទីតាំងជាក់លាក់ ។ ការធ្វើបែបនេះអាចទទួលព័ត៌មានបន្ថែម ទាក់ទងនឹងជនរងគ្រោះ និងជនសង្ស័យ

    - ការទទួលសារទូរស័ព្ទអាចកំណត់អត្តសញ្ញាណជនរងគ្រោះ ។

- ការប្រាស្រ័យទាក់ទងនៅដំណាក់កាលទីតាំងប្រភព

    - ទូរស័ព្ទត្រូវបានប្រើដើម្បីទាក់ទងជនដែលអាចរងគ្រោះ រៀបចំជំនួបជាមួយពួកគេ រៀបចំការធ្វើដំណើរ ការរៀបចំផ្សេងទៀត និងនិយាយជាមួយអតិថិជននៅទីតាំង ដែលបានកំណត់

    - អ៊ីម៉េលក៏ផ្តល់ព័ត៌មានលម្អិតអំពីពេលវេលាដែលជនរងគ្រោះត្រូវមកដល់

    - កុំព្យូទ័រត្រូវបានប្រើដើម្បីធ្វើការកក់សំបុត្រធ្វើដំណើរ ។

- ការប្រាស្រ័យទាក់ទងនៅដំណាក់កាលទីតាំងឆ្លងកាត់

- ទូរស័ព្ទត្រូវបានប្រើដើម្បីផ្តល់ដំណឹងដល់ដៃគូជនល្មើសថា ជនរងគ្រោះបានមកដល់ទីតាំងដែលពួកគេកំពុងឆ្លងកាត់ហើយ ។ ទូរស័ព្ទក៏អាចត្រូវបានប្រើដើម្បីប្រាប់អំពីបញ្ហាដែលអាចនឹងជួបប្រទះ ឬការផ្លាស់ប្តូរគម្រោងនៅតាមផ្លូវ
- អ៊ីម៉ែលក៏អាចត្រូវបានប្រើដើម្បីតាមដានដំណើរផ្លូវរបស់ជនរងគ្រោះផងដែរ ។

* ការប្រាស្រ័យទាក់ទងនៅដំណាក់កាលទីតាំងគោលដៅ
  - ទូរស័ព្ទត្រូវបានប្រើ ដើម្បីរៀបចំការលក់ដូរជនរងគ្រោះ ឬប្រើដើម្បីរៀបចំការធ្វើដំណើរប្រចាំថ្ងៃរបស់ជនរងគ្រោះ
  - កុំព្យូទ័រអាចនឹងមានព័ត៌មាន ទាក់ទងនឹងផ្នែកជាច្រើននៃអំពើជួញដូរមនុស្ស ជាពិសេស អាស័យដ្ឋានអ៊ីម៉ែល និងអ៊ីនធើណិត ៕

ឆឆឆ ✸ លលល

# ឯកសារយោង


- ការិយាល័យអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម
- សៀវភៅណែនាំអំពីការប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អ្នកធ្វើកិច្ចការយុត្តិធម៌
- ឯកសារមេរៀនរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ២០០៣
  - Bourg, Wendy et al; *A Child Interviewer's Guidebook*, Thousand Oaks, CA: Sage Publications, 1999
  - Goodman, Gail; Bottoms, Bette; *Child Victims, Child Witnesses: Understanding and Improving Testimony*, New York, NY: The Guilford Press, 1993
  - Mapes, Bruce; *Child Eyewitness Testimony in Sexual Abuse Investigations*, Brandon, VT: Clinical Psychology Publishing Co., 1995
  - Milne, Rebecca; Bull, Ray; *Investigative Interviewing: Psychology and Practice*, Chichester, West Sussex, UK: John Wiley & Sons Press, 1999
  - Morgan, Marcia; *How to Interview Sexual Abuse Victims Including the Use Of Anatomical Dolls*, Thousand Oaks, CA: Sage Publications, 1995
  - Poole, Debra A; *Investigative Interviews of Children: A Guide for Helping Professionals*, Washington, DC: American Psychological Association, 1998
  - Schafer, John; Navarro, Joe; *Advanced Interviewing Techniques: Proven Strategies for Law Enforcement, Military, and Security Personnel*, Springfield. IL: Thomas Books, 2003
  - Shuy, Roger W.; *The Language of Confession, Interrogation, and Deception*, Thousand Oaks, CA: Sage Publications, 1998
  - Swanson, Charles R. et al; *Criminal Investigation*, Boston, MA: McGraw Hill Publications, 2003, 8th edition
  - Yeschke, Charles; *The Art of Investigative Interviewing: A Human Approach to Testimonial Evidence*, Boston, MA: Butterworth-Heinemann Press, 1997

**MANUALS USED**

- Faller, Kathleen C.; *Child Sexual Abuse: Intervention and Treatment Issues*, U.S. Department of Health and Human Services Administration for Children and Families, McLean, VA: The Circle, Inc, 1993
- Ministry of Interior, General Director of National Police, Kingdom of Cambodia; *Understanding and Investigating Child Sexual Exploitation*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2000
- Ministry of Interior, General Director of National Police, Kingdom of Cambodia; *Training Document on Child Victim Sensitivity*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2003
- Sas, Louise; *The Interaction Between Children's Developmental Capabilities and the Courtroom Environment: The Impact on Testimonial Competency*, Report prepared for the Department of Justice Canada, 2002

**OTHER MATERIALS USED**

- U. S. Department of State Trafficking in Persons Report, 2004

**WEB SITES USED**

- HTTP://www.childdevelopmentinfo.com/development/language_development.shtml
- HTTP://www.families.qld.gov.au/projectaxis/orgbooklet/development.html
- HTTP://danenet.wicip.org/dcccrsa/saissues/parent/1.html
- HTTP://www.aacap.org/publications/factsfam/develop.htm
- HTTP://www.secasa.com.au/index.php/family/12/120
- HTTP://www.earlychildhoodbehavioralhealth.com/ChildDev/sexdevelop.htl
- HTTP://www.ces.perdue.edu/providerparent/Child%20Growth-Development/SexualDEV.htm
- HTTP://www.state.gov/g/tip/rls/tiprpt/2004/34021pf.htm

USAID
ជំនួយពីពលរដ្ឋអាមេរិក

WINROCK
INTERNATIONAL

IJM

# បណ្ឌិត្យសភានគរបាលកម្ពុជា

## កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ

# ការកសាង ប្រើប្រាស់
# អ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់

២០១៧

សូមរក្សាសិទ្ធិ

---

មេរៀននេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការវីនរ៉ក់ ឬរដ្ឋាភិបាលអាមេរិក

# ការកសាង ប្រើប្រាស់អ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់

## សេចក្តីផ្តើម

លក្ខណៈនៃមុខតំណែងរបស់អ្នកជាមន្ត្រីនគរបាល មានព្រំដែននៃព័ត៌មាន ដែលអ្នកអាចប្រមូលបាន តាមរយៈវិធីសាស្ត្រស៊ើបអង្កេតបែបបុរាណ ៖ ការសម្ភាសជនរងគ្រោះ សាក្សី និងជនសង្ស័យ ការស៊ើបអង្កេតទីកន្លែងកើតហេតុ ការឃ្លាំមើល ជាដើម ។ ព័ត៌មានសម្ងាត់ ដែលទទួលបានពីប្រភពដែលគួរឱ្យទុកចិត្ត អាចធ្វើឱ្យអ្នកចាប់បាននូវមធ្យោបាយ និងវិធីសាស្ត្រនៃបណ្តាញឧក្រិដ្ឋជន ដែលលើសពីវិធីសាស្ត្រស៊ើបអង្កេតបែបបុរាណ ។ ការបង្កើតបណ្តាញអ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់ អាចទម្លុះចំណុចខ្សោយលាក់កំបាំងរបស់ជនល្មើស ដែលមានសារៈសំខាន់ដល់ ការស៊ើបអង្កេតបែបសកម្មជាមុន ទៅលើបណ្តាញជួញដូរមនុស្ស និងបទល្មើសដែលមានការចាត់តាំង ។

អ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់ គឺជាធនធានដ៏សំខាន់ក្នុងការប្រមូលព័ត៌មានសម្ងាត់របស់សត្រូវ ចាប់តាំងពីការកកើតមានមនុស្សជាតិមកម្ល៉េះ ។ ស៊ុន ជឺ អ្នកនិពន្ធសៀវភៅអំពីសិល្បៈសង្គ្រាមកាលពីជាង ២០០០ ឆ្នាំកន្លងមក ស្វែងយល់អំពីតម្លៃនៃព័ត៌មានក្នុងការទទួលបានប្រៀបទៅលើគូបដិបក្ខ ។ គាត់បាននិយាយថា "អ្វីដែលធ្វើឱ្យមហាក្សត្រដ៏ឆ្លាតវៃ និងឧត្តមសេនីយ៍ដ៏ពូកែ អាចវាយប្រហារយកឈ្នះបាន និងសម្រេចកិច្ចការបានលើសពីសមត្ថភាពមនុស្សទូទៅ គឺការដឹងព័ត៌មានមុន ។ ការដឹងព័ត៌មានមុន មិនអាចប្រមូលបានតាមការប្រើអារម្មណ៍នោះទេ វាក៏មិនអាចទទួលបានតាមរយៈបទពិសោធន៍បានដែរ ។ ការដឹងព័ត៌មានមុនអំពីចរិតលក្ខណៈរបស់សត្រូវ អាចទទួលបានតាមរយៈមនុស្សដទៃទៀត" ។

## I. អ្នកផ្តល់ព័ត៌មាន

### ១. តើអ្នកផ្តល់ព័ត៌មានគឺជានរណា?

អ្នកផ្តល់ព័ត៌មាន គឺជាមនុស្សដែលអាចទទួលបានព័ត៌មានពិសេស ឬធ្វើកិច្ចការផ្សេងៗ តាមការណែនាំរបស់មន្ត្រីអនុវត្តច្បាប់ ។ ជាទូទៅ កិច្ចការទាំងនេះរួមមាន ប្រមូលព័ត៌មានទាក់ទងនឹងសកម្មភាពឧក្រិដ្ឋជន ធ្វើការឃ្លាំមើល ឬបំពេញកិច្ចការផ្សេងៗ ដែលជួយដល់ការស៊ើបអង្កេត ។

### ២. ហេតុអ្វីបានជាមន្ត្រីស៊ើបអង្កេតជ្រើសរើសអ្នកផ្តល់ព័ត៌មាន?

- មន្ត្រីស៊ើបអង្កេត អាចជួយបង្កើនប្រសិទ្ធភាពនៃការស៊ើបអង្កេតរបស់ខ្លួន ដោយរៀនអំពីរបៀបកសាង និងប្រើប្រាស់អ្នកផ្តល់ព័ត៌មាន ។ អ្នកផ្តល់ព័ត៌មានមានតម្លៃខ្លាំងណាស់ក្នុងការប្រមូលព័ត៌មានអំពី ៖
    - សកម្មភាព ឬបណ្តាញឧក្រិដ្ឋជន
    - កំណត់បែបផែនឧបាយកលរបស់ឧក្រិដ្ឋជន
    - កំណត់ទីតាំងសកម្មភាពឧក្រិដ្ឋជន
    - ការស៊ើបអង្កេតសម្ងាត់
    - ការបង្កើនភ្នាក់ងារឃ្លាំមើល

  ○ កំណត់ បញ្ជាក់ព័ត៌មាន និងកិច្ចការជាច្រើនទៀត ។

- អ្នកផ្តល់ព័ត៌មានៈ នៅក្នុងការងារករណីរបស់អ្នក តើអ្នកធ្លាប់ប្រើអ្នកផ្តល់ព័ត៌មាន ឬទេ? តើអ្នកប្រើអ្នកផ្តល់ព័ត៌មាន តាមរបៀបណា?

## II. បណ្តាញសម្ងាត់

តម្លៃរបស់អ្នកផ្តល់ព័ត៌មានពឹងពាក់លើការទទួលបានព័ត៌មាន ទោះបីជាអតីតកាល បច្ចុប្បន្នកាល ឬអនាគតក្តី ។ ធាតុសំខាន់នៃការទទួលបានព័ត៌មាន គឺការទុកចិត្ត ។ កម្រិតផ្សេងៗនៃការទទួលបានព័ត៌មាន អាស្រ័យលើបរិមាណនៃការទុកចិត្តទាំងស្រុងនៅក្នុងទំនាក់ទំនង ។ ការទទួលបានព័ត៌មាន មិនស្មើនឹងការចូលទៅដល់គោលដៅ ឬបុគ្គលណាម្នាក់ទេ ។ ប្រសិនបើអ្នកផ្តល់ព័ត៌មានមិនមែនជាបណ្តាញសម្ងាត់ដែលគួរឱ្យទុកចិត្តទេ គាត់នឹងមិនអាចទទួលបានព័ត៌មានដែលចាំបាច់ដើម្បីដំណើរការករណីបានទេ ។ ទោះបីជាអ្នកផ្តល់ព័ត៌មានអាចផ្តល់ការសង្កេតក៏ពិតមែន ក៏ប៉ុន្តែអាចនឹងមិនមានព័ត៌មានពិតប្រាកដទេ ។ បន្ថែមពីលើនេះទៀត ប្រសិនបើអ្នកផ្តល់ព័ត៌មានមិនមែនជាបណ្តាញសម្ងាត់ដែលគួរឱ្យទុកចិត្តទេនោះ ជនគោលដៅអាចនឹងផ្តល់នូវព័ត៌មានខុស ដើម្បីសាកល្បងភាពស្មោះត្រង់របស់អ្នកផ្តល់ព័ត៌មាន ឬផ្តល់ព័ត៌មានមិនពិតទៅដល់នរណាម្នាក់ ។

### ១. មូលដ្ឋានសម្ងាត់

- មូលដ្ឋានសម្ងាត់ គឺជាមនុស្សដែលនៅកៀកនឹងព័ត៌មានជាងគេ ហើយជាញឹកញាប់ បានចូលរួមនៅក្នុងបទល្មើស ។ មូលដ្ឋានសម្ងាត់នៅទីតាំង ឬបុគ្គលគោលដៅណាមួយ មានសមត្ថភាពទៅកាន់ទីកន្លែងផ្សេងៗ និងនិយាយជាមួយមនុស្ស ដែលមន្ត្រីស៊ើបអង្កេតអាចនឹងចូលទៅនិយាយជាមួយបាន ។ ជាទូទៅ មូលដ្ឋានសម្ងាត់គឺជាសហការី ឬជនល្មើសដូចគ្នា ដែលជនគោលដៅមានការទុកចិត្ត ដោយសារចំណងទំនាក់ទំនង ឬមានការចាប់អារម្មណ៍ដូចគ្នា ។
- មូលដ្ឋានសម្ងាត់ គឺជាអ្នកផ្តល់ព័ត៌មានដ៏មានសារសំខាន់ ប៉ុន្តែទន្ទឹមគ្នានេះ មានការប្រកាន់ពីសង្គម និងការប្រកាន់ផ្ទាល់ខ្លួនអំពីការក្បត់មនុស្សដែលបានផ្តល់ការទុកចិត្តដល់ពួកគេ ។ ការមិនទុកចិត្ត គឺជាសត្រូវដែលគួរឱ្យភ័យខ្លាច នៅពេលព្យាយាមបង្កើតអ្នកផ្តល់ ព័ត៌មាននៅក្នុងបណ្តាញឧក្រិដ្ឋជនដែលជិតស្និទ្ធិ និងស្គាល់គ្នា ។ បន្ថែមពីលើនេះទៀត ប្រសិនបើមូលដ្ឋានសម្ងាត់ក្បត់នរណាម្នាក់ ដែលជិតស្និទ្ធិចំពោះខ្លួន បុគ្គលនោះក៏អាចនឹងក្បត់អ្នកផ្សេងផងដែរ ។ ដូច្នេះ យើងត្រូវរក្សាការគ្រប់គ្រងឱ្យបានជិតដល់ទៅលើមូលដ្ឋានសម្ងាត់នោះ ។

### ២. មូលដ្ឋានទុកចិត្ត (សហការីកិត្តិយស)

អ្នកដែលអាចចូលទៅកាន់ព័ត៌មានបាន ប៉ុន្តែមានឱកាសតិចជាងអ្នកចូលរួមផ្ទាល់ ។ ពួកគេជាអ្នកអង្កេតការណ៍ ឬតាមរយៈការស្តាប់ឮពីមនុស្សដទៃ ។ ទោះបីជាមូលដ្ឋានទុកចិត្តអាចដឹងខ្លះតាមរយៈទំនាក់ទំនងផ្ទាល់ខ្លួនក្តី ប៉ុន្តែពួកគេមិនស្ថិតនៅក្នុងចំណោមមនុស្សដែលគេទុកចិត្តនោះទេ ។ នៅពេលឱកាសផ្តល់ឱ្យពួកគេអាចនឹងជ្រៀតចូលទៅក្នុងចំណោមមនុស្សស្និទ្ធស្នាល និងក្លាយជាមូលដ្ឋានសម្ងាត់ ។ មន្ត្រីស៊ើបអង្កេតត្រូវធ្វើយ៉ាងណា មិនលាតត្រដាងឱ្យគេដឹងអំពីមូលដ្ឋានទុកចិត្តនោះទេ ដើម្បី ឱ្យពួកគេអាចចូលទៅក្នុងបណ្តាញសម្ងាត់ ។

**៣. ទំនាក់ទំនងប្រយោល ឬចម្ងាយ**

ឱកាសចូលទៅកៀកព័ត៌មានដែលទាបបំផុត គឺអ្នកដែលមានចំណែកតូចមួយនៃរូបផ្គុំ ។ ការចូលទៅកៀកព័ត៌មានត្រូវបានបង្កើតឡើង តាមរយៈទំនាក់ទំនងដែលកើតឡើងដំណាលគ្នា ។ ពួកគេមានការយល់ដឹងមិនសូវសំខាន់តាមរយៈទំនាក់ទំនងប្រយោល ។ បុគ្គលដែលអាចចូលទៅកាន់បរិយាកាស និងព័ត៌មានជាក់លាក់ណាមួយ ដោយសារតែតួនាទី ឬប្រភេទការងាររបស់ពួកគេ អាចផ្តល់ព័ត៌មានដ៏មានតម្លៃ ចំពោះអ្វីដែលពួកគេអង្កេត ឬស្តាប់ឮ ។ ឧទាហរណ៍ ៖ អ្នកបើកតាក់ស៊ីល្អដែលព្យាយាមស្តាប់សន្ទនាដែលកំពុងតែកើតមាន និងដឹងអំពីនរណាម្នាក់ដែលចូល និងចេញ អាចជួយឱ្យមន្ត្រីស៊ើបអង្កេតផ្គុំផ្នែកផ្សេងៗនៃព័ត៌មានបញ្ចូលគ្នា ។

## III. ប្រភេទនៃអ្នកផ្តល់ព័ត៌មាន

មានអ្នកផ្តល់ព័ត៌មានជាច្រើនប្រភេទខុសៗគ្នា ដែលអាចកំណត់អំពីឱកាសទទួលព័ត៌មានបាន និងអំពីរបៀបដែលពួកគេអាចត្រូវបានប្រើនៅក្នុងការបំពេញកិច្ចការផ្ទាល់ ។

**១. អ្នកផ្តល់ព័ត៌មានជាសាក្សី**

មុខងារចម្បងរបស់អ្នកផ្តល់ព័ត៌មានជាសាក្សី គឺធ្វើបន្ទាល់អំពីព្រឹត្តិការណ៍កន្លងមក និងជាទូទៅ មិនមានឱកាសដើម្បីចូលទៅកៀកគោលដៅទេ ។ អ្នកផ្តល់ព័ត៌មានជាសាក្សីផ្តល់ព័ត៌មានអំពីសកម្មភាព ឬហេតុការណ៍ពីអតីតកាល ពួកគេមិនមែនជាធនធានរយៈពេលយូរ និងអាចផ្តល់ព័ត៌មានទៅលើករណីតែមួយ ឬករណីពាក់ព័ន្ធជាច្រើននោះទេ ។ ឧទាហរណ៍៖ អតីតបុគ្គលិកក្រុមហ៊ុនធ្វើដំណើរ អាចផ្តល់ព័ត៌មានអំពីថៅកែក្រុមហ៊ុន ដែលជួយមេខ្យល់ទទួលឯកសារធ្វើដំណើរក្លែងក្លាយសម្រាប់កុមារី ដែលត្រូវបានជួញដូរទៅរៀបការនៅប្រទេស C ។ ទោះបីជាបុគ្គលិករូបនោះឈប់ធ្វើការឱ្យក្រុមហ៊ុនធ្វើដំណើរនោះហើយក៏ដោយ គាត់អាចកំណត់អត្តសញ្ញាណមេខ្យល់ និងមនុស្សពាក់ព័ន្ធក្នុងការក្លែងឯកសារទាំងនោះ ។

**២. អ្នកផ្តល់ព័ត៌មានសកម្ម**

អ្នកផ្តល់ព័ត៌មានសកម្ម គឺជាមនុស្សម្នាក់ដ៏មានតម្លៃបំផុត ព្រោះពួកគេអាចផ្តល់ព័ត៌មានផ្ទៃក្នុងដែលកំពុងតែកើតឡើង ។ ព័ត៌មានទាំងអស់ដែលត្រូវបានផ្តល់ដោយអ្នកផ្តល់ព័ត៌មានសកម្ម គឺចង់បញ្ជាក់ព័ត៌មានរបស់ពួកគេ ដោយប្រើប្រភពផ្សេងៗ ។ ទោះបីជាអ្នកផ្តល់ព័ត៌មានសកម្ម គឺជាប្រភេទអ្នកផ្តល់ព័ត៌មានដែលពេញនិយមពិតមែន ក៏អាចនៅតែមានបញ្ហាដែលកើតឡើង នៅពេលប្រើពួកគេ ។ បញ្ហារួមមួយគឺថា ដើម្បីបន្តផ្តល់ព័ត៌មាន អ្នកផ្តល់ព័ត៌មានសកម្មត្រូវរក្សាភាពជាជនល្មើសរបស់ខ្លួន ដូច្នេះ ពួកគេអាចនឹងបន្តប្រព្រឹត្តសកម្មភាពបទល្មើស ។ ឧទាហរណ៍ ៖ នៅក្នុងការស៊ើបអង្កេតលើអំពើជួញដូរផ្លូវភេទ អ្នកផ្តល់ព័ត៌មានសកម្មអាចក្លែងធ្វើជាភ្ញៀវដែលប្រើសេវានៅគ្រឹះស្ថានបម្រើផ្លូវភេទ ប៉ុន្តែផ្តល់ព័ត៌មានដល់អ្នក នៅពេលជនល្មើសជួញដូរមនុស្សនាំកុមារីចូលមក ។

**៣. អ្នកផ្តល់ព័ត៌មានក្នុងពន្ធនាគារ**

- ករណីខ្លះ អ្នកផ្តល់ព័ត៌មានក្នុងពន្ធនាគានឹងផ្តល់ព័ត៌មានអំពីបទល្មើសពីអតីតកាល ដែល

អ្នកជាប់ពន្ធនាគារដូចគ្នាអាចធ្លាប់បានប្រព្រឹត្ត ។ តាមរយៈការទទួលបានការទុកចិត្តពីអ្នកជាប់ពន្ធនាគារដូចគ្នា អ្នកផ្តល់ព័ត៌មានអាចចូលពន្ធនាគារ និងទទួលបានសក្ខីកម្ម ទាក់ទងនឹងការពាក់ព័ន្ធរបស់អ្នកជាប់ពន្ធនាគារនោះ នៅក្នុងបទល្មើសកន្លងមក ។ ក្នុងករណីផ្សេងទៀត អ្នកជាប់ពន្ធនាគារនោះ អាចនឹងជួយដល់ការស៊ើបអង្កេតសកម្មភាពបទល្មើសដែលកំពុងបន្តនៅក្នុងពន្ធនាគារ អាចតាមរយៈអ្នកជាប់ពន្ធនាគារដទៃទៀត ឬអនុរក្សពន្ធនាគារ ។

- អ្នកផ្តល់ព័ត៌មានក្នុងពន្ធនាគារ មិនត្រូវបានទុកចិត្តពីសំណាក់អ្នកជាប់ពន្ធនាគារដូចគ្នា ឬមនុស្សផ្សេងទៀតដែលមានការពាក់ព័ន្ធជាមួយពួកគេ ។ ពួកគេទទួលបានការជំរុញពីខ្លួនឯង និងសង្ឃឹមថាទទួលបានការសម្រាលទោស ក្នុងករណីព្រហ្មទណ្ឌរបស់ខ្លួន ហើយជាទូទៅពួកគេមានប្រវត្តិប្រព្រឹត្តបទល្មើសច្រើន ដូច្នេះព្រះរាជអាជ្ញាអាចនឹងមានភាពស្ទាក់ស្ទើរក្នុងការប្រើអ្នកផ្តល់ព័ត៌មានក្នុងពន្ធនាគារ ជាសាក្សីក្នុងការកាត់ទោសជនល្មើស ។
- ព័ត៌មានដែលទទួលបានពីអ្នកផ្តល់ព័ត៌មានក្នុងពន្ធនាគារ ត្រូវតែបញ្ជាក់តាមរយៈការប្រមូលព័ត៌មាន ឬភស្តុតាងបន្ថែមទៀត ។ របៀបប្រសើរបំផុតក្នុងការប្រើអ្នកផ្តល់ព័ត៌មានក្នុងពន្ធនាគារ គឺត្រូវបំពេញបន្ថែមទៅលើការស៊ើបអង្កេតជាមួយព័ត៌មាន ដើម្បីបង្កើតភស្តុតាងឯករាជ្យនៅក្នុងបទល្មើស និងដើម្បីចៀសវាងការប្រើប្រាស់អ្នកផ្តល់ព័ត៌មាន ជាសាក្សីនៅក្នុងតុលាការ ។
- អ្នកផ្តល់ព័ត៌មានដោយចៃដន្យ
    - ជាធម្មតា អ្នកផ្តល់ព័ត៌មានដោយចៃដន្យ មិនដឹងថា អ្នកជាមន្ត្រីមានសមត្ថកិច្ចទេ ។ ពួកគេបែកធ្លាយព័ត៌មានដោយចៃដន្យ នៅពេលអ្នកស្ថិតនៅក្នុងសម្លៀកបំពាក់ស៊ីវិល ឬស្ថិតនៅក្នុងប្រតិបត្តិការសម្ងាត់
    - ពួកគេអាចផ្តល់នូវព័ត៌មានដ៏ល្អ ដោយមិនស្គាល់អំពីអត្តសញ្ញាណពិតប្រាកដរបស់មនុស្សដែលពួកគេផ្តល់ឱ្យ
    - ពួកគេអាចណែនាំអ្នកឱ្យស្គាល់គោលដៅ ឬបុគ្គលផ្សេងទៀត ដែលជួយឱ្យអ្នកប្រមូលបានព័ត៌មានដោយសម្ងាត់
    - ជាញឹកញាប់ ពួកគេមើលឃើញអ្នកដូចជាមិត្តភ័ក្ត និងជាឧក្រិដ្ឋជនដូចគ្នា ដូច្នេះហើយអ្នកត្រូវរំពឹងទុកជាមុននូវប្រតិកម្មពីពួកគេ នៅពេលពួកគេដឹងអំពីអត្តសញ្ញាណពិតប្រាកដរបស់អ្នក
    - ព័ត៌មានដែលទទួលបានពីអ្នកផ្តល់ព័ត៌មានដោយចៃដន្យ ជាមូលដ្ឋានក្នុងការពិចារណាថា គួរដកចេញអ្នកផ្តល់ព័ត៌មាននេះ ចេញពីករណីរឿង
    - អ្នកផ្តល់ព័ត៌មានដោយចៃដន្យ មិនផ្តល់ព័ត៌មានដល់អ្នកទេ ប្រសិនបើពួកគេដឹងថាអ្នកគឺជាសមត្ថកិច្ច ។ មន្ត្រីស៊ើបអង្កេតត្រូវពិចារណាថា តើពួកគេស្ថិតនៅក្នុងតួនាទីណាមួយ ដែលយើងអាចកសាងជាមូលដ្ឋានសម្ងាត់ប្រើប្រាស់ក្នុងការស៊ើបអង្កេត ។ ឧទាហរណ៍៖ ក្នុងសម្លៀកបំពាក់ស៊ីវិល អ្នកកំណត់បានអត្តសញ្ញាណជនជ្រើសរើសពលករ ដែលកំពុងតែជ្រើសរើសមនុស្សប្រុសឱ្យធ្វើការនៅលើទូកនេសាទនៅក្នុងប្រទេសថៃ ។ អ្នកជ្រើសរើសពលករបញ្ជូនបុរសទាំងនេះទៅមេខ្យល់ម្នាក់ក្នុងខេត្តសៀមរាប ហើយមេខ្យល់នេះនាំពួកគេឆ្លងកាត់ព្រំដែនប្រទេសថៃ និងលក់ពួកគេទៅកាន់ម្ចាស់

ទូកនេសាទនៅផៃប៉ាក់ណាម សាមុតប្រាក់ខាន់ ។ អ្នកអាចធ្វើជាមិត្តភក្តិជាមួយអ្នកជ្រើសរើសពលករនេះ ហើយធ្វើឱ្យពួកគេជឿថា អ្នកមានមនុស្សមួយចំនួនចាប់អារម្មណ៍ធ្វើចំណាកស្រុក ទៅប្រទេសថៃដើម្បីរកការងារធ្វើ ប៉ុន្តែអ្នកចង់ជួបជាមួយមេខ្យល់ ដើម្បីពិភាក្សាអំពីប្រាក់កម្រៃជើងសារ ដែលគាត់នឹងត្រូវចំណាយសម្រាប់ពលករ ប្រសិនបើគាត់នាំពលករមក ។ អ្នកជ្រើសរើសពលករបានយល់ព្រម ។

- អតីតជនរងគ្រោះ ឬសាច់ញាតិរបស់ជនរងគ្រោះ

អតីតជនរងគ្រោះ ឬសាច់ញាតិជនរងគ្រោះ គឺជាប្រភពសំខាន់ក្នុងការផ្តល់ព័ត៌មានដល់មន្ត្រីស៊ើបអង្កេត អំពីមធ្យោបាយ កលល្បិចជនល្មើស ដើម្បីជួយដល់មន្ត្រីស៊ើបអង្កេត ។ ការផ្តល់ព័ត៌មាន ពិតជាសំខាន់ដើម្បីស្វែងយល់ធាតុផ្សំនៃបទល្មើស និងអំពីរបៀបធ្វើអាជីវកម្ម ។ លើសពីនេះទៀត ពួកគេអាចផ្តល់ព័ត៌មានអំពីទីតាំង ជនល្មើស ជនរងគ្រោះ ... ។ ឧទាហរណ៍ ៖ ជនរងគ្រោះម្នាក់បានមកជួបអ្នក ដែលជាពលករដោះបំណុលនៅក្នុងឡឥដ្ឋ ។ ថៅកែឡឥដ្ឋផ្តល់នូវប្រាក់ឈ្នួលបើកមុនទៅដល់ពលករ ប៉ុន្តែបើកប្រាក់ឈ្នួលទាប ជាហេតុធ្វើឱ្យកម្មករមិនអាចសងប្រាក់កម្ចីរួច បន្ទាប់ពីធ្វើការក្នុងឡឥដ្ឋអស់រយៈពេល ១០ឆ្នាំមក ។ ថៅកែនេះមិនអនុញ្ញាតឱ្យកម្មករ ឬគ្រួសាររបស់កម្មករចាកចេញពីឡឥដ្ឋ ឬធ្វើការនៅកន្លែងផ្សេងទេ រហូតទាល់តែប្រាក់កម្ចីត្រូវបានសងរួច ។ សមាជិកគ្រួសារម្នាក់របស់កម្មករបានលក់ដីរបស់ខ្លួនសងបំណុល ដើម្បីឱ្យគ្រួសារអាចចាកចេញពីឡឥដ្ឋនោះ។ កម្មកររូបនោះ បានប្រាប់អ្នកថា មានគ្រួសារចំនួន ២៥ ទៀតដែលជាប់បំណុលនៅក្នុងឡឥដ្ឋ ដោយពួកគេមិនអាចដោះបំណុល និងចាកចេញពីឡឥដ្ឋបាន ។ អ្នកអាចចងក្រងព័ត៌មាននេះអំពីថៅកែឡឥដ្ឋ ជនរងគ្រោះ ទីតាំងឡឥដ្ឋ មធ្យោបាយ និងកលល្បិចដែលថៅកែប្រើ ដើម្បីធ្វើឱ្យ ២៥ គ្រួសារជំពាក់បំណុល ។

- អ្នករួចទោស (អតីតទណ្ឌិត)

អ្នករួចទោស ដែលបានកែប្រែខ្លួនរួចហើយ អាចផ្តល់ព័ត៌មានអំពីបណ្តាញ មធ្យោបាយ និងកលល្បិចប្រព្រឹត្តបទល្មើស ដែលអាចប្រើក្នុងការកសាងករណី និងផ្តល់នូវព័ត៌មាន ដើម្បីស្វែងរកបណ្តាញ និងជនល្មើស ។ ជាញឹកញាប់ អ្នកអាចទទួលបានព័ត៌មានដ៏មានតម្លៃទាក់ទងនឹងសកម្មភាពបទល្មើស ។ ពួកគេអាចនឹងផ្តល់នូវព័ត៌មានសម្រាប់ធ្វើការស៊ើបអង្កេត ប៉ុន្តែត្រូវប្រយ័ត្ន និងមិនត្រូវផ្តល់ព័ត៌មានបន្ថែមទៅដល់ពួកគេ ដែលមិនចាំបាច់ ។

- ប្រភពព័ត៌មាន

ប្រភពព័ត៌មាន គឺជាមនុស្សដែលធ្វើការទាក់ទងនឹងសកម្មភាពឧក្រិដ្ឋ តាមរយៈការងាររបស់ពួកគេ ឬតាមរយៈមនុស្សរស់នៅក្នុងតំបន់ដែលសកម្មភាពឧក្រិដ្ឋកំពុងតែកើតឡើង ។ ប្រភពទាំងនេះក៏អាចជាអ្នកជំនួញដែលអាចផ្តល់ព័ត៌មានអំពីឧក្រិដ្ឋជន និងអតិថិជន ព្រមទាំងជាប្រភពព័ត៌មានដ៏ល្អ ព្រោះពួកគេអាចឃ្លាំមើលហេតុការណ៍បាន ដោយសារការងារ ឬទីតាំងរបស់ពួកគេ ហេតុដូច្នេះ ជាទូទៅ ជនគោលដៅមិនសង្ស័យពួកគេនោះទេ ។

ឧទាហរណ៍៖ នៅក្នុងអំពើជួញដូរពលកម្ម ប្រភពព័ត៌មានអាចជាអ្នកបើកឡានក្រុងដែលទាក់ទងមកអ្នក នៅពេលគាត់មើលឃើញស្ត្រីវ័យក្មេងអមដំណើរដោយមនុស្សម្នាក់ ដែលត្រូវបាន

សង្ស័យថាជួញដូរមនុស្សឆ្លងដែន ។ ឧទាហរណ៍មួយទៀតអាចជាម្ចាស់រទេះលក់ម្ហូប ដែលដាក់រទេះរបស់គាត់នៅទល់មុខផ្ទះសុវត្ថិភាព ដែលសង្ស័យថា មានកម្មករនៅខាងក្នុងនៅពេលពួកគេកំពុងរង់ចាំឯកសារធ្វើដំណើរ មុនពេលត្រូវបានគេជួញដូរទៅប្រទេសម៉ាឡេស៊ី ដើម្បីធ្វើការបម្រើក្នុងផ្ទះ ។

ប្រភពព័ត៌មានផ្សេងទៀតដែលអាចមាន ចំពោះប្រភេទអំពើជួញដូរមនុស្សះ

- អំពើជួញដូរមនុស្សឆ្លងដែនះ ភ្នាក់ងារជ្រើសរើស និងធ្វើដំណើរ ភ្នាក់ងារលក់សំបុត្រ ការិយាល័យទិដ្ឋាការ/លិខិតឆ្លងដែន អ្នករត់តាក់ស៊ី អ្នករត់ម៉ូតូ មេភូមិ អង្គការ...
- អំពើជួញដូរផ្លូវភេទះ គ្រូពេទ្យ ជំនួយការពេទ្យ អ្នករត់តាក់ស៊ី អ្នករត់ម៉ូតូ អង្គការ...
- ពលកម្មបម្រើតាមផ្ទះដោយបង្ខំះ ថៅកែហាង មេភូមិ គ្រូបង្រៀន វេជ្ជបណ្ឌិត... ។

## IV. ការជំរុញឱ្យមានការផ្តល់ព័ត៌មាន

ការលើកទឹកចិត្តដល់អ្នកផ្តល់ព័ត៌មាន មានសារៈសំខាន់ក្នុងការទទួលបានព័ត៌មាន ដែលជំរុញឱ្យគាត់សហការជាមួយមន្ត្រីស៊ើបអង្កេត ។ ការលើកទឹកចិត្តដល់អ្នកផ្តល់ព័ត៌មាន អាចនឹងមានការផ្លាស់ប្តូរ ហើយការយល់ដឹងអំពីជំហរបស់អ្នក ទាក់ទងនឹងការលើកទឹកចិត្តដល់អ្នកផ្តល់ព័ត៌មាន គឺជាមធ្យោបាយប្រសើរបំផុតក្នុងការគ្រប់គ្រង ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពរបស់អ្នកផ្តល់ព័ត៌មាន និងភាពជោគជ័យរបស់មន្ត្រីស៊ើបអង្កេត ។ វាក៏ជាការសំខាន់ផងដែរក្នុងការយល់ថា ការលើកទឹកចិត្តនោះអាចនឹងមិនមែនជាអ្វីដែលអ្នកផ្តល់ព័ត៌មានត្រូវការគ្រប់ពេលវេលានោះទេ ។

### ១. ភាពភ័យខ្លាច

- ភាពភ័យខ្លាចគឺជាកត្តាជំរុញមួយដែលមានឥទ្ធិពល និងមានប្រសិទ្ធភាព ។ ជាញឹកញាប់ការការពារខ្លួនត្រូវបានរៀបរាប់ថា ជាច្បាប់ធម្មជាតិដំបូង ដូច្នេះយើងគួររំពឹងថា ភាពភ័យខ្លាចនឹងជំរុញឱ្យមានការឆ្លើយតបមួយដ៏ខ្លាំងចំពោះអ្នកផ្តល់ព័ត៌មាន ដែលអាចត្រូវបានប្រើដោយមន្ត្រីស៊ើបអង្កេត
- ភារកិច្ចសំខាន់របស់មន្ត្រីអនុវត្តច្បាប់ទាក់ទងនឹងអ្នកផ្តល់ព័ត៌មាន ដែលជាបុគ្គលត្រូវសង្ស័យ គឺត្រូវស្វែងរកឱកាសសហការ ដើម្បីទទួលបានព័ត៌មាន ទាក់ទងដល់សកម្មភាពល្មើសរបស់ជនជួញដូរ ។ ត្រូវពិគ្រោះយោបល់ជាមួយព្រះរាជអាជ្ញា ដើម្បីរួចផុតពីការចោទប្រកាន់ ហើយលើកទឹកចិត្តអ្នកផ្តល់ព័ត៌មាន ក្រោយពេលប្រតិបត្តិការស៊ើបអង្កេត
- ជនល្មើសដែលស្ម័គ្រចិត្តផ្តល់ព័ត៌មានដ៏មានតម្លៃ សម្រាប់ឈានដល់ការបង្ក្រាបជនល្មើស ឬបណ្តាញ ត្រូវបានពិចារណា ប្រសិនបើពួកគេសហការជាមួយមន្ត្រីអនុវត្តច្បាប់ ។ ការផ្តន្ទាទោសជនល្មើស អាចជាការផ្តល់រង្វាន់ដ៏មានឥទ្ធិពល ដើម្បីឱ្យពួកគេសហការ និងផ្តល់ព័ត៌មាន ។ ប្រសិនបើពួកគេផ្តល់ព័ត៌មានមិនពិត នោះពួកគេនឹងត្រូវបានផ្តន្ទាទោស
- ជនល្មើសអាចមានការព្រួយបារម្ភចំពោះការក្បត់ វាយប្រហារ ឬសងសឹកពីសំណាក់ក្រុមជនល្មើសដូចគ្នាផង និងការស្រាវជ្រាវពីមន្ត្រីអនុវត្តច្បាប់ផង ។ ដូច្នេះ មន្ត្រីស៊ើបអង្កេតអាចជាអ្នកទទួលផលពីការខ្វែងគំនិតគ្នានៅក្នុងជួរជនល្មើស ដោយកសាងពួកគេជាអ្នកផ្តល់ព័ត៌មាន នៅពេលពួកគេមានអារម្មណ៍ថា ត្រូវបក្ខពួករបស់ខ្លួនក្បត់ ឬគំរាមកំហែង ។

### ២. ការទិញព័ត៌មាន

• ហេតុផលមួយចំនួនដែលមុខសញ្ញាត្រូវបានស្វែងរកចាប់ខ្លួន គឺការផ្តល់ប្រាក់រង្វាន់ដល់អ្នកផ្តល់ព័ត៌មាន ដែលឈានទៅដល់ការចាប់ខ្លួនជនល្មើស ។ ប៉ុន្តែ ក្នុងករណីខ្លះ អ្នកផ្តល់ព័ត៌មានដោយសារប្រាក់ មន្ត្រីស៊ើបអង្កេតត្រូវមានការប្រុងប្រយ័ត្ន ថាតើព័ត៌មានដែលផ្តល់ឱ្យនោះ ពិតក្នុងកម្រិតណា

• អ្នកផ្តល់ព័ត៌មានភាគច្រើនត្រូវបានលើកទឹកចិត្តដោយផ្តល់នូវថវិកាតែប៉ុណ្ណោះ ។ ការផ្តល់ប្រាក់ចំនួនបន្តិចបន្តួចជាប្រចាំ អាចមានឥទ្ធិពលដើម្បីរក្សាភាពស្មោះត្រង់របស់អ្នកផ្តល់ព័ត៌មាន ជាងការផ្តល់ប្រាក់ច្រើនតែម្តង ។ អ្នកផ្តល់ព័ត៌មានចាប់ផ្តើមមានភាពស៊ាំ និងមានការពឹងអាងទៅលើប្រាក់ផ្តល់ឱ្យជាប្រចាំ ក្នុងរយៈពេលយូរ ដូច្នេះមានប្រយោជន៍ក្នុងការបន្តសហការ ឬផ្តល់ព័ត៌មាន

• អ្នកផ្តល់ព័ត៌មានដែលគិតតែពីប្រាក់ ជាញឹកញាប់ ត្រូវបានជ្រើសរើសឱ្យធ្វើជាមូលដ្ឋានសម្ងាត់ ។ មូលដ្ឋានសម្ងាត់ គឺជាធនធានលាក់កំបាំងមួយ រយៈពេលយូរ ដែលជួយដល់មន្ត្រីស៊ើបអង្កេតក្នុងការតស៊ូករណី ។ មូលដ្ឋានសម្ងាត់អាចចូលទៅក្នុងក្រុម និងបណ្តាញឧក្រិដ្ឋជន តាមការណែនាំរបស់មន្ត្រីស៊ើបអង្កេត ។

### ៣. ការសងសឹក

• អាស្រ័យទៅលើប្រភេទករណី ជនល្មើសខ្លះនឹងសហការផ្តល់ព័ត៌មានឱ្យសមត្ថកិច្ច ដើម្បីប្រឆាំងនឹងបក្ខពួករបស់ខ្លួន

• ព័ត៌មានដែលត្រូវបានផ្តល់ដោយមនុស្ស ដែលមានចិត្តប្រឆាំងនឹងបក្ខពួករបស់ខ្លួន គឺជាព័ត៌មានល្អ ប៉ុន្តែត្រូវបញ្ជាក់ព័ត៌មាន ព្រោះវាក៏អាចត្រូវបានបំប៉ោង

• ត្រូវទទួលយកព័ត៌មានភ្លាម ពីអ្នកដែលមានចិត្តប្រឆាំងនឹងបក្ខពួករបស់ខ្លួន នៅពេលដែលពួកគេកំពុងចង់ផ្តល់ព័ត៌មាន

• មន្ត្រីស៊ើបអង្កេត ត្រូវលើកទឹកចិត្តអ្នកផ្តល់ព័ត៌មានដែលមានចិត្តប្រឆាំងនឹងបក្ខពួករបស់ខ្លួន (អាចទទួលស្គាល់សម្រាលទោស...) ដើម្បីអប់រំណែនាំ និងប្រើប្រាស់សម្រាប់ផ្តល់ព័ត៌មាន ។

### ៤. អត្តទត្ថបុគ្គល

• អ្នកផ្តល់ព័ត៌មានដែលមានលក្ខណៈអត្តទត្ថបុគ្គល គឺជាមនុស្សម្នាក់ ដែលព្យាយាមបំប៉ោងអំពីសារៈសំខាន់នៃព័ត៌មានរបស់ពួកគេ ឬអួតអំពីលក្ខណៈសម្បត្តិ ដែលពួកគេអាចចូលទៅកៀកគោលដៅបាន ហើយតែងតែមានបំណងបង្កើនភាពអស្ចារ្យរបស់ខ្លួន ។ ពួកគេតែងតែចង់មានការងារពាក់ព័ន្ធនឹងមន្ត្រីអនុវត្តច្បាប់ ប៉ុន្តែមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ

• ពួកគេក៏អាចនឹងប្រើល្បិចដើម្បីចង់ដឹងពីសមត្ថភាពយល់ដឹងរបស់សមត្ថកិច្ច និងក្លាយជាបញ្ហាលំបាកគ្រប់គ្រង សម្រាប់មន្ត្រីស៊ើបអង្កេត ដោយចង់ធ្វើកិច្ចការឯករាជ្យ ឬធ្វើការសម្រេចចិត្តដោយខ្លួនឯង

• អ្នកផ្តល់ព័ត៌មានប្រភេទនេះ គិត និងជឿថា ខ្លួនឆ្លាតជាងអ្នកដទៃ ដឹងអំពីរបៀបចូលរួម ។

### ៥. គោលបំណងលាក់កំបាំង

• អ្នកផ្តល់ព័ត៌មានដែលមាន "គោលបំណងលាក់កំបាំង" ផ្តល់ព័ត៌មានដោយសង្ឃឹមថា នឹងទទួលបានគុណប្រយោជន៍ណាមួយ

- មូលហេតុរបស់ពួកគេ មិនមែនជាអ្វីដែលមន្ត្រីស៊ើបអង្កេតចង់បាន ។ ឧទាហរណ៍៖ប្រឆាំងគូបដិបក្ខនៅក្នុងមុខជំនួញផ្ទាល់ខ្លួន រៀនអំពីបច្ចេកទេសស៊ើបអង្កេត កំណត់អត្តសញ្ញាណមន្ត្រីស៊ើបអង្កេត ឬស្វែងយល់អំពីសកម្មភាពប្រតិបត្តិការរបស់មន្ត្រីស៊ើបអង្កេត លាតត្រដាងអំពើពុករលួយ ឬទង្វើខុសឆ្គងរបស់មន្ត្រីនគរបាល
- គោលបំណងពិតប្រាកដរបស់អ្នកផ្តល់ព័ត៌មាន ត្រូវបានលាក់ការសម្ងាត់យ៉ាងប្រុងប្រយ័ត្ន ដូច្នេះមន្ត្រីស៊ើបអង្កេតត្រូវកំណត់អំពីគោលបំណងពិតប្រាកដនៃការផ្តល់ព័ត៌មាន ។

**៦. ការសារភាព ឬពលរដ្ឋល្អ**

- ប្រភេទនៃអ្នកផ្តល់ព័ត៌មានដ៏កម្រ គឺជាអ្នកដែលបានកែខ្លួន និងជាមនុស្សស្មោះត្រង់ក្នុងគោលបំណងឈប់ប្រព្រឹត្តបទល្មើស និងកែប្រែកំហុស ចំពោះអំពើល្មើសពីអតីតកាល ។ បុគ្គលទាំងនេះមានគោលបំណងល្អ និងត្រូវលើកទឹកចិត្ត ដើម្បីទទួលបានព័ត៌មានច្រើន
- អ្នកផ្តល់ព័ត៌មានប្រភេទនេះ គឺជាអ្នកផ្តាច់ខ្លួនចេញពីក្រុមជនល្មើស ។ ត្រូវប្រយ័ត្នចំពោះអ្នកផ្តល់ព័ត៌មាន "ដែលមានគោលបំណងលាក់កំបាំង" ដោយយកលេសកែប្រែខ្លួន ដើម្បីបិទបាំងគោលបំណងពិតប្រាកដរបស់ខ្លួន
- អ្នកផ្តល់ព័ត៌មាន ដែលផ្តល់ព័ត៌មានសម្រាប់ផលប្រយោជន៍សង្គម មានគោលបំណងផ្នែកមនោគមវិជ្ជា នេះហើយជាមូលហេតុដែលពួកគេគឺជាពលរដ្ឋល្អ ។

## V. កត្តាដែលមានឥទ្ធិពលទៅលើការសម្រេចចិត្តក្នុងការផ្តល់ព័ត៌មាន

មានករណីដែលអ្នកផ្តល់ព័ត៌មាននឹងចូលទៅកាន់មន្ត្រីស៊ើបអង្កេត និងបង្ហាញគោលបំណងសហការ និងផ្តល់ព័ត៌មាន ដោយផ្អែកលើមូលហេតុមួយ ឬពីរ ដូចបានរៀបរាប់ខាងលើ ។ ប៉ុន្តែករណីភាគច្រើន មន្ត្រីស៊ើបអង្កេតនឹងត្រូវបន្តជ្រើសរើសអ្នកផ្តល់ព័ត៌មានឱ្យធ្វើការ ប្រមូលព័ត៌មានទូទៅ ឬព័ត៌មានជាក់លាក់ ។

មានបច្ចេកទេសបី ដែលមានឥទ្ធិពលទៅលើការសម្រេចចិត្តរបស់បុគ្គលម្នាក់ ក្នុងការក្លាយជាអ្នកផ្តល់ព័ត៌មាន ៖

**១. ការលើកទឹកចិត្ត**

- មន្ត្រីស៊ើបអង្កេតត្រូវយល់ដឹងអំពីមូលហេតុ និងគោលបំណង ដែលអ្នកផ្តល់ព័ត៌មានចង់សហការ
- មន្ត្រីស៊ើបអង្កេតត្រូវមានការលើកទឹកចិត្តក្នុងការកសាងអ្នកផ្តល់ព័ត៌មាន ៖
  - យល់អំពីតម្រូវការរបស់បុគ្គលម្នាក់ៗ
  - ពន្យល់ឱ្យបានក្បោះក្បាយអំពីអត្ថប្រយោជន៍នៃដំណោះស្រាយ និង
  - បង្ហាញ និងដោះស្រាយទៅតាមតម្រូវការរបស់អ្នកផ្តល់ព័ត៌មាន ដែលអាចធ្វើបាន ។

**២. ការទុកចិត្ត**

ហេតុអ្វីបានជាការទុកចិត្តគឺជាកត្តាមួយដ៏សំខាន់ ក្នុងទំនាក់ទំនងមន្ត្រីស៊ើបអង្កេត/អ្នកផ្តល់ព័ត៌មាន?

- អ្នកផ្តល់ព័ត៌មានត្រូវតែទុកចិត្តពាក្យសម្តីរបស់មន្ត្រីស៊ើបអង្កេត
  - សំណួរចម្បងនៅក្នុងចិត្តរបស់អ្នកផ្តល់ព័ត៌មានគឺ "តើខ្ញុំអាចទុកចិត្តមនុស្សនេះបាន ឬទេ?" ។ អ្នកផ្តល់ព័ត៌មានកំពុងឈានទៅក្នុងស្ថានភាពមិនប្រាកដអំពីភាពទុកចិត្ត ហើយគាត់ចង់ដឹងថា តើគាត់អាចទុកចិត្តមន្ត្រីស៊ើបអង្កេត មុនចាប់ផ្តើមផ្តល់ព័ត៌មានដែលអាចផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្នរបស់គាត់
  - គុណសម្បត្តិដ៏មានតម្លៃបំផុតរបស់មន្ត្រីស៊ើបអង្កេត គឺកេរ្តិ៍ឈ្មោះ និងពាក្យសម្តី ដូច្នេះមន្ត្រីស៊ើបអង្កេតត្រូវរក្សាពាក្យសម្តីរបស់ខ្លួន ។ មន្ត្រីស៊ើបអង្កេតចាប់ផ្តើមដំណើរការនេះដោយនិយាយការពិត និងមិនធ្វើការសន្យាណាមួយ ដែលខ្លួនមិនអាចរក្សាពាក្យសន្យានោះបានទេ ។ ជាចុងក្រោយការទុកចិត្តចាប់ផ្តើមកសាងឡើង បន្ទាប់ពីមានការពិភាក្សាគ្នា ។

**កំណត់ចំណាំ** ៖ គាត់កំពុងវាយតម្លៃអ្នក ដូចជាអ្នកវាយតម្លៃគាត់ដែរ ។

- អ្នកផ្តល់ព័ត៌មានត្រូវតែទុកចិត្តដល់ការសម្រេចចិត្តរបស់មន្ត្រីស៊ើបអង្កេត
  - នេះមានន័យថា ត្រូវរក្សាព័ត៌មានសម្ងាត់ ដូចជា អត្តសញ្ញាណរបស់អ្នកផ្តល់ព័ត៌មាន ។ មន្ត្រីស៊ើបអង្កេតគួរបង្ហាញនៅពេលជួបគ្នាដំបូង ដល់អ្នកផ្តល់ព័ត៌មានថា ការសម្រេចចិត្តនេះសំខាន់
  - មន្ត្រីស៊ើបអង្កេតគួរបញ្ជាក់អំពីការការពារ និងរក្សាការសម្ងាត់អត្តសញ្ញាណអ្នកផ្តល់ព័ត៌មានតាំងពីដំបូង
  - ប្រសិនបើមន្ត្រីស៊ើបអង្កេតបង្ហាញអំពីកង្វល់នៃសុវត្ថិភាពរបស់អ្នកផ្តល់ព័ត៌មាន ដូច្នេះអ្នកផ្តល់ព័ត៌មានអាចនឹងធ្វើការជាមួយមន្ត្រីស៊ើបអង្កេត ។
- អ្នកផ្តល់ព័ត៌មានត្រូវតែទុកចិត្តដល់សមត្ថភាពរបស់មន្ត្រីស៊ើបអង្កេត
  - សុវត្ថិភាព និងការលាក់ការណ៍សម្ងាត់អត្តសញ្ញាណរបស់អ្នកផ្តល់ព័ត៌មាន ត្រូវពឹងផ្អែកទៅលើចំណាត់ការរបស់មន្ត្រីស៊ើបអង្កេត
  - តាមរយៈការត្រៀមចម្លើយចំពោះសំណួរ និងការជំទាស់ មន្ត្រីស៊ើបអង្កេតអាចបញ្ជាក់ការយល់ដឹងអំពីច្បាប់ ការស៊ើបអង្កេត និងតួនាទីភារកិច្ច ។ សមត្ថភាពពិតប្រាកដនឹងបង្ហាញចេញមក
  - មន្ត្រីស៊ើបអង្កេតមិនត្រូវនិយាយដោយគ្មានការទទួលខុសត្រូវនោះទេ ។

### ៣. មនសិការ

ជាញាណក្នុងខ្លួនមនុស្ស ដែលគិតពិចារណាអំពីអ្វីដែលត្រូវ ឬខុស ចំពោះសកម្មភាព ឬបំណងចិត្តរបស់នរណាម្នាក់ ។

- ការសម្រេចចិត្ត "និយាយ ឬមិននិយាយ" អាចប៉ះពាល់មនសិការ ។ ទោះបីជាអ្នកអាចរៀបរាប់ក្បោះក្បាយនៅក្នុងការងារករណី (casework) អំពីអត្ថប្រយោជន៍សម្រាប់ជនរងគ្រោះ និងសង្គម ក្នុងកិច្ចសហការស៊ើបអង្កេតរបស់អ្នកក៏ដោយ ក៏មនសិការរបស់មនុស្សដែលមិនស្មោះត្រង់អាចនឹងត្រូវបង្ហាញឱ្យឃើញ ។ អ្វីដែលមន្ត្រីស៊ើបអង្កេតត្រូវសាកល្បង គឺមិនត្រូវឱ្យអ្នកផ្តល់ព័ត៌មានធ្វើផ្ទុយពីឆន្ទៈនោះទេ
- យើងកំណត់អំពីមនសិការរបស់អ្នកផ្តល់ព័ត៌មាន តាមរយៈការពិនិត្យទៅលើពាក្យសម្តីនិងសកម្មភាព ។ អ្វីដែលអ្នកផ្តល់ព័ត៌មាននិយាយ និងធ្វើ ពិតជាមានសារៈសំខាន់ស្មើគ្នាក្នុងការវាយតម្លៃ

អំពីជំហររបស់បុគ្គលនោះ ទាក់ទងនឹងមនសិការរបស់គាត់ ។ មន្ត្រីស៊ើបអង្កេតត្រូវធ្វើជាអ្នកស្ដាប់ដ៏ល្អ និងយកចិត្តទុកដាក់ផ្ដោតទៅលើសកម្មភាពដែលអ្នកផ្ដល់ព័ត៌មានតែងតែជំទាស់ និងលាតត្រដាង

- វិធីសាស្ត្រពីរដើម្បីជម្នះលើមនសិការ
    - ការយល់ច្រឡំចំពោះភាពស្មោះត្រង់ ៖ ជនសង្ស័យអាចប្រើប្រាស់អ្នកផ្ដល់ព័ត៌មានឱ្យផ្ដល់ព័ត៌មានមិនពិតដល់មន្ត្រីស៊ើបអង្កេត ក្នុងគោលបំណងទាញយកផលប្រយោជន៍ពីអ្នកផ្ដល់ព័ត៌មានតែប៉ុណ្ណោះ ។ ដូច្នេះ មន្ត្រីស៊ើបអង្កេតត្រូវចាត់វិធានការឱ្យបានមុនជនសង្ស័យប្រើប្រាស់អ្នកផ្ដល់ព័ត៌មាន
    - មធ្យោបាយទិញទឹកចិត្ត៖ ឱ្យអ្នកផ្ដល់ព័ត៌មានធ្វើសកម្មភាពក្បត់គ្នាឯង ឬសកម្មភាពបោកបញ្ឆោត និងបន្ទាប់មកឈានដល់សកម្មភាពផ្សេងទៀត ។ នេះមិនមែនជាមធ្យោបាយអាក្រក់ទេ ព្រោះអាចជួយឱ្យអ្នកផ្ដល់ព័ត៌មានទុកចិត្តលើកិច្ចសហការស៊ើបអង្កេត ។ ឧទាហរណ៍៖ នៅក្នុងការស៊ើបអង្កេតទៅលើបទល្មើសគ្រឿងញៀន សកម្មភាពខាងលើនេះគឺជាការ "ទិញទឹកចិត្ត" ពីអ្នកផ្ដល់ព័ត៌មាន ។ នៅពេលដែលការទិញទឹកចិត្ត ដំណើរការទៅល្អដោយមិនប៉ះពាល់ដល់មនសិការរបស់គាត់ យើងអាចចាប់ផ្ដើមឱ្យគាត់ផ្ដល់ព័ត៌មានពីសកម្មភាពសំខាន់ៗ សម្រាប់ការស៊ើបអង្កេត ។
- ការលើកទឹកចិត្តនេះ អាចជាជម្រើសល្អ នៅពេលដែលអ្នកផ្ដល់ព័ត៌មានសម្រេចចិត្តសហការជាមួយអ្នក ។ អ្នកត្រូវតែធ្វើឱ្យគាត់ជឿថា អ្នកគឺជាមនុស្សដែលគួរឱ្យទុកចិត្ត និងគិតពីប្រយោជន៍របស់គាត់ និងត្រូវឆ្លើយតបចំពោះមនសិការរបស់គាត់ ទាក់ទងនឹងសកម្មភាពក្បត់គ្នាឯង ឬការបោកបញ្ឆោត ដើម្បីផ្ដល់នូវព័ត៌មាន ឬភស្តុតាង ។

## VI. បុគ្គលដែលអាចក្លាយជាអ្នកផ្ដល់ព័ត៌មាន

នៅពេលពិចារណាថា តើត្រូវជ្រើសរើសអ្នកផ្ដល់ព័ត៌មានណាម្នាក់ មន្ត្រីស៊ើបអង្កេតគួរតែប្រមូលព័ត៌មានអំពីបុគ្គលដែលអាចក្លាយជាអ្នកផ្ដល់ព័ត៌មាន និងត្រួតពិនិត្យបុគ្គលិកលក្ខណៈជាក់លាក់ ដែលជួយដល់ទំនាក់ទំនងមន្ត្រីស៊ើបអង្កេត/អ្នកផ្ដល់ព័ត៌មាន ឱ្យមានប្រសិទ្ធភាព ។

### ១. ទំនុកចិត្ត និងជឿជាក់

- ការពិចារណាមួយដ៏សំខាន់ នៅពេលប្រមូលព័ត៌មានអំពីអ្នកផ្ដល់ព័ត៌មាន គឺថាអ្នកផ្ដល់ព័ត៌មានមានភាពគួរឱ្យទុកចិត្ត និងជឿជាក់ឬទេ ។ នៅក្នុងការអនុវត្តច្បាប់ មន្ត្រីស៊ើបអង្កេតត្រូវមានទំនុកចិត្ត និងជឿជាក់លើព័ត៌មាន ដែលអ្នកផ្ដល់ព័ត៌មានផ្ដល់ឱ្យ
- មន្ត្រីស៊ើបអង្កេតត្រូវបង្កើតភាពគួរឱ្យជឿជាក់របស់អ្នកផ្ដល់ព័ត៌មាន ដោយផ្ដល់នូវកិច្ចការឱ្យគាត់ធ្វើ ហើយមន្ត្រីស៊ើបអង្កេតត្រូវបញ្ជាក់អំពីភាពគួរឱ្យជឿទុកចិត្តនៃព័ត៌មានរបស់គាត់ ។ ប្រសិនបើអ្នកផ្ដល់ព័ត៌មាននោះនិយាយការពិតនៅក្នុងកិច្ចការរបស់គាត់ នោះយើងអាចមានទំនុកចិត្តថែមទៀត ក្នុងការប្រើប្រាស់គាត់ជាអ្នកផ្ដល់ព័ត៌មាន
- ប្រសិនបើអ្នកបញ្ជាក់ថា អ្នកផ្ដល់ព័ត៌មាននេះមិនគួរឱ្យទុកចិត្ត សូមប្រយ័ត្ននៅពេលប្រើគាត់ ឬកុំប្រើគាត់តែម្ដង ។

**២. បុគ្គលិកលក្ខណៈ**

- បុគ្គលិកលក្ខណៈផ្សេងទៀតដែលអ្នកអាចស្វែងយល់អំពីអ្នកផ្ដល់ព័ត៌មាន ៖
  - មានចិត្តចង់សហការ
  - មានទំនុកចិត្តលើខ្លួនឯង
  - ចេះទប់ចិត្ត និងអារម្មណ៍
  - ចេះបត់បែន
  - អំណត់
  - ក្លាហាន
  - ការតាំងចិត្ត
  - ជំនាញអង្កេតល្អ ។
- សូមពិនិត្យមើលបុគ្គលិកលក្ខណៈនីមួយៗ ហើយពិភាក្សាអំពីមូលហេតុអ្វី ដែលបុគ្គលិកលក្ខណៈទាំងនេះសំខាន់ សម្រាប់អ្នកផ្ដល់ព័ត៌មាន ។

## VII. ការកសាងអ្នកផ្ដល់ព័ត៌មាន

ដោយសារអ្នកផ្ដល់ព័ត៌មានភាគច្រើនត្រូវបានកសាងឡើង ព្រោះពួកគេមិនមែនដើរចូលទៅក្នុងអង្គភាពរបស់នគរបាល ហើយសុំផ្ដល់ព័ត៌មាននោះទេ ដូច្នេះត្រូវពិចារណាអំពីវិធីសាស្ត្រ និងរបៀបវាយតម្លៃអ្នកផ្ដល់ព័ត៌មាន ។

**១. វិធីសាស្ត្រ**

- វិធីសាស្ត្រកំណត់៖ កំណត់ឱ្យបានច្បាស់លាស់អំពីបុគ្គលនោះ ក្នុងរយៈពេលជាក់លាក់
- វិធីសាស្ត្រឈានទៅមុខ៖ ការអភិវឌ្ឍបន្តិចម្ដងៗនូវកិច្ចសហការ ដោយប្រើរយៈពេលយូរ។

**២. ការរៀបចំ**

ទោះបីជាអ្នកសាកល្បងប្រើវិធីសាស្ត្រកសាងអ្នកផ្ដល់ព័ត៌មានមួយណាក៏ដោយ អ្នកគួរតែត្រៀមខ្លួនជាមុន ទាក់ទងនឹងប្រវត្តិសាវតាររបស់អ្នកផ្ដល់ព័ត៌មាន ។ អ្នកត្រូវដឹងឱ្យបានច្រើនអំពីបុគ្គលម្នាក់នេះ មុនពេលអ្នកជួបជាមួយពួកគេ ។ ការរៀបចំ និងការបង្កើត ៖

- ប្រមូលព័ត៌មានអំពីអ្នកផ្ដល់ព័ត៌មាន៖ សាវតារ បក្សពួក ប្រវត្តិប្រព្រឹត្តបទល្មើស ការអប់រំ ករណីបទល្មើសដែលមិនទាន់សម្រេច ស្ថាប័នអនុវត្តច្បាប់ផ្សេងទៀត ដែលអ្នកផ្ដល់ព័ត៌មានអាចកំពុងធ្វើការជាមួយ ឬបានធ្វើពីអតីតកាល
- គោលបំណងកសាងអ្នកផ្ដល់ព័ត៌មាន
- ការជ្រើសរើសទីកន្លែងទំនាក់ទំនង ឬលេខទំនាក់ទំនង
- ការបង្កើតទំនាក់ទំនងស្និទ្ធស្នាល ការជំរុញទឹកចិត្ត ការជឿជាក់ និងមនសិការ
- ពិចារណាអំពីសំណើរបស់អ្នកផ្ដល់ព័ត៌មាន
- ពិចារណាអំពីការផ្ដល់ឱ្យ អត្ថប្រយោជន៍ ឬដំណោះស្រាយដែលបំពេញសំណើនោះ ។

**៣. ការឆ្លើយតប(កង្វល់)**

- នៅពេលអ្នកផ្តល់ព័ត៌មានលើកឡើងអំពីកង្វល់ យ៉ាងហោចណាស់ ធ្វើឱ្យមន្ត្រីស៊ើបអង្កេតដឹងថា អ្នកផ្តល់ព័ត៌មានកំពុងពិចារណាអំពីកិច្ចសហការ ឬគាត់គ្រាន់តែប្រាប់អ្នកថា "ទេ" ដែលជាកង្វល់សមហេតុផល ហើយមន្ត្រីស៊ើបអង្កេតត្រូវត្រៀមខ្លួនឆ្លើយតបចំពោះកង្វល់ទាំងនេះ ។ ការឆ្លើយតប និងអាកប្បកិរិយារបស់មន្ត្រីស៊ើបអង្កេត នឹងជួយធ្វើឱ្យអ្នកផ្តល់ព័ត៌មានស្ងប់អារម្មណ៍ ឬធ្វើឱ្យមានកង្វល់ថែមទៀត ។ នៅពេលឆ្លើយតបហើយ មន្ត្រីស៊ើបអង្កេតអាចនឹងបន្តដំណើរការជ្រើសរើស ។
- កង្វល់ទាក់ទងនឹងអ្នកផ្តល់ព័ត៌មាន ៖
    - ការបញ្ជាក់ថា រាល់ការព្រមព្រៀងទាំងអស់ត្រូវទទួលកិត្តិយស
    - កង្វល់អំពីការសម្ងាត់
    - កង្វល់អំពីសុវត្ថិភាព និងការសងសឹក
    - កង្វល់អំពីសក្ខីកម្ម
    - កង្វល់អំពីការបង្កើតករណី ។

**៤. បញ្ចប់នូវដំណើរការជ្រើសរើស**

- មន្ត្រីស៊ើបអង្កេតអាចសង្ខេបអំពីការពិភាក្សា
- បញ្ជាក់ពីភាពវិជ្ជមានអំពីតម្រូវការដែលត្រូវបំពេញ តាមរយៈកិច្ចសហការ
- ការសន្យា
- ជំរុញឱ្យមានការព្រមព្រៀង ។

## VIII. ការគ្រប់គ្រងអ្នកផ្តល់ព័ត៌មាន

ការគ្រប់គ្រងអ្នកផ្តល់ព័ត៌មានមានភាពស្រដៀងគ្នាច្រើនទៅនឹងការគ្រប់គ្រងបុគ្គលិក ក៏ប៉ុន្តែក៏មានលក្ខណៈខុសគ្នាផងដែរ ។ របៀបនៃការគ្រប់គ្រងរបស់អ្នក ត្រូវតែមានលក្ខណៈត្រួតត្រា ដែលមន្ត្រីស៊ើបអង្កេតធ្វើការសម្រេចចិត្ត និងផ្តល់ការណែនាំ អ្នកផ្តល់ព័ត៌មានមិនឯករាជ្យទេ ។

**១. ការសម្រេចចិត្ត**

ការត្រួតត្រាគឺជាគន្លឹះនៃការគ្រប់គ្រងអ្នកផ្តល់ព័ត៌មាន ដោយគ្មានការផ្ទេរការងារនៅក្នុងទំនាក់ទំនងរវាងអ្នកផ្តល់ព័ត៌មាន/មន្ត្រីស៊ើបអង្កេត ។ មន្ត្រីស៊ើបអង្កេតប្រាប់អ្នកផ្តល់ព័ត៌មានអំពីការសម្រេចចិត្ត ដោយរបៀបណា ។ នេះមិនមែនមានន័យថា មន្ត្រីស៊ើបអង្កេតមិនគួរស្តាប់អ្នកផ្តល់ព័ត៌មាន ឬអ្នកផ្តល់ព័ត៌មានមិនត្រូវទទួលការប្រឹក្សាយោបល់នោះទេ ។ ផ្ទុយទៅវិញ ការធ្វើសេចក្តីសម្រេចចិត្តរួចហើយ អ្នកផ្តល់ព័ត៌មានត្រូវបានរំពឹងថានឹងអនុវត្តការសម្រេចចិត្ត តាមការណែនាំ ។

**២. ការទទួលខុសត្រូវ**

ការគ្រប់គ្រងអ្នកផ្តល់ព័ត៌មាន ត្រូវមានការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក រវាងមន្ត្រីស៊ើបអង្កេត និងអ្នកផ្តល់ព័ត៌មាន ។ កម្រិតនៃការទុកចិត្តក៏ចាំបាច់ផងដែរ ។ អ្នកផ្តល់ព័ត៌មានត្រូវតែមានទំនុកចិត្តលើមន្ត្រីស៊ើបអង្កេត ។

**៣. ការគ្រប់គ្រងអ្នកផ្តល់ព័ត៌មាន**

- មន្ត្រីស៊ើបអង្កេតដែលកសាងអ្នកផ្តល់ព័ត៌មាន ត្រូវគ្រប់គ្រងអ្នកផ្តល់ព័ត៌មាននោះ
- មន្ត្រីស៊ើបអង្កេតអាចគ្រប់គ្រងអ្នកផ្តល់ព័ត៌មានម្នាក់ ឬច្រើននាក់ ប៉ុន្តែអ្នកផ្តល់ព័ត៌មានវិញ មិនអាចរាយការណ៍លើសពីមួយករណីឡើយ
- វាជាការសំខាន់ដែលត្រូវយល់ថា ការស៊ើបអង្កេតអាច និងគួរតែចែករំលែកព័ត៌មានដែលត្រូវបានទទួល ឬប្រមូលពីអ្នកផ្តល់ព័ត៌មាន នៅពេលចាំបាច់ ប៉ុន្តែពួកគេមិនត្រូវផ្ទេរអ្នកផ្តល់ព័ត៌មាន ឬបង្ហាញអត្តសញ្ញាណរបស់អ្នកផ្តល់ព័ត៌មាន លើកលែងតែករណីចាំបាច់
- ហានិភ័យមានអ្នកគ្រប់គ្រងអ្នកផ្តល់ព័ត៌មានលើសពីម្នាក់ គឺថាអ្នកផ្តល់ព័ត៌មានអាចនឹងធ្វើឱ្យអ្នកគ្រប់គ្រងប្រកួតប្រជែងគ្នា ។

**៤. ការទំនាក់ទំនងជាអចិន្ត្រៃយ៍**

ការគ្រប់គ្រងទៅលើអ្នកផ្តល់ព័ត៌មាន គឺជាដំណើរការមួយជាប្រចាំ និងជាប់លាប់ ដែលគួរតែបង្កើតឡើងជាមួយអ្នកផ្តល់ព័ត៌មាន ជាវិធីសាស្ត្រនៃការគ្រប់គ្រង ។ តាមរយៈការបង្កើតកាលវិភាគជាក់លាក់ជាមួយអ្នកដែលត្រូវទាក់ទង មន្ត្រីស៊ើបអង្កេតទាមទារឱ្យអ្នកផ្តល់ព័ត៌មានអនុវត្តទៅតាមរចនាសម្ព័ន្ធ ដែលបានកំណត់ ។

**៥. ការបណ្តុះបណ្តាល និងការណែនាំ**

មន្ត្រីស៊ើបអង្កេតគួរតែផ្តល់ការបណ្តុះបណ្តាល និងការណែនាំដល់អ្នកផ្តល់ព័ត៌មាន ដើម្បីធានាថា អ្នកផ្តល់ព័ត៌មានយល់អំពីគោលបំណងរបស់មន្ត្រីស៊ើបអង្កេត ។

**៦. រក្សាទំនាក់ទំនងបែបវិជ្ជាជីវៈ**

- ទំនាក់ទំនងរវាងមន្ត្រីស៊ើបអង្កេត និងអ្នកផ្តល់ព័ត៌មាន ត្រូវតែមានភាពវិជ្ជាជីវៈគ្រប់ពេល ហើយមន្ត្រីស៊ើបអង្កេតមិនគួរជួបជាមួយអ្នកផ្តល់ព័ត៌មានតែម្នាក់ឯងទេ ប្រសិនបើអាចទៅបាន
- ការជួបជាមួយអ្នកផ្តល់ព័ត៌មានតែម្នាក់ឯង ធ្វើឱ្យមន្ត្រីស៊ើបអង្កេតប្រឈមនឹងការចោទប្រកាន់ខុសឆ្គង ហើយអាចជាបញ្ហាសុវត្ថិភាព ដែលអាស្រ័យទៅលើប្រភេទនៃអ្នកផ្តល់ព័ត៌មាន
- អ្នកផ្តល់ព័ត៌មានអាចក្បត់អ្នក ដូចដែលគាត់ក្បត់បក្ខពួកខ្លួនដែរ ។

**៧. ការចងក្រងឯកសារអំពីសកម្មភាពការងាររបស់អ្នកផ្តល់ព័ត៌មាន**

- មន្ត្រីស៊ើបអង្កេតត្រូវតាមដាន និងចងក្រងជាឯកសារនូវការបំពេញការងាររបស់អ្នកផ្តល់ព័ត៌មាន
- អ្នកត្រូវតែបន្តវាយតម្លៃគុណភាព និងភាពជឿជាក់របស់ព័ត៌មាន ដែលអ្នកផ្តល់ព័ត៌មានផ្តល់ឱ្យ និងថាតើអ្នកអាចទុកចិត្តអ្នកផ្តល់ព័ត៌មានបានដែរឬទេ
- បន្ថែមពីលើនេះទៀត ប្រសិនបើអ្នកជួយឱ្យអ្នកផ្តល់ព័ត៌មានក្លាយជាភ្នាក់ងារសម្ងាត់ មានឯកសារកត់ត្រាអមពីការបំពេញការងាររបស់ពួកគេ ជួយដល់ការសម្រេចចិត្តជ្រើសរើស ។

**៨. ការផ្តល់រង្វាន់**

- មន្ត្រីស៊ើបអង្កេតមិនគួរផ្តល់ប្រាក់ឱ្យអ្នកផ្តល់ព័ត៌មានទេ ប្រសិនបើពួកគេមិនធ្វើតាមការណែនាំរបស់មន្ត្រីស៊ើបអង្កេត ឬប្រសិនបើព័ត៌មានដែលអ្នកផ្តល់ព័ត៌មានផ្តល់ឱ្យមិនត្រឹមត្រូវ

• ម៉្យាងទៀត អ្នកផ្តល់ព័ត៌មានគួរតែទទួលបានរង្វាន់សមរម្យ និងទទួលនូវភាពស្មោះត្រង់ ។ កុំធ្វើការសន្យាដែលអ្នកមិនអាចធ្វើបាន និងប្រសិនបើអ្នកសន្យាអ្វីមួយ សូមរក្សាពាក្យសន្យានោះ

• មន្ត្រីស៊ើបអង្កេតគួរតែរក្សាទំនាក់ទំនងស្មោះត្រង់ជាមួយអ្នកផ្តល់ព័ត៌មាន ។

**៩. ការរក្សាការសម្ងាត់**

• ការរក្សាការសម្ងាត់របស់អ្នកផ្តល់ព័ត៌មានពិតជាសំខាន់ និងត្រូវតែការពារ ។ ប្រសិនបើអ្នកលាតត្រដាងអត្តសញ្ញាណអ្នកផ្តល់ព័ត៌មានរបស់អ្នកនៅពេលដែលមិនចាំបាច់ អ្នកនឹងមិនគ្រាន់តែបាត់បង់អ្នកផ្តល់ព័ត៌មាននោះទេ ប៉ុន្តែអ្នកក៏អាចនឹងលំបាកជ្រើសរើសអ្នកផ្តល់ព័ត៌មានថែមទៀតដែរ

• កេរ្តិ៍ឈ្មោះរបស់អ្នកក្នុងការប្រព្រឹត្តិត្រឹមត្រូវចំពោះអ្នកផ្តល់ព័ត៌មានគឺជាគន្លឹះក្នុងការកសាងអ្នកផ្តល់ព័ត៌មានក្នុងការងារ ។

**១០. ការប្រុងប្រយ័ត្ន**

• កុំធ្វេសប្រហែសឱ្យសោះនៅពេលធ្វើការជាមួយអ្នកផ្តល់ព័ត៌មាន និងយល់ថា ការជំរុញ និងភាពស្មោះត្រង់របស់ពួកគេ អាចផ្លាស់ប្តូរបាន ។ ដូច្នេះ យើងត្រូវប្រុងប្រយ័ត្ន នៅពេលធ្វើការជាមួយអ្នកផ្តល់ព័ត៌មាន ទោះបីជាអ្នកជឿថា អ្នកស្គាល់បុគ្គលនោះច្បាស់លាស់ក៏ដោយ

• សុវត្ថិភាពរបស់អ្នកផ្តល់ព័ត៌មានជាការទទួលខុសត្រូវរបស់អ្នក និងត្រូវយកចិត្តទុកដាក់ ។

**១១. ការបញ្ជាក់ព័ត៌មាន**

មន្ត្រីស៊ើបអង្កេតគួរតែព្យាយាមបញ្ជាក់ព័ត៌មានដែលអ្នកផ្តល់ព័ត៌មានផ្តល់ឱ្យ។ មានហេតុផលមួយចំនួនសម្រាប់ការបញ្ជាក់ព័ត៌មាន៖

• កាត់បន្ថយលទ្ធភាពដែលអ្នកផ្តល់ព័ត៌មាននឹងត្រូវធ្វើសក្ខីកម្មក្នុងតុលាការ ។ ប្រសិនបើអ្នកអាចប្រមូលព័ត៌មានបានតាមរយៈប្រភពផ្សេងទៀត វានឹងកាត់បន្ថយឱកាសដែលអ្នកនឹងប្រើអ្នកផ្តល់ព័ត៌មាននៅក្នុងតុលាការ

• បង្កើតភាពគួរឱ្យទុកចិត្តរបស់អ្នកផ្តល់ព័ត៌មាន និងប្រាប់អ្នកផ្តល់ព័ត៌មានថា អ្នកនឹងបញ្ជាក់ព័ត៌មានដែលគាត់ផ្តល់ឱ្យ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ

• ផ្តល់ការការពារសម្រាប់អ្នកផ្តល់ព័ត៌មាន ប្រសិនបើបក្ខពួកមានការសង្ស័យ ។

**១២. ការផ្តល់ប្រាក់ដល់អ្នកផ្តល់ព័ត៌មាន**

ភ្នាក់ងារអនុវត្តច្បាប់គួរតែមានគោលនយោបាយ និងនីតិវិធី ដែលណែនាំអំពីរបៀបដែលមន្ត្រីស៊ើបអង្កេតកសាង គ្រប់គ្រង និងផ្តល់ប្រាក់ដល់អ្នកផ្តល់ព័ត៌មាន ។ នៅពេលផ្តល់ប្រាក់ដល់អ្នកផ្តល់ព័ត៌មាន សម្រាប់ព័ត៌មានដែលផ្តល់ឱ្យ ត្រូវពិចារណាចំណុចខាងក្រោម៖

• គុណភាព និងភាពគួរឱ្យទុកចិត្តនៃព័ត៌មាន

• រយៈពេល ភាពលំបាក និងហានិភ័យ ។

## IX. ភ្នាក់ងារសម្ងាត់

**១. ដូចម្តេចដែលហៅថា ភ្នាក់ងារសម្ងាត់?**

• ភ្នាក់ងារសម្ងាត់ គឺជាបុគ្គលដែលជួយដល់មន្ត្រីស៊ើបអង្កេតក្នុងការបង្កើត និងស៊ើបអង្កេត

លើករណី ។ ភ្នាក់ងារសម្ងាត់ត្រូវបានប្រគល់កិច្ចការដែលត្រូវធ្វើ និងអាចចូលទៅក្នុងក្រុម និងបណ្តាញនានា តាមការណែនាំរបស់មន្ត្រីស៊ើបអង្កេត។

- ត្រូវយកចិត្តទុកដាក់ក្នុងការជ្រើសរើស បណ្តុះបណ្តាល អភិវឌ្ឍ និងគ្រប់គ្រងឱ្យបានល្អ
- នៅពេលភ្នាក់ងារសម្ងាត់ហត់នឿយក្នុងពេលបំពេញការងារ វាមាននូវផលប៉ះពាល់យ៉ាងខ្លាំងទៅលើប្រសិទ្ធភាពនៃការស៊ើបអង្កេតបែបសកម្មជាមុន ដូច្នេះការរក្សាការសម្ងាត់អំពីអត្តសញ្ញាណរបស់ពួកគេពិតជាសំខាន់ ។

## ២. ការជ្រើសរើសភ្នាក់ងារសម្ងាត់

ភ្នាក់ងារសម្ងាត់មានលក្ខណៈដូចអ្នកផ្តល់ព័ត៌មានដែរ គឺពួកគេត្រូវមានលក្ខណៈសម្បត្តិ ៖

- ការទទួលបានព័ត៌មាន

ភ្នាក់ងារសម្ងាត់ត្រូវតែអាចបង្កើតច្រកផ្លូវ ដើម្បីទទួលព័ត៌មាន និងជាមួយបុគ្គលដែលពាក់ព័ន្ធ ក្នុងប្រភេទជាក់លាក់នៃការងារករណី៖

  - ក្នុងអំពើជួញដូរផ្លូវភេទ ភ្នាក់ងារសម្ងាត់អាចបន្លំខ្លួនធ្វើជាភ្ញៀវ ដើម្បីអាចចូលទៅក្បែរស្ត្រីរងគ្រោះ ឬស្ត្រីពេស្យា
  - ក្នុងអំពើជួញដូរពលកម្មដោយបង្ខំ ភ្នាក់ងារសម្ងាត់ត្រូវមានសមត្ថភាពបន្លំខ្លួនជាមួយក្រុមកម្មករ និងទទួលបានការទុកចិត្តពីពួកគេ ដើម្បីឱ្យមន្ត្រីស៊ើបអង្កេតអាចធ្វើសម្ភាសន៍ពួកគេបាន
  - ក្នុងអំពើជួញដូរមនុស្សឆ្លងដែន ភ្នាក់ងារសម្ងាត់ត្រូវបានបញ្ជ្រៀតចូលក្នុងបណ្តាញជួញដូរមនុស្ស បន្លំខ្លួនធ្វើជាកម្មករ ថៅកែ ឬជនល្មើសជួញដូរមនុស្ស
  - ភ្នាក់ងារសម្ងាត់ពង្រីកវិសាលភាពរបស់មន្ត្រីស៊ើបអង្កេត ។

- ការជំរុញទឹកចិត្ត

ជាការចាំបាច់ដែលអ្នកត្រូវយល់អំពីការជំរុញទឹកចិត្តក្នុងការទទួលបានព័ត៌មាន ឬក្នុងការធ្វើការជាមួយអ្នក ។ ទោះបីជាអ្នកមិនយល់ព្រមជាមួយនឹងបំណងចិត្ត (គោលបំណង លាក់កំបាំង ឬការសងសឹក) ក្នុងនាមជាមន្ត្រីស៊ើបអង្កេត អ្នកនៅតែប្រើបុគ្គលនោះ ដើម្បីទទួលបានព័ត៌មាន ឬចូលទៅជិតមនុស្សដែលអ្នកមិនអាចចូលទៅបាន ។ យើងត្រូវធ្វើការស្វែងយល់អំពីគោលបំណងរបស់ពួកគេក្នុងពេលធ្វើការជាមួយយើង ។ ភ្នាក់ងារសម្ងាត់ភាគច្រើន ធ្វើការជាមួយមន្ត្រីស៊ើបអង្កេតដើម្បីទទួលបានប្រាក់ ព្រោះពួកគេយល់ថា បានរួមចំណែក នៅក្នុងបុព្វហេតុមួយដែលស័ក្តិសម ។ វាជាការសំខាន់ដែលយើងត្រូវបន្តពង្រឹងគោលបំណងទាំងនេះ ដើម្បីរក្សាទំនាក់ទំនងរវាងមន្ត្រីស៊ើបអង្កេត/ភ្នាក់ងារសម្ងាត់ ។

- ការគ្រប់គ្រង

  - ដោយសារភ្នាក់ងារសម្ងាត់ធ្វើការ គ្មានអ្នកគ្រប់គ្រងផ្ទាល់នៅក្នុងការងារ មន្ត្រីស៊ើបអង្កេតត្រូវបង្កើតការគ្រប់គ្រងទៅលើសកម្មភាពភ្នាក់ងារសម្ងាត់ និងផ្តល់ការបណ្តុះបណ្តាល ការណែនាំ និងការតម្រង់ទិស
  - ការរក្សាទំនាក់ទំនងជាប្រចាំ និងការរំលឹកខ្លីៗអំពីសកម្មភាពរបស់ពួកគេ ពិតជាការចាំបាច់ក្នុងការរក្សាការគ្រប់គ្រង ។

### ៣. ការគ្រប់គ្រងលើភ្នាក់ងារសម្ងាត់

- ការបណ្តុះបណ្តាល ៖ នៅពេលអ្នកបានជ្រើសរើសជាភ្នាក់ងារសម្ងាត់រួចហើយ ចាំបាច់ត្រូវធ្វើការបណ្តុះបណ្តាល ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម និងឥទ្ធិពលនៃការងារ ។ មិនត្រូវបញ្ជូនភ្នាក់ងារសម្ងាត់ទៅបំពេញការងារ ដោយមិនបានបណ្តុះបណ្តាល និងផ្តល់ព័ត៌មានត្រៀមដល់ពួកគេជាមុន ។ យើងត្រូវរៀបចំការបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារសម្ងាត់ ដែលអ្នកនឹងបណ្តុះបណ្តាលមុនពេលបំពេញកិច្ចការណាមួយ ។
- ទំនាក់ទំនងជាប្រចាំ
  - រក្សាទំនាក់ទំនងជាប្រចាំជាមួយភ្នាក់ងារសម្ងាត់ និងផ្តល់ព័ត៌មានឱ្យពួកគេដឹងអំពីអ្វីដែលពួកគេសម្រេចបាននៅក្នុងការងារ ដើម្បីឱ្យអ្នកអាចផ្តល់មតិត្រឡប់ និងការណែនាំ ។ ត្រូវពិនិត្យមើលសញ្ញាណាមួយដែលភ្នាក់ងារសម្ងាត់កំពុងទទួលរងផលប៉ះពាល់ពីការងារ ផ្នែកអារម្មណ៍ និង/ឬផ្នែករាងកាយ
  - ប្រសិនបើនៅជាប់ជាមួយមនុស្សមួយក្រុមក្នុងរយៈពេលយូរ ត្រូវពិនិត្យមើលការប្រែប្រួលចំពោះភាពស្មោះត្រង់ ឬបង្ហាញអារម្មណ៍អាណិតអាសូរ ជាមួយជនគោលដៅ ។
- ទំនុកចិត្ត
  - ការបង្កើតទំនាក់ទំនងដំបូង និងកម្រិតនៃការទុកចិត្តជាមួយភ្នាក់ងារសម្ងាត់ ពិតជាសំខាន់ក្នុងការគ្រប់គ្រងសកម្មភាពរបស់ពួកគេនៅក្នុងការងារ ។ ដូចជាអ្នកផ្តល់ព័ត៌មានដែរ ភ្នាក់ងារសម្ងាត់នឹងទុកចិត្តអ្នក ដោយសារអ្នកគោរពចំពោះពាក្យសម្តី ភាពឈ្លាសវៃក្នុងការងារ
  - ពួកគេវាយតម្លៃអ្នក ដូចជាអ្នកវាយតម្លៃពួកគេដែរ ។
- គោលបំណង ៖ មន្រ្តីស៊ើបអង្កេត គួរតែដឹងពីអ្វីដែលជំរុញទឹកចិត្តភ្នាក់ងារសម្ងាត់ និងពង្រឹងគោលបំណងទាំងនោះ នៅពេលដែលអាចធ្វើទៅបាន ។ ប្រសិនបើភ្នាក់ងារសម្ងាត់ឱ្យតម្លៃដល់អ្នកជាសំខាន់ ភ្នាក់ងារសម្ងាត់នោះពិតជាមានប្រយោជន៍ ដើម្បីធ្វើឱ្យករណីដំណើរការទៅមុខ និងទទួលបានជោគជ័យ
- រក្សាការសម្ងាត់ ៖ ការការពារអត្តសញ្ញាណភ្នាក់ងារសម្ងាត់ និងការបង្ហាញពីកង្វល់ពិតប្រាកដចំពោះសុវត្ថិភាពរបស់ពួកគេ គឺជាផ្នែកមួយក្នុងការកសាង និងពង្រឹងទំនុកចិត្តជាមួយ ភ្នាក់ងារសម្ងាត់ ។ ភ្នាក់ងារសម្ងាត់បំពេញការងារដ៏គ្រោះថ្នាក់ ដើម្បីប្រយោជន៍របស់អ្នក និងសង្គម ហើយមន្រ្តីស៊ើបអង្កេតគួរតែពិចារណាអំពីសុវត្ថិភាពរបស់ពួកគេ នៅពេលផ្តល់កិច្ចការឱ្យពួកគេធ្វើ ។

## សេចក្តីសង្ខេប

អ្នកផ្តល់ព័ត៌មានគឺជាមនុស្សសំខាន់ សម្រាប់មន្រ្តីស៊ើបអង្កេត និងជាធនធានដ៏មានតម្លៃដើម្បីទទួលព័ត៌មានអំពីសកម្មភាព និងបណ្តាញជនល្មើស កំណត់អំពីវិធីសាស្រ្តប្រតិបត្តិការរបស់ជនល្មើស កំណត់អំពីទីតាំងនៃសកម្មភាពល្មើស ធ្វើការស៊ើបអង្កេត ពង្រីកធនធានឃ្លាំមើល បញ្ជាក់ភាពសុក្រឹតនៃព័ត៌មាន និងអ្វីផ្សេងទៀត ។ ព័ត៌មានសម្ងាត់ទទួលបានពីប្រភពដែលគួរឱ្យទុកចិត្ត

អាចជួយឱ្យអ្នកជ្រៀតចូលកាន់តែជ្រៅថែមទៀត ទៅក្នុងមធ្យោបាយ បែបផែនឧបាយកលនៃបណ្តាញជនល្មើស ។ ការកសាងបណ្តាញអ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់ដែលអាចជ្រៀតចូលទៅក្នុងបណ្តាញរបស់ជនល្មើស ពិតជាសំខាន់ដល់ការស៊ើបអង្កេតបែបសកម្មជាមុនទៅលើអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ។ ដើម្បីកសាងអ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់ មន្ត្រីស៊ើបអង្កេតត្រូវ យល់អំពីការជំរុញទឹកចិត្តរបស់បុគ្គលម្នាក់ៗក្នុងកិច្ចសហការ បណ្តុះកម្រិតនៃការទុកចិត្ត និងយកឈ្នះទៅលើមនសិការ ។ បន្ថែមពីលើនេះទៀត មន្ត្រីស៊ើបអង្កេតត្រូវគ្រប់គ្រងអ្នកផ្តល់ព័ត៌មាន ឬភ្នាក់ងារសម្ងាត់ តាមរយៈការបណ្តុះបណ្តាល ការទំនាក់ទំនងជាប្រចាំ ការបញ្ជាក់ព័ត៌មាន និងការចងក្រងជាឯកសារនូវសកម្មភាពរបស់អ្នកផ្តល់ព័ត៌មាន ៕

៙៙៙ ✸ ៚៚៚

# ឯកសារយោង

- ការិយាល័យអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម
- សៀវភៅណែនាំអំពីការប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អ្នកធ្វើកិច្ចការយុត្តិធម៌
- ឯកសារមេរៀនរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ២០០៣


- Malinger, John. Confidential Informant: Law enforcement's most valuable tool. Boca Raton, FL. CRC Press, 1999.
- Bourg, Wendy et al; A Child Interviewer's Guidebook, Thousand Oaks, CA: Sage Publications, 1999
- Goodman, Gail; Bottoms, Bette; Child Victims, Child Witnesses: Understanding and Improving Testimony, New York, NY: The Guilford Press, 1993
- Mapes, Bruce; Child Eyewitness Testimony in Sexual Abuse Investigations, Brandon, VT: Clinical Psychology Publishing Co., 1995
- Milne, Rebecca; Bull, Ray; Investigative Interviewing: Psychology and Practice, Chichester, West Sussex, UK: John Wiley & Sons Press, 1999
- Morgan, Marcia; How to Interview Sexual Abuse Victims Including the Use Of Anatomical Dolls, Thousand Oaks, CA: Sage Publications, 1995
- Poole, Debra A; Investigative Interviews of Children: A Guide for Helping Professionals, Washington, DC: American Psychological Association, 1998
- Schafer, John; Navarro, Joe; Advanced Interviewing Techniques: Proven Strategies for Law Enforcement, Military, and Security Personnel, Springfield. IL: Thomas Books, 2003
- Shuy, Roger W.; The Language of Confession, Interrogation, and Deception, Thousand Oaks, CA: Sage Publications, 1998
- Swanson, Charles R. et al; Criminal Investigation, Boston, MA: McGraw Hill Publications, 2003, 8th edition
- Yeschke, Charles; The Art of Investigative Interviewing: A Human Approach to Testimonial Evidence, Boston, MA: Butterworth-Heinemann Press, 1997

MANUALS USED

- Faller, Kathleen C.; Child Sexual Abuse: Intervention and Treatment Issues, U.S. Department of Health and Human Services Administration for Children and Families, McLean, VA: The Circle, Inc, 1993
- Ministry of Interior, General Director of National Police, Kingdom of Cambodia; Understanding and Investigating Child Sexual Exploitation, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2000
- Ministry of Interior, General Director of National Police, Kingdom of Cambodia; Training Document on Child Victim Sensitivity, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2003
- Sas, Louise; The Interaction Between Children's Developmental Capabilities and the Courtroom Environment: The Impact on Testimonial Competency, Report prepared for the Department of Justice Canada, 2002

OTHER MATERIALS USED

- U. S. Department of State Trafficking in Persons Report, 2004

WEB SITES USED

- HTTP://www.childdevelopmentinfo.com/development/language_development.shtml
- HTTP://www.families.qld.gov.au/projectaxis/orgbooklet/development.html
- HTTP://danenet.wicip.org/dcccrsa/saissues/parent/1.html
- HTTP://www.aacap.org/publications/factsfam/develop.htm
- HTTP://www.secasa.com.au/index.php/family/12/120
- HTTP://www.earlychildhoodbehavioralhealth.com/ChildDev/sexdevelop.htl
- HTTP://www.ces.perdue.edu/providerparent/Child%20Growth-Development/SexualDEV.htm
- HTTP://www.state.gov/g/tip/rls/tiprpt/2004/34021pf.htm

USAID
ជំនួយពីពលរដ្ឋអាមេរិក

WINROCK INTERNATIONAL

IJM

# បណ្ឌិត្យសភានគរបាលកម្ពុជា

## កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ

# ការគ្រប់គ្រង
# សាក្សី និងដំណើរការសវនាការ

២០១៧

សូមរក្សាសិទ្ធិ

មេរៀននេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការវីនរ៉ក់ ឬរដ្ឋាភិបាលអាមេរិក

# ការគ្រប់គ្រងសាក្សី និងដំណើរការសវនាការ

## I. សេចក្តីផ្តើម

ការភ័យខ្លាចរបស់ជនរងគ្រោះ និងសាក្សី ធ្វើឱ្យមានឧបសគ្គដល់ដំណើរការនៃប្រព័ន្ធយុត្តិធម៌ ដោយសារមិនសហការក្នុងការផ្តល់ភស្តុតាងសំខាន់ៗ ដល់មន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញា ។ បញ្ហានេះអាចធ្វើឱ្យបាត់បង់ការជឿជាក់លើសមត្ថភាពរបស់ប្រព័ន្ធយុត្តិធម៌ ដើម្បីការពារប្រជាពលរដ្ឋ ។ ការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា គ្រប់ករណីនៃការបំភិតបំភ័យសាក្សី អាចត្រូវបានចាត់ចូលក្នុងដែនវិសាលភាពនៃទម្រង់ទាំងបី ដែលទាក់ទងនឹងភាពធ្ងន់ធ្ងរនៃការបំភិតបំភ័យគឺ ៖

- ស្នូលខាងក្នុង រួមមាន បុគ្គលផ្ទាល់ខ្លួន និងក្រុមគ្រួសារ ដែលកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ និងការបំភិតបំភ័យដល់ជីវិត ទាក់ទងនឹងការស៊ើបអង្កេតទៅលើឧក្រិដ្ឋជន
- ផ្នែកកណ្តាល រួមមាន ជនរងគ្រោះ និងសាក្សី ត្រូវបានបំភិតបំភ័យក្នុងការផ្តល់ភស្តុតាង។ ប៉ុន្តែការគំរាមកំហែងនេះ គឺមិនមែនជាការបំភិតបំភ័យដល់ជីវិតទេ
- ផ្នែកខាងក្រៅ រួមមាន សាធារណជនដែលយល់ដឹងច្បាស់ ពីលទ្ធភាពនៃការបំភិតបំភ័យ ធ្វើឱ្យពួកគេមិនបានត្រៀមខ្លួនដើម្បីផ្តល់ភស្តុតាង ។

ជាធម្មតា ការបំភិតបំភ័យជនរងគ្រោះ និងសាក្សី ពាក់ព័ន្ធនឹងករណីក្រុមឧក្រិដ្ឋជនមានរចនាសម្ព័ន្ធចាត់តាំង និងករណីនៃអំពើហិង្សាក្នុងគ្រួសារ ។ ប៉ុន្តែ រូបភាពនៃការបំភិតបំភ័យ កំពុងវិវត្តនូវចរិតលក្ខណៈថ្មីៗ ដោយសារឧក្រិដ្ឋកម្មហិង្សាដែលពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជនកាន់តែកើនឡើង ។

ការបំភិតបំភ័យត្រូវបានកំណត់លក្ខណៈដូចខាងក្រោម ៖

- លក្ខណៈជាក់លាក់ ៖ ការគំរាមកំហែង ឬអំពើហិង្សាដែលប៉ុនប៉ងរារាំងជនរងគ្រោះ ឬសាក្សីមិនឱ្យធ្វើបន្ទាល់ក្នុងរឿងក្តីជាក់លាក់ណាមួយ
- លក្ខណៈទូទៅ ៖ សកម្មភាពល្មើសធ្វើដោយចំហ នៃក្រុមឧក្រិដ្ឋជន ឬក្រុមជួញដូរគ្រឿងញៀន ដែលប៉ុនប៉ងបង្កភាពភ័យខ្លាច និងមិនសហការជាមួយសហគមន៍ ។

### ១. ការគ្រប់គ្រង និងការការពារសាក្សី

ការរក្សាសុវត្ថិភាព និងការសហការជាមួយសាក្សី គឺចាប់ផ្តើមតាំងពីពេលដែលសាក្សីបានឆ្លើយបំភ្លឺលើកដំបូង រហូតដល់ពេលបើកសវនាការ និងនៅពេលបន្ទាប់មកទៀត ហើយនេះគឺជាភារកិច្ចដ៏សំខាន់របស់មន្ត្រីនគរបាលស៊ើបអង្កេត ។

បញ្ហានេះ មានការលំបាកក្នុងការវាយតម្លៃពីហានីភ័យ ដែលកើតមានចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលយល់ព្រមផ្តល់ការឆ្លើយបំភ្លឺ គំរាមដល់សេរីភាពរបស់ជនជួញដូរ ដូច្នេះ ហានីភ័យគឺមានកម្រិតខ្ពស់ ដោយសារតែអាចកើតមានការសងសឹកមកលើជនរងគ្រោះ ឬអ្នកដែលខ្លួនស្រឡាញ់ ។ បទពិសោធន៍កន្លងមក បានបង្ហាញឱ្យឃើញថា ជនជួញដូរ ហាក់បង្កើននូវឧបាយកលផ្សេងៗរបស់ខ្លួន ដើម្បីទប់ស្កាត់មិនឱ្យសាក្សី ផ្តល់ចម្លើយប្រឆាំងនឹងខ្លួន ។ ឧបាយកលទាំងនេះ ផ្តើមចេញពីការគំរាមកំហែងក្នុងកម្រិតទាបបំផុត ដូចជាការហៅតាមទូរស័ព្ទ (ណែនាំ) ជន

រងគ្រោះ ឬគ្រួសារជនរងគ្រោះថា ការឆ្លើយបំភ្លឺមិននាំមកនូវផលល្អនោះទេ ។

ដូច្នេះហើយអាទិភាពដំបូងរបស់មន្ត្រីនគរបាលស៊ើបអង្កេត គឺការគិតគូរដល់សន្តិសុខរបស់សាក្សី បើអាចធ្វើទៅបាន យកល្អត្រូវពិនិត្យមើល ថាតើសាក្សីទទួលបានការការពារដែរឬទេ ។

**២. ដំណើរការសវនាការ**

ដំណើរការសវនាការ ទាមទារឱ្យមន្ត្រីនគរបាលស៊ើបអង្កេតយកចិត្តទុកដាក់ដូចខាងក្រោម៖

- ការចូលរួមសវនាការ និងការផ្តល់ភស្តុតាង គឺជាផ្នែកមួយដែលលំបាកស្មុគស្មាញបំផុតសម្រាប់សាក្សី ដែលជាជនរងគ្រោះ
- វាជាបំណងប្រាថ្នាតែមួយគត់ ដែលមន្ត្រីនគរបាលស៊ើបអង្កេតត្រូវប្រើប្រាស់តាមគ្រប់វិធីសាស្ត្រទាំងអស់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដល់ជនរងគ្រោះ ។

ទំហំដែលអាចសម្រេចគោលដៅនេះបាន គឺត្រូវពឹងផ្អែកទាំងស្រុងលើកត្តាសំខាន់ពីរគឺ ៖

- សាក្សី ត្រូវផ្តល់ចម្លើយតាមបទបញ្ញត្តិ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- សមត្ថភាពរបស់មន្ត្រីនគរបាលស៊ើបអង្កេត ក្នុងការចាត់វិធានការចាំបាច់មួយចំនួនដើម្បីកាត់បន្ថយគ្រោះថ្នាក់ចំពោះការផ្តល់ភស្តុតាងនៅតុលាការ ។

ប្រការសំខាន់នោះ គឺការទទួលខុសត្រូវពីសុវត្ថិភាព និងសុខុមាលភាពរបស់សាក្សី នៅក្រោយពេលសវនាការដែលមិនទាន់ចប់ភ្លាមៗនៅឡើយ ។ ក្នុងករណីភាគច្រើន គឺទាមទារឱ្យជនរងគ្រោះមានសេចក្តីក្លាហានក្នុងការផ្តល់ភស្តុតាង ដែលមានគ្រោះថ្នាក់ខ្លាំង ។ ដើម្បីធ្វើដូច្នេះបាន គឺទាមទារឱ្យមន្ត្រីនគរបាលស៊ើបអង្កេត ធានាការពារជនរងគ្រោះ ។

## II. សង្ខេបពីភាតព្វកិច្ចអន្តរជាតិ ស្តីពីសុវត្ថិភាព និងសុខុមាលភាពរបស់សាក្សី

### ១. គោលការណ៍សង្ខេបពីភាតព្វកិច្ចអន្តរជាតិ

- ដោយមានការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ត្រូវធានាសុវត្ថិភាព និងកន្លែងស្នាក់នៅតាមសេចក្តីត្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមដែលអាចធ្វើបាន ។ មិនត្រូវដាក់ជនរងគ្រោះនៅក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ មន្ទីរឃុំឃាំង ឬមណ្ឌលជនអានាថា
- ក្នុងភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល ត្រូវធានាផ្តល់ឱ្យមានការថែទាំសុខភាព និងការប្រឹក្សាយោបល់ចាំបាច់ផ្សេងៗ ដល់ជនរងគ្រោះ
- ត្រូវធានាថា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស បានទទួលការណែនាំពីសិទ្ធិចូលជួបតំណាងស្ថានទូត ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួន
- ត្រូវធានាថា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អាចចូលរួមក្នុងដំណើរការតាមផ្លូវច្បាប់ និងមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ សេចក្តីថ្លៃថ្នូរ ឬសុខុមាលភាពខាងផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ
- ត្រូវផ្តល់ឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្ស នូវជំនួយផ្នែកច្បាប់ និងជំនួយផ្សេងទៀតទាក់ទងនឹងបណ្តឹងអាជ្ញា បណ្តឹងរដ្ឋប្បវេណី និងបណ្តឹងផ្សេងៗទៀត ប្រឆាំងនឹងជនជួញដូរ

មនុស្ស ឬអាជីវកម្មផ្លូវភេទ ។ ត្រូវផ្តល់ព័ត៌មានឱ្យជនរងគ្រោះ តាមភាសាដែលពួកគេអាចយល់បាន

• ត្រូវធានាថា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចាកផុតពីគ្រោះថ្នាក់ ការគំរាមកំហែង ឬការបំភិតបំភ័យ ពីជនជួញដូរ ឬបក្សពួកជនជួញដូរ ។ ទីបញ្ចប់ មិនត្រូវលាតត្រដាងជាសាធារណៈ ពីអត្តសញ្ញាណរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ហើយត្រូវគោរព និងការពារសិទ្ធិឯកជនរបស់ជនរងគ្រោះ តាមដែលអាចធ្វើបាន ។ ទន្ទឹមគ្នានេះដែរ ត្រូវគោរពសិទ្ធិរបស់ជនជាប់ចោទនៅពេលសវនាការប្រកបដោយយុត្តិធម៌

• ត្រូវប្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សជាមុន អំពីការលំបាកក្នុងការរក្សាអត្តសញ្ញាណរបស់ពួកគេ ហើយមិនត្រូវផ្តល់សេចក្តីសង្ឃឹមក្លែងក្លាយ ឬមិនពិតអំពីសមត្ថភាពរបស់ស្ថាប័នអនុវត្តច្បាប់ក្នុងបញ្ហានេះឡើយ

• ត្រូវធានាសុវត្ថិភាព ចំពោះការវិលត្រឡប់ទៅប្រទេសដើមវិញ ដោយស្ម័គ្រចិត្តរបស់ជនរងគ្រោះ និងការស្វែងរកជម្រើសសម្រាប់ការស្នាក់នៅក្នុងប្រទេសគោលដៅចុងក្រោយ ឬការតាំងទីលំនៅថ្មី នៅប្រទេសទីបី ក្នុងកាលៈទេសៈជាក់លាក់មួយចំនួន ប្រសិនបើអាចធ្វើទៅបាន ( ឧទាហរណ៍ ដើម្បីទប់ស្កាត់ការសងសឹក ឬត្រូវបានគេយកទៅជួញដូរជាថ្មី )

• ក្នុងភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល ត្រូវធានាថា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលវិលត្រឡប់មកប្រទេសដើមរបស់ខ្លួនវិញ ត្រូវផ្តល់ជំនួយ និងការជួយឧបត្ថម្ភគាំទ្រជាចាំបាច់ ដើម្បីធានាដល់សុខុមាលភាពរបស់ពួកគេ និងសម្រួលដល់ការចូលទៅរួមរស់ក្នុងសង្គមជាតិឡើងវិញ ហើយនិងការទប់ស្កាត់កុំឱ្យមានការជួញដូរជាថ្មី

• ត្រូវចាត់វិធានការផ្សេងៗ ដើម្បីធានាឱ្យមានការផ្តល់កិច្ចគាំពារសុខភាពផ្លូវកាយ និងផ្លូវចិត្ត កន្លែងស្នាក់នៅ សេវាការងារ និងការអប់រំសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលវិលត្រឡប់មកប្រទេសខ្លួនវិញ ។ (ប្រភព៖ គោលការណ៍ និងគោលការណ៍ណែនាំ)

### ២. ស្តង់ដារអាស៊ាន-គោលការណ៍ណែនាំអាស៊ានសម្រាប់អ្នកអនុវត្តផ្ទាល់

• ព្រះរាជអាជ្ញា និងមន្ត្រីនគរបាលស៊ើបអង្កេត ត្រូវធ្វើការឱ្យបានជិតស្និទ្ធ ដើម្បីធ្វើឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្ស យល់ព្រមសហការធ្វើជាសាក្សី ក្នុងនាមខ្លួនជាជនរងគ្រោះ ព្រមទាំងផ្តល់នូវកំណត់ហេតុដែលជាភស្តុតាង

• តាមលទ្ធភាពដែលអាចធ្វើទៅបាន ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនត្រូវធ្វើការចោទប្រកាន់ ឬផ្តន្ទាទោស ដោយសារតែពួកគេជាប់ទាក់ទិនក្នុងការប្រព្រឹត្តបទល្មើស ដោយខ្លួនឯងផ្ទាល់ ដោយសារតែផលវិបាកដោយផ្ទាល់ពីអំពើជួញដូរ

• ត្រូវផ្តល់ឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានកិច្ចការពារ និងមណ្ឌលស្នាក់នៅ យ៉ាងឆាប់រហ័ស ដូចមានចែងដោយច្បាប់ក្នុងស្រុក

• ត្រូវមានបញ្ញត្តិរដ្ឋបាល និង/ឬ បញ្ញត្តិច្បាប់ ឱ្យបានត្រឹមត្រូវ ដើម្បីផ្តល់លទ្ធភាព ឱ្យជនរងគ្រោះជាសាក្សីដែលបានយល់ព្រមសហការ បានបន្តស្នាក់នៅប្រទេសគោលដៅ ក្នុងគោលបំណងជួយដល់ការស៊ើបអង្កេត និង/ឬ ផ្តល់ភស្តុតាង នៅក្នុងនីតិវិធីរឿងក្តីព្រហ្មទណ្ឌ

• ព្រះរាជអាជ្ញាជំនាញ និងទីភ្នាក់ងារគាំពារជនរងគ្រោះ ត្រូវរួមសហប្រតិបត្តិការគ្នា ដើម្បីគាំទ្រដល់ជនរងគ្រោះ ឱ្យបានចប់ចុងចប់ដើម ក្នុងពេលពួកគេចូលរួមនៅក្នុងនីតិវិធីរឿងក្ដីព្រហ្មទណ្ឌ

• ត្រូវគោរពដល់ជីវិតឯកជនរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងត្រូវរក្សាការសម្ងាត់នូវលក្ខណៈពិសេសផ្ទាល់ខ្លួនរបស់ពួកគេ ទៅតាមកម្រិតដែលច្បាប់បានចែង

• តាមលទ្ធភាពដែលអាចធ្វើទៅបាន ត្រូវធ្វើការខិតខំ ដើម្បីពន្លឿនចំណាត់ការរឿងក្ដីព្រហ្មទណ្ឌ នៅក្នុងករណីរឿងក្ដីជួញដូរមនុស្ស ដើម្បីកាត់បន្ថយនូវភាពតានតឹង និងសម្ពាធដែលជនរងគ្រោះ កំពុងតែទទួលរង ក្នុងខណៈពួកគេត្រូវទន្ទឹងរង់ចាំរយៈពេលយូរ ដើម្បីផ្ដល់ភស្ដុតាងនៅឯសវនាការជំនុំជម្រះ ។ (ផ្នែក-គ-ការគ្រប់គ្រងជនរងគ្រោះដែលធ្វើជាសាក្សី) ។

**៣. ការការពារសាក្សី**

ការការពារសាក្សីបានឆ្លុះបញ្ចាំងលើហេតុការណ៍ពិតជាក់ស្ដែងមួយចំនួន ។ ក្នុងករណីខ្លះ វាមិនអាច ឬមិនចាំបាច់ក្នុងការចាត់វិធានការការពារសាក្សីនោះទេ ។ នៅតំបន់ខ្លះ មិនមានកម្មវិធីការពារជនរងគ្រោះឱ្យបានពេញលេញតាមការចាំបាច់ នោះទេ ។

ម៉្យាងវិញទៀត ទោះជាមានវិធានការការពារហើយក៏ដោយ ក៏សាក្សីអាចមិនយល់ស្របតាមវិធានការនោះដែរ ។ ការការពារសាក្សី ទាមទារឱ្យអនុវត្តតាមការណែនាំ ដែលជាបរិយាកាសត្រឹមត្រូវសម្រាប់សាក្សី ដែលពេលខ្លះពួកគេមិនបានត្រៀមខ្លួនដើម្បីទទួលយកវិធានការនោះទេ ។

មានលទ្ធភាពពីរយ៉ាង សម្រាប់ការរៀបចំឱ្យមានការការពារសាក្សី ដែលអាចប្រើប្រាស់ក្នុងការស៊ើបអង្កេតករណីជួញដូរមនុស្ស ៖

• ការការពារសាក្សី ធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច

• ការការពារសាក្សី ធ្វើឡើងដោយសហប្រតិបត្តិការរវាងមន្ត្រីនគរបាលស៊ើបអង្កេត និងអង្គការ ឬស្ថាប័ននានាដែលជួយជនរងគ្រោះ ដើម្បីផ្ដល់សុវត្ថិភាព ការគាំពារ និងការជួយឧបត្ថម្ភ ។

នៅក្នុងករណីភាគច្រើន សាក្សីត្រូវការជំនួយពីគ្រូពេទ្យឯកទេស និងគ្រូពេទ្យចិត្តសាស្ត្រ ជាធម្មតាកម្មវិធីការពារជនរងគ្រោះរបស់ស្ថាប័នអនុវត្តច្បាប់ មិនអាចផ្ដល់កិច្ចគាំពារបានទាន់ពេលវេលានោះទេ ។

នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ វិធានការការពារ និងគាំពារដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អាចឆ្លើយតបដោយរដ្ឋាភិបាល ឬដោយអង្គការក្រៅរដ្ឋាភិបាលដែលគាំពារជនរងគ្រោះ ។ ទោះបីជាប្រភេទណាក៏ដោយ មន្ត្រីនគរបាលស៊ើបអង្កេតគួរអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

• សុវត្ថិភាពរបស់សាក្សី ក្រុមគ្រួសារជនរងគ្រោះ ឬអ្នកដែលជាទីស្រឡាញ់ គឺពឹងផ្អែកលើមន្ត្រីនគរបាលស៊ើបអង្កេត គ្រប់ពេលវេលា ប្រសិនបើអាច

• អាស្រ័យលើកាលៈទេសៈនៅថ្នាក់មូលដ្ឋាន បញ្ហាសន្តិសុខ និងសុវត្ថិភាពប្រចាំថ្ងៃដែលអាចកើតមានចំពោះបុគ្គលិកដែលបម្រើការនៅក្នុងអង្គការ ឬស្ថាប័នជួយជនរងគ្រោះ ក្នុងការផ្ដល់កន្លែងស្នាក់នៅ និងជំនួយផ្សេងទៀតដល់ជនរងគ្រោះ ប៉ុន្តែការងារនេះ នៅតែស្ថិតក្រោមការទទួលខុសត្រូវរបស់មន្ត្រីនគរបាលស៊ើបអង្កេត ក្នុងការពិនិត្យនូវវិធានការធានាសន្តិសុខ និងសុវត្ថិភាពដើម្បី

ការពារសាក្សី និងឆ្លុះបញ្ចាំងពីការវាយតម្លៃ នៃកម្រិតគ្រោះថ្នាក់ ដែលអាចកើតឡើងចំពោះជនរងគ្រោះ បើពុំនោះទេ ត្រូវពិចារណាឡើងវិញ ពីការសម្រេចឱ្យជនរងគ្រោះធ្វើជាសាក្សី

- តាមសភាពជាក់ស្តែង នៅទូទាំងពិភពលោក មានករណីតិចតួច ដែលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានកិច្ចការពារពីកម្មវិធីការពារសាក្សីដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ។

## ៤. ការពិនិត្យវាយតម្លៃពីហានិភ័យដែលអាចកើតឡើង

### ក. សេចក្តីសង្ខេបពីកិច្ចការពារសាក្សីសំខាន់




### ខ. កំណត់សម្គាល់នូវចំណុចគន្លឹះនៃការអនុវត្តល្អៗ

- ហានិភ័យកើនឡើង ៖ នៅពេលដែលជនរងគ្រោះសម្រេចចិត្តធ្វើជាសាក្សី ពេលនោះ គ្រោះថ្នាក់ថ្មីនឹងបន្ថែមលើគ្រោះថ្នាក់ចាស់ ហើយអ្វីដែលសំខាន់សម្រាប់កិច្ចដំណើរការនេះ គឺការវាយតម្លៃពីគ្រោះថ្នាក់ថ្មី ដែលត្រូវធ្វើភ្លាមៗ ដើម្បីដោះស្រាយគ្រោះថ្នាក់ចាស់នោះ ។ ជាការសំខាន់ណាស់ ត្រូវកំណត់ពីវិធានការការពារដ៏សមស្រប និងចាំបាច់សម្រាប់កិច្ចដំណើរការវាយតម្លៃ ពីគ្រោះថ្នាក់ ដែលមិនត្រូវអូសបន្លាយពេលវេលាឡើយ
- ការវាយតម្លៃពីហានិភ័យជាក់ស្តែង ៖ ការវាយតម្លៃពីគ្រោះថ្នាក់ ត្រូវតែជាក់ស្តែងទាំងស្រុងអំពីលទ្ធភាពពិតប្រាកដក្នុងការអនុវត្តវិធានការទាំងនេះ ។ ការផ្តល់កិច្ចការពារដល់សាក្សី ទោះជា

ក្នុងកម្រិតណាក៏ដោយ ក៏ជាការងារមួយដែលត្រូវចំណាយថវិកាច្រើន ហើយវិធានការដែលបានដាក់ចេញនោះ ទំនងជាមិនអាចធ្វើបាន ។ ប្រការសំខាន់ គឺត្រូវវាយតម្លៃពីគ្រោះថ្នាក់ជាក់ស្តែងចំពោះជនរងគ្រោះ ការធ្វើដូច្នេះអាចឱ្យជនរងគ្រោះដឹងច្បាស់ពីសភាពការណ៍នេះ នៅមុនពេលដែលខ្លួនសម្រេចចិត្តផ្តល់កិច្ចសហការ

- ការពិភាក្សាជាមួយជនរងគ្រោះ ៖ ទោះជាការចាត់វិធានការធ្វើឡើងតាមបែបណាក៏ដោយ ត្រូវពិគ្រោះយោបល់ជាមួយជនរងគ្រោះ ព្រោះពួកគេអាចមិនទទួលយកនូវវិធានការនោះទេ ។ ជនរងគ្រោះខ្លះអាចគ្រាន់តែស្នើសុំឱ្យជួយផ្តល់មធ្យោបាយទំនាក់ទំនងបន្ទាន់ណាមួយ ដូចជាទូរស័ព្ទដៃ និងឧបករណ៍សម្រាប់ប្រកាសភាពអាសន្នផ្ទាល់ខ្លួន និងលេខទូរស័ព្ទសម្រាប់ទំនាក់ទំនងក្នុងករណីបន្ទាន់រយៈពេល ២៤ម៉ោង ពីព្រោះពួកគេមិនចង់ស្ថិតក្រោមការគ្រប់គ្រងពីមន្ត្រីនគរបាល ទោះបីជាមន្ត្រីនគរបាលនោះត្រូវគេចាត់ឱ្យការពារសុវត្ថិភាពខ្លួនក៏ដោយ
- ការពន្យល់ប្រាប់សាក្សី ៖ តាមការអនុវត្តដ៏ប្រសើរបំផុតនោះ គឺត្រូវពន្យល់ប្រាប់សាក្សីដោយផ្ទាល់មាត់ ឬជាលាយលក្ខអក្សរអំពីវិធានការការពារសាក្សីដែលមាន ឬដែលមិនមាន ។ នេះគឺជាភារកិច្ចមួយផ្នែកក្នុងការផ្តល់ឱ្យជនរងគ្រោះបានដឹង មុននឹងយល់ព្រមផ្តល់កិច្ចសហការ
- ផ្តល់ការណែនាំសំខាន់ៗផ្នែកសន្តិសុខ ៖ ត្រូវធ្វើការណែនាំពីបញ្ហាសំខាន់ៗ ស្តីពីសន្តិសុខរបស់សាក្សីដែលជាជនរងគ្រោះ ទាក់ទងនឹងសកម្មភាពរបស់សាក្សីនៅមុនពេលសវនាការ ដូចជាជនណាខ្លះដែលសាក្សីមិនត្រូវជួប និងមិនត្រូវទំនាក់ទំនង ទីកន្លែងណាខ្លះដែលគាត់មិនត្រូវទៅ... ។ ការណែនាំប្រភេទនេះមានហានិភ័យខ្លាំងណាស់ ក្នុងករណីដែលគ្រួសារជនរងគ្រោះបានសមគំនិតនៅក្នុងបទល្មើសជួញដូរមនុស្ស
- ករណីជួញដូរផ្លូវភេទ ៖ ការណែនាំមិនឱ្យជនរងគ្រោះចូលរួមក្នុងសកម្មភាពពេស្យាចារជាថ្មី ។ តាមបទពិសោធន៍ថ្មីៗនេះបានបង្ហាញឱ្យឃើញថា មានករណីជួញដូរផ្លូវភេទមួយចំនួន លុះក្រោយមក ជនរងគ្រោះបានស្ម័គ្រចិត្តវិលត្រឡប់ទៅប្រកបមុខរបរពេស្យាកម្មជាថ្មី បញ្ហានេះនាំឱ្យមានផលវិបាកធ្ងន់ធ្ងរដល់សុវត្ថិភាព និងការជឿទុកចិត្តរបស់ពួកគេ ជាសាក្សីនៅក្នុងសវនាការ
- គោលការណ៍ណែនាំសម្រាប់តែករណីជួញផ្លូវភេទ ៖ គួរធ្វើការណែនាំដល់ជនរងគ្រោះអំពីផលវិបាកជាអវិជ្ជមានដល់សុវត្ថិភាព និងការស៊ើបអង្កេត ដោយសារជនរងគ្រោះមានការពាក់ព័ន្ធក្នុងសកម្មភាពពេស្យាចារ ។ គ្រោះថ្នាក់នេះអាចកើតឡើង ដូច្នេះ មន្ត្រីនគរបាលស៊ើបអង្កេតគួរផ្តួចផ្តើមគំនិត និងណែនាំដល់ជនរងគ្រោះតាំងពីដំបូង ពីផលវិបាកនៃការវិលត្រឡប់ទៅប្រកបមុខរបរពេស្យាកម្មជាថ្មី ដែលនាំឱ្យប៉ះពាល់ដល់កិច្ចដំណើរការស៊ើបអង្កេត ។

### គ. កិច្ចសហការរវាងស្ថាប័នអនុវត្តច្បាប់ និងទីភ្នាក់ងារគាំពារជនរងគ្រោះ

- គួរចងចាំថា គោលការណ៍ដែលបានពិចារណានៅទីនេះ អាចធ្វើបានតែជាមួយអង្គការ ឬស្ថាប័នជួយជនរងគ្រោះណាមួយ ដែលផ្តល់កន្លែងស្នាក់នៅ និង/ឬជួយសាក្សី ដោយមិនគិតថាស្ថាប័ននេះជាស្ថាប័នរដ្ឋ ឬជាអង្គការក្រៅរដ្ឋាភិបាលឡើយ

• មន្ត្រីនគរបាលស៊ើបអង្កេត ត្រូវទទួលស្គាល់តម្លៃនៃភាពជាដៃគូ ជាមួយអង្គការជួយជនរងគ្រោះនានា ក្នុងការរក្សាសន្តិសុខ និងជួយដល់សាក្សី ។ ទីភ្នាក់ងារនានាដែលជួយជនរងគ្រោះអាចផ្តល់កិច្ចគាំពារផ្នែកសុខភាព និងសុខុមាលភាពដល់ជនរងគ្រោះ ហើយត្រូវសហការគ្នាទាំងក្នុងពេល និងក្រោយពេលជំនុំជម្រះ ដែលជាការអនុវត្តដ៏ប្រសើរបំផុត ។

**ឃ. ការវាយតម្លៃពីហានិភ័យនៃការផ្តល់កន្លែងស្នាក់នៅដល់សាក្សី**

• ដូចបានបញ្ជាក់រួចហើយ ត្រូវធ្វើការវាយតម្លៃជាបន្ទាន់ នៅពេលដែលជនរងគ្រោះក្លាយជាសាក្សី ដែលកម្រិតនៃគ្រោះថ្នាក់បានកើនឡើងថែមទៀត

• ប្រសិនបើ សាក្សីស្នាក់នៅក្នុងមណ្ឌលរបស់អង្គការជួយជនរងគ្រោះ កិច្ចដំណើរការវាយតម្លៃពីហានិភ័យ កាន់តែមានភាពស្មុគ្រស្មាញខ្លាំងថែមទៀត ពីព្រោះពួកគេត្រូវយកចិត្តទុកដាក់មិនត្រឹមតែជនរងគ្រោះផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគិតពីសន្តិសុខរបស់ជនរងគ្រោះដទៃទៀត ដែលរស់នៅជាមួយគ្នា និងបុគ្គលិកជំនួយការរបស់អង្គការផ្សេងទៀត

• ការវាយតម្លៃត្រូវពិចារណាលើកត្តាមួយចំនួន

  ◦ ហានិភ័យជាក់លាក់ទាក់ទងនឹងជនរងគ្រោះជាសាក្សី គឺអាយុ ប្រវត្តិគ្រួសារ ភាពបត់បែន សមត្ថភាពក្នុងការគោរពតាមការណែនាំ ពីសុវត្ថិភាព ។ល។

  ◦ ហានិភ័យអាចកើតឡើងចំពោះគ្រួសារជនរងគ្រោះ ឬអ្នកដែលជាទីស្រឡាញ់

  ◦ ហានិភ័យដែលបានបង្កឡើងដោយអ្នកដែលគេសង្ស័យថា ជាជនជួញដូរ - តើមានព័ត៌មាន ឬភស្តុតាងទាក់ទិននឹងការប្រើប្រាស់ ឬការគំរាមសងសឹកក្នុងរយៈពេលកន្លងមកដែរឬទេ...។

ក្រៅពីហានិភ័យទាំងបីខាងលើ តើអាចមានហានិភ័យផ្សេងទៀតកើតឡើងដល់ជនរងគ្រោះដទៃទៀត កន្លែងស្នាក់នៅ ឬបុគ្គលិករបស់មណ្ឌលថែទាំដែរឬទេ ។

• នៅពេលដែលបានកំណត់សម្គាល់ និងវាយតម្លៃពីគ្រោះថ្នាក់រួចហើយ ដំណាក់កាលបន្ទាប់ គឺមន្ត្រីនគរបាលស៊ើបអង្កេត និងបុគ្គលិកអង្គការគាំពារ ត្រូវកំណត់ និងព្រមព្រៀងលើវិធានការការពារដែលអាចមាន និងចាំបាច់សម្រាប់គ្រប់គ្រងហានិភ័យ

• គេមិនអាចគ្រប់គ្រងលើការផ្លាស់ប្តូរទាំងអស់បានទេ ប៉ុន្តែ វាអាចមានសារៈសំខាន់សម្រាប់អង្គការនានា ក្នុងការផ្ទេរជនរងគ្រោះឱ្យទៅកាន់កន្លែងស្នាក់នៅថ្មីមួយទៀត ដើម្បីការពារដល់ជនរងគ្រោះដទៃទៀត ។ ប្រសិនបើបញ្ហានេះកើតឡើង ហើយស្ថិតក្នុងកាលៈទេសៈនៃករណីនីមួយៗ ដែលស្ថាប័នអនុវត្តច្បាប់អាចត្រូវការឱ្យមានការផ្តល់សន្តិសុខដល់ជនរងគ្រោះនៅកន្លែងថ្មី

• ក្នុងករណីធ្ងន់ធ្ងរ ចាំបាច់ត្រូវពិនិត្យពីលទ្ធភាពសម្រាប់ផ្ទេរជនរងគ្រោះ ទៅកាន់អាសយដ្ឋានមួយដែលស្ថិតនៅក្រៅប្រទេស ដើម្បីធានាសុវត្ថិភាពរបស់ជនរងគ្រោះ កន្លែងស្នាក់នៅផ្សេងទៀត ឬសមាជិកគ្រួសារ និងបុគ្គលិករបស់អង្គការ

• ត្រូវមានការព្រមព្រៀងគ្នាលើវិធានការចាំបាច់មួយចំនួន រវាងមន្ត្រីនគរបាលស៊ើបអង្កេត និងអ្នកគ្រប់គ្រងកន្លែងស្នាក់នៅ ក៏ប៉ុន្តែមានបញ្ញត្តិមួយសំខាន់ជាងគេបំផុតគឺៈ

  ◦ ប្រសិនជាការចាំបាច់ សម្រាប់ជនរងគ្រោះត្រូវនៅក្នុងការគ្រប់គ្រងរបស់អង្គការជួយ

ជនរងគ្រោះ ហើយអង្គការនេះមិនអាចចាត់វិធានការការពារ ឱ្យមានសុវត្ថិភាពលើគ្រោះថ្នាក់ដែលអាចកើតឡើង មន្ត្រីនគរបាលស៊ើបអង្កេតត្រូវតែផ្តើមធ្វើការវាយតម្លៃភ្លាមពីគ្រោះថ្នាក់ថ្មី ថាតើអាចអនុញ្ញាតឱ្យជនរងគ្រោះ បន្តសហការ ក្នុងនាមជាសាក្សីតទៅទៀតដែរឬទេ

○ មន្ត្រីនគរបាលស៊ើបអង្កេតត្រូវចងចាំពីការទទួលខុសត្រូវដ៏ចម្បង ដែលត្រូវរក្សាសុវត្ថិភាពដល់សាក្សី ។

**ង. បញ្ហាសុវត្ថិភាព និងសុខុមាលភាព**

ទោះជាការធ្វើសេចក្តីសម្រេច ឬការចាត់វិធានការអ្វីក៏ដោយ ដើម្បីដោះស្រាយអំពីសុវត្ថិភាព និងសុខុមាលភាពរបស់សាក្សី នៅមុនពេលសវនាការ និងក្រោយពេលសវនាការ សំខាន់គឺ មន្ត្រីនគរបាលស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុលម្អិត និងច្បាស់លាស់ ដូចខាងក្រោម ៖

- រាល់កិច្ចដំណើរការវាយតម្លៃពីហានិភ័យ ធ្វើឡើងសម្រាប់សាក្សី
- ការរៀបរាប់លម្អិតពីកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដូចជាព័ត៌មានអ្វីខ្លះ ដែលមាននៅពេលធ្វើសេចក្តីសម្រេច ការព្រួយបារម្ភធំៗ ជម្រើស...
- ការរៀបរាប់លម្អិតពីទំនាក់ទំនងជាមួយសាក្សី រួមមាន កាលបរិច្ឆេទ ពេលវេលា ទីកន្លែង បុគ្គលដែលមានវត្តមាន មូលហេតុនៃការពាក់ព័ន្ធ បរិយាយពីសេចក្តីណែនាំ ឬការផ្តល់ដំបូន្មានដល់សាក្សី ។

ការបញ្ជាក់ពីមូលហេតុសម្រាប់ការរៀបចំរបាយការណ៍នេះ ត្រូវមានភាពសាមញ្ញ តាមវិធីដែលអាចធ្វើទៅបាន មន្ត្រីនគរបាលស៊ើបអង្កេតអាជីពមានតួនាទី ត្រូវឆ្លើយសំណួរផ្លូវច្បាប់ចំពោះចំពោះការពាក់ព័ន្ធរវាងមន្ត្រីនគរបាល និងសាក្សី ។

## ៥. កិច្ចដំណើរការសវនាការ

### ក. សេចក្តីសង្ខេបពីភារកិច្ចសំខាន់

**ភារកិច្ចសំខាន់ៗ**

- មិនត្រូវភ្លេច-សេចក្តីភ័យខ្លាចសំខាន់ៗរៀងរាល់ថ្ងៃរបស់ជនរងគ្រោះជាសាក្សី
  ការទៅតុលាការ ភាពខ្មាស់អៀន ភាពអសោចន៍ ការមើលឃើញ និងត្រូវបានមើលឃើញដោយជនបំពានមកលើខ្លួន
- កាត់បន្ថយភាពភ័យខ្លាចពីការផ្តល់ចម្លើយសាក្សី និងជនមិនស្គាល់មុខ
  ត្រូវពិគ្រោះជាមួយជនរងគ្រោះ-ផ្តល់ព័ត៌មានលម្អិត-មានភាពបើកចំហ និងស្មោះត្រង់គ្រប់ពេល
- ចងចាំពីផលប៉ះពាល់ខាងជំងឺផ្លូវអារម្មណ៍
  ជំងឺផ្លូវអារម្មណ៍នឹងប៉ះពាល់ទៅលើសមត្ថភាពរបស់សាក្សីក្នុងការផ្តល់ចម្លើយ រាយការណ៍ជូនព្រះរាជអាជ្ញា-ពិចារណាភស្តុតាងរបស់អ្នកជំនាញចិត្តសាស្ត្រ ដើម្បីពន្យល់ពីចម្លើយមិនស៊ីចង្វាក់គ្នា
- វិធានការគាំពារ
  ព័ត៌មានពេញលេញ-ណែនាំពីទិដ្ឋភាពនៅក្នុងបន្ទប់សវនាការ-រំឭកភាពចងចាំ
- ភារកិច្ចក្រោយពេលសវនាការ
  ភារកិច្ចបន្តទៀត-ការវាយតម្លៃជាបន្ទាន់ពីហានិភ័យ-ពិចារណាពីហានិភ័យនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម-ពន្យល់ដល់ជនរងគ្រោះ

### ខ. គោលការណ៍ណែនាំអាស៊ានស្តីពីដំណើរការសវនាការសម្រាប់អ្នកអនុវត្តផ្ទាល់

- ព្រះរាជអាជ្ញា និងមន្ត្រីនគរបាលស៊ើបអង្កេត ត្រូវធ្វើការឱ្យបានជិតស្និទ្ធជាមួយគ្នា ដើម្បីធានាឱ្យទទួលបានការយល់ព្រម និងការសហការពីជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់នូវភស្តុតាងនៅក្នុងការចោទប្រកាន់ជនល្មើស ដែលជាការចាំបាច់ សម្រាប់ការផ្តន្ទាទោស
- ការជំនុំជម្រះទាក់ទងនឹងអំពើជួញដូរមនុស្ស ត្រូវចាប់ផ្តើម និងបញ្ចប់ ដោយគ្មានការពន្យាពេល ដែលមិនសមហេតុផល ក្នុងការស្វែងរកយុត្តិធម៌ និងការពារជនរងគ្រោះ
- ដើម្បីកាត់បន្ថយភាពតានតឹង នៅក្នុងពេលសវនាការជំនុំជម្រះ សម្រាប់ជនរងគ្រោះជាសាក្សី ត្រូវរិះរកជម្រើសផ្សេងៗ ដើម្បីផ្តល់ភស្តុតាង ដូចជាតាមរយៈការតភ្ជាប់បណ្តាញវីដេអូ
- វិធានការគាំទ្រជាក់ស្តែងផ្សេងទៀត រួមមាន ការពិនិត្យមើលបន្ទប់តុលាការ មុនពេលការជំនុំជម្រះ ការជូនទៅកាន់អាគារតុលាការ និងជូនត្រឡប់មកវិញ ការប្រើប្រាស់ច្រកចូល ទៅកាន់អាគារតុលាការផ្សេងគ្នា កន្លែងរង់ចាំដោយឡែកពីគ្នា និងការផ្តល់ព័ត៌មានយ៉ាងទៀងទាត់ពី ផ្នែកអយ្យការ ស្តីពីការប្រព្រឹត្តិទៅនៃការជំនុំជម្រះ រហូតដល់ទីបញ្ចប់របស់នីតិវិធីរឿងក្តីនៅតុលាការ

• ព្រះរាជអាជ្ញា និងចៅក្រម ត្រូវទទួលខុសត្រូវ ក្នុងការធានាថា ការជំនុំជម្រះ ប្រព្រឹត្តទៅដោយយុត្តិធម៌ អនុលោមទៅតាមបទដ្ឋានអន្តរជាតិ ដែលអាចអនុវត្តបាន ។ (ផ្នែកទីមួយ-បញ្ហាភស្តុតាង ៖ ផ្នែក-ច-បញ្ហាជំនុំជម្រះ) ។

### គ. មគ្គុទ្ទេសក៍ល្អៗសម្រាប់ការអនុវត្ត

មន្ត្រីនគរបាលស៊ើបអង្កេតរឿងក្តីជួញដូរមនុស្ស ត្រូវចងចាំអង្គហេតុដូចខាងក្រោម ៖

• សម្រាប់ជនរងគ្រោះភាគច្រើន ការផ្តល់ចម្លើយនៅក្នុងតុលាការ គឺជាការខិតខំប្រឹងប្រែង នៅក្នុងកិច្ចសហប្រតិបត្តិការទាំងស្រុង ហើយជាព្រឹត្តិការណ៍មួយ ដែលពួកគេភ័យខ្លាចជាងព្រឹត្តិការណ៍ណាៗទាំងអស់

• មិនមានអ្វីដែលមន្ត្រីអនុវត្តច្បាប់ ឬអ្នកវិភាគ អាចធ្វើបាន ដើម្បីបំបាត់ការភ័យខ្លាចនេះទាំងស្រុងបានទេ ក៏ប៉ុន្តែមានជំហានជាក់ស្តែងមួយចំនួន ដែលពួកគេអាចអនុវត្តបាន ដើម្បីកាត់បន្ថយគ្រោះថ្នាក់របស់ជនរងគ្រោះ ដែលធ្លាប់មានក្នុងពេលផ្តល់ចម្លើយនៅតុលាការ

• មន្ត្រីនគរបាលស៊ើបអង្កេតត្រូវផ្តល់ជំនួយជាក់ស្តែង ដើម្បីឱ្យជនរងគ្រោះទទួលបាននូវសិទ្ធិរបស់ខ្លួនក្នុងការស្វែងរកយុត្តិធម៌ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ឱ្យនៅកម្រិតទាប

• តាមការបញ្ជាក់ពីគ្រូពេទ្យចិត្តសាស្ត្រ ដែលធ្វើការជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យដឹងថា សាក្សីជាជនរងគ្រោះដែលបានដឹងពីកិច្ចដំណើរការនេះច្បាស់លាស់ អាចដឹងពីរបៀបដោះស្រាយបញ្ហាដែលកើតឡើង និងមានវិធានការគាំទ្រនានា ដូចខាងក្រោម៖

  ○ ជម្រើសក្នុងការផ្តល់ចម្លើយ

ដំបូងបង្អស់ វាជួយឱ្យយើងអាចរកឃើញមធ្យោបាយផ្សេងៗ ដើម្បីឱ្យសាក្សី អាចផ្តល់ចម្លើយបាន ហើយនេះវាអាស្រ័យទៅលើប្រព័ន្ធយុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌនៃប្រទេសសាមីនោះ ។ លក្ខខណ្ឌទាំងឡាយដែលសាក្សីត្រូវផ្តល់ចម្លើយ គឺមានសារៈសំខាន់ សម្រាប់ហេតុផលពីរយ៉ាង ដែលជាផ្នែកមួយដ៏សំខាន់សម្រាប់ជនរងគ្រោះ ៖

  ▪ ការខ្លាចមិនហ៊ានលាតត្រដាងប្រាប់ពីអត្តសញ្ញាណ និងមុខងាររបស់ខ្លួនជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការខ្មាស់អៀន ដែលជនរងគ្រោះជាប់ពាក់ព័ន្ធក្នុងរឿងនេះ

  ▪ ការខ្លាចជនជួញដូរបង្ហាញខ្លួន ជាពិសេសក្នុងករណីទាំងឡាយ ដែលពាក់ព័ន្ធនឹងការរំលោភផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ ។

មធ្យោបាយច្រើនយ៉ាង ដែលជនរងគ្រោះអាចផ្តល់ចម្លើយដល់តុលាការ ៖

  ▪ ការផ្តល់ចម្លើយដោយបើកចំហ នៅក្នុងបន្ទប់សវនាការ ដោយគ្មានការសម្ងាត់ និងមិនបិទបាំងពីជនជាប់ចោទ ឬសាធារណៈជន

  ▪ ការផ្តល់ចម្លើយដោយប្រើរបាំងមុខ នៅពីក្រោយរនាំងបាំងមុខ ដោយជនរងគ្រោះ និងជនជាប់ចោទមិនអាចមើលគ្នាឃើញ

  ▪ ការប្រើអត្តសញ្ញាណក្លែង ដើម្បីធានាការសម្ងាត់នៅចំពោះមុខជនជាប់ចោទ ប៉ុន្តែបើកឱ្យសាធារណៈជន ចូលស្តាប់សវនាការនេះបាន

- ការប្រើប្រាស់បណ្តាញវីដេអូនៅក្នុងពេលធ្វើសវនាការ ដែលជនរងគ្រោះ អាចឆ្លើយតាមរយៈការតភ្ជាប់បណ្តាញវីដេអូ ទៅបន្ទប់មួយទៀត នៅក្នុងពេលសវនាការ ដែលសាក្សីបានផ្តល់ចម្លើយ តាមមធ្យោបាយធម្មតា និងត្រូវសួរដេញដោល
- ការផ្តល់ចម្លើយសាក្សី តាមរយៈបណ្តាញវីដេអូ (video conference) ពីទីតាំងដាច់ដោយឡែក ដោយប្រើបណ្តាញវីដេអូពេញលេញ ឬគ្រាន់តែបញ្ចាំងវីដេអូពីការផ្តល់ចម្លើយសាក្សី។

◦ ចំណុចអនុវត្តន៍ល្អៗ

- ការរក្សាអត្តសញ្ញាណជាសម្ងាត់ គឺជាដំណោះស្រាយដែលល្អប្រសើរសម្រាប់ជនរងគ្រោះ និងសាក្សី ហើយមិនអនុញ្ញាតឱ្យពួកគេចូលរួមក្នុងសវនាការឡើយ ។ ប្រសិនជាអាចធ្វើបានទៅតាមនីតិវិធី គឺត្រូវផ្តល់ចម្លើយដោយការតភ្ជាប់វីដេអូទៅបន្ទប់មួយផ្សេងដាច់ដោយឡែក
- ជនរងគ្រោះមិនត្រូវផ្តល់ចម្លើយក្នុងសវនាការសាធារណៈ នៅចំពោះមុខជនជាប់ចោទទេ ពីព្រោះ វាធ្វើឱ្យជនរងគ្រោះភ័យខ្លាច ដោយមានការចុះផ្សាយតាមប្រព័ន្ធសារព័ត៌មាន
- មន្ត្រីនគរបាលស៊ើបអង្កេតត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នអយ្យការ ឱ្យបានឆាប់រហ័ស ក្នុងការស្វែងរកមតិយោបល់ផ្លូវច្បាប់ ដើម្បីជៀសវាងការព្រួយបារម្ភខាងលើ ។

◦ ផលប៉ះពាល់នៃជំងឺផ្លូវអារម្មណ៍របស់ជនរងគ្រោះជាសាក្សី

- ការតក់ស្លុតខ្លាំងអាចនាំឱ្យជនរងគ្រោះមិនចាំបានពីហេតុការណ៍ផ្សេងៗ ។ ប៉ុន្តែក្រោយពេលដែលមានស្មារតីធម្មតាឡើងវិញ ពួកគេអាចផ្តល់ព័ត៌មានមិនពិត ដើម្បីបំពេញចន្លោះ ដែលពួកគេចាំមិនបាន កត្តាទាំងនេះហើយគឺជាផលវិបាកដោយផ្ទាល់នៃភាពតក់ស្លុត ។ កត្តាទាំងពីរនេះអាចធ្វើឱ្យប៉ះពាល់ដល់គុណភាព និងភាពស៊ីចង្វាក់នៃចម្លើយណាមួយដែលពួកគេបានផ្តល់នៅក្នុងការសម្ភាស ជាមួយមន្ត្រីនគរបាលស៊ើបអង្កេត
- គ្រោះថ្នាក់សម្រាប់សាក្សីនោះ គឺមេធាវីជនជាប់ចោទ អាចចោទសួរបញ្ជាក់ពីការជឿជាក់របស់សាក្សី ដែលអាចនាំឱ្យបាត់បង់ការជឿជាក់ និងការចោទប្រកាន់លើករណីនេះ ។ នេះ គឺជាទង្វើមួយដែលស្របច្បាប់ ហើយវាជាការងារមួយផ្នែករបស់មេធាវី ដើម្បីសួរបញ្ជាក់ពីចម្លើយរបស់ជនរងគ្រោះ ក្នុងនាមជាមេធាវីរបស់ជនជាប់ចោទ
- ចំពោះលទ្ធភាពបែបនេះ គឺជាភារកិច្ចរបស់មន្ត្រីនគរបាលស៊ើបអង្កេត និងព្រះរាជអាជ្ញា ដើម្បីគិតគូរ ជាពិសេសពីការលំបាករបស់ជនរងគ្រោះ ដែលមានការតក់ស្លុតខ្លាំង នៅពេលដែលពួកគេផ្តល់ចម្លើយ ។ ក្នុងការផ្តល់ចម្លើយ ជានិច្ចកាល សាក្សីមានភាពតានតឹងក្នុងអារម្មណ៍ ហើយជនរងគ្រោះមានភាពតក់ស្លុត ងាយនឹងភ័យខ្លាចចំពោះការចោទសួរដោយមេធាវី ហើយភ្លេចគិតថា ការតក់ស្លុតនោះនឹងនាំឱ្យប៉ះពាល់ដល់ការផ្តល់ចម្លើយរបស់ខ្លួន ដែលជាសញ្ញាបង្ហាញថា ការផ្តល់ចម្លើយនោះមិនត្រឹមត្រូវ និង/ឬមិនអាចយកជាការបាន
- ប្រសិនបើគេយល់ថា ភាពតក់ស្លុតគឺជាកត្តាមួយដ៏សំខាន់នោះ ភារកិច្ចរបស់មន្ត្រីនគរបាលស៊ើបអង្កេត ត្រូវពិនិត្យវាយតម្លៃលើកស្តុតាង ដែលបានផ្តល់ឱ្យ និងផលប៉ះពាល់ទៅលើលទ្ធភាពរបស់ជនរងគ្រោះ ក្នុងការផ្តល់ចម្លើយ ។ មន្ត្រីនគរបាលស៊ើបអង្កេតត្រូវយកចម្លើយរបស់សាក្សី

ជំនាញ គឺគ្រូពេទ្យចិត្តសាស្ត្រដែលមានបទពិសោធន៍ក្នុងការពិនិត្យព្យាបាលជំងឺផ្លូវអារម្មណ៍ ហើយដែលអាចរៀបរាប់លម្អិតពីស្ថានភាព មូលហេតុ និងរោគសញ្ញា

- គ្រូពេទ្យចិត្តសាស្ត្រអាចផ្តល់យោបល់ជំនាញ ពីរបៀបដែលរោគសញ្ញានៃជំងឺផ្លូវអារម្មណ៍អាចប៉ះពាល់ដល់ជនរងគ្រោះជាសាក្សី ក្នុងការផ្តល់ចម្លើយជូនតុលាការ ចំពោះភាពផ្ទុយគ្នា ឬភាពមិនស៊ីចង្វាក់គ្នា រវាងសកម្មភាព និងចម្លើយរបស់ជនរងគ្រោះបានផ្តល់ជូនមេធាវី នាំឱ្យគេយល់ថាភាពផ្ទុយគ្នា ឬភាពមិនស៊ីចង្វាក់គ្នា គឺជាភស្តុតាង ដែលមិនត្រឹមត្រូវ និង/ឬមិនអាចយកជាការបាន
- ក្នុងលក្ខខណ្ឌជាក់លាក់មួយចំនួន ផលប៉ះពាល់នៃភាពតក់ស្លុត និងយុទ្ធសាស្ត្រទាំងឡាយដែលជនរងគ្រោះប្រើប្រាស់ ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ធ្វើឱ្យសាក្សីតក់ស្លុតខ្លាំង ងាយទទួលគ្រោះថ្នាក់ តាមវិធីបីផ្សេងៗគ្នា ដូចខាងក្រោម៖

- ផលប៉ះពាល់លើអាកប្បកិរិយា ៖ នៅក្នុងពេលប្រព្រឹត្តបទល្មើស ជនរងគ្រោះអាចធ្វើសកម្មភាពអ្វីមួយ ដែលបង្ហាញថា ខ្លួនមិនមែនជាជនរងគ្រោះ ដោយអំពើរំលោភធ្ងន់ធ្ងរទេ ផ្ទុយទៅវិញខ្លួនបានស្ម័គ្រចិត្តចូលរួមក្នុងសកម្មភាពនោះ ។
- ភាពមិនអាចរំឭកបានពីព្រឹត្តិការណ៍ ៖ នៅក្នុងដំណាក់កាលដំបូងនៃការស៊ើបអង្កេត ជនរងគ្រោះដែលតក់ស្លុត ទំនងជាមិនអាចផ្តល់ចម្លើយឱ្យបានច្បាស់លាស់ និងស៊ីចង្វាក់ ពីហេតុការណ៍ដែលបានកើតឡើងនោះទេ ហើយការសម្ភាសអាចធ្វើជាច្រើនលើក ដោយមានរយៈពេលយូរ ដើម្បីអាចដឹងរឿងរ៉ាវសព្វគ្រប់ ។ ការបង្ហាញរបស់មេធាវីជនជាប់ចោទ ធ្វើឱ្យជនរងគ្រោះនឹកមិនឃើញពីហេតុការណ៍ផ្សេងៗ ព្រោះចម្លើយមិនអាចឱ្យគេយកជាការបាន ឬថាជនរងគ្រោះ គឺជាអ្នកប្រឌិតចម្លើយនោះឡើង ឬថាមន្ត្រីនគរបាលជាអ្នកបង្គាប់ឱ្យនិយាយតាម ដែលវាមិនមែនជាសញ្ញាណនៃភាពតក់ស្លុតទេ ។ ក្នុងបរិបទនេះ សំខាន់ត្រូវប្រើសាក្សីជំនាញ ដើម្បីបញ្ជាក់ពីភាពតក់ស្លុត និងដើម្បីបញ្ជាក់ពីហេតុ ដែលនាំឱ្យគាត់មិនអាចនឹកឃើញពីហេតុការណ៍ទាំងអស់បានភ្លាមៗ ហើយអាចនឹងនឹកឃើញរឿងរ៉ាវទាំងនោះវិញបន្តិចម្តងៗ នៅពេលក្រោយ ដែលនេះជាផលវិបាកនៃស្ថានការណ៍ ហើយមិនមែនជាភស្តុតាង ដែលថាជនរងគ្រោះ ឬនគរបាលជាអ្នកអនុវត្តខុសនោះទេ ។
- ការប្រឌិតព្រឹត្តិការណ៍ ៖ នៅក្នុងដំណាក់កាលដំបូង ដោយសារតែពួកគេមិនអាចដឹងពីមូលហេតុដែលគេមិនអាចនឹកឃើញពីព្រឹត្តការណ៍ដ៏តក់ស្លុតមួយចំនួននោះ ទើបជនរងគ្រោះមានការតក់ស្លុត អាចចង់បំពេញចន្លោះខ្វះខាត នូវហេតុការណ៍ដែលខ្លួននឹកមិនឃើញ ដោយប្រឌិតរឿងរ៉ាវមិនពិតនៅក្នុងព្រឹត្តិការណ៍មួយ ។ ការស៊ើបអង្កេតជាបន្តបន្ទាប់ បានឱ្យគេដឹងពីរឿងរ៉ាវដែលប្រឌិតឡើងទាំងនោះ ។ ជាការពិត និងត្រឹមត្រូវណាស់ ដែលមេធាវីជនជាប់ចោទនឹងព្យាយាមសួរសំណួរផ្ទុយ ឬស្វែងរកកំហុសផ្សេងៗ ដើម្បីឱ្យចម្លើយរបស់ជនរងគ្រោះមិនអាចយកជាការបាន ហើយអ្វីដែលសំខាន់នោះ គឺគេត្រូវតែលើកយកហេតុផលមកបញ្ជាក់ពីភាពតក់ស្លុតរបស់ជនរងគ្រោះ និងមិនចាំបាច់បញ្ជាក់ថា ជនរងគ្រោះមានចេតនាផ្តល់ចម្លើយមិនពិត ឬមិនអាចនិយាយការពិតទេ ។

## ៦. វិធានការជួយដល់ជនរងគ្រោះដទៃទៀត

វិធានការជាក់ស្តែងមួយចំនួន ដែលបានបង្កើតឡើង គឺដើម្បីកាត់បន្ថយកម្រិតនៃភាពតាន

តឹងក្នុងអារម្មណ៍ ដែលជនរងគ្រោះមិនអាចអត់ទ្រាំបាន នៅពេលត្រូវបង្ហាញភស្តុតាងជូនតុលាការ ។ គោលបំណងទូទៅ គឺការកាត់បន្ថយភាពភ័យខ្លាច របស់ជនរងគ្រោះចំពោះជនមិនស្គាល់មុខ ដែលអាចធ្វើឱ្យកម្រិតនៃហានិភ័យកើនឡើងក្នុងពេលសវនាការ ហើយត្រូវផ្តល់ព័ត៌មានដល់ជនរងគ្រោះឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន មុនពេលជនរងគ្រោះត្រូវផ្តល់ចម្លើយជូនតុលាការ ។

ចំណុចដែលត្រូវកត់សម្គាល់ពីវិធានការដែលបានលើកឡើងទាំងនោះ ជួយធ្វើឱ្យកម្រិតនៃភាពតានតឹងក្នុងអារម្មណ៍មានជាអប្បបរមា ហើយពួកគេមិនបាច់ត្រូវការធនធាន ឬវិធានការបច្ចេកទេសច្រើនទេ ។

**ក. មុនពេលសវនាការ**

• ជនរងគ្រោះត្រូវការឱ្យគេជួយយ៉ាងខ្លាំងក្នុងដំណាក់កាលនេះ ប្រសិនបើគេត្រូវការឱ្យជនរងគ្រោះ ចូលខ្លួនទៅបំភ្លឺនៅតុលាការ

• គួរតែប្រាប់ជនរងគ្រោះឱ្យបានលម្អិតនូវនីតិវិធី ដើម្បីផ្តល់ការណែនាំដល់ជនរងគ្រោះអំពីអ្វីដែលនឹងកើតឡើង ។ នៅពេលដែលជនរងគ្រោះយល់ដឹងបានច្រើន ជាកត្តាកាត់បន្ថយភាពភ័យខ្លាច ។ តាមធម្មតា ជនរងគ្រោះមិនបានដឹងមុនថា នឹងមានអ្វីកើតឡើងទេ ហើយរឿងដែលកើតឡើងនោះ នឹងបង្កើននូវសម្ពាធយ៉ាងធ្ងន់ដល់ជនរងគ្រោះ ។

**ខ. ការអមដំណើរជនរងគ្រោះចូលតុលាការ**

• ក្នុងពេលសវនាការ បើគេត្រូវការឱ្យសាក្សីចូលខ្លួនមកតុលាការ មន្ត្រីនគរបាលស៊ើបអង្កេតត្រូវអមដំណើរសាក្សីទាំងនេះ ជាដរាប ដោយមិនគិតពីរយៈពេលដែលសាក្សីជាជនរងគ្រោះត្រូវរង់ចាំផ្តល់ចម្លើយជូនតុលាការឡើយ ។ នៅពេលដែលសាក្សីមកដល់តុលាការ មិនត្រូវឱ្យសាក្សីទាំងនោះ ស្ថិតនៅកន្លែងណាដែលមានវត្តមានជនជាប់ចោទ គ្រួសារ ឬបក្សពួករបស់ជនជាប់ចោទ ឬទុកឱ្យសាក្សីជាជនរងគ្រោះទាំងនោះ ស្ថិតនៅតែឯកឯងឡើយ

• វិធីល្អបំផុតក្នុងការធានាឱ្យបានពីបញ្ហានេះ គឺជាការងាររបស់មន្ត្រីនគរបាល ដែលត្រូវបានចាត់តាំងឱ្យអញ្ជើញសាក្សីជាជនរងគ្រោះតាមអាសយដ្ឋាននីមួយៗ ដែលបានកំណត់ទុក ឬតាមកន្លែងដែលបានណាត់ជួបគ្នាជាមុន ត្រូវអមដំណើរសាក្សីទៅតុលាការ និងនៅជាមួយសាក្សីជាជនរងគ្រោះរហូតដល់ចប់សវនាការ និងត្រូវអមដំណើរសាក្សីជាជនរងគ្រោះត្រឡប់ទៅវិញ ។

**គ. ការចូលតុលាការ**

• សាក្សីជាជនរងគ្រោះ គួរអនុញ្ញាតឱ្យចូលក្នុងតុលាការតាមផ្លូវដាច់ដោយឡែក ជាជាងចូលតាមផ្លូវសាធារណៈ ទៅក្នុងបន្ទប់ដាច់ដោយឡែក ដើម្បីរង់ចាំវេនផ្តល់ចម្លើយជូនតុលាការ ។ សាក្សីជាជនរងគ្រោះអាចមានការបារម្ភខ្លាំង ចំពោះវត្តមានរបស់អ្នកសារព័ត៌មាន និងជនជាប់ចោទព្រមទាំងបក្សពួកអាចមើលឃើញសាក្សី ពេលចូលតុលាការ ដូចនេះត្រូវព្យាយាមទប់ស្កាត់តាមគ្រប់មធ្យោបាយ ដែលអាចធ្វើទៅបាន

• ការបើកសវនាការ បានធ្វើឱ្យសាក្សីជាជនរងគ្រោះមានការព្រួយបារម្ភខ្លាំង និងកាន់តែមានភាពតានតឹង ក្នុងការរង់ចាំផ្តល់ចម្លើយជូនតុលាការ ជាពិសេសនៅពេលថ្ងៃបើកសវនាការដំបូង ។

មន្ត្រីនគរបាលដែលអមដំណើរជនរងគ្រោះមកតុលាការ ត្រូវតែនៅជាមួយសាក្សី ក្នុងកន្លែងមួយមានសុវត្ថិភាព នៅជិតបន្ទប់សវនាការ បើអាចធ្វើទៅបាន ដើម្បីឱ្យសាក្សីត្រៀមខ្លួនជាស្រេច ក្នុងការចាប់ផ្តើមផ្តល់ចម្លើយជូនតុលាការ ។

### ឃ. ការជូនដំណឹង

- តាមបទពិសោធន៍បានបង្ហាញឱ្យឃើញថា ក្នុងករណីបែបនេះ សាក្សីបានបង្កើតឱ្យមានទំនាក់ទំនងការងារជិតស្និទ្ធជាមួយមន្ត្រីនគរបាលម្នាក់ ឬច្រើននាក់ដែលកាន់សំណុំរឿងនេះ។ នេះគឺជាកត្តាវិជ្ជមានមួយ ដែលធ្វើឱ្យមានការរក្សាទំនាក់ទំនងបានល្អក្នុងក្របខណ្ឌការងារ
- បើទោះជាមានការស្នាក់ស្ទើរ ក្នុងការផ្តល់ចម្លើយក៏ដោយ ក៏នៅតែអាចមានផលប៉ះពាល់ជាអវិជ្ជមានខ្លះ ក្នុងដំណាក់កាលផ្តល់ចម្លើយជូនតុលាការ
- នៅពេលដែលមានការរំខានដល់ការផ្តល់ចម្លើយ វាអាចបណ្តាលឱ្យមានភាពតានតឹងដែលមិនអាចជៀសផុតបានចំពោះសាក្សី ពីព្រោះពួកគេតែងតែយល់ច្រឡំថា ការរំខាននេះកើតចេញពីអ្វីដែលពួកគេធ្លាប់ប្រព្រឹត្តខុស ហើយក៏ចាប់ផ្តើមស្តីបន្ទោសខ្លួនឯង និងចាប់ផ្តើមមានការធុញថប់ក្នុងអារម្មណ៍ខ្លាំងបន្ថែមទៀត នៅពេលសម្រាកពីសវនាការ ។ ស្ថានភាពបែបនេះ អាចបង្កើតបានជាអារម្មណ៍មួយទៀត ដែលពួកគេគិតថា ខ្លួនបានធ្វើឱ្យមន្ត្រីនគរបាលអស់សង្ឃឹម ហើយក៏បានធ្វើឱ្យពួកគេរិះរកវិធីផ្សេងទៅវិញ
- មន្ត្រីនគរបាលអមដំណើរ អាចកាត់បន្ថយការព្រួយបារម្ភរបស់សាក្សីបាន ដោយធ្វើការពន្យល់សាក្សីឱ្យបានច្បាស់លាស់ អំពីមូលហេតុនៃការកើតឡើង ហើយដោយបញ្ជាក់ប្រាប់ដល់ពួកគេជាថ្មីថា បញ្ហាទាំងនេះមិនមែនជាកំហុសរបស់ពួកគេទេ ព្រោះថា ពួកគេគ្រាន់តែជាផ្នែកមួយនៃដំណើរការសវនាការតែប៉ុណ្ណោះ ។ មន្ត្រីនគរបាលស៊ើបអង្កេតមានទំនោរទៅរកការសន្មតថា សាក្សីជាជនស៊ីវិលមានការយល់ដឹងពីនីតិវិធីក្នុងកម្រិតមួយដូចគ្នា ។

### ង. ការរំឭកភាពចងចាំ

សាក្សីត្រូវបានអនុញ្ញាតឱ្យធ្វើការរំឭកឡើងវិញនូវអ្វីខ្លួនដែលបានផ្តល់ចម្លើយ ដោយផ្ទាល់មាត់ ឬតាមកំណត់ហេតុ តាមការថតសំឡេង ឬបង្ហាញវីដេអូឡើងវិញ មុននឹងធ្វើការផ្តល់ចម្លើយក្នុងសវនាការ ។

### ច. សេចក្តីសង្ខេបពីវិធានការជួយដល់ជនរងគ្រោះក្នុងកិច្ចដំណើរការសវនាការ

- វាយតម្លៃពីហានិភ័យដែលអាចកើតឡើង
- ពិគ្រោះយោបល់ជាមួយជនរងគ្រោះ
- ពន្យល់សាក្សីអំពីវិធានការការពារ
- ផ្តល់យោបល់អំពីសន្តិសុខ សុវត្ថិភាព មុនពេល និងក្រោយពេលសវនាការ
- ណែនាំសាក្សីកុំឱ្យត្រឡប់ទៅធ្វើជាពេស្យាចារសារជាថ្មីឡើងវិញ
- ពន្យល់អំពីនីតិវិធីដល់ជនរងគ្រោះក្នុងការផ្តល់ចម្លើយជូនតុលាការ
- ប្រាប់ពីនីតិវិធីរបស់តុលាការដល់ជនរងគ្រោះឱ្យបានក្បោះក្បាយ

• រៀបចំចាត់ចែងឱ្យមានការអមដំណើរជនរងគ្រោះចូលតុលាការ
• រៀបចំឱ្យជនរងគ្រោះចូលក្នុងពេលសវនាការតាមផ្លូវដាច់ដោយឡែក
• រំឭកដល់ជនរងគ្រោះ អំពីនីតិវិធីរបស់តុលាការក្នុងពេលសវនាការ ។

## ៧. ការវាយតម្លៃអំពីហានិភ័យដែលអាចកើតឡើង ក្រោយពេលសវនាការ

### ក. បញ្ហាក្រោយពេលសវនាការ

បញ្ចប់ដំណើរការសវនាការ មន្ត្រីនគរបាលស៊ើបអង្កេត និងព្រះរាជអាជ្ញា មានអារម្មណ៍រីករាយរួមគ្នាថា ការងារត្រូវបានចប់ ។ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលផ្តល់ចម្លើយប្រឆាំងជនល្មើស មិនបានទទួលអារម្មណ៍រីករាយដូចនេះទេ ពីព្រោះ ហានិភ័យនឹងមានជាបន្ត ហើយជាការពិតហានិភ័យបានកើនឡើងមែន ។ បន្ទាប់ពីបញ្ចប់សវនាការ មន្ត្រីនគរបាលស៊ើបអង្កេតនៅតែទទួលខុសត្រូវចំពោះសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ហើយដំណើរការវាយតម្លៃពីហានិភ័យនៅតែបន្ត ។

បន្ទាប់ពីសវនាការរួច កិច្ចដំណើរការវាយតម្លៃពីហានិភ័យ ត្រូវតែចាត់ទុកថា ជាផ្នែកមួយដ៏សំខាន់ ហើយត្រូវពិនិត្យមើលពីហានិភ័យចំពោះសាក្សីឡើងវិញ មុនពេលជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទ ដឹងពីការសហការរបស់សាក្សីជាមួយមន្ត្រីនគរបាល ។ ហានិភ័យអាចនឹងកើតមានទោះបីជនរងគ្រោះសហការ ឬមិនសហការជាមួយមន្ត្រីនគរបាលក៏ដោយ ។

### ខ. ការបញ្ជូនជនរងគ្រោះជាសាក្សីត្រឡប់ទៅលំនៅដ្ឋានវិញ

ក្នុងករណីសាក្សីជាប្រជាពលរដ្ឋរបស់ប្រទេសមួយ ដែលតុលាការរបស់ប្រទេសនោះបានបើកសវនាការជំនុំជម្រះពីរឿងក្តី ក្រោយពីសវនាការហើយភ្លាម ពួកគេអាចចង់ទៅរស់នៅជាមួយគ្រួសាររបស់ខ្លួនវិញ ។ វាជាចំណុចមួយដែលមន្ត្រីនគរបាលអាចផ្តល់មធ្យោបាយ និងជួយឧបត្ថម្ភគាំពារដល់សាក្សីទាំងនោះ ។ ផ្ទុយទៅវិញ ជនរងគ្រោះអាចជួបនឹងគ្រោះថ្នាក់ ដោយសារសាច់ញាតិរបស់ខ្លួន ជាអ្នកជួញដូរពួកគេ ។

### គ. ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះជាជនបរទេស

នៅពេលធ្វើការសន្និដ្ឋានពីដំណើរការទាំងនេះ សាក្សីជាជនរងគ្រោះជាជនបរទេសអាចបញ្ជូន ឬត្រូវបញ្ជូនទៅប្រទេសដើមរបស់គេវិញបាន គឺត្រូវស្ថិតលើលក្ខខណ្ឌពីរយ៉ាង៖

• ការបញ្ជូនត្រឡប់ទៅវិញតាមគោលការណ៍ស្ម័គ្រចិត្ត ៖ បើសាក្សីចង់ត្រឡប់ទៅប្រទេសដើមវិញ ពួកគេមានសិទ្ធិត្រឡប់ទៅបាន ដោយគ្មានហេតុផលអ្វីត្រូវហាមឃាត់នោះទេ ទោះជាកម្រិតនៃគ្រោះថ្នាក់មានច្រើនយ៉ាងណាក៏ដោយ ។ នៅក្នុងស្ថានភាពបែបនេះ មន្ត្រីនគរបាលត្រូវរិះរកមធ្យោបាយណាមួយ ដើម្បីជួយការពារ និងសម្រួលឱ្យពួកគេបានត្រឡប់ទៅដល់ប្រទេសដើមវិញ ។

• ការបញ្ជូនត្រឡប់ទៅវិញតាមគោលការណ៍មិនស្ម័គ្រចិត្ត ៖ ក្រសួងមហាផ្ទៃសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះទៅប្រទេសដើមវិញ ។

### ឃ. ការពន្យល់ និងការសាកសួរសាក្សី

ក្រោយពីសវនាការរួច មន្ត្រីនគរបាលស៊ើបអង្កេតត្រូវឧស្សាហ៍ទាក់ទងជាមួយសាក្សីជាជនរងគ្រោះ ដើម្បីឱ្យបានដឹងថា ពួកគេរស់នៅប្រកបដោយសុវត្ថិភាព និងមានសុខុមាលភាពដែរឬទេ ។ មន្ត្រីនគរបាលស៊ើបអង្កេតគួរតែឆ្លៀតឱកាសសំណេះសំណាលជាមួយជនរងគ្រោះជាសាក្សី ដើម្បីចង់ដឹងពីការយល់ឃើញរបស់ពួកគេ ក្នុងការស្វែងរកយុត្តិធម៌ ។ កិច្ចដំណើរការបន្ទាប់ទៀត អាចកំណត់បាននូវការកែប្រែពីគុណវិបត្តិផ្សេងៗ ដែលមាននៅក្នុងនីតិវិធី ក្នុងការជួយដល់សាក្សី ។

**៨. គោលការណ៍ណែនាំនៃអនុស្សរណៈយោគយល់គ្នារវាងកម្ពុជា-ថៃ**

ការធ្វើមាតុភូមិនិវត្តន៍ ៖ គោលការណ៍ណែនាំនៃអនុស្សរណៈយោគយល់គ្នារវាងកម្ពុជា-ថៃ គឺជាឧទាហរណ៍មួយ ពីអ្វីដែលបានធ្វើនៅក្នុងតំបន់នេះ ទាក់ទងនឹងសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះជាសាក្សី

ប្រការ ៩ ៖ ក្នុងករណីសមស្រប ស្ថាប័នពាក់ព័ន្ធនៃរដ្ឋភាគី ដោយមានកិច្ចសហប្រតិបត្តិការពីអង្គការក្រៅរដ្ឋាភិបាល ត្រូវផ្ដល់ដល់កុមារ និងស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាជិកគ្រួសារដែលជិតស្និទ្ធ នូវជម្រកប្រកបដោយសុវត្ថិភាព ការថែទាំសុខភាព សិទ្ធិទទួលជំនួយផ្នែកច្បាប់ និងការជួយឧបត្ថម្ភចាំបាច់ផ្សេងទៀត សម្រាប់កិច្ចការពារកុមារ និងស្ត្រីរងគ្រោះទាំងនោះ ។

ប្រការ ១៥ ៖ មន្ត្រីនគរបាល និងអាជ្ញាធរពាក់ពន្ធ័ផ្សេងទៀតនៃរដ្ឋភាគី ត្រូវអនុវត្តនូវកម្មវិធីទប់ស្កាត់ ដើម្បីធានាសុវត្ថិភាពជនរងគ្រោះ និងសាក្សី ពីការសងសឹក ឬការគំរាមកំហែងនៅក្នុងពេលដំណើរការ និងក្រោយពីដំណើរការរឿងក្ដីតាមនីតិវិធីតុលាការ បើចាំបាច់ ។

ប្រការ ១៦ ៖

- អាជ្ញាធរទទួលបន្ទុកការធ្វើមាតុភូមិនិវត្តន៍ ត្រូវប្រើប្រាស់ផ្លូវការទូត ក្នុងការទំនាក់ទំនងជូនព័ត៌មាន ជាមុនទៅភាគីម្ខាងទៀត ដើម្បីរៀបចំការធ្វើមាតុភូមិនិវត្តន៍ កុមារនិងស្ត្រីរងគ្រោះ
- ការធ្វើមាតុភូមិនិវត្តន៍កុមារ និងស្ត្រីរងគ្រោះ ត្រូវរៀបចំឡើង និងប្រព្រឹត្តទៅ ក្នុងផលប្រយោជន៍ដ៏ល្អបំផុតដល់ពួកគេ
- កុមារ និងស្ត្រីទាំងឡាយដែលត្រូវបានរកឃើញថា ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នឹងមិនត្រូវចាប់បញ្ជូនឡើយ ។ ការធ្វើមាតុភូមិនិវត្តន៍របស់ស្ត្រី និងកុមាររងគ្រោះ ត្រូវអនុវត្តឱ្យបានសមស្របតាមលក្ខខណ្ឌខាងលើ ។

ប្រការ ១៧ ៖

- រដ្ឋភាគីត្រូវបង្កើតក្រុមអ្នកសម្របសម្រួល ដើម្បីអនុវត្តដំណើរការធ្វើមាតុភូមិនិវត្តន៍កុមារនិងស្ត្រីរងគ្រោះ
- ក្រុមសម្របសម្រួលត្រូវបង្កើតឡើង ដោយមានសមាសភាពអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទាំងពីរ
- ក្រុមសម្របសម្រួល មានភារកិច្ច ដូចតទៅ៖
    - រៀបចំការធ្វើមាតុភូមិនិវត្តន៍ស្ត្រី និងកុមាររងគ្រោះ
    - អនុវត្តការធ្វើមាតុភូមិនិវត្តន៍ ដែលរៀបចំឡើងសម្រាប់ស្ត្រី និងកុមាររងគ្រោះ

○ ផ្តល់កិច្ចការពារសន្តិសុខដល់ស្ត្រី និងកុមាររងគ្រោះ នៅក្នុងការធ្វើមាតុភូមិនិវត្តន៍

○ ប្រឹងប្រែងត្រួតពិនិត្យ និងតាមដានការជួញដូរស្ត្រី និងកុមារ

○ បង្កើតបណ្តាញព័ត៌មាន ក្នុងចំណោមអាជ្ញាធរអនុវត្តច្បាប់ជាតិ អន្តរជាតិនិងអង្គការសង្គមស៊ីវិល ដែលទាក់ទងនឹងអំពើជួញដូរស្ត្រី និងកុមារ ។

(ប្រភពឯកសារ ៖ អនុស្សរណៈយោគយល់គ្នារវាងកម្ពុជា-ថៃ)

## III. សេចក្តីសង្ខេប

- ជនរងគ្រោះដែលបានសហការជាមួយមន្ត្រីនគរបាលក្នុងនាមជាសាក្សី អាចប្រឈមមុខនឹងគ្រោះថ្នាក់យ៉ាងខ្លាំង ដោយសារពួកគេបានគំរាមដល់សេរីភាពជនជួញដូរ ។ ហេតុដូច្នេះហើយ មន្ត្រីនគរបាលស៊ើបអង្កេតត្រូវតែគិតពីបញ្ហាសន្តិសុខសុវត្ថិភាពរបស់ជនរងគ្រោះជាអាទិភាព
- មានវិធីការពារសាក្សីពីរយ៉ាង គឺរដ្ឋត្រូវគ្រប់គ្រង ដោយផ្តល់មូលនិធិដល់កម្មវិធីការពារជនរងគ្រោះទាំងស្រុង និង ត្រូវបង្កើតគម្រោងកម្មវិធីការពារ ដោយមានការចូលរួមពីក្រុមមន្ត្រីនគរបាលស៊ើបអង្កេត និងអង្គការជួយសង្គ្រោះជនរងគ្រោះជាដៃគូ
- គោលការណ៍សំខាន់ៗបី ៖
    - ត្រូវប្រាប់ជនរងគ្រោះឱ្យបានក្បោះក្បាយ និងដោយស្មោះត្រង់ជានិច្ចអំពីលទ្ធភាពដែលមាន ដើម្បីផ្តល់ការការពារដល់ជនរងគ្រោះ ហើយត្រូវធ្វើការពិគ្រោះជាមួយជនរងគ្រោះ ដោយសួរជនរងគ្រោះ ថាតើជនរងគ្រោះចង់សុំឱ្យមានការការពារដោយរបៀបណា
    - វិធានការថ្មីនេះ ត្រូវតែឆ្លើយតបទៅនឹងកម្រិតនៃហានិភ័យ ដែលបានកំណត់ជាមុន ដោយមិនគិតពីវិធានការនៃការការពារដែលបានប្រើរួចហើយនោះទេ
    - មន្ត្រីនគរបាលស៊ើបអង្កេតទទួលខុសត្រូវ អំពីសន្តិសុខសុវត្ថិភាពជនរងគ្រោះទាំងស្រុង និងគ្រប់ពេលវេលា ។
- នៅពេលដែលជនរងគ្រោះបានផ្តល់ចម្លើយជូនមន្ត្រីនគរបាលស៊ើបអង្កេតរួចហើយ មន្ត្រីនគរបាលស៊ើបអង្កេត ត្រូវពិនិត្យ និងវាយតម្លៃពីហានិភ័យឡើងវិញ និងដោយអត្តនោម័ត ដើម្បីឆ្លើយតបទៅនឹងស្ថានភាពថ្មីៗនេះ
- ការវាយតម្លៃពីហានិភ័យនេះ គឺមិនគិតត្រឹមតែសាក្សីប៉ុណ្ណោះទេ សូម្បីតែអ្នកដែលជាទីស្រឡាញ់របស់ជនរងគ្រោះ ក៏យើងត្រូវតែគិតដែរ ប្រសិនបើអាចធ្វើបាន
- កិច្ចដំណើរការនេះគួររាប់បញ្ចូលផងដែរ នូវការវាយតម្លៃចំពោះជនរងគ្រោះដទៃ និងបុគ្គលិករបស់អង្គការជួយសង្គ្រោះផ្ទាល់ ឬអ្នកដែលគេបានជួលពីខាងក្រៅមក ដើម្បីឱ្យជួយរៀបចំកន្លែងស្នាក់នៅ និង/ឬជួយដល់សាក្សី
- ត្រូវធ្វើរបាយការណ៍វាយតម្លៃលើហានិភ័យទាំងអស់នេះ ឱ្យបានច្បាស់លាស់ និងក្បោះក្បាយ
- ការផ្តល់ចម្លើយរបស់សាក្សី គឺជាចំណុចមួយដែលគ្រោះថ្នាក់ និងមានការតឹងតែងក្នុងអារម្មណ៍ តែសាក្សីនេះអាចមានជម្រើសជាច្រើនក្នុងការផ្តល់ចម្លើយជូនតុលាការ

• ដំណោះស្រាយថ្មីៗ ដែលអនុវត្តបានល្អបំផុតនោះ គឺសាក្សីអាចផ្តល់ចម្លើយជូនតុលាការពីកន្លែងមួយដែលឆ្ងាយពីបន្ទប់សវនាការ តាមរយៈបណ្តាញវីដេអូ

• មន្ត្រីនគរបាលស៊ើបអង្កេត គួរតែធ្វើការពិគ្រោះយោបល់ជាមួយសាក្សី ពីរបៀបផ្តល់ចម្លើយតាមដែលពួកគេចូលចិត្ត ដោយប្រើជម្រើសណាមួយក្នុងការផ្តល់ចម្លើយ

• សាក្សីអាចមានការតក់ស្លុត ក្នុងពេលផ្តល់ចម្លើយជូនតុលាការ ក្នុងករណីបែបនេះ ត្រូវរាយការណ៍ជូនតំណាងអយ្យការ

• ត្រូវអនុវត្តនូវវិធានការជាក់ស្តែងមួយចំនួន ដែលអាចជួយផ្នែកស្មារតី ដើម្បីឱ្យសាក្សីអាចរៀបរាប់ពីរឿងរ៉ាវរបស់ខ្លួន ក្នុងស្ថានភាពណាមួយ ដែលកាត់បន្ថយភាពភ័យខ្លាច

• គន្លឹះក្នុងការសម្រេចឱ្យបាននូវគោលបំណងនេះ ធ្វើយ៉ាងណាកុំឱ្យសាក្សី មានការភ័យខ្លាចចំពោះអ្នកដែលខ្លួនមិនស្គាល់ ។ មន្ត្រីនគរបាលស៊ើបអង្កេតត្រូវពន្យល់ដល់សាក្សីជាជនរងគ្រោះ ឱ្យបានក្បោះក្បាយពីកិច្ចដំណើរការរបស់តុលាការ ។ បើសាក្សីជាជនរងគ្រោះអាចដឹងជាមុនបានច្រើន គឺធ្វើឱ្យពួកគេអាចបញ្ចៀសពីការលំបាកក្នុងការផ្តល់ចម្លើយបាន

• ទោះជាសាក្សី បានផ្តល់ចម្លើយជូនតុលាការរួចហើយក៏ដោយ ការទទួលខុសត្រូវរបស់មន្ត្រីនគរបាលស៊ើបអង្កេតមិនទាន់ចប់ និងត្រូវបន្តរហូតដល់ក្រោយសវនាការទៀត

• សាក្សីអាចប្រឈមមុខនឹងគ្រោះថ្នាក់ ដោយសារការផ្តល់ចម្លើយជូនតុលាការ សំខាន់យើងមិនត្រូវបោះបង់ពួកគេចោលភ្លាម បន្ទាប់ពីបានផ្តល់ចម្លើយជូនតុលាការរួចនោះទេ ។ មន្ត្រីនគរបាលស៊ើបអង្កេតមានភារកិច្ចត្រូវពន្យល់ និងសួរនាំសាក្សី ដើម្បីឱ្យបានដឹងថា ពួកគេមានសុវត្ថិភាព និងមានការជួយឧបត្ថម្ភគាំពារ ក្រោយពីពេលសវនាការ ការពន្យល់ និងការសួរនាំនេះ ត្រូវគិតទាំងផ្នែកយុទ្ធសាស្ត្រ និងមនុស្សធម៌ផង

• ការពន្យល់ និងការសួរនាំ ត្រូវរាប់បញ្ចូលការវាយតម្លៃភ្លាមៗពីហានិភ័យ ក្រោយពីពេលសវនាការ និងត្រូវគិតពីវិធានការក្នុងការបញ្ជូនសាក្សីជាជនរងគ្រោះឱ្យទៅរស់នៅក្នុងប្រទេសដើម

• នៅក្នុងវិធានការនីមួយៗ ត្រូវគិតពីសុវត្ថិភាពរបស់សាក្សីជាមុនសិន

• វិធានការចុងក្រោយ បន្ទាប់ពីពេលសវនាការរួចមក មន្ត្រីនគរបាលស៊ើបអង្កេតគួរតែឆ្លៀតឱកាសសំណេះសំណាលជាមួយជនរងគ្រោះជាសាក្សី ដើម្បីចង់ដឹងពីការយល់ឃើញរបស់ពួកគេ ក្នុងការស្វែងរកយុត្តិធម៌ ។

## សំណួររំឭកមេរៀន

១. ចូរគូសបញ្ជាក់អំពីកាតព្វកិច្ចជាអន្តរជាតិសំខាន់ៗ របស់មន្ត្រីអនុវត្តច្បាប់ ដោយគិតពីសុវត្ថិភាព និងសុខុមាលភាពរបស់សាក្សី ។

២. ចូរពន្យល់ពីដំណើរការការពារសាក្សី និងការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងពន្យល់ ពីកិច្ចដំណើរការណាមួយដែលមាន ឬដែលអាចធ្វើបាននៅក្នុងប្រទេសរបស់លោកអ្នក ។

៣. ចូរបរិយាយពីជម្រើសក្នុងការផ្តល់ចម្លើយ និងវិធានការនានារបស់តុលាការក្នុងការជួយសាក្សីជាជនរងគ្រោះ ។

៤. ចូររៀបរាប់ពីវិធានការជាក់ស្តែង ដែលបានរៀបចំឡើង ដើម្បីកាត់បន្ថយនូវហេតុការណ៍ទាំងឡាយ ដែលសាក្សីជាជនរងគ្រោះមិនបានដឹងមុន និងដើម្បីកាត់បន្ថយភាពតានតឹងក្នុងអារម្មណ៍របស់សាក្សី ដែលជាជនរងគ្រោះ ។

៥. ចូរពន្យល់ ថាតើមន្ត្រីនគរបាលស៊ើបអង្កេត គួរធ្វើការវាយតម្លៃពីហានិភ័យ ដែលអាចកើតឡើង ដោយរបៀបណា ក្រោយពេលសវនាការរួចមក ។

៦. ចូររៀបរាប់ពីចំណុច ដែលមន្ត្រីអនុវត្តច្បាប់ គួរលើកយកមកពន្យល់ និងសួរនាំដល់សាក្សីក្រោយពេលសវនាការរួច ៕

ឡឡឡ ✸ ឡឡឡ

# ឯកសារយោង


- ឯកសារមេរៀនរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ២០០៣
  - Bourg, Wendy et al; *A Child Interviewer's Guidebook*, Thousand Oaks, CA: Sage Publications, 1999
  - Goodman, Gail; Bottoms, Bette; *Child Victims, Child Witnesses: Understanding and Improving Testimony*, New York, NY: The Guilford Press, 1993
  - Mapes, Bruce; *Child Eyewitness Testimony in Sexual Abuse Investigations*, Brandon, VT: Clinical Psychology Publishing Co., 1995
  - Milne, Rebecca; Bull, Ray; *Investigative Interviewing: Psychology and Practice*, Chichester, West Sussex, UK: John Wiley & Sons Press, 1999
  - Morgan, Marcia; *How to Interview Sexual Abuse Victims Including the Use Of Anatomical Dolls*, Thousand Oaks, CA: Sage Publications, 1995
  - Poole, Debra A; *Investigative Interviews of Children: A Guide for Helping Professionals*, Washington, DC: American Psychological Association, 1998
  - Schafer, John; Navarro, Joe; *Advanced Interviewing Techniques: Proven Strategies for Law Enforcement, Military, and Security Personnel*, Springfield. IL: Thomas Books, 2003
  - Shuy, Roger W.; *The Language of Confession, Interrogation, and Deception*, Thousand Oaks, CA: Sage Publications, 1998
  - Swanson, Charles R. et al; *Criminal Investigation*, Boston, MA: McGraw Hill Publications, 2003, 8th edition
  - Yeschke, Charles; *The Art of Investigative Interviewing: A Human Approach to Testimonial Evidence*, Boston, MA: Butterworth-Heinemann Press, 1997

**MANUALS USED**

- Faller, Kathleen C.; *Child Sexual Abuse: Intervention and Treatment Issues*, U.S. Department of Health and Human Services Administration for Children and Families, McLean, VA: The Circle, Inc, 1993
- Ministry of Interior, General Director of National Police, Kingdom of Cambodia; *Understanding and Investigating Child Sexual Exploitation*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2000
- Ministry of Interior, General Director of National Police, Kingdom of Cambodia; *Training Document on Child Victim Sensitivity*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2003
- Sas, Louise; *The Interaction Between Children's Developmental Capabilities and the Courtroom Environment: The Impact on Testimonial Competency*, Report prepared for the Department of Justice Canada, 2002

**OTHER MATERIALS USED**

- U. S. Department of State Trafficking in Persons Report, 2004

**WEB SITES USED**

- HTTP://www.childdevelopmentinfo.com/development/language_development.shtml
- HTTP://www.families.qld.gov.au/projectaxis/orgbooklet/development.html
- HTTP://danenet.wicip.org/dcccrsa/saissues/parent/1.html
- HTTP://www.aacap.org/publications/factsfam/develop.htm
- HTTP://www.secasa.com.au/index.php/family/12/120
- HTTP://www.earlychildhoodbehavioralhealth.com/ChildDev/sexdevelop.htl
- HTTP://www.ces.perdue.edu/providerparent/Child%20Growth-Development/SexualDEV.htm
- HTTP://www.state.gov/g/tip/rls/tiprpt/2004/34021pf.htm

- ឯកសារមេរៀនរបស់ ARTIP ២០០៩ ។

USAID
ជំនួយពីពលរដ្ឋអាមេរិក

WINROCK INTERNATIONAL

IJM

# បណ្ឌិត្យសភាណគរបាលកម្ពុជា

## កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ

# ការរៀបចំឡើងសមនាការ

២០១៧

សូមរក្សាសិទ្ធិ

មេរៀននេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការវីនរ៉ក់ ឬរដ្ឋាភិបាលអាម៉េរិក

# ការរៀបចំឡើងសវនាការ

## I. សេចក្តីផ្តើម

ភាពជោគជ័យលើការស៊ើបអង្កេតបទល្មើស គឺត្រូវបានវាស់ស្ទង់ឃើញចុងក្រោយបំផុតតាមរយៈគុណភាព និងប្រសិទ្ធភាពនៃការបង្ហាញភស្តុតាងរបស់មន្ត្រីអនុវត្តន៍ច្បាប់នៅតុលាការ ។ ដោយសារតែគោលបំណងចម្បងមួយនៃដំណើរការស៊ើបអង្កេតបទល្មើសទាំងមូល គឺដើម្បីនាំឱ្យមានការឃាត់ខ្លួន ឬចាប់ខ្លួន និងការផ្តន្ទាទោសទៅលើអ្នកប្រព្រឹត្តបទល្មើសច្បាប់ព្រហ្មទណ្ឌ ។ តម្រូវការនៃការព្រួយបារម្ភលើការបង្ហាញរឿងក្តីនៅក្នុងតុលាការ គឺមានសារសំខាន់បំផុតចំពោះអ្នកស៊ើបអង្កេតតាំងពីខណៈដែលបទល្មើសបានកើតឡើង ។ លទ្ធភាពមិនអាចយល់ដឹង និងការដែលឃើញពីគុណតម្លៃនៃតួនាទីដ៏សំខាន់បំផុត នៅក្នុងដំណើរការនីតិវិធី គឺមិនត្រឹមតែមានឥទ្ធិពលមិនល្អទៅលើវិសាលភាពរបស់អ្នកស៊ើបអង្កេតដែលជាសាក្សីប៉ុណ្ណោះទេ ប៉ុន្តែវាមានឥទ្ធិពលលើប្រសិទ្ធភាពជាអាជីពរបស់អ្នកស៊ើបអង្កេត ។

សាក្សីជានគរបាលយុត្តិធម៌ទាំងអស់មិនថាជាមន្ត្រីមិនពាក់ឯកសណ្ឋាន ឬ អ្នកស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌនោះទេ គឺត្រូវតែមានជំនាញក្នុងការធ្វើបន្ទាល់របស់សាក្សី ។ ការរៀបចំគួរតែរួមមានចំណេះដឹងខាងការគ្រប់គ្រងភស្តុតាង ។ ការធ្វើបែបនេះ មន្ត្រីអនុវត្តន៍ច្បាប់មិនត្រឹមតែមានសមត្ថភាពអាចធ្វើការនៅកន្លែងកើតហេតុបានយ៉ាងមានប្រសិទ្ធភាពនោះទេ ប៉ុន្តែថែមទាំងអាចយល់ដឹងពីនីតិវិធីនៅបន្ទប់សវនាការ និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ។ ដើម្បីរៀបចំរឿងក្តីឱ្យបានគ្រប់គាន់ អ្នកស៊ើបអង្កេតត្រូវតែយល់ដឹងវិធានអាចយកជាការបាន និងភាពទាក់ទងគ្នានឹងភស្តុតាងដែលប្រមូលបាន ។ សាក្សីដែលល្អបំផុតគឺអ្នកដែលមានការយល់ដឹងជ្រៅជ្រះ និងការឱ្យតម្លៃលើតួនាទីរបស់ខ្លួននៅក្នុងបន្ទប់សវនាការ ព្រមទាំងទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធក្នុងដំណើរការនៃនីតិវិធី ។

### ១. តួនាទីរបស់សាក្សីជានគរបាលយុត្តិធម៌

មុខងាររបស់សាក្សីនៅក្នុងបន្ទប់សវនាការ រាប់បញ្ចូលទាំងអ្នកស៊ើបអង្កេត គឺដើម្បីបង្ហាញពីការដឹងឮដំបូងបង្អស់នៃអង្គហេតុទៅកាន់អង្គជំនុំជម្រះដើម្បីធ្វើការពិចារណា ។ អ្នកស៊ើបអង្កេតត្រូវតែផ្តល់ព័ត៌មានដល់អង្គជំនុំជម្រះពីគ្រប់ហេតុការណ៍ ដែលបានស៊ើបអង្កេតនៅក្នុងរឿងក្តី និងបង្ហាញព័ត៌មាននេះឱ្យអង្គជំនុំជម្រះនូវហេតុការណ៍សំខាន់ទាំងឡាយ ។ ប៉ុន្តែអ្នកស៊ើបអង្កេតមិនអាចផ្តល់នូវសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួនបានទេ ។

ដើម្បីយល់ពីតួនាទីរបស់ខ្លួននៅក្នុងបន្ទប់សវនាការ សាក្សីក៏យល់ពីមុខងាររបស់ភាគីពាក់ព័ន្ធនៅក្នុងដំណើររឿងនៃបទល្មើសផងដែរ ។ ជាពិសេស សាក្សីត្រូវយល់ដឹងពីមុខងារអង្គជំនុំជម្រះ ដែលទាក់ទងនឹងមុខងាររបស់សាក្សី ។

មុខងាររបស់អង្គជំនុំជម្រះ គឺថ្លឹងថ្លែងអង្គហេតុដែលត្រូវបានបង្ហាញដោយដើមចោទ និងចុងចោទ ហើយបកស្រាយអង្គហេតុទាំងនោះ ដោយធ្វើការវិនិច្ឆ័យយ៉ាងត្រឹមត្រូវ និងអាចជឿទុកចិត្តបានទៅលើភស្តុតាង និងសាក្សី ក្នុងគោលបំណងទទួលឱ្យបានសេចក្តីសម្រេចមួយ ដែលពាក់ព័ន្ធ

នឹងការមានទោស ឬគ្មានទោសរបស់ជនជាប់ចោទ ។ ការទទួលខុសត្រូវរបស់ចៅក្រមមានមុខងារពីរៈ

- មុខងារជាអ្នកកាត់សេចក្តី(អាជ្ញាកណ្តាល)ដើម្បីអះអាងការប្រព្រឹត្តតាមវិធានភស្តុតាង
- បកស្រាយច្បាប់ដែលអាចយកមកអនុវត្តចំពោះអង្គហេតុនៅក្នុងរឿងក្តី ។

**២. ភាពគួរជឿបាន**

នៅក្នុងបន្ទប់សវនាការ មន្ត្រីនគរបាលមិនត្រូវបានឱ្យសិទ្ធិនៃការជឿទុកចិត្តបានជាងសាក្សីទេ ។ មន្ត្រីនគរបាលមានការទទួលខុសត្រូវស្មើៗគ្នា តាមរយៈការបង្ហាញឱ្យស្គាល់អាចារៈ ឥរិយាបថ និងខ្លឹមសារនៃបន្ទាល់ ដើម្បីធ្វើឲ្យអង្គជំនុំជម្រះជឿជាក់លើអង្គហេតុដែលជាប់ពាក់ព័ន្ធ ។

បញ្ហានៃភាពគួរជឿបាន គឺជាការព្រួយបារម្ភ ជាពិសេសចំពោះសាក្សីជានគរបាលយុត្តិធម៌ ។ មនុស្សភាគតិចណាស់ជាប្រជាពលរដ្ឋសាមញ្ញ អាចយល់ដឹងពីភាពមានទោស ឬសកម្មភាពរបស់សាក្សីនៅក្នុងបន្ទប់សវនាការ ។ ពួកគេមានការលំបាក ក្នុងការរំលឹកឡើងវិញអំពីព្រឹត្តិការណ៍ ដែលបានកើតឡើង ដោយសារពួកគេមានការប៉ះទង្គិចខាងផ្លូវចិត្ត ។ យ៉ាងណាមិញ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌរបស់មន្ត្រីនគរបាល អាចធ្វើឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំង ។ ដូច្នេះ ភាពញឹកញាប់ និងចន្លោះពេល រវាងការស៊ើបអង្កេត និងការចូលបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការ អាចធ្វើឲ្យមានការលំបាកច្រើនក្នុងការធ្វើបន្ទាល់ ។

ផ្នែកពាក់ព័ន្ធដែលមានឥទ្ធិពលទៅលើភាពគួរជឿបានរបស់សាក្សីជានគរបាលយុត្តិធម៌ មានឫសគល់ចេញពីការរំពឹងទុករបស់សាធារណជន ប្រត្យក្សារម្មណ៍ និងតួនាទីរបស់នគរបាល ។ ប្រជាពលរដ្ឋជាច្រើន សង្ឃឹមភាគតិចណាស់ទៅលើភាពល្អឥតខ្ចោះរបស់មន្ត្រីនគរបាល រួមទាំងវិសាលភាពនៃកាតព្វកិច្ចរបស់ពួកគេ និងការធ្វើបន្ទាល់នៅតុលាការ ។ ការរំលឹកការចងចាំ មិនបានល្អឥតខ្ចោះធ្វើឲ្យគេបាត់ជំនឿលើមន្ត្រីនគរបាលនោះ ។

បញ្ហាមួយទៀតដែលកើតមាននៅក្នុងភាពគួរជឿទុកចិត្តបាន របស់អ្នកស៊ើបអង្កេត គឺពាក់ព័ន្ធនឹងប្រត្យក្សារម្មណ៍របស់សមាជិកអង្គជំនុំជម្រះ ។ អំណះអំណាងដែលមានពីដំបូងរបស់សមាជិកអង្គជំនុំជម្រះ និងភាពគួរជឿទុកចិត្ត អាចត្រូវបានពង្រឹងឡើងវិញដោយមេធាវីរបស់ជនជាប់ចោទ នៅពេលធ្វើការសាកសួរសាក្សីដាក់បន្ទុក តាមរយៈការឆ្លើយតបដោយស្មោះត្រង់ និងគ្មានលម្អៀង ។

**៣. អត្តចរិតរបស់សាក្សី**

បន្ទាល់ដែលនាំឱ្យសម្រេចបានជោគជ័យរបស់អ្នកស៊ើបអង្កេត គឺត្រូវអាស្រ័យលើការរៀបចំរឿងក្តីឱ្យបានគ្រប់គ្រាន់ វិធានភស្តុតាង អង្គជំនុំជម្រះឆ្លើយតបមកវិញ ការយល់ដឹងពីដំណើរការជំនុំជម្រះ និងការរៀបចំឥរិយាបទឱ្យបានត្រឹមត្រូវគ្រប់ពេលវេលា ។ ការរៀបចំបន្ទាល់ គឺមានសារសំខាន់ខ្លាំងណាស់ ហើយវាមិនអាចបញ្ជាក់បន្ថែមឱ្យលើសពីការពិតនោះទេ ។ ចំពោះសាក្សីជានគរបាលយុត្តិធម៌ ជំហានដំបូងនៃការរៀបចំបន្ទាល់ គឺត្រូវប្រាកដថា ការស៊ើបអង្កេតត្រូវបានធ្វើឱ្យបានចប់សព្វគ្រប់ និងពេញលេញ ។ គួរចងចាំថា ការទទួលខុសត្រូវដ៏ចម្បងបំផុតរបស់អ្នកស៊ើបអង្កេតគឺមិនមែនដើម្បីដាក់ទោស ប៉ុន្តែដើម្បីស្វែងរកការពិត ។ អ្នកស៊ើបអង្កេតក៏ត្រូវរៀបចំការកត់ត្រាត្រឹមត្រូវ និងពេញលេញលើព័ត៌មាន និងភស្តុតាងដែលប្រមូលបាន ។ មុនបង្ហាញជូនតុលាការ អ្នកស៊ើបអង្កេតត្រូវតែពិនិត្យសារឡើងវិញលើកំណត់ត្រាទាំងអស់របស់សាក្សី រំលឹកព្រឹត្តការណ៍ទាំងអស់ឱ្យបាន

លម្អិតតាមដែលអាចធ្វើទៅបាន ដោយសំអាងលើកំណត់ត្រាតិចបំផុត ។ បន្ថែមពីលើកំណត់ត្រានេះដែរ វាសំខាន់ណាស់ចំពោះអ្នកស៊ើបអង្កេតគួរពិនិត្យគ្រប់របាយការណ៍ ភស្តុតាងទាំងអស់ឱ្យបានល្អិតល្អន់ និងច្បាស់លាស់ ដើម្បីធានាថា ការចងចាំរបស់ពួកគេ គឺមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។

អ្នកស៊ើបអង្កេតគួរពិនិត្យរឿងក្ដីសារឡើងវិញជាមួយតំណាងអយ្យការ ដើម្បីឱ្យដឹងពីបន្ទាល់ និងភស្តុតាងដែលអ្នកស៊ើបអង្កេតអាចផ្ដល់ឲ្យ ។ ការពិនិត្យឡើងវិញនេះ ក៏អាចផ្ដល់ឱ្យអ្នកស៊ើបអង្កេតនូវឱកាសមួយដើម្បីសិក្សាអំពីលក្ខណៈនៃសំណួរ ដែលអាចចោទសួរដោយផ្ទាល់ ។ តម្រូវការពេលវេលារបស់ព្រះរាជអាជ្ញា និងបន្ទុករឿងក្ដី ភាគច្រើន ត្រូវរៀបចំឱ្យបានស៊ីជម្រៅជាមួយសាក្សីម្នាក់ៗនូវភាពគ្មានលទ្ធភាពជាក់ស្ដែង ។

## II. ការរៀបចំដើម្បីធ្វើបន្ទាល់

ឥរិយាបថដ៏សាមញ្ញដែលអ្នកជាអាជីពមាន គឺសមត្ថភាពរបស់ពួកគេក្នុងការរៀបចំខ្លួន ដើម្បីសម្រេចបានដល់កម្រិតមួយដែលគួរឱ្យចង់បាន ។

ឧទាហរណ៍៖ អត្តពលកររួសរាន់កម្ដៅសាច់ដុំ និងធ្វើលំហាត់ប្រាណ មុនការប្រកួតប្រជែង ។ អ្នកចម្រៀងតែងតែហាត់សមសំឡេងរបស់ខ្លួនយ៉ាង ប្រុងប្រយ័ត្ន តាមរយៈការលើកដាក់សំឡេងមុនពេលឡើងឆាក ។ តារាភាពយន្តផ្ចិតផ្ចង់ទន្ទេញឈុតសម្ដែងមុនពេលវាំងននបើកឱ្យឡើងសម្ដែង ។

តាមរយៈការជំនុំជម្រះ អ្នកស៊ើបអង្កេតត្រូវតែប្រើកម្លាំងកាយ ប្រាជ្ញា និងសំឡេង ។ ដើម្បីទទួលបានជោគជ័យ ក្នុងការធ្វើបន្ទាល់នៃរឿងក្ដី មន្ត្រីនគរបាលគួរតែរៀបចំ និងត្រៀមគ្រប់ផ្នែកទាំងអស់ មុនការជំនុំជម្រះក្ដី ។ មានមេរៀនជាច្រើនបានផ្ដោតទៅលើបច្ចេកទេសនៅបន្ទប់សវនាការ ប៉ុន្តែចំពោះមេរៀននេះ ផ្ដោតលើវិធីដែលមន្ត្រីនគរបាលអាចរៀបចំធ្វើឱ្យបានប្រសើរបំផុត មុននឹងគាត់ចូលក្នុងបន្ទប់សវនាការធ្វើបន្ទាល់ ។

### ១. ការគំរាមកំហែង ឬឧបសគ្គ

មនុស្សមួយភាគធំមានការភ័យខ្លាចក្នុង ការនិយាយនៅទីសាធារណៈ ជាងការនិយាយដល់ការស្លាប់របស់ខ្លួនទៅទៀត ។ ការភ័យខ្លាចក្នុងការ និយាយនៅទីសាធារណៈ អាចបណ្ដាលឱ្យខ្លួនគេជួបប្រទះនឹងការប្រទូស្តរាយនៅក្នុងស្ថាប័ន ឬបង្កប្រតិកម្មតបណាមួយ ។ នៅពេលកំពុងទទួលរងនូវប្រតិកម្មតបនេះ ខ្លួនគេនឹងខំប្រឹងប្រែងដោយប្រើ គ្រប់ថាមពលដែលមានដើម្បីឱ្យបានធូរអារម្មណ៍តានតឹងក្នុងចិត្ត ។ ប្រតិកម្មនេះប្រឆាំងនឹងមន្ត្រីនគរបាលដែលព្យាយាមតវ៉ា និងបង្កើតឱ្យមានការជឿជាក់នៅក្នុងបន្ទប់សវនាការ ។

### ២. ការរៀបចំរឿងក្ដី

មន្ត្រីនគរបាលដែលស្គាល់ និងដឹងរឿងក្ដី ព្រមទាំងបរិយាកាស នៅបន្ទប់សវនាការកាន់តែច្រើន នោះភាពជឿជាក់នៅពេលជំនុំជម្រះក៏មានកាន់តែច្រើនផងដែរ ។ តាមរយៈការស៊ើបអង្កេតរឿងក្ដីដ៏ហ្មត់ចត់ និងវាងវៃ មន្ត្រីនគរបាលអាចទម្លាប់ខ្លួនគាត់ទៅនឹងរឿងក្ដីបានយ៉ាងល្អ ។ ដំណើរការនេះទាក់ទងនឹងការអានសំណុំរឿងច្រើនដង និងមានការប្រុងប្រយ័ត្ន ព្រមទាំងយកចិត្តទុកដាក់ខ្ពស់ ។ លើសពីនេះទៅទៀត មន្ត្រីនគរបាលគួរតែពិនិត្យបន្ទាល់របស់សាក្សីសារឡើងវិញ និងដោយ

ប្រុងប្រយ័ត្ន យ៉ាងហោចណាស់ឱ្យបានមួយដង និងចំពោះបន្ទាល់សំខាន់របស់សាក្សី យ៉ាងហោចណាស់ ២ ដង ។

ការត្រួតពិនិត្យរូបភស្តុតាងក៏មានសារសំខាន់ដែរ ។ មន្ត្រីនគរបាលមិនគួរសំអាងតែទៅលើសំណុំឯកសារ ដែលយកពីសំណុំឯកសារស៊ើបអង្កេតរបស់មន្ត្រីអនុវត្តន៍ច្បាប់ ដើម្បីយកទៅពិពណ៌នារូបភស្តុតាងឱ្យបានត្រឹមត្រូវប៉ុណ្ណោះនោះទេ ។ មានភិនភាគនៃរូបភស្តុតាងដែលប្រហែលបាត់បង់ ឬក៏ត្រូវដាក់ក្នុងក្រុមភិនភាគខុសនៅក្នុងរបាយការណ៍ ប៉ុន្តែផ្នែករូបភស្តុតាងនេះ គឺមានសារសំខាន់ណាស់ចំពោះរឿងក្តី ។ វិធីតែមួយគត់ដើម្បីរកឱ្យឃើញព័ត៌មាននេះគឺត្រូវពិនិត្យពិច័យដោយប្រុងប្រយ័ត្ន និងដោយផ្ទាល់ទៅលើរូបភស្តុតាងនោះ ។ ត្រូវបង្កើនការប្រុងប្រយ័ត្នក្នុងការថែរក្សាភស្តុតាងដើម្បីការពារការបាក់បែក ឬខូចខាតតម្លៃរបស់ភស្តុតាង ។

### ៣. ការហាត់សម

នៅពេលមន្ត្រីនគរបាលបានរកឃើញអាថ៌កំបាំងណាមួយ នៅក្នុងរឿងក្តីតាមរយៈការត្រួតពិនិត្យរបស់គាត់មុនជំនុំជម្រះ នោះជំហានបន្ទាប់របស់គាត់ គឺត្រូវសម្រួលអារម្មណ៍ ពេលនៅក្នុងបន្ទប់សវនាការ ។ ចូរពិចារណាឱ្យបានល្អិតល្អន់ពីប្រភេទនៃសំណួរដែលនឹងត្រូវចោទសួរ និងត្រូវគិតទុកជាមុននូវចម្លើយរបស់អ្នក ។ ការហាត់ត្រៀមនេះនឹងអនុញ្ញាតឱ្យមន្ត្រីនគរបាលមានឱកាសគិតពីចម្លើយដែលគួរឆ្លើយ និងធ្វើឲ្យពួកគេប្រាកដថា ពួកគេកំពុងស្ថិតនៅក្នុងបរិបទត្រឹមត្រូវមួយ ។ ក្រៅពីចម្លើយទាំងនោះ ព័ត៌មានគួរតែពិត "ជានិច្ច" ដោយមិនគិតដល់ផលវិបាកនៅពេលក្រោយឡើយ (ប្រសិនបើអ្នកស៊ើបអង្កេតរៀបចំនឹងប្រើវេទិកាក្រាមនៅក្នុងបន្ទប់សវនាការ គាត់អាចហាត់សមនិយាយពីអត្ថប្រយោជន៍របស់វា ជាមួយមេធាវីមុនជំនុំជម្រះក្តី) ។ ការធ្វើបែបនេះនឹងមិនត្រឹមតែជួយធានាឱ្យទទួលបានការបង្ហាញដ៏ត្រឹមត្រូវនៅមុខសមាជិកចូលរួមប៉ុណ្ណោះទេ ប៉ុន្តែវានឹងកាត់បន្ថយការភ្លេចភ្លាំងនូវចំណុចសំខាន់ៗនៃបន្ទាល់របស់ពួកគេ ។

មន្ត្រីនគរបាលស្មានទុកជាមុននូវសំណួរ ដែលអាចមានប្រតិកម្មតបពីមេធាវីរបស់ជនជាប់ចោទ និងការគិតពីសំណួរដែលជនជាប់ចោទសួរ ។ ជាពិសេស អ្នកស៊ើបអង្កេត គឺជាអ្នកដឹងពីរបៀបរៀបចំ រឿងក្តី និងភស្តុតាងច្រើនបំផុត ។

### ៤. មុនដំណាក់កាលជំនុំជម្រះ

បន្ថែមពីលើការរៀបចំបន្ទាល់របស់គាត់ឱ្យបានហ្មត់ចត់ មន្ត្រីនគរបាលត្រូវរៀបចំឥរិយាបថចិត្ត និងពាក្យសម្តី ដើម្បីឆ្លើយតបនៅពេលធ្វើបន្ទាល់ ។ មន្ត្រីនគរបាលត្រូវអត់ធ្មត់ និងវាងវៃ ដើម្បីទទួល ឱ្យបានព័ត៌មាននៅពេលជំនុំជម្រះក្តី ។ ដើម្បីទទួលឱ្យបានលទ្ធផលល្អ មន្ត្រីនគរបាលគួរសម្រាន្តយប់ឱ្យបានគ្រប់គ្រាន់ មុនថ្ងៃជំនុំជម្រះក្តី ។ អសមត្ថភាពរបស់មន្ត្រីនគរបាលក្នុងការរក្សាភាពវាងវៃនៅអំឡុងពេលជំនុំជម្រះក្តីនឹងបាត់គុណប្រយោជន៍ដែលទាញបានពីការរៀបចំបន្ទាល់ ។ គន្លឹះចំពោះអ្នក ដែលមានបញ្ហាគេងមិនលក់នៅមុនថ្ងៃជំនុំជម្រះរួមមាន ៖

- ចូលដំណេកទៀងទាត់តាមពេលដែលធ្លាប់បានចូលគេង
- អានសៀវភៅកំសាន្ត មុនចូលដំណេក
- ហាត់ប្រាណឱ្យបានទៀតទាត់ ។

## ៥. ដំណាក់កាលជំនុំជម្រះ

នៅពេលព្រឹកថ្ងៃជំនុំជម្រះ មន្ត្រីនគរបាលគួរមានពេលបន្ថែមឱ្យបានគ្រប់គ្រាន់ក្នុងការរៀបចំខ្លួន រាប់បញ្ចូលទាំងពេលវេលាទទួលទានអាហារពេលព្រឹកឱ្យបានគ្រប់គ្រាន់ ។ លើសពីនេះទៅទៀត វាជាការប្រសើរណាស់ក្នុងការខ្ចប់អាហារស្រស់ស្រួបដែលមានថាមពលខ្ពស់ សម្រាប់បរិភោគនៅពេលសម្រាក ។ ជាចុងបញ្ចប់ មន្ត្រីនគរបាលមិនត្រូវភ្លេចផឹកទឹក ភេសជ្ជៈ អំឡុងពេលជំនុំជម្រះ ដើម្បីរក្សាជាតិសំណើមក្នុងខ្លួន ។

ការក្រោកពីដំណេកពីព្រឹកព្រលឹម មិនត្រឹមតែអនុញ្ញាតឱ្យពេលវេលាអ្នកស៊ើបអង្កេតត្រៀមខ្លួនជាស្រេចនៅក្នុងលក្ខណៈមួយដែលធ្វើតាមសម្រួល និងមិនប្រញាប់ប្រញាល់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏អនុញ្ញាតឱ្យគាត់ទៅដល់បន្ទប់សវនាការមុនពេលផងដែរ ។ ការទៅដល់បន្ទប់សវនាការមុន ជាការសំខាន់ណាស់ ដោយសារវាអនុញ្ញាតឱ្យមន្ត្រីនគរបាលមានពេលវេលាគ្រប់គ្រាន់ ក្នុងការរៀបចំកិច្ចការ និងគំនិតរបស់គាត់បានដោយមានរបៀប ។ ជាពិសេស មន្ត្រីនគរបាលគួរទៅដល់តុលាការឱ្យបានមុនចាប់ពី ៤៥ នាទីទៅ ១ ម៉ោង ។

ជំហានចុងក្រោយដែលពាក់ព័ន្ធ គឺការធ្វើលំហាត់ខ្សែសំឡេង ។ ដើម្បីធ្វើលំហាត់ខ្សែសំឡេងឱ្យបានពេញលេញ មន្ត្រីនគរបាលគួរប្រើទាំង "ការបញ្ចេញសំឡេង" និង "ការបន្ទរសំឡេង"។

ការហាត់បញ្ចេញសំឡេងរួមមានៈ

- ការហាត់សំឡេងផ្លាស់គ្នាដោយធ្វើមុខឱ្យជារាងកណ្តាប់ដៃតូច ហើយបន្ទាប់មក ហាមាត់ឱ្យធំ ដោយលានអណ្តាតចេញមកក្រៅ
- ការធ្វើសំឡេង "ស្រែក" ដោយឱ្យចេញតាមប្រហោងបបូរមាត់ និងអណ្តាត
- និយាយឡើងវិញនូវពាក្យចុងជួន ។

ការធ្វើលំហាត់សំឡេងទាំងនេះនឹងបង្កើនលំដាប់ និងទីតាំងសំឡេង ។ ចំណុចល្អស្តីពីការហាត់សំឡេង គឺថាមន្ត្រីនគរបាលអាចហាត់វានៅក្នុងឡាន នៅពេលធ្វើដំណើរតាមផ្លូវទៅតុលាការ ក្នុងករណីគ្មានពេលហាត់ឱ្យបានត្រឹមត្រូវ ។ ដោយមិនគិតពីពេលណាដែលត្រូវហាត់សំឡេងនេះទេ ប៉ុន្តែទីកន្លែងហាត់សំឡេង គួរតែមានលក្ខណៈឯកជនតាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការរំខានណាមួយក្នុងការហាត់ ។

## ៦. សន្និដ្ឋាន

ថ្វីបើជំហានជាច្រើននៃការរៀបចំទំនងសមតែចំពោះតារាភាពយន្តជាងមន្ត្រីនគរបាលក៏ដោយ ប៉ុន្តែតាមពិតទៅ បន្ទប់សវនាការគឺជាឆាកពិតប្រាកដ ។ នៅឆាកនេះហើយដែលមេធាវីបង្ហាញរឿងល្ខោនស្តីពីរឿងក្តីរបស់កូនក្តីគាត់ ឬរឿងរបស់ជនរងគ្រោះ ។ ហេតុដូច្នេះហើយ វានឹងផ្តល់អត្ថប្រយោជន៍ដល់រឿងក្តី នៅពេលដែលអ្នកស៊ើបអង្កេតបានរៀបចំខ្លួន ក្នុងការនាំយកមកបង្ហាញនូវការសម្តែងដ៏ប្រសើរបំផុត ប្រសិនបើពួកគេហ៊ានចំណាយពេលវេលា និងការខិតខំប្រឹងប្រែងទៅលើការរៀបចំរឿងក្តីនៅដំណាក់កាលមុនពេលជំនុំជម្រះ ដំណាក់កាលជំនុំជម្រះ ដើម្បីរៀបចំចិត្ត និងសំឡេងរបស់ពួកគេ ។

## III. ដំណើរការនៃកិច្ចពិភាក្សាដេញដោល

### ១. ឥរិយាបថខាងក្រៅ

មន្រ្តីគួរដើរដំណើរធម្មតា នៅពេលដើរទៅកាន់កន្លែងឈរបស់សាក្សី ។ មិនត្រូវមើល ឬនិយាយទៅកាន់តំណាងអយ្យការ និងមិនត្រូវចងចិញ្ចើមដាក់ជនជាប់ចោទឡើយ ។ ប្រសិនបើអង្គជំនុំជម្រះមើលឃើញកាយវិការទាំងនោះ វាត្រូវបានបកស្រាយថា ជាសញ្ញានៃសេចក្ដីលម្អៀង ។ សាក្សីជានគរបាលយុត្តិធម៌គួរតែឈរ និងអង្គុយឱ្យត្រង់ខ្លួន បែរមុខឱ្យចំអង្គជំនុំជម្រះប្រសិនបើអាចធ្វើបាន ។ សាក្សីជានគរបាលយុត្តិធម៌មិនគួរអង្គុយគងជើងចុះឡើង ឬបញ្ចេញកាយវិការមិនសមរម្យ ។

ការប្រើក្រសែភ្នែក និងសំឡេងនិយាយ គឺជាចំណុចសំខាន់បំផុត ។ អាជ្ញាធរមានសមត្ថកិច្ចជាច្រើនប្រកែកគ្នាថា សាក្សីគួររក្សាក្រសែភ្នែកទៅលើអង្គជំនុំជម្រះ នៅពេលកំពុងឆ្លើយសំណួរ ចៀសវាងមើលទៅតំណាងអយ្យការ ឬក៏មេធាវីរបស់ជនជាប់ចោទ ។ ប្រសិនបើអង្គជំនុំជម្រះមិនអាចឮ ឬយល់ពីរឿងដែលសាក្សីកំពុងនិយាយ នោះបន្ទាល់គ្មានតម្លៃអ្វីទាំងអស់ ។ សាក្សីទាំងអស់គួរនិយាយឱ្យបានឮៗ ល្មមនឹងអាចឱ្យមនុស្សនៅក្នុងបន្ទប់សវនាការបានឮពីអ្វីដែលខ្លួនកំពុងនិយាយ ។

### ២. ការឆ្លើយសំណួរ

ជាធម្មតា សមត្ថភាពឆ្លើយសំណួរក្រោមការសាកសួរផ្ទាល់ និងការសាកសួរសាក្សី គឺត្រូវបានបង្កើតតាមរយៈបទពិសោធន៍ ។ សាក្សីជានគរបាលយុត្តិធម៌ត្រូវតែឆ្លើយដោយមិនគិតដល់មនោសញ្ចេតនា ឬភាពលម្អៀង ត្រូវមានគំនិតវិជ្ជមាន និងកាន់គោលជំហរឱ្យរឹងមាំក្នុងការឆ្លើយសំណួរទាំងអស់ ។ សាក្សីដែលឆ្លើយពង្វាងសំណួរ ធ្វើឱ្យមានផលអាក្រក់ដល់រឿងក្ដី ហើយបន្ទាល់បែបនេះ គឺជាការភូតភរ និងត្រូវបានលាតត្រដាង នៅពេលមេធាវីការពារជនជាប់ចោទធ្វើការសាកសួរ ។ គួរចងចាំថា ការភ័ន្តច្រឡំតែងតែមាន ហើយជាធម្មតា សាក្សីជានគរបាលយុត្តិធម៌អាចធ្វើឲ្យមានកំហុសខ្លះៗនៅក្នុងបន្ទាល់ ។ ការទទួលកំហុសនឹងត្រូវបានលើកយកមកពិភាក្សាពន្យល់ ហើយបើកំហុសនោះមិនបានបកស្រាយរហូតដល់បញ្ចប់ការធ្វើបន្ទាល់ សាក្សីស្នើសុំភ្លាមៗទៅចៅក្រមជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ចំពោះកំហុសនោះ ដើម្បីកែតម្រូវ ។

សាក្សីត្រូវតែចៀសវាងប្រើប្រាស់ឃ្លាដូចជា "ខ្ញុំគិតថា ខ្ញុំជឿជាក់ថា ឬក៏តាមអ្វីដែលខ្ញុំនឹកឃើញ និងចាំបាន" ។ វាជាការលំបាកក្នុងការចៀសវាងប្រើប្រាស់ឃ្លាទាំងនេះ ព្រោះឃ្លាទាំងនេះជាឃ្លាដែលប្រើជារៀងរាល់ថ្ងៃ ។ ប៉ុន្តែនៅក្នុងតុលាការ ពួកគេអាចចោទសួរពីភាពជាក់លាក់នៃបន្ទាល់របស់មន្ត្រី និងអាចជាមូលដ្ឋានមួយនៃភាពគួរជឿបានរបស់បន្ទាល់ដោយអង្គជំនុំជម្រះ ។ មានវិធីសាស្ត្រជាមូលដ្ឋានពីរដែលយកទៅសួរសាក្សី ៖

- **បច្ចេកទេសនិទានកថា** អនុញ្ញាតឱ្យសាក្សីប្រាប់ពីអង្គហេតុ ដោយប្រើពាក្យសំដីរបស់ខ្លួន ដូចអ្វីដែលគេបានដឹង ដើម្បីឆ្លើយនឹងសំណួរ ។ បច្ចេកទេសនេះត្រូវបានប្រើក្នុងករណីដែលអ្នកត្រួតពិនិត្យស្គាល់សាក្សីច្បាស់ ហើយមានជំនឿទុកចិត្តថា សាក្សីនឹងនិយាយអ្វីដែលទាក់ទង និងមិនប្រឆាំង ។ បច្ចេកទេសនិទានកថា អនុញ្ញាតឱ្យសាក្សីនិយាយតាមលំដាប់លំដោយនៃពេលវេលាឱ្យបានលម្អិត ព្រមទាំងឱ្យបានច្បាស់លាស់ នៅចំពោះមុខអង្គជំនុំជម្រះ ។ សាក្សីដែលគ្មានបទពិសោធន៍ អាចនិយាយឥតចុង ឥតដើម ផ្ដល់បន្ទាល់ដែលធ្វើឱ្យមានការជំទាស់ប្រឆាំង និងមិនទាក់

ទង ឬថ្លែងប្រាប់ អង្គជំនុំជម្រះនូវភស្តុតាង ដែលបានមកដោយអំពើទុច្ចរិតផ្សេងទៀត ពិសេសបង្កឱ្យដំណើរការជំនុំជម្រះ និងការសម្រេចរឿងក្តីមិនត្រឹមត្រូវ ។

- **បច្ចេកទេសសួរ និងឆ្លើយ** អនុញ្ញាតឲ្យមេធាវីអាចសួរសំណួរចង្អុលបង្ហាញ តែមួយគត់ដើម្បីទទួលបានចម្លើយ ។ នៅពេលប្រើបច្ចេកទេសសួរ និងឆ្លើយ សាក្សីជានគរបាលយុត្តិធម៌គួរគិតពិចារណា មុននឹងឆ្លើយ ។ ការធ្វើបែបនេះនឹងអនុញ្ញាតឱ្យមេធាវីម្ខាង ទៀតលើកយោបល់ទំនាស់ ។ វាក៏អាចផ្តល់ឱកាសដល់សាក្សី វិភាគសំណួរឱ្យ បានច្បាស់ថា គាត់បានយល់សំណួរច្បាស់លាស់ ។ ប្រសិនបើមិនច្បាស់ សាក្សីអាច ចោទសួរទៅវិញបាន ។

ភាសារបស់សាក្សីគួរជាភាសាអាចស្តាប់បាន និងងាយយល់ចំពោះអង្គជំនុំជម្រះ ។ សាក្សីជានគរបាលយុត្តិធម៌គួរចៀសវាងកុំប្រើពាក្យ ឬភាសាសម្ងាត់ ដែលមានប្រើនៅក្នុងអង្គភាពនគរបាល ដែលអង្គជំនុំជម្រះមិនអាចយល់បាន ។ ពាក្យអាសគ្រាម(អាសអាភាស)គួរកុំប្រើនៅក្នុងបន្ទប់សវនាការ ប្រសិនបើសាក្សីមិនដកស្រង់សំដីផ្ទាល់របស់នរណាម្នាក់ ។ ប្រសិនបើមានករណីនេះកើតឡើង សាក្សីគួរកុំស្ទាក់ស្ទើរប្រើពាក្យជាក់លាក់ណាមួយ ដែលត្រូវបានប្រើក្នុងអំឡុងពេលស៊ើបអង្កេត ។

ជួនកាល ចម្លើយ "បាទ ឬ ចាស" ឬ "ទេ" សាក្សីអាចប្រើបានដែរ ពិសេសនៅពេលសួរភាគីសាក្សី ។ ជួនកាលចម្លើយបែបនេះ មិនអាចជាចម្លើយត្រឹមត្រូវចំពោះសំណួរទេ ។ ប្រសិនបើមានសាក្សីមិនគួរមានអារម្មណ៍មួម៉ៅចំពោះចម្លើយត្រឹមត្រូវ ដើម្បីផលប្រយោជន៍នោះទេ ។ សាក្សីតែងតែត្រូវបានអនុញ្ញាតឱ្យបកស្រាយចម្លើយ ប្រសិនបើមានករណីចាំបាច់ត្រូវសុំចៅក្រមជំនុំជម្រះ ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ អនុញ្ញាតឱ្យពន្យល់ចម្លើយ ។ ប៉ុន្តែ ប្រសិនបើសំណួរអាចត្រូវបានឆ្លើយតបបានត្រឹមត្រូវដោយពាក្យ "បាទ ឬ ចាស" ឬ "ទេ" សាក្សីគួរឆ្លើយតបទៅតាមកាលៈទេសៈនោះ ។

### ៣. ការដើរចេញពីកន្លែងឈររបស់សាក្សី

របៀបដែលសាក្សីដើរចេញពីកន្លែងឈរ គឺមានលក្ខណៈសំខាន់ដូចបែបបទដែលពួកគេដើរចូលដែរ ព្រោះថាអង្គជំនុំជម្រះតែងតែសម្លឹងមើលពួកគេ ។ វាជាការខុសឆ្គងចំពោះសាក្សីដែលក្រោកឈរ ហើយចាកចេញពីកន្លែង នៅពេលបញ្ចប់ការសាកសួរភាគីសាក្សី ។ អង្គជំនុំជម្រះអាចធ្វើការសាកសួរដោយប្រយោល ឬមេធាវីរបស់ជនជាប់ចោទអាចគិតដល់សំណួរនាទីចុងក្រោយ ។ ក្នុងអំឡុងពេលនេះ សាក្សីគួរប្រុងប្រយ័ត្នកុំឱ្យគេចាប់ចំណុចសង្ស័យបាន ។ បច្ចេកទេសដ៏សាមញ្ញនៅក្នុងការសាកសួរភាគីសាក្សី គឺត្រូវសួរសំណួរនាទីចុងក្រោយ នៅពេលសាក្សីកំពុងត្រៀមខ្លួនដើរចេញពីកន្លែង ដោយសង្ឃឹមថា នឹងចាប់ចំណុចសង្ស័យពីសាក្សីបាន បន្ទាប់ពីគាត់កំពុងស្ថិតក្នុងភាពតានតឹងក្នុងការធ្វើបន្ទាល់ដែលរៀបនឹងចប់ ។ សាក្សីគួររង់ចាំការអនុញ្ញាតដោយចៅក្រម និងគួរចាកចេញពីបន្ទប់សវនាការដោយភាពម៉ឺងម៉ាត់ ទន់ភ្លន់ (កុំនិយាយ ឬសម្លឹងមើលទៅនរណាម្នាក់ឡើយ) ។

## IV. ការប្រើប្រាស់សម្លៀកបំពាក់នៅតុលាការ

### ១. ទិដ្ឋភាពទូទៅ

- ស្លៀកពាក់ឯកសណ្ឋាន
- ស្លៀកពាក់ស្អាតបាត

- ប្រសិនបើអ្នកមានជម្រើស ចូរឱ្យអ្នកដទៃដែលចូលរួមក្នុងតុលាការស្លៀកពាក់ឱ្យបានសមរម្យដូចអ្នកដែរ
- រក្សាភាពមានសណ្តាប់ធ្នាប់
- កុំលាបប្រេងម្សៅ ឬពាក់វ៉ែនតាខ្មៅនៅក្នុងបន្ទប់សវនាការ (គេនឹងមិនជឿទុកចិត្តអ្នកទេ ប្រសិនបើពួកគេមិនអាចមើលឃើញភ្នែករបស់អ្នក)
- ចូរពាក់តែគ្រឿងអលង្ការដែលមានន័យចំពោះអ្នក ហើយអ្នកមិនអាចដោះបាន
- កុំពាក់របស់ដែលតំណាងឲ្យជំនឿ ឬសញ្ញាតំណាងបក្សនយោបាយ អាចបង្កការរើសអើងប្រឆាំងនឹងអ្នកនៅក្នុងចិត្តរបស់សមាជិកអង្គជំនុំជម្រះ
- ចូរចាំថា ថ្វីបើវាជាកំហុសដ៏តិចតួចមួយ ដែលមាននៅលើរូបរាងកាយរបស់អ្នកក៏ដោយ ក៏ត្រូវបានកត់ចំណាំដោយនរណាម្នាក់នៅក្នុងអង្គជំនុំជម្រះដែរ ហើយវាអាចប៉ះពាល់ដល់ភាពដែលគួរជឿទុកចិត្តបានរបស់អ្នក ។

**២. អ្វីដែលមិនគួរស្លៀកពាក់**

- ខោខ្លី អាវអត់ដៃ អាវរំភើយ
- សម្លៀកបំពាក់ដែលមានពាក្យ ឬរូបភាពដែលទាក់ទងនឹងការប្រមាថមើលងាយ ទាបថោក សិចស៊ី អាសអាភាស
- មួក
- សម្លៀកបំពាក់កខ្វក់ រហែក ឬដាច់រយ៉េរយ៉ៃ ។

### ៣. ការត្រួតពិនិត្យសន្តិសុខ

អ្នកតម្រូវឱ្យឆ្លងកាត់កន្លែងឆែកឆេរ ដែលប្រើប្រដាប់ត្រួតពិនិត្យ នៅពេលចូលទៅក្នុងតុលាការ ។ ប្រសិនបើមានការត្រួតពិនិត្យ កាបូបអាចអនុញ្ញាតឱ្យកាន់ចូលតុលាការបាន បន្ទាប់ពីត្រូវបានពិនិត្យ ។ កុំកាន់កាបូប ឬវត្ថុដែលមិនចាំបាច់ច្រើនពេកចូលក្នុងតុលាការ ព្រោះវាអាចពន្យឺតការត្រួតពិនិត្យសន្តិសុខ លើកលែងតែការអនុញ្ញាតឱ្យចូលមុនត្រូវបានអនុញ្ញាតដោយតុលាការ ។

## V. លំហាត់អនុវត្ត

ចូរបំបែកសិក្ខាកាមជាពីរក្រុមតូចៗដែលមានសមាជិកពី ៤-៦ នាក់ក្នុងក្រុមតូចនីមួយៗ ។ ចូរឱ្យក្រុមនីមួយៗ ធ្វើលំហាត់មេរៀនស្តីពីការហាត់ប្រាណដែលទើបបានបង្រៀន ។

ចូរឱ្យសិក្ខាកាមម្នាក់នៅក្នុងក្រុមតូចៗចោទសំណួរគ្នាទៅវិញទៅមក ដើម្បីអនុវត្តពីវិធីឆ្លើយសំណួរ ។ ជំរុញសិក្ខាកាមឱ្យបង្កើតការតទល់គ្នាទៅវិញទៅមក ក្នុងករណីចម្លើយរបស់ពួកគេមានលក្ខណៈមិនជាអាជីព ឬមិនពេញលេញ ។ គោលបំណង គឺចង់ឱ្យសិក្ខាកាមទាំងអស់មានអារម្មណ៍ល្អក្នុងការនិយាយ និងថ្លែងពីអ្វីមួយដោយប្រើពាក្យសំដីរបស់ខ្លួន ។ ទាំងនេះគ្រាន់តែជាសំណួរចាប់ផ្តើមប៉ុណ្ណោះ ការបន្ថែមអ្វីផ្សេងៗទៀត គឺអាស្រ័យលើចំនួនសិក្ខាកាម និងការយល់ដឹងរបស់គ្រូបង្គោលពីបុគ្គលលក្ខណៈរបស់សិក្ខាកាម ។

- ឈ្មោះ ឋានៈ និងអង្គភាព
- គោលបំណង
- លទ្ធផលរំពឹងទុករបស់សិក្ខាកាម

## VI. របៀបរៀបចំសាក្សីធ្វើបន្ទាល់

នៅពេលជំនុំជម្រះ រឿងក្តីជាច្រើនអាស្រ័យលើប្រត្យក្សារម្មណ៍របស់សមាជិកអង្គជំនុំជម្រះទៅលើសាក្សីសំខាន់ ។ ចំណាប់អារម្មណ៍ដែលសាក្សីបង្កើត អាចមានឥទ្ធិពលដល់ការសម្រេចចិត្តក្នុងការត្រៀមខ្លួនធ្វើបន្ទាល់ ។ ជាអកុសល សាក្សីដែលមិនយល់ដឹងពីនីតិវិធី ឬក៏សារសំខាន់នៃបន្ទាល់របស់ខ្លួន អាចធ្វើឲ្យមានអារម្មណ៍ភ័យខ្លាច និងច្របូកច្របល់ ។

ការរៀបចំសាក្សីមិនចាំបាច់មានកិច្ចការច្រើនលើសលុបនោះទេ ។ ភាគច្រើនកិច្ចការនេះគឺជាបន្ទុករបស់មេធាវីការពាររឿងក្តី ។ ប៉ុន្តែអ្នកស៊ើបអង្កេតជានគរបាល ត្រូវតែយល់ពីនីតិវិធី ដើម្បីជួយនៅពេលត្រូវការ ។ ជារឿយៗ អ្នកស៊ើបអង្កេតជានគរបាល បានបង្កើតទំនាក់ទំនងជាមួយសាក្សីតាំងពីមានការស៊ើបអង្កេតបឋម ។ ភាពស្និទ្ធស្នាលនឹងជួយបង្កភាពងាយស្រួលដល់សាក្សី ហើយអនុញ្ញាតឱ្យពួកគេផ្តោតសំខាន់ទៅលើបន្ទាល់ ។ ការត្រៀមខ្លួនរបស់សាក្សីអាចចែកជា ៣ ដំណាក់កាលៈ

### ១. ដំណាក់កាលទី ១

ពាក់ព័ន្ធនឹងការបង្ហាញសាក្សីឱ្យស្គាល់ពីបន្ទប់សវនាការ រួមមានការណែនាំពីតួនាទីរបស់អ្នកចូលរួមក្នុងបន្ទប់សវនាការ និងវិធានភស្តុតាងជាមូលដ្ឋានដែលពាក់ព័ន្ធនឹងបន្ទាល់ ។

សាក្សីយល់ដឹងត្រួសៗពីវិធានសំខាន់ៗ នៃការសាកសួរ ព្រមទាំងវិធីជំទាស់ដែលទំនងនឹងកើតឡើង ។ សាក្សីគួរធ្លាប់ឆ្លងកាត់ការអប់រំ ដើម្បីយល់ពីនីតិវិធី និងមានការរំដួលចិត្ត នៅអំឡុងពេលសាកសួរ ។

ការជួយសាក្សីឲ្យយល់ពីមូលហេតុជាចំហ និងសម្ងាត់នៃវិធីជំទាស់ អាចឱ្យពួកគេទទួលបានការជឿជាក់ទៅលើបន្ទាល់ ។ នៅពេលការជំទាស់ដែលបានគ្រោងទុកត្រូវបានលើកឡើង នោះពួកគេមានអារម្មណ៍ដឹង និងជឿជាក់ ។ គ្រប់កត្តាសំខាន់ៗទាំងអស់ក្នុងការកាត់បន្ថយភាពច្របូកច្របល់ នៅក្នុងស្ថានការណ៍ណាមួយ គឺសុទ្ធតែទាក់ទងនឹងការដែលស្ថិតនៅ "ពេលធ្វើបន្ទាល់"។

សាក្សីដែលធ្លាប់មានការយល់ដឹងពីនីតិវិធីនៅតុលាការ ជារឿយៗវាជាការរំលឹក ។ ចំពោះសាក្សីថ្មី មេរៀននិងការណែនាំទាំងនេះមានសារសំខាន់ និងជាជំនួយមួយដល់គាត់ ។ សាក្សីជាច្រើនដែលមិនយល់ដឹងពីនីតិវិធីតុលាការ អាចមិនហ៊ាន និងភ័យខ្លាចក្នុងការធ្វើបន្ទាល់ ហើយនឹងមិនសួរសំណួរជាមូលដ្ឋាននោះទេ ។ ហេតុនេះហើយ វាជាការសំខាន់ណាស់ ដែលព័ត៌មានអង្គហេតុត្រូវផ្តល់ឱ្យច្បាស់លាស់ និងមានប្រសិទ្ធភាព ។

### ២. ដំណាក់កាលទី ២

ចំណាប់អារម្មណ៍សំខាន់គឺផ្តោតទៅលើ "មាតិកា" នៃបន្ទាល់របស់សាក្សី ។ តាមរយៈការបង្ហាញសេចក្តីសង្ខេប ដោយភ្ជាប់ជាមួយសេចក្តីលម្អិត ទៅនឹងចំណុចរបស់គម្រោងនៃសេចក្តីសង្ខេប

ដ៏ត្រឹមត្រូវ សាក្សីអាចយល់ពីសភាពនៃបន្ទាល់ ។ វាជាការសំខាន់ណាស់ដែលសាក្សីយល់ពីគំនិតនៃកម្មវត្ថុបន្ទាល់របស់ខ្លួន ។ ការត្រួតពិនិត្យពីបន្ទាល់របស់សាក្សីណាម្នាក់ដោយចោទសួរពីសំណួរមួយទៅសំណួរមួយ ហើយមិនបានគិតទៅដល់បរិបទទាំងមូល អាចបណ្ដាលឱ្យសាក្សីច្របូកច្របល់ និងមិនអាចឆ្លើយតបដោយប្រសិទ្ធភាពក្នុងអំឡុងពេលសាកសួរភាគីសាក្សី ។ បើយល់ពីដំណើររឿងក្ដី និងពីរបៀបដែលធាតុផ្សំមួយនៃបន្ទាល់ទាក់ទងទៅនឹងដំណើររឿងក្ដី សាក្សីនឹងអាចចេះដោះស្រាយ ។

### ៣. ដំណាក់កាលទី ៣

នៅពេលសាក្សីយល់ពីនីតិវិធីក្នុងបន្ទប់សវនាការ ក៏ដូចជាកម្មវត្ថុនៃបន្ទាល់ ជារឿយៗក៏មានសាក្សីភាគច្រើនមិនយល់អ្វីសោះ ទាក់ទងនឹងរបៀបទំនាក់ទំនងឱ្យមានប្រសិទ្ធភាព ។ ការធ្វើបន្ទាល់របស់សាក្សី គឺជាបទពិសោធន៍ដ៏ពិសេសមួយ ហើយវាខុសពីស្ថានភាពនិយាយនៅមុខមហាជន ។ សាក្សីត្រូវការណែនាំពីការប្រាស្រ័យទាក់ទងគ្នានៅក្នុងបន្ទប់សវនាការ ។

មានរឿងជាច្រើនដែលសាក្សីគួរតែយល់ដឹងដែរ ។ អ្នកស្រាវជ្រាវជាច្រើន បានរកឃើញជាប្រាកដថា ចំពោះអ្នកដែលធ្វើការទំនាក់ទំនងដោយប្រើប្រាស់ពាក្យនិយាយដែលមានអំណាច គឺមានប្រសិទ្ធភាព និងគួរជឿបាន ច្រើនជាងអ្នកដែលប្រើពាក្យនិយាយដែលមិនមានអំណាច ។ ពាក្យសម្ដីខ្សោយត្រូវបានកំណត់ថាជាប្រភេទបន្ទាល់ដែលសាក្សីឆ្លើយបង្វែងដាន ឬក៏ឆ្លើយតបដោយប្រើពាក្យថា "តាមខ្ញុំស្មាន" ឬ "តាមខ្ញុំសន្និដ្ឋាន" ។ ការប្រើពាក្យផ្អែម គោរពជ្រុលចំពោះសមត្ថកិច្ចដូចជាពាក្យថា "បាទទាន" ជាសញ្ញាបង្ហាញពីពាក្យនិយាយខ្សោយ ។ អ្នកដែលប្រើពាក្យនិយាយពោរពេញដោយអំណាច មិនបង្ហាញពីចរិតបែបដូចរៀបរាប់ខាងលើ ។

សាក្សីជាច្រើនបានរាយការណ៍ថា នៅពេលសមាជិកអង្គជំនុំជម្រះមិនមើលមុខពួកគេ ពួកគេព្រួយថាបន្ទាល់របស់ខ្លួនមិនត្រូវបានទទួលស្គាល់ ។ សាក្សីត្រូវបានបង្រៀនថា ចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះ ម្ដងមាន ម្ដងអត់ ហើយមិនសំឡឹងមើលទៅសាក្សីជានិច្ចកាលនោះទេ ។

ជាការពិត មេធាវីមិនអាចប្រាប់សាក្សីណាម្នាក់នូវអ្វីដែលត្រូវនិយាយទេ ប៉ុន្តែតួនាទីរបស់មេធាវី គឺជួយឱ្យសាក្សីរៀនពីទំនាក់ទំនងឱ្យមានប្រសិទ្ធភាព ។

## VII. ការស្ដាប់ចម្លើយសាក្សីនៅក្នុងសវនាការ

### ១. ការសាកសួរដោយចៅក្រម និងតំណាងអយ្យការ

ដំណាក់កាលដំបូងនៃការចោទសួរសាក្សី គឺជាការចោទសួរដោយចៅក្រម និងតំណាងអយ្យការ ដោយប្រាប់ពីអង្គហេតុទាំងឡាយ ដែលមានប្រយោជន៍ដល់រឿងក្ដី ។ នៅក្នុងការសាកសួរដំបូង សំណួរនាំមុខមិនគួរត្រូវបានយកមកចោទសួរទេ ។ សំណួរទាំងនេះ គឺជាសំណួរដែលផ្ដល់ចម្លើយដល់សាក្សីជាស្រេច ដើម្បីឆ្លើយ ។

ឧទាហរណ៍៖ "តើបុរសដែលអ្នកឃើញបានពាក់អាវធំពណ៌ ទឹកក្រូចឬ?" ដោយជំនួសឱ្យសំណួរដែលសួរថា "តើបុរសដែលអ្នកឃើញបានស្លៀកពាក់អ្វី?" ដោយជំនួសឱ្យសំណួរ "តើបុរសនោះបញ្ចេញសកម្មភាពដូចម្ដេច?" ។

ពាក់ព័ន្ធនឹងការធ្វើឱ្យសាក្សីចងចាំឡើងវិញ វិធានទូទៅ គឺមិនត្រូវឱ្យសាក្សីនិយាយតាមភស្តុតាងនៅក្នុងបែបបទជាសេចក្ដីអំណះអំណាង ឬឯកសារដទៃទៀត ដែលត្រូវបានរៀបចំក្នុងគោល

បំណងបណ្ដឹងនោះទេ ។ យ៉ាងណាក៏ដោយ មុនពេលទៅតុលាការ សាក្សីត្រូវបានអនុញ្ញាតឱ្យរំលឹកការចងចាំពីសេចក្ដីអំណះអំណាង ។

ឯកសារអាចត្រូវបានធ្វើឡើង ឬត្រួតពិនិត្យដោយសាក្សីដើម្បីឱ្យវាក្លាយជាឯកសារមួយចេញមកពីការចងចាំរបស់សាក្សី ។ ឯកសារដែលត្រូវប្រើដើម្បីរំលឹកការចងចាំរបស់សាក្សី គឺមិនមែនជាភស្តុតាងទេ ។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះអាចពិនិត្យឯកសារនោះបាន បន្ទាប់មកសាក្សីអាចត្រូវបានសាកសួរទាក់ទងនឹងឯកសារនោះ ។

**២. ការសាកសួរដោយមេធាវី**

ការសាកសួរសាក្សីដោយមេធាវី មិនដូចការសាកសួរដំបូងទេ ព្រោះអាចចោទសួរដោយប្រើសំណួរនាំមុខ ។ សំណួរទាំងអស់ត្រូវបានចោទសួរដើម្បីស្ទង់ការចងចាំរបស់សាក្សី ឬភាពពិតប្រាកដ និងអាចបញ្ចុះបញ្ចូល ឬតទល់គ្នា ។

វិធានទូទៅ គឺគ្រប់សាក្សីទាំងអស់ អាចត្រូវបានសាកសួរដោយមេធាវីការពារជនជាប់ ចោទ ។ បើមេធាវីការពារជនជាប់ចោទមិនបានធ្វើការសាកសួរសាក្សីទេ គេនឹងទទួលយកភស្តុតាងដែលផ្ដល់ដោយសាក្សីនៅក្នុងដំណាក់កាលដំបូង ។ កម្មវត្ថុនៃការសាកសួរសាក្សី ដោយមេធាវីការពារជនជាប់ចោទ គឺដើម្បីបញ្ជាក់អង្គហេតុនូវគ្រប់ចំណុចនៃរឿងក្ដី ។

យ៉ាងណាក៏ដោយ ប្រសិនបើសាក្សីត្រូវបានគេសន្មតថា ជាអ្នកប្រព្រឹត្តខុស ឬផ្ដល់សក្ខីកម្មក្លែងក្លាយ មេធាវីការពារជនជាប់ចោទមិនអាចបង្កើតភស្តុតាងដើម្បីបង្ហាញថា មនុស្សម្នាក់កំពុងនិយាយកុហកនៅចំណុចដែលមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអង្គហេតុនៃវិវាទនោះទេ តែវាពាក់ព័ន្ធទៅលើភាពគួរជឿបានរបស់សាក្សី ។

## VIII. ការកំណត់អត្តសញ្ញាណសាក្សី

កម្រិតនៃភាពជឿជាក់បានបង្ហាញដោយសាក្សី ផ្ដល់នូវបន្ទាល់នៃការកំណត់អត្តសញ្ញាណដែលមានឥទ្ធិពល ទៅលើការវាយតម្លៃលើភាពគួរជឿបាននៃភស្តុតាង ។ សាក្សីមួយចំនួនអាចធ្វើការសម្រេចចិត្តលើការកំណត់អត្តសញ្ញាណជនសង្ស័យនៅក្នុងការស៊ើបអង្កេតរបស់នគរបាល ។ សមាជិកអង្គជំនុំជម្រះជួបតែសាក្សីមួយចំនួន ដែលបានកំណត់អត្តសញ្ញាណនៅក្នុងការស៊ើបអង្កេត ប៉ុន្តែចំពោះមន្ត្រីស៊ើបអង្កេតវិញ ពួកគេសុទ្ធតែបានជួបសាក្សីទាំងអស់ ។

មន្ត្រីនគរបាលអាចបង្កើតគំនិត ដែលពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃការសម្រេចចិត្តចំពោះការកំណត់អត្តសញ្ញាណរបស់សាក្សី និងការចាប់អារម្មណ៍ ដូច្នេះអាចមានឥទ្ធិពលទៅលើកិច្ចប្រឹងប្រែងស៊ើបអង្កេតបន្តបន្ទាប់ (ឧទាហរណ៍ ការលើកទឹកចិត្ត ឬការបំបាក់ទឹកចិត្តឱ្យមានការស៊ើបអង្កេតលើជនសង្ស័យណាម្នាក់បន្ថែមទៀត)។ គោលបំណងមួយនៃការស្រាវជ្រាវថ្មីជាច្រើនទៀត គឺដើម្បីការវាយតម្លៃរបស់អ្នកស៊ើបអង្កេត និងអ្នកចូលរួមទៅលើសុក្រិតភាពរបស់សាក្សី ។

**១. ភាពជឿជាក់របស់សាក្សី**

ហេតុអ្វីយើងចាំបាច់រំពឹងទៅលើភាពជឿជាក់របស់សាក្សី ឱ្យចង្អុលបង្ហាញលើសុក្រិតភាពរបស់ពួកគេ? ការរំពឹងទុកនេះកើតចេញមកពីបទពិសោធន៍ការងារប្រចាំថ្ងៃ ដែលចង្អុលបង្ហាញថា បុគ្គលដែលមានជំនាញនៅក្នុងការផ្ដល់នូវភាពជឿជាក់ និងសុក្រិតភាព នៅពេលដែលត្រូវបាន

ធ្វើការវិនិច្ឆ័យ ។ ដូចគ្នាដែរ ចំពោះមនុស្សមួយចំនួនដែលគ្មានជំនាញ មានភាពលម្អៀង កង្វះខាតទាំងភាពជឿជាក់ និងសុក្រិតភាព ។

**២. ការវាយតម្លៃរបស់អ្នកស៊ើបអង្កេត ទៅលើសុក្រិតភាពរបស់សាក្សី**

អ្នកស៊ើបអង្កេតជានគរបាលជួបប្រទះសាក្សីគ្រប់ប្រភេទ ចាប់ពីអ្នកដែលមិនអាចពណ៌នាជនសង្ស័យបាន រហូតដល់អ្នកដែលបានធ្វើការប្រទល់មុខជាមួយជនសង្ស័យ ។ តាមការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា គេអាចប៉ាន់ស្មានភាពជឿជាក់លើខ្លួនឯង និងសុក្រិតភាពរបស់សាក្សីក្រោយពីការកំណត់អត្តសញ្ញាណ ដែលត្រូវបានធ្វើឡើងនៅក្នុងលក្ខណៈមួយមិនលម្អៀង បន្ទាប់ពីការសាកសួរហើយ ។ នគរបាលកម្រស្នើសុំឱ្យសាក្សីធ្វើការកំណត់ភាពជឿជាក់ណាស់ ប៉ុន្តែជារឿយៗពួកគេធ្វើការវាយតម្លៃពីសុក្រិតភាពរបស់សាក្សី តាមរយៈការស្តាប់ចម្លើយ ។ ការណ៍នេះបានលើកឡើងនូវសំណួរថា តើអ្នកស៊ើបអង្កេតវាយតម្លៃលើសុក្រិតភាពរបស់សាក្សី បានយ៉ាងត្រឹមត្រូវដោយវិធីណា ?

ការសិក្សាមួយចំនួនបានវាយតម្លៃលើប្រត្យក្សារម្មណ៍របស់សមាជិកអង្គជំនុំជម្រះ ទៅលើពជឿជាក់របស់សាក្សី ។ យ៉ាងណាក៏ដោយ មានមូលហេតុជាច្រើនដើម្បីស្ទង់មើល ថាតើនគរបាលស៊ើបអង្កេតមានការយល់ដឹងពីសុក្រិតភាពរបស់សាក្សី ច្រើនជាងសមាជិកអង្គជំនុំជម្រះឬទេ ។

## IX. ការការពារសាក្សីនៅបន្ទប់សវនាការ

មូលដ្ឋានគ្រឹះលើសមភាព និងសេចក្តីសុចរិតនៃការជំនុំជម្រះ គឺជាសញ្ញាណដែលសាក្សីផ្តល់ភស្តុតាងពេញលេញត្រឹមត្រូវ និងមិនលម្អៀង ។ យ៉ាងណាក៏ដោយ សាក្សីមួយចំនួនមិនអាចធ្វើដូច្នេះបានទេ ប្រសិនបើពួកគេតម្រូវឱ្យធ្វើបន្ទាល់ធម្មតាមួយ នៅក្នុងបន្ទប់សវនាការដោយបើកចំហ ។ នៅក្នុងកាលៈទេសៈបែបនេះ ភាពយុត្តិធម៌តម្រូវឱ្យមានគ្រប់ជំហានទាំងអស់ ដើម្បីធ្វើឱ្យសាធារណជនទទួលស្គាល់ពីបន្ទាល់ ឬអត្តសញ្ញាណនៃសាក្សី ហើយផ្តល់ឱ្យសាក្សីនូវការការពារពីការចោទប្រកាន់នៅក្នុងបន្ទប់សវនាការ ។

**១. តើសាក្សីគឺជានរណា ?**

អត្ថន័យដ៏សាមញ្ញបំផុតនៃពាក្យថា "សាក្សី" គឺជាមនុស្សដែលមានវត្តមាននៅក្នុងព្រឹត្តការណ៍ណាមួយ ហើយអាចផ្តល់ព័ត៌មានពីព្រឹត្តការណ៍នោះបាន ។ សាក្សីគឺជាបុគ្គលទាំងឡាយណា ដែលបានឃើញ ដឹង ឮ នូវហេតុការណ៍អ្វីមួយកើតឡើង ហើយអាចរៀបរាប់ច្បាស់បាន ជូនសមត្ថកិច្ច និងតុលាការ ។ ម្យ៉ាងវិញទៀត សាក្សីគឺជាមនុស្សដែលមានវត្តមាន ចាំបាច់ណាស់ក្នុងការបញ្ជាក់អ្វីមួយ ឬឧប្បត្តិហេតុណាមួយជាភស្តុតាង ។ វាគ្មាននិយមន័យជាទូទៅណាមួយ ចំពោះពាក្យថាសាក្សីនោះទេ ។ ច្បាប់ផ្សេងៗបានព្យាយាមកំណត់និយមន័យសាក្សី ប៉ុន្តែគ្មាននិយមន័យណាដែលអាចផ្តល់ទិដ្ឋភាពទាំងមូលនៃពាក្យសាក្សីទេ ទោះបីក្នុងច្បាប់អន្តរជាតិក៏ដោយ ។

**២. តួនាទីជាសាក្សី**

សេចក្តីអំណះអំណាងនីមួយៗរបស់សាក្សី គឺមានសារៈសំខាន់ណាស់ ដោយសារតែវាមានអំណាចផ្លាស់ប្តូរដំណើរការរឿងក្តីទាំងមូល ។ ដូច្នេះ វត្តមានរបស់សាក្សីនៅក្នុងពេលសវនាការគឺត្រូវមានវត្តមានជាចាំបាច់ ។ ប៉ុន្តែមានសាក្សីជាច្រើនមិនមានបំណងចង់ធ្វើបន្ទាល់ក្នុងពេលសវនាការ

ស្តីពីអំណះអំណាង និងភស្តុតាង ពីព្រោះពួកគេមានអារម្មណ៍ថាគ្មានសុវត្ថិភាព ។

នៅក្នុងប្រទេសដែលគ្មានច្បាប់ទាក់ទងនឹងការការពារសាក្សី បញ្ហាកាន់តែធ្ងន់ធ្ងរឡើងមួយជាពីរ ដោយសារតែសាក្សីមានអារម្មណ៍ថាគ្មានសុវត្ថិភាព ។

### ៣. សារសំខាន់របស់សាក្សី

តួនាទីរបស់សាក្សីមានសារសំខាន់ណាស់ នៅក្នុងប្រព័ន្ធយុត្តិធម៌របស់ប្រទេសនីមួយៗ ។ រឿងក្តីព្រហ្មទណ្ឌអាចទទួលបានជោគជ័យអាស្រ័យលើភស្តុតាងទាំងស្រុង ពោលភស្តុតាងដែលទទួលយកបានតាមច្បាប់ គឺតម្រូវឱ្យសាក្សីផ្តល់ភស្តុតាងផ្ទាល់ ឬប្រយោល ។ សាក្សីជាភាគីសំខាន់មួយនៅក្នុងរឿងក្តី ក្រៅពីដើមចោទ និងជនជាប់ចោទ ។ តាមរយៈការផ្តល់ភស្តុតាងដែលជាប់ទាក់ទងនឹងការប្រព្រឹត្តិរបស់ជនល្មើស គាត់បំពេញតួនាទីដ៏សំខាន់ដើម្បីជួយតុលាការក្នុងការស្វែងរកការពិត ។ ដោយសារតែមូលហេតុនេះហើយ ដែលសាក្សីតម្រូវឱ្យធ្វើសម្បថ ។ សាក្សីមានករណីយកិច្ចជាសាធារណៈដ៏សំខាន់មួយ ដើម្បីជួយតុលាការក្នុងការសម្រេចទោសកំហុសជនជាប់ចោទនៅក្នុងរឿងក្តី ហើយត្រូវផ្តល់ព័ត៌មានទាំងអស់ឱ្យត្រឹមត្រូវ បើមិនដូច្នោះទេ សាក្សីត្រូវប្រឈមមុខនឹងផ្លូវច្បាប់ ។

តួនាទីដ៏សំខាន់របស់សាក្សី គឺបញ្ជាក់សកម្មភាពជនល្មើសនៅតុលាការ ដែលជាចំណុចដ៏ចម្បង ចំពោះប្រព័ន្ធយុត្តិធម៌ ដោយសារសេចក្តីសន្និដ្ឋានដ៏ជោគជ័យនៃដំណាក់កាលនីមួយៗ នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ផ្តើមពីសេចក្តីរាយការណ៍ដំបូងនៃបទល្មើសរហូតដល់ពេលជំនុំជម្រះក្តី ។ ពេលជំនុំជម្រះក្តី សាក្សីមានសារសំខាន់នៅក្នុងការវាយតម្លៃ ដែលអង្គជំនុំជម្រះត្រូវតែបញ្ជាក់រឿងក្តីតាមរយៈភស្តុតាងនាំមុខ ហើយវាស្ថិតនៅក្នុងទម្រង់ជាការសាកសួរផ្ទាល់មាត់ទៅលើសាក្សី ដែលត្រូវបានជំទាស់ដោយជនជាប់ចោទសម្រាប់ឱ្យសាធារណជនដឹងឮ ។

សាក្សីត្រូវបានគេទទួលស្គាល់ ជាពិសេសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដូចជា ភេរវកម្ម ការជួញដូរគ្រឿងញៀន អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសព្រហ្មទណ្ឌ ។ល។ ភាពប្រឈមរបស់សាក្សី រួមមាន ការបំភិតបំភ័យ ការគំរាមកំហែងដល់ជីវិត និងក្រុមគ្រួសារ របស់ពួកគេ ។ នៅពេលដែលសាក្សីរាយការណ៍ដល់សមត្ថកិច្ច ការស៊ើបអង្កេតត្រូវបានឆ្លើយតប ប៉ុន្តែពេលខ្លះក៏មិនបានយកចិត្តទុកដាក់ក្នុងកិច្ចការពារសាក្សីដែរ ។ ដោយឡែក សាក្សីដទៃទៀតក៏ អាចប្រឈមនឹងការលំបាកដែរ រួមមានសាក្សីចំពោះ អំពើហិង្សាក្នុងគ្រួសារ ឬទំនាក់ទំនងក្នុង សហគមន៍ ។

អង្គជំនុំជម្រះពឹងផ្អែកលើសក្ខីកម្មដោយផ្ទាល់របស់សាក្សី ដើម្បីបញ្ជាក់រឿងក្តីប្រឆាំងនឹងជនជាប់ចោទ ។ ដោយហេតុនេះហើយ ទើបសាក្សីត្រូវទទួលបានកិច្ចគាំពារ និងការពារពិសេស ។

### ៤. ការដាក់សាក្សីឱ្យនៅដោយឡែក

ជាទូទៅ សាក្សីតម្រូវឱ្យនៅក្រៅបន្ទប់សវនាការ នៅពេលពួកគេមិនទាន់ផ្តល់សក្ខីកម្ម ដើម្បីការពារសាក្សីកុំឱ្យផ្លាស់ប្តូរបន្ទាល់នៅពេលពួកគេស្តាប់ ឬឮសាក្សីដទៃទៀតដែលនៅរង់ចាំ ។ នៅក្នុងរឿងក្តីពាក់ព័ន្ធនឹងកុមារ វិធាននៃការដាក់សាក្សីឱ្យនៅដោយឡែកអាចត្រូវបានបន្ធូរបន្ថយ ។ សាក្សីជាកុមារ តម្រូវឱ្យមានអ្នកតំណាងនៅជាមួយ ដើម្បីឱ្យកុមារមានភាពកក់ក្តៅ ។ បើគ្មានការគាំទ្រ ពីអ្នកតំណាងទាំងនោះទេ នឹងអាចធ្វើឱ្យកុមារភ័យខ្លាច ហើយធ្វើឱ្យកុមារមិនអាចនិយាយបាន និងអាចធ្វើឱ្យកុមារមានបញ្ហាខាងសតិអារម្មណ៍ផងដែរ ។

## X. ការត្រៀមឯកសារមុនឡើងតុលាការ

ជោគជ័យនៃដំណើរការជំនុំជម្រះក្តី គឺទាក់ទងដោយផ្ទាល់ទៅនឹងជោគជ័យនៃការរៀបចំសំណុំរឿង ។ ចំណុច និងពេលវេលាដ៏ត្រឹមត្រូវ ដើម្បីចាប់ផ្តើមការរៀបចំសម្រាប់ការជំនុំជម្រះ លុះត្រាតែទទួលបានការអញ្ជើញដំបូង ។

**១. ការរៀបចំនៅកន្លែងកើតហេតុ**

- ធ្វើការស៊ើបអង្កេតបឋមឱ្យបានពេញលេញ
- ការពារកន្លែងកើតហេតុ និងភស្តុតាង
- កត់ត្រាសម្គីអះអាងភ្លាមៗ
- ទទួលយកឱ្យបានពាក្យអំណះអំណាងពីសាក្សី ។

**២. សាក្សី**

- សាក្សីគឺជាគន្លឹះដើម្បីឈានទៅដល់ជោគជ័យនៃការស៊ើបអង្កេត
- ការពិតនៃប្រសិទ្ធភាពរបស់នគរបាល គឺមានលក្ខណៈសាមញ្ញ
- នគរបាលបើកការស៊ើបអង្កេត នៅពេលទទួលបានព័ត៌មានថាមានបទល្មើសកើតឡើង ។

**៣. ការរៀបចំសាក្សី**

- រៀបចំសាក្សីឱ្យឡើងតុលាការ គិតចាប់ពីនៅកន្លែងកើតហេតុ
- ការប្រព្រឹត្តិ និងភាពគួរសមរបស់មន្ត្រីនគរបាល ជួយធ្វើឱ្យសាក្សីមិនមានការភ័យខ្លាច
    - កំហឹងនឹងគ្នាទៅវិញទៅមក
    - គោលជៅសងសឹករបស់ជនសង្ស័យ
    - ការពាក់ព័ន្ធនឹងនីតិវិធីច្បាប់ ដោយត្រូវចំណាយពេលវេលា និងថវិកា ។
- មន្ត្រីនគរបាលត្រូវប្រាប់សាក្សី ពីកាលបរិច្ឆេទឡើងតុលាការ ឲ្យសាក្សីរំលឹកការចងចាំរបស់ខ្លួន និងពិនិត្យមើលសេចក្តីអំណះអំណាងឡើងវិញ
- មន្ត្រីនគរបាលត្រូវប្រាប់សាក្សីឱ្យស្លៀកពាក់ និងអាចារៈ(មារយាទ)សមរម្យ
- មន្ត្រីនគរបាលគួរលើកទឹកចិត្តសាក្សី ។

**៤. ការរៀបចំសំណុំរឿងនៅអង្គភាពនគរបាល**

- ដំណើរការនៅអង្គភាព គឺជាសកម្មភាពបន្តគ្នាដែលបានចាប់ផ្តើមនៅកន្លែងកើតហេតុ
- រូបភស្តុតាងគួរធ្វើកំណត់សម្គាល់ និងដំណើរការទៅដោយប្រុងប្រយ័ត្ន
- នៅពេលការចងចាំរបស់មន្ត្រីត្រូវបានរំលឹកឃើញឡើងវិញ ការកត់ត្រាទុកគួរត្រូវត្រួតពិនិត្យ ដោយប្រុងប្រយ័ត្ន និងបំពេញឱ្យបានត្រឹមត្រូវ និងតាមលំដាប់លំដោយ
- ការសម្ភាសសាក្សីចុងក្រោយគួរធ្វើឱ្យបានចប់សព្វគ្រប់ ។

**៥. ការសម្ភាសសាក្សីនៅអង្គភាពនគរបាល**

- ត្រូវសម្ភាសសាក្សីឱ្យហ្មត់ចត់ និងទៀងពេលតាមការកំណត់
- ត្រូវពិចារណាជាសំខាន់ចំពោះមុខរបរ ការភ័យខ្លាច និងសុវត្ថិភាពរបស់សាក្សី
- ចូរចាំថា សាក្សីនឹងត្រូវបានកោះហៅឱ្យធ្វើសក្ខីកម្មនៅក្នុងតុលាការ ។ ការធ្វើសក្ខីកម្មរបស់ពួកគេ ជារឿយៗ ពាក់ព័ន្ធនឹងការវាយតម្លៃរបស់មន្ត្រីស៊ើបអង្កេត ។

**៦. មុនពេលជំនុំជម្រះក្តី**

- មន្ត្រីនគរបាលទាំងអស់គួររំលឹកការចងចាំរបស់ខ្លួន ដោយមើលកំណត់ត្រាឡើងវិញ
- មន្ត្រីនគរបាលគួរជួបជាមួយតំណាងអយ្យការ ដើម្បីពិភាក្សា និងរៀបចំរឿងក្តី
- មន្ត្រីនគរបាលគួរបញ្ជាក់អត្តសញ្ញាណភស្តុតាង និងធានាភាពយកជាការបាន នៅក្នុងតុលាការ ។

**៧. កត្តាលើកទឹកចិត្ត**

- បង្ហាញការដឹងគុណចំពោះបំណងធ្វើសក្ខីកម្មរបស់សាក្សី
- បង្ហាញការយល់ចិត្តចំពោះភាពភ័យខ្លាចរបស់សាក្សី
- ពន្យល់អំពីដំណើរការនីតិវិធីនៅតុលាការ
- បញ្ជាក់ពីតម្រូវការឱ្យសាក្សីមានភាពស្មោះត្រង់ និងសច្ចភាពក្នុងការធ្វើសក្ខីកម្ម ។

**៨. ការរៀបចំនៅបន្ទប់សវនាការ**

- មន្ត្រីនគរបាលត្រូវការពារសាក្សីទៅតុលាការ
- មន្ត្រីនគរបាលគួរអង្គុយជាមួយសាក្សីនៅក្នុងបន្ទប់សាក្សី និងទាក់ទងគ្នាដូចធម្មតា
- ចូរចាំថា សាក្សីទាំងអស់មានអារម្មណ៍ភ័យខ្លាច ។ អាចារៈស្ងប់ស្ងាត់ និងការលើកទឹកចិត្ត អាចជួយកាត់បន្ថយភាពភ័យខ្លាចរបស់សាក្សី ។

**៩. ការឆ្លើយតបទៅសំណួររបស់មេធាវី**

- សាក្សីគួររក្សាឥរិយាបថឱ្យបានសមរម្យនៅលើកន្លែងឈររបស់សាក្សី
- ឆ្លើយសំណួរទាំងអស់ដោយស្មោះត្រង់ និងសុភាពរាបសា
- ចម្លើយតបគួរឆ្លើយទៅកាន់អ្នកដែលសួរសំណួរផ្ទាល់
- ចម្លើយទាំងអស់គួរតែច្បាស់លាស់ ។

**១០. ទំនាក់ទំនងរវាងសាក្សី និងមេធាវី**

- ចម្លើយត្រូវមានលក្ខណៈស្មោះត្រង់ ។ ប្រសិនបើសាក្សីមានភាពមិនប្រាកដនឹងចម្លើយ ឬមិនដឹងចម្លើយ គួរនិយាយប្រាប់ឱ្យគេដឹង ។ ប្រសិនបើសាក្សីមានភាពច្របូកច្របល់ ដោយសារសំណួរដែលត្រូវចោទសួរ ចូរសុំឱ្យចោទសួរម្តងទៀត
- សាក្សីមិនត្រូវនិយាយផ្ទាញ់ផ្ទាលជាមួយនឹងមេធាវីទេ
- សាក្សីត្រូវតែរក្សាភាពស្ងៀមស្ងាត់ និងទឹកមុខស្មើនៅពេលធ្វើសក្ខីកម្ម ។

**១១. មូលហេតុបណ្តាលឱ្យសក្ខីកម្មបរាជ័យ**

- ឥរិយាបថ ការវាយឫក ឬអត្តចរិតមិនសមរម្យ
- ការរៀបចំធ្វើសក្ខីកម្មមិនបានល្អ
- រៀបចំខ្លួនមិនបានល្អ (រូបរាងខាងក្រៅ)

## XI. ទិដ្ឋភាពទូទៅលើអាចារៈនៅបន្ទប់សវនាការ

ជោគជ័យនៃការផ្តន្ទាទោសជនជាប់ចោទ អាស្រ័យលើការស៊ើបអង្កេត របស់មន្ត្រីនគរបាលដែលពាក់ព័ន្ធ និងអាស្រ័យលើវិធីដែលមន្ត្រីស៊ើបអង្កេតណាម្នាក់ យកមកប្រើនៅក្នុងបន្ទប់សវនាការ ។

មន្ត្រីនគរបាលត្រូវតែដឹងពីសារសំខាន់នៃវត្តមានរបស់សាធារណជន (ជាពិសេស នៅក្នុងតុលាការ) និងរក្សាការយល់ដឹងលើខ្លឹមសារតាមរយៈ សកម្មភាព និងពាក្យសំដីរបស់ពួកគេ ។ អាចារៈនៅបន្ទប់សវនាការ អាចមានឥទ្ធិពលនៅពេលអនាគត នៅក្នុងប្រត្យក្សារម្មណ៍របស់អង្គជំនុំជម្រះ ។

**១. អត្ថប្រយោជន៍នៃវិជ្ជាជីវៈនៅក្នុងបន្ទប់សវនាការ**

- ការថែរក្សាភស្តុតាង ការសម្ភាស របាយការណ៍ពេញលេញ និងត្រឹមត្រូវ អាចធ្វើឱ្យរឿងក្តីឈានដល់ការជំនុំជម្រះ
- កិត្តិនាមរបស់មន្ត្រីនគរបាល និងអង្គភាព នឹងបង្កើនឡើង ឬធ្លាក់ចុះ អាស្រ័យលើអាចារៈ និងអាកប្បកិរិយាខាងក្រៅរបស់មន្ត្រីនគរបាលនៅក្នុងបន្ទប់សវនាការ
- លទ្ធផលវិជ្ជមានអាចត្រូវបានសម្រេចនៅពេលមានការបង្ហាញខ្លួននៅតុលាការ និងកម្មវត្ថុរបស់ការជំនុំជម្រះរឿងក្តី
- មន្ត្រីនគរបាលដែលមិនបានរៀបចំខ្លួន អាចជួបភាពអាម៉ាស ដោយសារឥរិយាបថរបស់ខ្លួនមិនអាចទទួលយកបាន ឬមិនបាននិយាយឱ្យបានច្បាស់នៅពេលធ្វើបន្ទាល់
- បន្ទាល់នៅបន្ទប់សវនាការ គឺជាការធ្វើតេស្តសាកល្បងសមត្ថភាពពិត ដូចជាការគ្រប់គ្រងលើខ្លួនឯង ការវាងវៃ ការប្រព្រឹត្តិផ្ទាល់ខ្លួន ឫកពារ និងការប្រាស្រ័យទាក់ទងគ្នា ។

**២. ឥរិយាបថ និងអាចារៈ ក្នុងបន្ទប់សវនាការ**

- ចូរប្រាកដថា ត្រូវមកដល់មុនពេលកំណត់ ត្រូវរៀបចំខ្លួនរួចជាស្រេច ដើម្បីធ្វើបន្ទាល់
- ចៀសវាងការប្រើពាក្យសន្ទនាដោយប្រើសំឡេងខ្លាំង ឬសំឡេងអ៊ូអរច្រើនហួសហេតុ ។ បិទឧបករណ៍សម្រាប់កត់ត្រា និងទូរស័ព្ទមុនចូលក្នុងបន្ទប់សវនាការ
- ប្រសិនបើអ្នកពិភាក្សាអង្គហេតុនៃរឿងក្តីជាមួយទីប្រឹក្សា ឬភ្ញៀវនោះ ចូរពិភាក្សាចុះ ប៉ុន្តែត្រូវពិភាក្សាឱ្យនៅដាច់ពីគេ
- ត្រូវមានអាចារៈជាអាជីព ។

**៣. សមាសធាតុរៀបចំបន្ទាល់**

- សារសំខាន់ចំពោះបណ្តឹងព្រហ្មទណ្ឌ គឺជាការរៀបចំរបស់មន្ត្រីនគរបាលឱ្យធ្វើបន្ទាល់
- ការស្មានទុកលើសំណួរជាក់ស្តែងណាមួយ អនុញ្ញាតឱ្យរំលឹកការចងចាំស្តីពីព័ត៌មានសំខាន់ៗ
- ត្រូវចូលរួមឱ្យបានពេញលេញ នៅក្នុងរឿងក្តីដោយមានភស្តុតាង និងអង្គហេតុ ដែលពាក់ព័ន្ធ
- ធ្វើការសិក្សាលើរបាយការណ៍ ការសម្ភាស រូបថត ភស្តុតាង និងកំណត់ហេតុ ដោយប្រុងប្រយ័ត្ន ។ ការមិនបានធ្វើដូច្នេះ នឹងបណ្តាលឱ្យមានអំណះអំណាងខុស ។

**៤. ការប្រើប្រាស់ទម្រង់គំរូកំណត់ហេតុនៅអំឡុងពេលធ្វើបន្ទាល់**

- ការសម្រេចចិត្តប្រើទម្រង់គំរូកំណត់ហេតុនៅក្នុងតុលាការ ត្រូវតែពឹងផ្អែកលើការចងចាំព័ត៌មានរបស់មន្ត្រីនគរបាល ក្នុងករណីគ្មានកំណត់ហេតុ
- មន្ត្រីនគរបាលមួយចំនួនជឿជាក់ថា សមាជិកអង្គជំនុំជម្រះមានជំនឿជឿជាក់លើសំណុំ

រឿង ជាងទៅលើការចងចាំរបស់មន្ត្រីនគរបាល និងពួកគេមានអារម្មណ៍ជឿ ជាក់នៅពេលឃើញមន្ត្រីនគរបាលប្រើកំណត់ហេតុ

- ប្រសិនបើសាក្សី ឬមន្ត្រីនគរបាលមានការយល់ដឹងលើការរៀបចំកំណត់ហេតុ ដោយផ្ទាល់ដៃរបស់ពួកគេ សម្រាប់ការស៊ើបអង្កេត នោះសាក្សីគួរប្រើកំណត់ហេតុ ដើម្បី រំលឹកការចងចាំ
- យ៉ាងណាក៏ដោយ មន្ត្រីនគរបាល ឬសាក្សីប្រើកំណត់ហេតុទុកជាភស្តុតាង ។

### ៥. គោលការណ៍នៃភាពជាសាក្សី

- **ស្មោះត្រង់៖** បង្ហាញអាចារៈសមរម្យ និងចំណាប់អារម្មណ៍ស្មោះត្រង់ចំពោះអំណះអំណាងដែលមានសច្ចភាព
- **ស្សេរភាព៖** សាក្សីភាគច្រើនមិនមានចិត្តស្មុគ្រស្មាញច្របូកច្របល់ និងខ្មាស់អៀនទេ នៅពេលដែលពួកគេអាចឆ្លើយសំណួរបានច្បាស់លាស់ ។ ចូរឆ្លើយឱ្យបានខ្លី ចំចំណុច និងកុំផ្តល់ព័ត៌មាន ឬប្រកែកជាមួយមេធាវី ឬបញ្ចេញមតិដែលគេមិនចង់បាន
- **ភាពច្បាស់លាស់៖** កំហុស ភាពមិនច្បាស់លាស់ និងការច្របូកច្របល់ នឹងធ្វើឱ្យអង្គជំនុំជម្រះ គ្មានការជឿជាក់
- **កម្មវត្ថុច្បាស់លាស់៖** បង្ហាញទិដ្ឋភាពសំខាន់ៗ និងពោរពេញដោយមនសិការក្នុងភាពជាមន្ត្រីរាជការធ្វើការដើម្បីស្វែងរកភាពយុត្តិធម៌ ។ ត្រូវចេះគួរសម ឆ្លើយត្រង់ៗ និងរក្សាខ្លួនឱ្យបាននឹងនរ ។ ជារឿយៗ ជនជាប់ចោទនឹងខិតខំឆ្លើយដោះសារដើម្បី ដោះបន្ទាល់ និងព្យាយាមចោទប្រកាន់ទៅកាន់មន្ត្រីនគរបាលស៊ើបអង្កេត
- **ការគ្រប់គ្រងអារម្មណ៍រំជួលចិត្ត៖** កុំយកចិត្តទុកដាក់ការប្រមាថ ការសួរដេញដោល ពាក្យបញ្ឆិតបញ្ឆៀង និងការបញ្ចេញកំហឹង ដែលអាចប៉ះពាល់ដល់ភាពគួរឱ្យ ជឿទុកចិត្ត
- **ការឆ្លើយសំណួរ៖** មន្ត្រីនគរបាលគួរឆ្លើយតែសំណួរណាដែលពួកគេអាចឆ្លើយរួច ។ ការឆ្លើយថា "ខ្ញុំមិនដឹងទេ" មិនមែនមានន័យថា ការព្រងើយកន្តើយនោះទេ ហើយសាក្សីត្រូវឆ្លើយបែបនេះ ដោយសារមិនបានពិនិត្យអង្គហេតុផ្ទាល់ ។ ចម្លើយនេះនឹង ធ្វើឲ្យមេធាវីរបស់ជនជាប់ចោទមិនអាចសួរសំណួរបន្ថែមទៀតបាន ពាក់ព័ន្ធនឹង អង្គហេតុដែលមិនបាននិយាយ ។ ឃ្លាដែលថា "ទាំងអស់នោះគឺជាអ្វីដែលខ្ញុំចាំបាន" អាចជាឃ្លាដ៏សមស្រប ។ ឃ្លាថា "ខ្ញុំមិនចាំ" មានន័យថាសាក្សីមិនប្រាកដ ។ ចៀសវាង បង្ហាញភាពមួម៉ៅ ការយល់ខុស ការរៀបចំអន្ទាក់ ។ ត្រូវមានជំហរលើសេចក្តីពិតនៃរឿងក្តី ដោយចៀសវាងការនិយាយអះអាងខុសពីការពិត និងបង្កវិវាទនៅក្នុងបន្ទាល់ ។ ភស្តុតាងជាគំនិតគួរធ្វើឡើងដោយពឹងផ្អែកលើការពិត ។ ចូរយល់ឲ្យប្រាកដពី ការពិត គំនិត និងអង្គហេតុ ។
- **យុទ្ធវិធី ឬបច្ចេកទេសការពារក្តី**
  - **ការប្រហារដោយពាក្យសម្តី៖** ការចោទសួរដោយភាពបំភ័ន្តធ្វើឡើងក្នុងគោលបំណងធ្វើឱ្យសាក្សីច្របូកច្របល់ និងដើម្បីឱ្យឃើញចម្លើយដែលមិនច្បាស់ លាស់ ។ នៅពេលប្រឈមមុខនឹងស្ថានភាពបែបនេះ ចូរទុកពេលពិចារណាលើ សំណួរនីមួយៗ ដោយឆ្លើយតបទៅវិញដោយមានការគិតទុកជាមុន ហើយសុំ ឱ្យចោទ សួរសំណួរម្តងទៀត ។ ចូររក្សាចិត្តឲ្យនឹងន
  - **ការចុះសម្រុងនឹងគ្នា៖** ចូរសុំឱ្យសួរសំណួរនោះម្តងទៀត ហើយប្រសិនបើ ជាឃ្លាដែល

មិនត្រឹមត្រូវ ចូរឆ្លើយក្នុងលក្ខណៈម៉ឺងម៉ាត់ ។

○ **ភាពរាក់ទាក់៖** មេធាវីការពារជនជាប់ចោទ អាចសម្តែងចរិតគួរសម ដើម្បីព្យាយាមល្បួងសាក្សីឱ្យស្ថិតនៅក្នុងស្ថានភាពសន្តិសុខមិនពិតមួយ ដែលក្នុងនោះសាក្សីនឹងឆ្លើយទៅតាមអ្វីដែលគាត់ចង់បាន ។ នៅពេលជួបស្ថានភាព បែបនេះ ចូរប្រុងស្មារតី និងចាំក្នុងចិត្តថា មេធាវីការពារជនជាប់ចោទកំពុង ព្យាយាមធ្វើឲ្យមោឃភាពនៃបន្ទាល់ ។

○ **ការសាកសួរដេញដោល ឬការរករឿងប្រទូស្ត៖** ព្យាយាមបង្កឱ្យបាត់បង់ការគ្រប់គ្រងអារម្មណ៍ រំជួលចិត្ត និងភាពគួរជឿទុកចិត្តរបស់អង្គជំនុំជម្រះ ។ នៅពេលប្រឈមមុខនឹងស្ថានភាពបែបនេះ ចូរកុំយកចិត្តទុកដាក់លើ សកម្មភាពរបស់មេធាវីការពារជនជាប់ចោទ ។ ចូររក្សាភាពស្ងៀមស្ងាត់ និយាយដោយមានការគិតទុកជាមុន និងទុកពេលឱ្យតំណាងអយ្យការធ្វើការជំទាស់ដែលសមស្រប ។

### ៦. វិចារណ៍ទូទៅ

- សេចក្តីសម្រេចរបស់តុលាការ អាស្រ័យលើមួយផ្នែកនៃបន្ទាល់របស់សាក្សី ចូរឆ្លើយតាមសំណួររបស់មេធាវីឲ្យបានច្បាស់លាស់ ដោយចៀសវាងបន្ថែមគំនិត និងពេលវេលា បណ្តាលឲ្យមានការជំទាស់ ។
- ការជំទាស់មិនត្រូវរក្សាទុកជាកស្តុតាងទេ រហូតដល់មានកស្តុតាងផ្ទុយ ។ នៅពេលដែលមេធាវីរបស់ជនជាប់ចោទ ចោទសួរ ចូរទុកពេលសមល្មមឲ្យតំណាងអយ្យការជំទាស់ ។ ប្រសិនបើមានការជំទាស់លើកឡើង ចូររក្សាភាពស្ងៀមស្ងាត់ រហូតដល់ចៅក្រមសម្រេច (អនុញ្ញាតថាជំទាស់មានប្រសិទ្ធភាព ឬអត់) ។
- គោរពមេធាវី ដោយសុភាពរាបសា និងឥរិយាបថមិនលម្មៀង ។
- បង្ហាញសមត្ថភាពបន្ទាល់ឱ្យមានប្រសិទ្ធភាព ។

### ៧. ការផ្តល់អនុសាសន៍លើការធ្វើបន្ទាល់

- ជានិច្ចកាល ត្រូវប្រាប់ការពិត ។ នៅពេលជំនុំជម្រះ ជុំវិញបញ្ហាទាំងអស់ ភាពស្មោះត្រង់គឺជាគោលការណ៍ដ៏ល្អបំផុត ។ ប្រសិនបើអ្នកប្រាប់ការពិត និងនិយាយដោយ ភាពស្មោះត្រង់ គ្មាននរណាម្នាក់អាចប្រឆាំងជំទាស់អ្នកបានទេ ។ ចូរកុំឆ្លើយដោយប៉ាន់ស្មាន ឬដោយប្រឌិតចម្លើយ ។ ប្រសិនបើអ្នកមិនដឹងចម្លើយ អ្នកគួរនិយាយថា "ខ្ញុំមិនដឹងទេ" ។ ប្រសិនបើអ្នកត្រូវបានសួរពីរឿងលម្អិតណាមួយដែលអ្នកមិនចាំ អ្នកគួរឆ្លើយថា "ខ្ញុំមិនចាំទេ" ។
- ស្លៀកពាក់ឱ្យបានស្អាតបាត និងសមរម្យ ។ របៀបរបបដែលអ្នកស្លៀកពាក់ និងការបង្ហាញខ្លួនឯងផ្ទាល់ អាចមានប្រយោជន៍ដល់អ្នកវិញ ។ មន្ត្រីនគរបាលគួរស្លៀកពាក់ឯកសណ្ឋាននគរបាល ឬយ៉ាងហោចណាស់ក៏ពាក់អាវធំដូចអាវកីឡាសម្រាប់ពាក់ពីលើ និងក្រវ៉ាត់ក (បុរស) ឬសម្លៀកបំពាក់ដែលអាចជំនួសគ្នាបាន ។ ត្រូវឆ្លើយសំណួរ ដោយឆ្លើយ "បាទ ឬ ចាស" ឬ "ទេ" ។
- មានស្មារតីប្រុងប្រយ័ត្នខ្ពស់ ។ អ្នកគួរមានស្មារតីប្រុងប្រយ័ត្នគ្រប់ពេលទាំងអស់ ដើម្បីស្តាប់ យល់ និងឆ្លើយតបនឹងសំណួរឱ្យបានត្រឹមត្រូវ ។ ប្រសិនបើចៅក្រម ឬអង្គជំនុំជម្រះមានអារម្មណ៍ថា អ្នកមានអារម្មណ៍ធុញថប់ ឬអារម្មណ៍ខុសប្រក្រតី ពួកគេអាច សម្តែងចេញការមិនជឿជាក់

ចំពោះបន្ទាល់របស់អ្នក ។ ចូរសម្តែងអាកប្បកិរិយាឱ្យបាន ល្អ និងកុំខ្ជិលច្រអូស ។

- ធ្វើតាមសម្រួល និងនិយាយឱ្យបានច្បាស់ និងឱ្យបានឮៗ ។ កុំទំពារស្ករកៅស៊ូ និងកុំយកដៃទៅខ្ទប់មាត់ ។ ដោយសារតែបន្ទាល់ខ្លះ អាចត្រូវបានថតនិងរក្សាទុក ហេតុនេះចូរកុំងក់ក្បាលជំនួសឱ្យការនិយាយថា "បាទ ចាស ឬទេ" ។
- ចូររក្សាភាពនឹងននៅក្នុងបន្ទប់សវនាការ ។ ចៀសវាងនិយាយលេងសើច និងកំប្លែងនៅមុខអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះកំពុងស្ថិតក្នុងការរិះគន់ ឬវាយតម្លៃពីសាធារណជនដែលយកសេរីភាពជាគោល ។ នោះគឺតែងតែជាបញ្ហាដ៏ធ្ងន់ធ្ងរបំផុត ។ ចូរប្រយ័ត្នពីសកម្មភាព និងការសន្ទនាផ្សេងៗ ។
- ចូរឆ្លើយសំណួរត្រង់ៗ ។ ឆ្លើយតែសំណួរដែលបានសួរ បន្ទាប់ពីចប់ត្រូវឈប់ ។ ចៀសវាងផ្តល់ព័ត៌មានដែលមិនចាំបាច់ ។ ប្រសិនបើអ្នកមិនយល់សំណួរណាមួយ ចូរសុំពន្យល់បកស្រាយសំណួរនោះ ។ កុំក្រឡេកមើលទៅតំណាងអយ្យការឱ្យជួយ នៅពេលអ្នកកំពុងធ្វើបន្ទាល់ និងកុំសួរទៅចៅក្រមវិញ ប្រសិនបើអ្នកមានសំណួរ ។ នេះនឹងឱ្យអង្គជំនុំជម្រះមានអារម្មណ៍ថា អ្នកកំពុងលាក់រឿងអ្វីមួយ ។ អ្វីៗទាំងអស់ អាស្រ័យលើអ្នក ។
- ចូរទប់កំហឹងរបស់អ្នក ។ មេធាវីមួយចំនួនព្យាយាមបន្ទុះបង្អាប់អ្នក ដើម្បីឱ្យអ្នកបញ្ចេញកំហឹងតបត ហើយនិយាយនូវអ្វីដែលមិនត្រឹមត្រូវ ។ កុំនៅចចេសរឹងរូស ឬជំទាស់តវ៉ាជាមួយនឹងមេធាវី ។ ពួកគេមានសិទ្ធិសួរអ្នក ហើយមេធាវីជាច្រើនមាន ជំនាញដ៏ប៉ិនប្រសប់ក្នុងការចោទសួរ ។
- ត្រូវប្រយ័ត្នពីសំណួរដែលពាក់ព័ន្ធនឹងចម្ងាយ និងពេលវេលា ។ ប្រសិនបើអ្នកធ្វើការប៉ាន់ស្មាន ចូរប្រាកដថា មនុស្សទាំងអស់ដឹងថា អ្នកកំពុងធ្វើការប៉ាន់ស្មាន ។ ចូរប្រយ័ត្ន នឹងសំណួរដែលសួរថា តើអ្នកមានបំណងចង់ស្បថចំពោះព្រឹត្តការណ៍នេះឬទេ? តើអ្នកមានបាននិយាយទៅតំណាងអយ្យការ សាក្សី ឬមន្ត្រីដទៃឬទេ? ប្រសិនបើអ្នកបាន និយាយទៅពួកគេមែន ចូរឆ្លើយប្រាប់ដោយស្មោះត្រង់ ។ ការរៀបចំមុនការជំនុំជម្រះ នេះ គួរមានគ្រប់រឿងក្តីទាំងអស់ ។
- គ្រប់ពេលទាំងអស់ ចូរផ្តល់នូវចម្លើយទៀងត្រង់ និងវិជ្ជមាន ។ ចៀសវាងនិយាយថា "ខ្ញុំគិតថា ខ្ញុំជឿថា តាមគំនិតខ្ញុំ" ។ សាក្សីម្នាក់ធ្វើបន្ទាល់ដោយពឹងអាងលើការពិត មិនមែនសំអាងលើការយល់ឃើញ និងការជឿជាក់របស់ខ្លួនឡើយ ។
- កុំបញ្ចេញយោបល់ ស្តីពីម៉ាស៊ីនមើលដឹងពីចរិតលក្ខណៈរបស់មនុស្ស ឬឯកសារបទល្មើសពីមុនរបស់ជនជាប់ចោទ ។
- កុំប្រើនីត្យានុកូលសព្ទ ឬភាសាសម្ងាត់របស់នគរបាល ឱ្យអង្គជំនុំជម្រះចាប់អារម្មណ៍ ។ វានឹងបង្កផលប៉ះពាល់អវិជ្ជមាន ។
    - ឧទាហរណ៍៖ "នៅម៉ោង ២១៖ ៤០នាទី ជនសង្ស័យចេញពីទ្វារខាងជើង ឆៀងខាងកើតនៃរថយន្ត ហើយចាប់ផ្តើមរត់គេចខ្លួន នៅពេលមន្ត្រីនគរបាល ដេញចាប់ឃាត់ខ្លួន ជាលទ្ធផលក៏ត្រូវជាក់ខ្នោះ" មានប្រសិទ្ធភាពជាងការ ដែលនិយាយថា "នៅចន្លោះពីម៉ោង ៩-១០ អាជ្រូកបានចុះចេញពីអាក្លាម របស់វា ដោយរត់ចេញពីហ្វូងអ្នកដំណើរឆ្លងកាត់ហើយរត់គេចខ្លួន ប៉ុន្តែត្រូវ ដេញតាម និងចាប់ខ្លួនដោយមន្ត្រីដទៃទៀត" ។

## XII. លំហាត់ជាក្រុម ៖ ការសាកល្បងធ្វើបន្ទាល់នៅតុលាការ

សិក្ខាកាមម្នាក់ៗគួរត្រូវប្រាប់ឱ្យស្លៀកពាក់ទៅតុលាការ ដើម្បីធ្វើបន្ទាល់ ។ សិក្ខាកាមទាំងអស់នឹងប្រើរបាយការណ៍ស៊ើបអង្កេត ដែលពួកគេបានធ្វើនៅក្នុងលំហាត់ខាងលើ ។ សិក្ខាកាមនឹងត្រូវធ្វើបន្ទាល់នៅមុខដៃគូរបស់ពួកគេ ។

គ្រូបង្គោល ត្រូវជ្រើសរើសយកនរណាម្នាក់ជាមេធាវី ឱ្យចោទសួរមន្ត្រីនៅពេលជំនុំជម្រះក្តី ។ មនុស្សពីរនាក់ គួរធ្វើសម្ភាសន៍ (អ្នកបណ្តឹងនិងការពារបណ្តឹង)។

សិក្ខាកាមម្នាក់ៗនឹងត្រូវបានចោទសួរដោយមេធាវី ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតបទល្មើសដែលមាននៅក្នុងលំហាត់ខាងលើ ។ ចូរឱ្យសិក្ខាកាមម្នាក់ចោទសួរបញ្ជាក់ពីការពិតជាក់ស្តែងតាមដែលអាចធ្វើទៅបាន ។ សិក្ខាកាមណាដែលមិនចូលរួមក្នុងការសម្ភាស គួរជាអ្នកអង្កេតការណ៍ និងផ្តល់ការទិតៀន តាមរយៈការសរសេរ ឬនិយាយ ។

**ការវាយតម្លៃ**

- ទិដ្ឋភាពខាងក្រៅ
- សំឡេង
- ការប្រើប្រាស់ពាក្យសំដី
- ភាពជាអ្នកអាជីព
- ភាពច្បាស់លាស់
- ភាពពេញលេញគ្រប់គ្រាន់
- កត្តាដែលសំខាន់ដទៃទៀត ។

ចូរធ្វើឱ្យដូចការពិតតាមដែលអាចធ្វើទៅបាន ។ ប្រសិនបើអាចទៅរួច ត្រូវប្រើបន្ទប់សវនាការពិតជាក់ស្តែង ។ ការពិតជាក់ស្តែងកាន់តែច្រើន សិក្ខាកាមរៀនកាន់តែច្រើនពីបទពិសោធន៍ ។

៚៚៚ ✸ ៙៙៙

# ឯកសារយោង

- ឯកសារមេរៀនរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ២០០៣


- Bourg, Wendy et al; *A Child Interviewer's Guidebook*, Thousand Oaks, CA: Sage Publications, 1999
- Goodman, Gail; Bottoms, Bette; *Child Victims, Child Witnesses: Understanding and Improving Testimony*, New York, NY: The Guilford Press, 1993
- Mapes, Bruce; *Child Eyewitness Testimony in Sexual Abuse Investigations*, Brandon, VT: Clinical Psychology Publishing Co., 1995
- Milne, Rebecca; Bull, Ray; *Investigative Interviewing: Psychology and Practice*, Chichester, West Sussex, UK: John Wiley & Sons Press, 1999
- Morgan, Marcia; *How to Interview Sexual Abuse Victims Including the Use Of Anatomical Dolls*, Thousand Oaks, CA: Sage Publications, 1995
- Poole, Debra A; *Investigative Interviews of Children: A Guide for Helping Professionals*, Washington, DC: American Psychological Association, 1998
- Schafer, John; Navarro, Joe; *Advanced Interviewing Techniques: Proven Strategies for Law Enforcement, Military, and Security Personnel*, Springfield. IL: Thomas Books, 2003
- Shuy, Roger W.; *The Language of Confession, Interrogation, and Deception*, Thousand Oaks, CA: Sage Publications, 1998
- Swanson, Charles R. et al; *Criminal Investigation*, Boston, MA: McGraw Hill Publications, 2003, 8th edition
- Yeschke, Charles; *The Art of Investigative Interviewing: A Human Approach to Testimonial Evidence*, Boston, MA: Butterworth-Heinemann Press, 1997

**MANUALS USED**

- Faller, Kathleen C.; *Child Sexual Abuse: Intervention and Treatment Issues*, U.S. Department of Health and Human Services Administration for Children and Families, McLean, VA: The Circle, Inc, 1993
- Ministry of Interior, General Director of National Police, Kingdom of Cambodia; *Understanding and Investigating Child Sexual Exploitation*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2000
- Ministry of Interior, General Director of National Police, Kingdom of Cambodia; *Training Document on Child Victim Sensitivity*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2003
- Sas, Louise; *The Interaction Between Children's Developmental Capabilities and the Courtroom Environment: The Impact on Testimonial Competency*, Report prepared for the Department of Justice Canada, 2002

**OTHER MATERIALS USED**

- U. S. Department of State Trafficking in Persons Report, 2004

**WEB SITES USED**

- HTTP://www.childdevelopmentinfo.com/development/language_development.shtml
- HTTP://www.families.qld.gov.au/projectaxis/orgbooklet/development.html
- HTTP://danenet.wicip.org/dcccrsa/saissues/parent/1.html
- HTTP://www.aacap.org/publications/factsfam/develop.htm
- HTTP://www.secasa.com.au/index.php/family/12/120
- HTTP://www.earlychildhoodbehavioralhealth.com/ChildDev/sexdevelop.htl
- HTTP://www.ces.perdue.edu/providerparent/Child%20Growth-Development/SexualDEV.htm
- HTTP://www.state.gov/g/tip/rls/tiprpt/2004/34021pf.htm

# បណ្ឌិត្យសភានគរបាលកម្ពុជា

## កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ

# ការស៊ើបអង្កេត
# បណ្តាញឧក្រិដ្ឋជន

២០១៧

សូមរក្សាសិទ្ធិ

មេរៀននេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការវីនរ៉ក់ ឬរដ្ឋាភិបាលអាមេរិក

# ការស៊ើបអង្កេតបណ្តាញឧក្រិដ្ឋជន

## I. ឧក្រិដ្ឋជនមានអង្គការចាត់តាំងនៅលើពិភពលោក

### ១. ទិដ្ឋភាពទូទៅ

នៅលើពិភពលោក ឧក្រិដ្ឋជនមានអង្គការចាត់តាំង បានជ្រាបចូលនៅក្នុងសង្គម ដោយបានរីករាលដាលទៅជាវិសាលភាពមួយ ដែលឥឡូវនេះត្រូវបានគេចាត់ទុកថា ជាការគំរាមកំហែងផ្នែកសន្តិសុខអន្តរជាតិ ។ ការណ៍នេះអាចបណ្តាលឱ្យស្ថិរភាពនយោបាយធ្លាក់ចុះ បំផ្លាញដល់ស្ថានភាពសេដ្ឋកិច្ចពិភពលោក ហើយបង្កើនសេដ្ឋកិច្ចក្រុមឧក្រិដ្ឋជន ។ ឧក្រិដ្ឋជនមានអង្គការចាត់តាំងបានបង្កើតនូវបរិយាកាសអន្តរជាតិមួយ ដែលលើកទឹកចិត្តមនុស្សឱ្យធ្វើការក្រៅក្របខ័ណ្ឌច្បាប់ ។ លើសពីនេះទៀត ភាពលំបាកក្នុងការបង្កើតកិច្ចសហប្រតិបត្តិការដ៏សំខាន់ និងមានប្រសិទ្ធភាព ពីប្រទេសមួយទៅកាន់ប្រទេសមួយ ក៏ចូលរួមចំណែកធ្វើឱ្យឧក្រិដ្ឋជនមានអង្គការចាត់តាំងមានប្រយោជន៍ផងដែរ ។ ទន្ទឹមនឹងនេះ ស្ថានភាពដែលបានលេចឡើង ក្នុងទំនាក់ទំនងនយោបាយ ជាពិសេសនៅក្នុងប្រទេសអឺរ៉ុបខាងកើត និងកណ្តាល បានផ្តល់ឱ្យមានកន្លែងបង្កបង្កើតសកម្មភាពឧក្រិដ្ឋកម្ម ដែលនៅទីនោះ គោលការណ៍ច្បាប់ត្រូវបានប្រតិបត្តិដោយធូរលង់ ។ កត្តាទាំងនេះបានចូលរួមចំណែកដល់ការកើនឡើងកាន់តែល្អថែមទៀតរបស់ឧក្រិដ្ឋជនមានអង្គការចាត់តាំង ដែលមានមូលដ្ឋានជាអន្តរជាតិ និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុដ៏ទូលំទូលាយ និងបណ្តាញនៃឧក្រិដ្ឋជនមានអង្គការចាត់តាំងផ្សេងទៀត ។ ពីទស្សនៈនេះ ឧក្រិដ្ឋជនមានអង្គការចាត់តាំង បានក្លាយទៅជាការគំរាមកំហែងថ្មីមួយចំពោះស្ថិរភាពនៃការគ្រប់គ្រងអន្តរជាតិ ។

កន្លងមក មានមធ្យោបាយផ្សេងៗគ្នា ដើម្បីធ្វើការបង្ក្រាបឧក្រិដ្ឋជនមានអង្គការចាត់តាំង ហើយដោយសារតែរឿងនេះ ទើប " ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង" លេចរូបរាងឡើងជាច្រើនក្រុម ។

### ២. សកម្មភាព

ក្រុមទាំងឡាយណាដែលចូលរួមក្នុងឧក្រិដ្ឋជនមានអង្គការចាត់តាំង ត្រូវបានចាត់ទុកថា ជាប់ពាក់ព័ន្ធនឹងគោលបំណងគាំទ្រទៅលើសកម្មភាពរបស់ឧក្រិដ្ឋជន ។ សមាជិកម្នាក់ៗមិនធ្វើតែម្នាក់ឯងនោះទេ ហើយសកម្មភាពទាំងឡាយដែលពួកគេជាប់ពាក់ព័ន្ធ គឺមានអង្គការចាត់តាំង ។ លើសពីនេះទៅទៀត ស្ថានភាពសេដ្ឋកិច្ចនៅក្នុងអង្គការឧក្រិដ្ឋជនដែលកើតមានយូរអង្វែង គឺមានគោលបំណងច្បាស់លាស់ ហើយសកម្មភាពត្រូវមានមេខ្លោងជាអ្នកដឹកនាំ ។ ជាទូទៅ អង្គការឧក្រិដ្ឋជនដែលជាប់ពាក់ព័ន្ធដ៏ខ្លាំងក្លា បានក្លាយទៅជាសហគ្រាសដ៏ធំ ជាញឹកញាប់មានទំនាក់ទំនងឆ្លងប្រទេសដែលមានសមាជិករាប់រយទៅដល់រាប់ពាន់ ។

ក្រុមឧក្រិដ្ឋជនទាំងនេះធ្វើប្រតិបត្តិការតាមរចនាសម្ព័ន្ធនៃអង្គការចាត់តាំងផ្សេងៗគ្នា សម្រាប់គោលបំណងទូទៅនៅក្រៅក្របខ័ណ្ឌច្បាប់ ។ ទោះបីជាអង្គការនោះជាកត្តាដ៏សំខាន់ចំពោះក្រុមទាំងនេះក៏ដោយ ក៏គ្មានគំរូជាស្តង់ដានៃរចនាសម្ព័ន្ធនៅក្នុងក្រុមទាំងនោះឡើយ ។ ពួកឧក្រិដ្ឋជន អាចពឹង

ផ្អែកលើលក្ខណៈពិសេស ដែលត្រូវបង្កើតយ៉ាងល្អ ដើម្បីសម្រេចគោលបំណងរបស់ខ្លួន ។ លក្ខណៈពិសេស គឺជាការរៀបចំដែលមានរចនាសម្ព័ន្ធតាមឋានានុក្រម ដោយមានការគ្រប់គ្រងតឹងរ៉ឹង ដូចជាក្រុមហ៊ុនអន្តរជាតិកូកាអ៊ីនកូឡុមប៊ី ។ ប្រភេទផ្សេងទៀតរួមមាន អង្គការដែលមានរចនាសម្ព័ន្ធតាមតំបន់ អង្គការមូលនិធិផ្អែកសាសនា ជាដើម ។

គោលបំណងនៃអង្គការនេះ កំណត់អំពីអំពើឧក្រិដ្ឋរបស់ខ្លួន ។ ជាធម្មតា ប្រភេទនៃសកម្មភាពដែលពួកគេជាប់ពាក់ព័ន្ធ មាននៅក្នុងប្រភេទនៃអ្វីដែលត្រូវបានចាត់ទុកថាជា សហគ្រាសឧក្រិដ្ឋកម្ម ។ បញ្ហានេះរួមបញ្ចូលការបែងចែកទំនិញ សេវាកម្មខុសច្បាប់ និងទំនិញដែលត្រូវទទួលបានដោយមធ្យោបាយខុសច្បាប់ ដូចជាការឆបោក ឬអំពើចោរកម្ម ។ សកម្មភាពនៃឧក្រិដ្ឋជនមានអង្គការចាត់តាំង អាចប្រៀបធៀបដូចគ្នានឹងសហគ្រិននៅក្នុងទីផ្សារស្របច្បាប់ ជាអាទិ៍ គឺភាពចាំបាច់ដើម្បីថែរក្សា និងពង្រីកភាគហ៊ុនទីផ្សាររបស់ខ្លួន ។ ដូច្នេះ សកម្មភាពនៃក្រុមឧក្រិដ្ឋជន មានសមភាពទៅនឹងកិច្ចខិតខំប្រឹងប្រែងនៃជំនួញស្របច្បាប់ ដូចជា នាំចេញ នាំចូល ពាណិជ្ជកម្មជាទំនិញផ្សេងៗ ការលក់ដុំ លក់រាយ និងសេវាកម្មដទៃទៀត ។ តែទោះជាយ៉ាងណាក៏ដោយ សមាជិកនៃក្រុមនេះសកម្មប្រតិបត្តិនៅក្នុងវិស័យក្រៅក្របខ័ណ្ឌច្បាប់ ដោយធ្វើពាណិជ្ជកម្មទៅលើទំនិញ ដែលត្រូវកំណត់ថាខុសច្បាប់ ដូចជាគ្រឿងញៀន និងសព្វាវុធ ។

វិសាលភាពនៃសកម្មភាពឧក្រិដ្ឋជនរីករាលដាលដ៏ខ្លាំង ។ ក្រុមខ្លះមានជំនាញខ្ពស់ ហើយផ្តោតតែលើប្រភេទនៃសកម្មភាពណាមួយ ដូចជា ពេស្យាកម្ម និងគ្រឿងញៀន ។ ប៉ុន្តែ និន្នាការថ្មីៗនេះគឺសម្រាប់ក្រុមពាក់ព័ន្ធក្នុងលំដាប់នៃសកម្មភាពល្មើសច្បាប់ ដែលលេចធ្លោជាងគេគឺ ឧក្រិដ្ឋជនមានអង្គការចាត់តាំងបែបប្រពៃណី (ការប្រកបរបរទុច្ចរិត) និងផ្នែកហិរញ្ញវត្ថុដែលមានលក្ខណៈស្មុគស្មាញ (ការលួចវត្ថុសិល្បៈ) ។ ទោះជាសកម្មភាពនោះជាអ្វីក៏ដោយ គោលបំណងសំខាន់គឺ ការរកប្រាក់ចំណេញពីការងារខុសច្បាប់របស់មនុស្សជាច្រើន ដែលត្រូវបានសម្របសម្រួលជាយូរមកហើយ ។

អំពើហិង្សា គឺជាអត្តចរិតដំបូងនៃឧក្រិដ្ឋជនមានអង្គការចាត់តាំង ដែលត្រូវបានប្រើដើម្បីជំរុញ និងការពារផលប្រយោជន៍របស់ពួកគេ ។ ពួកឧក្រិដ្ឋជនប្រើអំពើហិង្សា ដើម្បីគ្រប់គ្រង និងដឹកនាំផលប្រយោជន៍របស់ខ្លួន ក្នុងវិធីជាក់លាក់ដើម្បីសម្រេចគោលបំណងណាមួយ ។

ជាទូទៅ អំពើហិង្សាត្រូវបានប្រើជាចម្បងសម្រាប់ "គោលបំណងជួញដូរ" ទោះបីជាជួនកាលពុំមានសកម្មភាពព្រៃផ្សៃរបស់បុគ្គលក្នុងបណ្តាញឧក្រិដ្ឋជនមានអង្គការចាត់តាំងក៏ដោយ ។ លក្ខណៈពិសេសមួយទៀតនៃឧក្រិដ្ឋជនមានអង្គការចាត់តាំង ហើយទាក់ទងនឹងការប្រើអំពើហិង្សា គឺសកម្មភាពស៊ីសំណូក ។ ដោយសារតែពួកគេមិនត្រូវជាមួយសមត្ថកិច្ច និងរដ្ឋាភិបាលផ្សេងទៀត ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង បានប្រើការសូកប៉ាន់ដើម្បីបំផ្លាញដល់ប្រព័ន្ធយុត្តិធម៌ និងគេចចេញពីការចោទប្រកាន់ ឬការផ្តន្ទាទោស ។ ចំនួនប្រាក់ជាច្រើនត្រូវបានប្រើជាគ្រឿងលើកទឹកចិត្ត ដោយប្រើអំណាចទឹកប្រាក់ ដើម្បីធ្វើឱ្យមន្ត្រីរដ្ឋាភិបាលទទួលសំណូកក្នុងទំហំដ៏ច្រើនសម្បើម ដែលជាជំនួយដល់ឧក្រិដ្ឋជនមានអង្គការចាត់តាំងក្នុងការសម្រេចគោលបំណងរបស់ខ្លួន ។

## II. ឧក្រិដ្ឋជនមានអង្គការចាត់តាំងអាស៊ី

ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងអាស៊ី មានឥទ្ធិពលត្រួតត្រាលើសកម្មភាពឧក្រិដ្ឋជនមានអង្គការចាត់តាំងផ្សេងទៀតនៅជុំវិញពិភពលោក ។ ជាញឹកញាប់ សហគ្រាសឧក្រិដ្ឋកម្ម និងឧក្រិដ្ឋជនមានអង្គការចាត់តាំងនៅអាស៊ីបែបប្រពៃណី ពាក់ព័ន្ធនឹងក្រុមហ៊ុនជំនួញឧក្រិដ្ឋកម្ម ដូចជា ការសម្អាតប្រាក់ ការលួចបន្លំប័ណ្ណឥណទាន ការលួចចម្លងកម្មវិធី software និងការនាំចេញ នាំចូលទំនិញខុសច្បាប់ផ្សេងទៀតដូចជា ការរត់ពន្ធមនុស្ស ការជួញដូរគ្រឿងញៀនពីតំបន់ត្រីកោណមាសចូលទៅទ្វីបអឺរ៉ុប និងអាម៉េរិកខាងជើង ។

សហគ្រាសឧក្រិដ្ឋកម្មអាស៊ី គឺជាក្រុមដែលរៀបចំដោយឧក្រិដ្ឋជនដ៏ច្រើន តាំងពីអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ ដែលរាប់ទាំងក្រុមដែលសមាជិករបស់ខ្លួនជាអ្នកដើមកំណើតចិន កូរ៉េ ជប៉ុន ថៃ ហ្វីលីពីន កម្ពុជា ឡាវ និងវៀតណាម ។ តែទោះជាយ៉ាងណាក៏ដោយ សហគ្រាសឧក្រិដ្ឋកម្មនៅអាស៊ីផ្សេងទៀត កំពុងតែលេចរូបឡើងជាការគំរាមកំហែងនៅក្នុងស្រុក និងអន្តរជាតិ ដោយរួមទាំងក្រុមមកពីប្រទេសនៅលើកោះប៉ាស៊ីហ្វិកខាងត្បូង អាស៊ីនិរតី ដូចជា ប៉ាគីស្ថាន ឥណ្ឌា អាហ្គានីស្ថាន នេប៉ាល់ និងអ៊ីរ៉ង់ ។ នៅក្នុងសហរដ្ឋអាម៉េរិក សហគ្រាសឧក្រិដ្ឋកម្មនៅអាស៊ីត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងរដ្ឋជាង ៥០ ដែលមានប្រជាជនរស់នៅគ្រប់ជាតិសាសន៍ចម្រុះ ដូចជារដ្ឋបុស្តុន ឈីខាហ្គូ ហូណូលូលូ ឡាសវេហ្គាស ឡូសអែនជឺលីស ញូអរលីន ញូយ៉ក ញូអាក ហ្វីឡាដឺហ្វៀ ផតឡែន សិនហ្វ្រិនស៊ីស្កូ ស៊ីអាថល និងវ៉ាស៊ីនតោនឌីស៊ី ។

សហគ្រាសឧក្រិដ្ឋកម្មអាស៊ីទាំងនេះ ប្រើប្រាស់បណ្ដាញដ៏ទូលំទូលាយនៃសមាជិកឧក្រិដ្ឋជនក្នុងប្រទេស និងអន្តរជាតិ ដែលមានលក្ខណៈប្រែប្រួល និងផ្លាស់ប្ដូរយ៉ាងខ្លាំង ។ ពួកគេសម្របយ៉ាងស្រួលទៅតាមការផ្លាស់ប្ដូរនៅជុំវិញពួកគេ មានសមត្ថភាពនិយាយបានច្រើនភាសា អាចមានចំណេះដឹងខ្ពស់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងមានសមត្ថភាពខាងហិរញ្ញវត្ថុដ៏ទូលំទូលាយ ។ សហគ្រាសឧក្រិដ្ឋកម្មអាស៊ីខ្លះ បានធ្វើសកម្មភាពឧក្រិដ្ឋរបស់ខ្លួនឱ្យទៅជាពាណិជ្ជកម្ម ហើយអាចត្រូវចាត់ទុក ជាក្រុមហ៊ុនជំនួញដែលមានទំហំផ្សេងៗគ្នា ចាប់ពីប្រតិបត្តិការគ្រប់គ្រងជាលក្ខណៈគ្រួសារ ទៅដល់សារជីវកម្មធំៗ ដោយផ្អែកលើភាពចំណាស់របស់ក្រុមនីមួយៗនៅក្នុងជំនួញឧក្រិដ្ឋកម្មដែលជាជំនាញរបស់ពួកគេ ។

នៅដើមឆ្នាំ ១៩០០ សហគ្រាសឧក្រិដ្ឋកម្មអាស៊ីបានលេចរូបឡើងនៅសហរដ្ឋអាម៉េរិក ជាមួយនឹងការចាប់ផ្ដើមនៃសមាគមចិនដែលមានឥទ្ធិពលលើឧក្រិដ្ឋកម្ម ។ ជាងមួយសតវត្សរ៍ មិនគ្រាន់តែមានសមាគមចិនដែលមានឥទ្ធិពលលើឧក្រិដ្ឋកម្មរីកចម្រើនជឿនលឿនប៉ុណ្ណោះទេ ថែមទាំងសហគ្រាសឧក្រិដ្ឋកម្មនៅអាស៊ីក៏បានវិវត្តផងដែរ ជាដំបូងដោយសារតែសកលភាវូបនីយកម្មនៃសេដ្ឋកិច្ចពិភពលោក បច្ចេកវិជ្ជា ទំនាក់ទំនង និងការធ្វើដំណើរជាលក្ខណៈអន្តរជាតិ ។ ទន្ទឹមនឹងនេះ នយោបាយសណ្ដោសប្រណីនៃការធ្វើអន្តោប្រវេសន៍ បានផ្ដល់ឱ្យសមាជិកជាច្រើននៃសហគ្រាសឧក្រិដ្ឋកម្មអាស៊ីនូវលទ្ធភាពចូល និងរស់នៅក្នុងទ្វីបនីមួយៗ ដែលមានប្រជាជនដ៏ច្រើនដោយមិនអាចកំណត់អត្តសញ្ញាណបាន ។

សហគ្រាសឧក្រិដ្ឋកម្មអាស៊ី អាចត្រូវបានបែងចែកជាលក្ខណៈប្រពៃណី និងមិនប្រពៃណី ។

សហគ្រាសឧក្រិដ្ឋកម្មបែបប្រពៃណី រួមមានអង្គការឧក្រិដ្ឋកម្មចិនដែលមានមូលដ្ឋាននៅហុងកុង តៃវ៉ាន់ និងម៉ាកាវ ក៏ដូចជា ក្រុមឧក្រិដ្ឋជនជប៉ុន Yakuza ឬ Boryokudan ។ សហគ្រាសឧក្រិដ្ឋកម្មបែបមិនប្រពៃណី រួមមាន សមាគមចិនដែលមានឥទ្ធិពលលើឧក្រិដ្ឋកម្ម សាខាអង្គការឧក្រិដ្ឋកម្មចិន និងក្រុមជនពាលអាស៊ីផ្សេងទៀត ជាមួយសហគមន៍អាស៊ីដែលមានតាមលំដាប់ ។ ឧក្រិដ្ឋកម្មដែលពាក់ព័ន្ធជាមួយសហគ្រាសឧក្រិដ្ឋកម្មអាស៊ី មិនគ្រាន់តែមានសកម្មភាពរកស៊ីបរទុច្ចរិតបែបប្រពៃណី ដែលជាធម្មតាមានទំនាក់ទំនងជាមួយឧក្រិដ្ឋជនមានអង្គការចាត់តាំង ដូចជា ការគំរាមកំហែងយកប្រាក់ ឃាតកម្ម ការចាប់ជំរិត ការបើកបនល្បែងខុសច្បាប់ ពេស្យាកម្ម និងចងការប្រាក់ប៉ុណ្ណោះទេ ថែមទាំងមានឧក្រិដ្ឋកម្មមានអង្គការចាត់តាំងបែបអន្តរជាតិទៀតផង ដូចជា ការរត់ពន្ធមនុស្ស ការជួញដូរថ្នាំញៀនហេរ៉ូអ៊ីន និងមេតំហ្វេតាមីន ការលួចបន្លំផ្នែកហិរញ្ញវត្ថុ ដូចជា ប័ណ្ណឥណទានខុសច្បាប់ ចោរកម្មបន្ទះឈីបកុំព្យូទ័រ កុំព្យូទ័រក្លែងបន្លំ ផលិតផលសម្លៀកបំពាក់ និងការសម្អាតប្រាក់ ។

និន្នាការមួយចំនួនបានលេចរូបឡើងទាក់ទងនឹងសហគ្រាសឧក្រិដ្ឋកម្មនៅអាស៊ី ។ ដំបូង សហប្រតិបត្តិការនៃក្រុមឧក្រិដ្ឋជន ទំនាក់ទំនងតាមជាតិសាសន៍ និងពូជពង្សវង្សត្រកូល ។ បន្ទាប់មកក្រុមជនពាលអាស៊ីដែលបានកើតឡើងយូរមកហើយ និងសហគ្រាសឧក្រិដ្ឋកម្មផ្សេងទៀតនៅអាស៊ី បានចាប់ផ្តើមបង្កើតរចនាសម្ព័ន្ធក្រុមរបស់ខ្លួន តាមឋានានុក្រម ដើម្បីឱ្យមានលក្ខណៈប្រកួតប្រជែង ហើយនិងសកម្មភាពឧក្រិដ្ឋកម្មដែលពួកគេជាប់ពាក់ព័ន្ធបានក្លាយជាសកលភាវូបនីយកម្ម ។ ចុងបញ្ចប់ សហគ្រាសឧក្រិដ្ឋកម្មកាន់តែច្រើនថែមទៀត ជាប់ពាក់ព័ន្ធក្នុងក្រុមហ៊ុនជំនួញឧក្រិដ្ឋកម្ម ហើយកំពុងរួមបញ្ចូលសកម្មភាពខុសច្បាប់របស់ពួកគេជាមួយជំនួញស្របច្បាប់ ។

## III. រចនាសម្ព័ន្ធនៃឧក្រិដ្ឋជនមានអង្គការចាត់តាំង

ទម្រង់ផ្សេងគ្នានៃឧក្រិដ្ឋជនមានអង្គការចាត់តាំង មានហេតុផល និងលក្ខខណ្ឌផ្ទាល់របស់ខ្លួន ។ ប៉ុន្តែ ចំណុចសំខាន់នៃពួកគេគឺស្រដៀងគ្នា ។ ឧក្រិដ្ឋជនមានអង្គការចាត់តាំងនៅក្នុងការប្រព្រឹត្តរបស់ខ្លួនទាំងអស់ គឺដើម្បីសេដ្ឋកិច្ច ។ ហេតុផលខាងសេដ្ឋកិច្ចពឹងផ្អែកលើអង្គការមូលនិធិរបស់ខ្លួន ។

ដំណើរការនៃការបង្កើតរចនាសម្ព័ន្ធចាត់តាំងរបស់ឧក្រិដ្ឋជនមានអង្គការចាត់តាំង បានទទួលនូវកម្រិតនៃគុណភាព និងបរិមាណ ដែលក្រុមជាច្រើនត្រូវបានបង្ខំឱ្យផ្ទេរផលប្រយោជន៍របស់ខ្លួន ទៅឱ្យអ្នកប្រកួតប្រជែង ដែលធ្វើឱ្យមានជម្លោះរវាងបក្សពួកឧក្រិដ្ឋជន ។ ចំពោះចំណុចនៃជម្លោះសញ្ញាវុធ និងការកំចាត់អ្នកប្រកួតប្រជែង កំពុងតែនាំទៅរកការកើតឡើងនៃអង្គការចាត់តាំងឧក្រិដ្ឋកម្មដ៏មានអំណាច ។ ការប្រតិបត្តិរបស់ក្រុមទាំងនេះ បានបង្រួបបង្រួមយូរៗទៅ ក្លាយជាសហគមន៍ និងតាមការជាក់ស្តែងបានបែងចែកប្រទេសទៅជាដែនឥទ្ធិពល ។ ឧក្រិដ្ឋកម្មដំបូងដ៏សាមញ្ញ ដូចជាការប្រកបរបរទុច្ចរិត បានផ្តល់ឱ្យនូវមោគ៌ាក្នុងការប្រតិបត្តិរបស់ពួកគេ ដើម្បីរីតបន្តឹងសន្តិសុខ សកម្មភាពដែលមានទ្រង់ទ្រាយធំ ការជ្រៀតចូលដ៏ជ្រៅតាមរយៈទំនាក់ទំនង អំពើពុករលួយទៅក្នុងសេដ្ឋកិច្ច ហើយមានគោលបំណងប្រើឥទ្ធិពលដោយផ្ទាល់ទៅលើនយោបាយរបស់រដ្ឋក្នុងដែនឥទ្ធិពលនេះ ។

ឧក្រិដ្ឋកម្មឆ្លងដែន បានធ្វើឱ្យមានការបង្កើតនូវប៉ូលិសអន្តរជាតិ (Interpol) នាឆ្នាំ ១៩២៣ ។

ការសម្រេចចិត្តរបស់ប៉ូលិសអន្តរជាតិ ទទួលស្គាល់ថា ឧក្រិដ្ឋកម្មនេះឆ្លងកាត់ប្រទេស និងប៉ាន់ប្រមាណការលេចឡើងនៃឧក្រិដ្ឋកម្មអន្តរជាតិ ដែលមានគ្រោះថ្នាក់បំផុត ។

អង្គការសហប្រជាជាតិ បានលើកឡើងពីបញ្ហានេះជាលើកដំបូង នៅឯមហាសន្និបាតលើកទី៥ (ហ្សឺណែវ, Switzerland ១៩៧៥)ដែលបញ្ហានេះត្រូវបានទទួលស្គាល់ថា ឧក្រិដ្ឋកម្មនៅក្នុងទម្រង់ជាជំនួញអន្តរជាតិ បង្ហាញឱ្យឃើញនូវការគំរាមកំហែងដ៏ខ្លាំងក្លា ជាងទម្រង់បែបប្រពៃណីនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ ជាបន្តបន្ទាប់ បញ្ហានេះត្រូវបានលើកឡើងនៅឯមហាសន្និបាតលើកទី៦ (ការ៉ាកាស, Venezuela ១៩៨០ ) ក្នុងការត្រួតពិនិត្យសកម្មភាពឧក្រិដ្ឋ និងឧក្រិដ្ឋជន ដែលនៅក្រៅក្របខ័ណ្ឌច្បាប់ និងនៅមហាសន្និបាតលើកទី៧ (មីឡង់, Italy ១៩៨៥ ) ដែលបញ្ហានេះត្រូវបានសង្កត់ធ្ងន់ថាឧក្រិដ្ឋជនមានអង្គការចាត់តាំង ដោយការប្រើប្រាស់ចន្លោះប្រហោងនៃច្បាប់របស់ប្រទេសផ្សេងៗគ្នា និងចំពោះកម្រិតដ៏គួរឱ្យចាប់អារម្មណ៍ដែលនៅតែមិនអាចដាក់ទណ្ឌកម្មបាន និងផលដែលមិនបិតថេររបស់ខ្លួននឹងកើនឡើង ប្រសិនបើវិធានការស្ថាបនា និងច្បាប់មិនត្រូវបានគេអនុម័តទេនោះ ។

មហាសន្និបាតលើកទី៩ (ហាវ៉ាណា, Cuba ១៩៩០) វាត្រូវបានកត់សម្គាល់ថា ឧក្រិដ្ឋជនមានអង្គការចាត់តាំង បង្កើតឱ្យមានការគំរាមកំហែងត្រង់ៗចំពោះសន្តិសុខ និងស្ថិរភាពរបស់ជាតិ និងអន្តរជាតិ ហើយជាការវាយប្រហារជួរមុខនៃអំណាចនយោបាយ និងសេដ្ឋកិច្ច ដោយបង្កើតឱ្យមានការគំរាមកំហែងចំពោះរដ្ឋនោះតែម្តង ។ វារំលោភទៅលើមុខងារទូទៅនៃស្ថាប័នសេដ្ឋកិច្ច និងសង្គម ព្រមទាំងសម្របសម្រួលពួកគេ ដែលនាំទៅដល់ការបាត់បង់ជំនឿនៅក្នុងដំណើរការប្រជាធិបតេយ្យ និងធ្វើឱ្យខូចដល់ដំណើរការនៃការអភិវឌ្ឍ ព្រមទាំងបំផ្លាញដល់ភាពជោគជ័យ ។ វាបង្កើតឱ្យមានចំនួនជនរងគ្រោះជាច្រើននៅគ្រប់ប្រទេស ហើយធ្វើអាជីវកម្មលើភាពងាយរងការឈឺចាប់របស់មនុស្ស ដោយទទួលបានប្រាក់ចំណូលជាបន្តបន្ទាប់ ធ្វើឱ្យច្របូកច្របល់ និងយកសង្គមធ្វើជាឈ្នាន់ និងអូសទាញប្រទេសទាំងនោះឱ្យចូលទៅក្នុងសហគ្រាសឧក្រិដ្ឋកម្មដែលមានទំនាក់ទំនងផ្សេងៗគ្នា ។

ការជួញដូរខុសច្បាប់នៃថ្នាំញៀនណារកូទិក(narcotics)គឺជាប្រភពប្រាក់ចំណូលដ៏សំខាន់មួយសម្រាប់អង្គការឧក្រិដ្ឋជនឆ្លងដែនភាគច្រើន ។ សកម្មភាពនេះក៏ដូចជាប្រភេទនៃឧស្សាហកម្មដែលមានដំណាក់កាលនៃការផលិត និងការបែងចែកផ្សេងៗគ្នា ដែលធ្វើឱ្យអង្គការនេះត្រូវបានគេស្គាល់ ។ តម្លៃសរុបនៃប្រតិបត្តិការនៅក្នុងជំនួញថ្នាំញៀនណារកូទិករកកម្រៃបាន ៥០០ ០០០ លាន ដុល្លារអាម៉េរិកក្នុងមួយឆ្នាំ ។ គោលបំណងពិសេសមួយសម្រាប់វិធានការហិរញ្ញវត្ថុ ដែលបង្កើតដោយរដ្ឋសំខាន់ៗនៃក្រុមប្រទេសឧស្សាហកម្មទាំង ៧ និងគណៈកម្មការនៃសហគមន៍អឺរ៉ុប បានឈានដល់សេចក្តីសន្និដ្ឋានថា ធនធានដែលទទួលបានពីការលក់ថ្នាំញៀនហេរ៉ូអ៊ីន កូកាអ៊ីន និងថ្នាំញៀនកញ្ចាប់ណាប៊ីស(កញ្ឆា) នៅក្នុងសហរដ្ឋអាម៉េរិក និងប្រទេសអឺរ៉ុប ដែលមានទឹកប្រាក់ប្រមាណ ៨៥ ០០០ លាន ដុល្លារអាម៉េរិក ត្រូវប្រើជាការវិនិយោគទុន ឬសម្អាតប្រាក់ ។

ប្រាក់ដែលទទួលបានពីថ្នាំញៀនណារកូទិក ជាញឹកញាប់ធ្លាក់ទៅលើអង្គការដែលពាក់ព័ន្ធក្នុងរូបភាពផ្សេងៗនៃពាណិជ្ជកម្មខុសច្បាប់ ។ វាបានក្លាយទៅជាគ្រឿងលើកទឹកចិត្តដ៏ខ្លាំងសម្រាប់ការអភិវឌ្ឍនៃអង្គការឧក្រិដ្ឋជនឆ្លងដែន ដែលមានទម្រង់ផ្សេងៗគ្នា ហើយឈានទៅដល់ប្រតិបត្តិការសម្អាតប្រាក់

ដ៏ច្រើន ។ ទំនាក់ទំនងជំនួញថ្នាំញៀនក៏បាននាំទៅដល់ការលក់អាវុធខុសច្បាប់ផងដែរ ។ ប្រាក់ដែលបានមកពីការលក់ថ្នាំញៀនណារកូទិក និងប្រភេទថ្នាំខុសច្បាប់ផ្សេងទៀត គឺជាប្រភពដ៏សំខាន់មួយនៃការធ្វើឱ្យមន្ត្រីរដ្ឋាភិបាលមួយចំនួន ពុករលួយសម្រាប់គោលបំណងធានានូវសុវត្ថិភាពនៃសកម្មភាពឧក្រិដ្ឋជន ។

បណ្តាញនៃការលក់សព្វាវុធខុសច្បាប់ និងស្របច្បាប់ មិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់នោះទេ ។ ការចែកចាយសព្វាវុធនៅលើទីផ្សារងងឹត គឺតែងតែត្រូវបានធ្វើដោយសម្ងាត់ ការទិញសព្វាវុធក៏ត្រូវសម្ងាត់ផងដែរ និងប្រាក់ចំណូលត្រូវបានសម្អាត ។ ការលក់សព្វាវុធ និងគ្រាប់រំសេវខុសច្បាប់មានផលប៉ះពាល់ដ៏ខ្លាំងទៅលើជម្លោះក្នុងប្រទេស និងតាមតំបន់ ព្រមទាំងមានផលទៅលើលទ្ធភាពនៃក្រុមភេរវជន ដើម្បីសម្រេចគោលបំណងរបស់ពួកគេ និងគំរាមកំហែងដល់សន្តិភាព ។ ឧក្រិដ្ឋជនមានអង្គការចាត់តាំង ដោយចូលរួមក្នុងពាណិជ្ជកម្មសព្វាវុធខុសច្បាប់ និងសកម្មភាពធ្វើវិច្ឆេទកម្ម បានចូលរួមចំណែកដល់ភាពរឹករវផ្នែកនយោបាយ និងចលាចលនៅក្នុងពិភពលោក ។ អ្នកផ្គត់ផ្គង់សព្វាវុធអាចញុះញង់ និងរៀបចំឱ្យមានភាពរឹករវ ដើម្បីគោលបំណងបង្វែរការយកចិត្តទុកដាក់របស់មន្ត្រីអនុវត្តច្បាប់ ចេញពីសកម្មភាពឧក្រិដ្ឋកម្មរបស់ពួកគេ ។ ការលក់សព្វាវុធខុសច្បាប់ជំរុញឱ្យមានការរីកដុះដាលឡើងនៃឧក្រិដ្ឋកម្ម ដែលពាក់ព័ន្ធនឹងការប្រើប្រាស់សព្វាវុធ និងអំពើហិង្សា ។

ការលក់សារធាតុគីមី និងនុយក្លេអ៊ែរខុសច្បាប់ គឺជាបញ្ហាធំបន្ទាប់ ដែលជាប់ពាក់ព័ន្ធនឹងអត្ថិភាពនៃឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ លទ្ធភាពនៃអាវុធគីមី ឬនុយក្លេអ៊ែរ អាចត្រូវបានផ្ទេរទៅឱ្យក្រុមភេរវជន ដែលនឹងប្រើអាវុធទាំងនោះ ដើម្បីគំរាមកំហែងពិភពលោក គឺពិតប្រាកដនៅក្នុងពេលបច្ចុប្បន្ន ដូចជា សកម្មភាពភេរវជនដែលប្រព្រឹត្តឡើងដោយមានជំនួយពីសារធាតុគីមីដោយនីកាយជប៉ុន Aum Sinryku ។

ឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនៃក្រុមម៉ាហ្វីយ៉ាឆ្លងដែន គឺការធ្វើអាជីវកម្មមនុស្ស ស្ត្រី កុមារ និងសរីរាង្គមនុស្ស ។ រូបភាពដំបូងនៃសកម្មភាពបែបនោះ គឺជាការនាំចេញនូវជនអន្តោប្រវេសន៍ខុសច្បាប់ពីប្រទេសក្រីក្រទៅកាន់ប្រទេសអ្នកមាន ។ ដោយយោងតាមការប៉ាន់ប្រមាណខ្លះ មានមនុស្សមួយលាននាក់ត្រូវបាននាំចេញរាល់ឆ្នាំ ។ ជនអន្តោប្រវេសន៍ពីប្រទេសចិនមានប្រហែល ២០% នៃចំនួនហូរចូលសរុបដែលធ្វើដំណើរពីឥណ្ឌា អ៊ីរ៉ាក់ អ៊ីរ៉ង់ ប៉ាគីស្ថាន អាហ្គានីស្ថាន រ៉ូម៉ានី ស្រីលង្កា បង់ក្លាដេស ស៊ូដង់ និងប្រទេសផ្សេងទៀត ។ ដោយសារព្រំដែនរបស់ខ្លួនដែលមានច្រកចូលជាច្រើន និងច្បាប់មិនទាន់ពេញលេញ ប្រទេសរុស្ស៊ីបានក្លាយជាប្រទេសមួយដែលមានជនអន្តោប្រវេសន៍ខុសច្បាប់ហូរចូល ។ ប្រាក់ចំណូល ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងដែលបានមកពីសកម្មភាពនេះគឺមានប្រមាណ ៣៥០០ លានដុល្លារអាម៉េរិក ។

ការធ្វើអន្តោប្រវេសន៍ខុសច្បាប់ គឺមានជាប់ពាក់ព័ន្ធជាមួយការធ្វើអាជីវកម្មផ្លូវភេទទៅលើស្ត្រី និងកុមារ ។ ជាយូរមកហើយ ពេស្យាកម្មបានក្លាយជាសកម្មភាពដ៏ចម្បងមួយនៃឧក្រិដ្ឋជនមានអង្គការចាត់តាំង ដែលមានកម្រិតលក្ខណៈជាតិ និងអន្តរជាតិ ។ ជាពិសេសទៅទៀត សកម្មភាពដ៏សកម្មគឺអង្គការឧក្រិដ្ឋជនសង្គមងងឹតចិន និង Yakuzi របស់ជប៉ុន ដែលទុកស្ត្រីជាទាសករ ក្នុងការបង្កើត

ទេសចរណ៍ផ្លូវភេទនៅក្នុងប្រទេសហ្វីលីពីន កូរ៉េខាងត្បូង និងប្រទេសថៃ ។ នៅពេលនៃការធ្វើពាណិជ្ជកម្មលើស្ត្រី ពួកគេត្រូវបានចាត់ទុកដូចជា ទំនិញដែលមានជីវិត ហើយមិនត្រឹមតែស្ត្រីប៉ុណ្ណោះទេ ថែមទាំងកុមារទៀតផង ក៏ត្រូវបានចាត់ទុកជាប្រភពនៃការធ្វើឱ្យពេញចិត្ត និងជាគ្រឿងបន្លាស់សម្រាប់ពិភពលោកដែលរីកចម្រើន ។ ប្រភេទជំនួញឧក្រិដ្ឋកម្មបែបនេះ បានរីករាលដាលនៅក្នុងប្រទេសរុស្ស៊ី អ៊ុយក្រែន និងបេឡារូស ដែលស្ត្រីមកពីប្រទេសទាំងនេះត្រូវបាននាំចេញទៅកាន់អឺរ៉ុបខាងលិច និងសហរដ្ឋអាម៉េរិក ។ ជំនួញមួយនៃជំនួញផ្សេងៗគ្នាក្នុងអំពើនេះ គឺការលក់ស្រីក្មេងៗដោយធ្វើជាកូនក្រមុំទៅឱ្យបុរសដែលមានទ្រព្យសម្បត្តិមកពីប្រទេសផ្សេងៗ ព្រមទាំងមានការលក់កុមារសម្រាប់គោលបំណងនៃការយកទៅចិញ្ចឹមរបស់ពួកគេទៀតផង ។ រដ្ឋាភិបាលរុស្ស៊ីត្រូវបានបង្ខំនៅក្នុងឆ្នាំ ១៩៩៥ ឱ្យពង្រឹងច្បាប់ស្តីពីនីតិវិធីផ្ទេរកុមារសម្រាប់ការយកទៅចិញ្ចឹមចំពោះជនជាតិរុស្ស៊ី និងបរទេស ។

ប្រភេទថ្មីមួយនៃសកម្មភាពឧក្រិដ្ឋជនឆ្លងដែន គឺការចាប់កុមារយកទៅលក់ ដើម្បីយកសរីរាង្គកាយប្រើប្រាស់ ។ ដោយយោងទៅតាមឯកសារយោងនៃអង្គការសហប្រជាជាតិ នៅក្នុងប្រទេសអាហ្សង់ទីន មានករណីដែលត្រូវបានគេដឹងពីការប្រើប្រាស់ខុសច្បាប់ដ៏ធ្ងន់ធ្ងរនៃនីតិវិធីផ្សាំសរីរាង្គដែលអ្នកជំងឺជាច្រើនព្យាបាលដោយយកកញ្ចក់ភ្នែករបស់ពួកគេចេញ ដោយសំអាងទៅលើការវិភាគខួរក្បាលកែបន្លំ ។ មានករណីដែលត្រូវកត់សម្គាល់ជាច្រើនដែលសរីរាង្គកាយមនុស្សត្រូវបាននាំចេញដោយឯកសារក្លែងបន្លំពីប្រទេសអាហ្សង់ទីន ប្រេហ្ស៊ីល ហុងឌូរ៉ាស ម៉ិចសិកកូ និងប៉េរូ សម្រាប់អ្នកទិញនៅក្នុងប្រទេសអាឡឺម៉ង់ អ៊ីតាលី និងស្វីស ។

## IV. កម្រិតនៃការរៀបចំសម្រាប់ឧក្រិដ្ឋជនមានអង្គការចាត់តាំង

អត្ថន័យនៃឧក្រិដ្ឋកម្មមានអង្គការចាត់តាំងត្រូវបានឱ្យនិយមន័យ មិនផ្តោតទៅលើអំពើហិង្សា តែគិតពីការកេងចំណេញផ្នែកសេដ្ឋកិច្ច ។ ភាពខុសគ្នារវាងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងការប្រព្រឹត្តខុសច្បាប់ គឺយោងទៅលើចរិត និងកម្រិតនៃការចូលរួមរបស់ឧក្រិដ្ឋជនខ្លះ ក្នុងសកម្មភាពឧក្រិដ្ឋកម្មរបស់ពួកគេ ដែលអនុវត្តដោយក្រុមមនុស្សប្រើពេលដ៏យូរ ហើយមិនត្រឹមតែសកម្មភាពមួយនៃក្រុមណាមួយនោះទេ ទោះបីជាក្រុមមកក្រោយគេ ក៏ជាអ្នកចាប់ផ្តើមបង្កើតនូវក្រុមឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងនោះដែរ ។

បាតុភូតនៃការរៀបចំនេះ សំដៅមិនគ្រាន់តែទៅលើការបំពេញនូវសកម្មភាពច្បាស់លាស់ចំពោះការបង្កើតទម្រង់នៃក្រុមឧក្រិដ្ឋជនប៉ុណ្ណោះទេ ថែមទាំងសំដៅទៅលើអត្ថិភាព និងសកម្មភាពឧក្រិដ្ឋកម្មទៀតផង ។ ការអនុវត្តនូវឧក្រិដ្ឋកម្មស្រដៀង ឬផ្សេងៗគ្នា គឺទាក់ទងជាអចិន្ត្រៃយ៍ជាមួយជំនួញទាំងស្រុងនៃក្រុមគោលដៅដែលបានរៀបចំទុកក្នុងចំណោមពួកគេ ហើយក្រុមនីមួយៗមានតួនាទីផ្ទាល់ខ្លួនផ្សេងៗគ្នា "សិទ្ធិ និង អំណាច " ។

គំរូសាមញ្ញនៃឧក្រិដ្ឋកម្មអាចត្រូវបានចាត់ទុកថាជា ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង គឺមានលក្ខណៈដូចជា ការចាប់ជំរិត អំពើចោរកម្ម ឃាតកម្ម ការរត់ពន្ធ ការគំរាមកំហែង...។ ជាប្រចាំ និង

ដោយចេតនា ឧក្រិដ្ឋជនមានអង្គការចាត់តាំងស្វែងរកប្រាក់ចំណូលខ្ពស់ ហើយមានការប្រថុយប្រថានតិច ធ្វើជំនួញគ្រឿងញៀន ឬសព្វាវុធខុសច្បាប់ ភេរវកម្ម អំពើពុករលួយ ការរត់ពន្ធ ការសម្អាតប្រាក់ ការបង្កើតសហគ្រាសក្លែងក្លាយ ដែលជាវិធីសម្រាប់ធ្វើសកម្មភាពរបស់ខ្លួនឱ្យស្របច្បាប់...។

ទម្រង់ឧក្រិដ្ឋកម្មនៃសកម្មភាពឧក្រិដ្ឋជនមានអង្គការចាត់តាំងដែលគិតតែពីប្រាក់ចំណេញគឺមានច្រើន និងចម្រុះគ្នា ។ ពួកគេផ្លាស់ប្តូរទៅតាមឱកាសដែលបើក និងបិទ នៅក្នុងប្រទេស តំបន់ ឬពិភពលោក ។ ឧទាហរណ៍ ៖

- នៅឆ្នាំ ១៩៩៣-១៩៩៤ នៅក្នុងប្រទេសរុស្សី ឧក្រិដ្ឋជនមានអង្គការចាត់តាំងបានប្រើប្រាស់នូវប័ណ្ណឥណទាន អ្នកវិនិយោគក្លែងក្លាយ សំបុត្រធានាឯកជនរបស់រដ្ឋ ។ល។ ក្លែងបន្លំជាច្រើន ដែលវាហាក់ដូចជាវិធីនៃការទទួលបានទ្រព្យធននោះ
- ឆ្នាំ ១៩៩៥-១៩៩៦ ពួកគេបែរទៅរកស៊ីប្រថុយប្រថានដើម្បីប្រាក់ចំណេញ ដូចជាទីផ្សារភាគហ៊ុន គ្រឿងញៀនខុសច្បាប់ ការលក់រូបិយប័ណ្ណក្នុងទីផ្សារងងឹត ការបំផ្លាញអ្នកប្រកួតប្រជែង ។ល។ ប៉ុន្តែនៅក្នុងទម្រង់ទាំងនេះ គោលការណ៍នាំមុខ គឺជាការចង់បានប្រាក់ចំណេញ ។

អង្គការសហប្រជាជាតិបានបង្កើតសេចក្តីបន្ថែមនៅឆ្នាំ ១៩៩២ ចំពោះការស្នើឱ្យមានការបង្កើតទម្រង់អំពីប្រភេទនៃឧក្រិដ្ឋកម្មមានអង្គការចាត់តាំងឆ្លងដែន ១៤ រួមមាន ៖

១. ការសម្អាតប្រាក់
២. ភេរវកម្ម
៣. ការលួចវត្ថុសិល្បៈ
៤. ការលួចកម្មសិទ្ធិបញ្ញា
៥. ការជួញដូរអាវុធខុសច្បាប់
៦. ការប្លន់យន្តហោះ
៧. ការប្លន់តាមសមុទ្រ
៨. ការប្លន់ការដឹកទំនិញតាមជើងគោក
៩. ការក្លែងបន្លំឯកសារ
១០. បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា(កុំព្យូទ័រ)
១១. បទល្មើសបរិស្ថាន
១២. ការជួញដូរមនុស្ស
១៣. ការជួញដូរសរីរាង្គមនុស្ស
១៤. ការជួញដូរថ្នាំញៀនណារកូទិក

បញ្ជីទាំងនេះត្រូវបានធ្វើបន្ថែមនៅក្នុងទីក្រុង Naples អ៊ីតាលី នៅឯសន្និសីទពិភពលោក ស្តីពីឧក្រិដ្ឋជនមានអង្គការចាត់តាំងនៅក្នុងខែ វិច្ឆិកា ១៩៩៤ ដោយបន្ថែម ការបើកបនល្បែង ការរត់ពន្ធជនអន្តោប្រវេសន៍ខុសច្បាប់ ការគំរាមកំហែង ការជួញដូរសម្ភារៈវិទ្យុសកម្មខុសច្បាប់ ការជួញដូរសត្វកម្រខុសច្បាប់ ការលួចឡានបែបអន្តរជាតិ និងបទល្មើសផ្សេងទៀត ។

បញ្ជីនៃទម្រង់ឧក្រិដ្ឋកម្មដ៏លើសលុបនេះ បានផ្តល់នូវតំណាងដ៏ច្បាស់លាស់នៃភាពទទួលបានប្រាក់ចំណេញចំពោះឧក្រិដ្ឋកម្មបែបប្រពៃណី ដែលប្រព្រឹត្តិដោយឧក្រិដ្ឋជនមានអង្គការចាត់តាំង ហើយទម្រង់ទាំងនោះអាចក្លាយជាជំនួញនៅក្នុងប្រទេស និងអន្តរជាតិ ។ ប្រាក់ចំណេញ គឺជាកត្តាសាមញ្ញជាក់ស្តែងរបស់ពួកគេ និងជាផ្នែកគាំទ្រដ៏សំខាន់នៃឧក្រិដ្ឋជនមានអង្គការចាត់តាំង ។

ឧក្រិដ្ឋជនមានអង្គការចាត់តាំងមានលក្ខណៈភិនភាគដែលមានអន្តរទំនាក់ទំនង និងការរៀបចំបង្កើតឧក្រិដ្ឋកម្មមានអង្គការចាត់តាំង អាចមានទម្រង់ជាសមាគមៈ

- អ្នកគ្រប់គ្រង(ប្រធាន អនុប្រធាន បងធំ អ្នកមានអំណាចនៅក្នុងអង្គការឧក្រិដ្ឋជន )
- រចនាសម្ព័ន្ធតាមឋានានុក្រមពិតប្រាកដ (មេដឹកនាំ អ្នកធ្វើសកម្មភាពដោយផ្ទាល់)
- ការបែងចែកតួនាទីច្បាស់លាស់ (មុខងារ )ដែលត្រូវដឹងក្នុងការបំពេញភារកិច្ច
- វិន័យដោយផ្អែកលើច្បាប់ផ្ទាល់ខ្លួន
- ប្រព័ន្ធនៃការដាក់ទណ្ឌកម្មដ៏តឹងរ៉ឹង រហូតដល់ការបំផ្លាញរាងកាយ ឬបាត់បង់បក្សពួក
- ការរៀបចំហិរញ្ញវត្ថុដើម្បីដោះស្រាយកិច្ចការទូទៅ
- ការប្រមូលផ្តុំព័ត៌មានពីតំបន់នៃសកម្មភាពឧក្រិដ្ឋកម្មទទួលផលចំណេញ និងសុវត្ថិភាព
- ប្រើអំពើពុករលួយលើមន្ត្រីអនុវត្តច្បាប់ ដើម្បីទទួលព័ត៌មានចាំបាច់ ជំនួយ ឬការការពារ
- ការប្រើប្រាស់ស្ថាប័នរដ្ឋាភិបាលមួយចំនួន និងសង្គម-សេដ្ឋកិច្ចដ៏សំខាន់ៗ ដែលប្រតិបត្តិនៅក្នុងប្រទេស និងជុំវិញពិភពលោក សម្រាប់គោលបំណងបង្កើតភាពត្រឹមត្រូវតាមច្បាប់នៅក្រៅប្រទេសសម្រាប់សកម្មភាពឧក្រិដ្ឋកម្មរបស់ពួកគេ
- ការផ្សព្វផ្សាយនូវពាក្យចចាមអារាមធ្វើឱ្យគេខ្លាច ដោយសារអំណាចរបស់ខ្លួន ដែលនាំឱ្យអង្គការឧក្រិដ្ឋជនមានផលប្រយោជន៍ច្រើន
- ការបង្កើតនូវរចនាសម្ព័ន្ធគ្រប់គ្រងដែលធ្វើឱ្យមេដឹកនាំរួចផុតពីការពាក់ព័ន្ធ នៃការរៀបចំ និងប្រព្រឹត្តិឧក្រិដ្ឋកម្មដោយផ្ទាល់ និងជាក់លាក់ ។ ហើយការណ៍នេះធ្វើឱ្យពួកគេចំណេញទាំងអស់គ្នា គឺមេដឹកនាំបានរួចផុតពីការទទួលខុសត្រូវ ហើយអ្នកអនុវត្តផ្ទាល់ មិនពាក់ព័ន្ធដល់ក្រុម
- ទទួលនូវផលប្រយោជន៍ជាប្រាក់ចំណេញ ហើយត្រួតត្រានៅក្នុងដែនដី ឬទឹកដីខ្លះផ្សេងទៀត ដើម្បីផលប្រយោជន៍រកប្រាក់ និងសុវត្ថិភាព ។

សកម្មភាពខាងលើអាចកើតមានឡើងតាមកម្រិត និងទម្រង់ខុសៗគ្នា ដែលឆ្លុះបញ្ចាំងឱ្យឃើញលក្ខណៈភិនភាគពិតប្រាកដនៃឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ។

កត្តាជាច្រើននៃកត្តាទាំងនេះអាចត្រូវបានស៊ើបអង្កេត ប្រសិនបើយើងគិតពិចារណាពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ ផ្អែកលើមូលដ្ឋាននេះ យើងអាចកំណត់នូវចំនួននៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ដែលបង្ហាញឱ្យដឹងនូវតំបន់ធ្វើសកម្មភាពឧក្រិដ្ឋកម្ម រយៈពេលដែលពួកគេមានអត្ថិភាព កម្រិតសកម្មភាព លក្ខណៈគ្រប់គ្រងភូមិសាស្ត្រនៃសកម្មភាពរបស់ពួកគេ និងវត្តមាននៃទំនាក់ទំនងអំពើពុករលួយ ។ល។

## V. ឧក្រិដ្ឋកម្មឆ្លងដែន ៖ ការគំរាមកំហែងចំពោះសន្តិសុខ និងសន្តិភាពអន្តរជាតិ

ប្រព័ន្ធអន្តរជាតិដែលត្រូវបានបង្កើតដោយមានការសម្រេចសន្ធិសញ្ញានៃ Westphalia (សន្ធិសញ្ញាដែលបានបញ្ចប់សង្គ្រាមរវាងហូឡង់ និងអេស្ប៉ាញដែលមានរយៈពេល ៨០ ឆ្នាំ ដើម្បីឯករាជ្យភាពរបស់ប្រទេសហូឡង់) បានទទួលនូវការផ្លាស់ប្ដូរដ៏ខ្លាំងក្លា និងមានអត្ថន័យ ។ ភាគីពិតប្រាកដនៅក្នុងទំនាក់ទំនងអន្តរជាតិ ដែលមាននូវរដ្ឋអធិបតេយ្យ និងឯករាជ្យ ត្រូវបានពង្រីកដើម្បីជួយភាគីដែលមិនមានរដ្ឋឱ្យចូលក្នុងអង្គការអន្តររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល និងក្រុមប្រឹក្សាចម្រុះជាតិសាសន៍ ។ ប្រទេសជាច្រើនមិនត្រូវបានធ្វើឱ្យបែកខ្ញែកគ្នាដោយជម្លោះមនោគមវិជ្ជា ប៉ុន្តែស្ថានភាពសេដ្ឋកិច្ចអាចត្រូវធ្វើឱ្យមានការបែកបាក់ ។ គោលបំណងដ៏ចម្បងក្នុងការដោះស្រាយជាមួយគ្នាទៅវិញទៅមកមិនត្រូវបានរឹតត្បិត ចំពោះការរីកចម្រើននៃផលប្រយោជន៍ជាតិ ប៉ុន្តែត្រូវរួមបញ្ចូលការទទួលបានសន្តិសុខ និងសន្តិភាពតាមតំបន់ និងអន្តរជាតិ ។

### ១. ការកំណត់ឧក្រិដ្ឋកម្មឆ្លងដែន

ចរិតនៃឧក្រិដ្ឋកម្មឆ្លងដែនខ្លះ ទោះបីជាមិនថ្មីក៏ដោយ មិនទាន់ត្រូវបានទទួលស្គាល់ឱ្យពេញលេញនៅឡើយទេ រហូតមកទល់ពេលនេះ ។ ឧក្រិដ្ឋកម្មត្រូវបានមើលឃើញជាយូរមកហើយថា ជាបញ្ហារបស់មន្ត្រីអនុវត្តច្បាប់នៅក្នុងស្រុក និងត្រូវបានចាត់ទុកជា ការព្រួយបារម្ភនៃរដ្ឋនីមួយៗ ។ ឧក្រិដ្ឋកម្មឆ្លងដែនជាការគំរាមកំហែងថ្មីមួយ ចំពោះផលប្រយោជន៍ និងសន្តិសុខក្នុងប្រទេស និងអន្តរជាតិ ហើយមិនទាន់ត្រូវបានកំណត់និយមន័យជាផ្លូវការនៅឡើយទេ ។ ទោះជាយ៉ាងក៏ដោយ មាននូវការយល់ស្របមតិជាទូទៅ ដើម្បីទទួលយកនិយមន័យផ្សេងៗគ្នានៃឧក្រិដ្ឋកម្មឆ្លងដែន ដែលបានកំណត់ថា ជាបទឧក្រិដ្ឋមួយដែលមានវិសាលភាពជាលក្ខណៈអន្តរជាតិ និងយ៉ាងហោចណាស់ ក៏បានឆ្លងកាត់ព្រំដែនប្រទេសមួយ ។

### ២. ឧក្រិដ្ឋកម្មតាមតំបន់

ដើម្បីដោះស្រាយនឹងបញ្ហាឧក្រិដ្ឋកម្មតាមតំបន់ និងអន្តរជាតិ រដ្ឋភាគីត្រូវមានការព្រមព្រៀងសម្រេចធ្វើសកម្មភាពដើម្បីដោះស្រាយបញ្ហាទាំងនោះជាលក្ខណៈអន្តរជាតិ ដោយមានកិច្ចសហប្រតិបត្តិការរវាងមន្ត្រីអនុវត្តច្បាប់អន្តរជាតិ ។ ទោះបីជាមានភាពផ្សេងៗគ្នានៃច្បាប់របស់ប្រទេសនីមួយៗក៏ដោយ ក៏គោលការណ៍ស្នូលនៃសន្តិសុខប្រទេសត្រូវមាន ៖

- រក្សាការពារឱ្យបាននូវការគ្រប់គ្រងអធិបតេយ្យភាព ចំពោះទិសដៅ និងតួនាទីនៃប្រព័ន្ធនយោបាយ សេដ្ឋកិច្ច និងសង្គម
- រក្សាការពារឱ្យបាននូវផលប្រយោជន៍របស់ប្រជាពលរដ្ឋ និង
- រក្សាការពារឱ្យបាននូវផលប្រយោជន៍ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងឱ្យមានស្ថិរភាព ។

ឧក្រិដ្ឋកម្មបានវាយប្រហារដល់គោលដៅផ្សេងៗគ្នានៃប្រព័ន្ធទាំងនោះ និងស្ថាប័ននានាដោយដាក់ការគំរាមកំហែង ចំពោះផលប្រយោជន៍នៃប្រទេសក្នុងតំបន់ ។ នៅពេលវេលាផ្សេងៗគ្នា និងសម្រាប់ដែនឧក្រិដ្ឋកម្ម ប្រទេសទាំងអស់គឺជាជនរងគ្រោះផង និងជាម្ចាស់ផ្ទះផង ។

កូនសោដ៏សំខាន់ចំពោះការតស៊ូប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន គឺកិច្ចសហប្រតិបត្តិការដ៏សកម្មដែលមានមូលដ្ឋានលើ ៖

- ការជឿទុកចិត្តគ្នាទៅវិញទៅមក
- ប្រត្យក្សារម្មណ៍ទូទៅនៃការគំរាមកំហែង
- ត្រូវដឹងថាអ្នកបង្កឧក្រិដ្ឋកម្មជាច្រើនមានឥទ្ធិពលពីក្រៅប្រទេស
- ត្រូវយល់ដឹងចំពោះកម្រិតនៃអន្តរាគមន៍ និងសកម្មភាពឯកតោភាគី និង
- គោលបំណងដើម្បីធ្វើការជាមួយប្រទេសដៃគូ ដើម្បីផលប្រយោជន៍ការពារបូរណភាព និងអធិបតេយ្យភាពរបស់ប្រទេស ។

**៣. ការវិវត្តនៃឧក្រិដ្ឋកម្មមានអង្គការចាត់តាំង**

ដំណើរការនៃការវិវត្តរបស់ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង មានចាប់ពីអំពើចោរកម្ម ទៅជាការរស់នៅដោយសារគេ និងទៅជាការពឹងផ្អែកគ្នាទៅវិញទៅមក ។

ដំណាក់កាលនៃអំពើចោរកម្ម គឺនៅពេលដែលក្រុមជនពាលតាមផ្លូវ ឬក្រុមឧក្រិដ្ឋជនក្នុងស្រុកផ្សេងទៀត ប្រព្រឹត្តអំពើឧក្រិដ្ឋ ក្នុងការរក្សាការគ្រប់គ្រងលើដែនដី ដើម្បីកំចាត់ដៃគូ និងដើម្បីបង្កើតនូវដំណើរការផ្តាច់មុខដោយការប្រើប្រាស់កម្លាំង និងមាននិន្នាការឆ្ពោះទៅរកការលើកទឹកចិត្ត និងការបំពេញចិត្ត ។ នៅពេលដែលការត្រួតត្រាត្រូវបានបង្កើតហើយ ក្រុមឧក្រិដ្ឋជនត្រូវបានទទួលស្គាល់ក្នុងចំណោមឈ្មួញកណ្តាលដែលមានអំណាច មេដឹកនាំនយោបាយក្នុងស្រុកខ្លះ និងអ្នកមានឥទ្ធិពលខាងសេដ្ឋកិច្ច ដែលអាចប្រើប្រាស់បណ្តាញក្រុមនេះ ដោយធ្វើមិនចំពោះមុខ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដូចជា ការប្រមូលបំណុល បង្កើតការបោះឆ្នោត ឬបំបាត់គូប្រជែងខាងនយោបាយ ឬខាងជំនួញ ។

បន្ទាប់មក ក្រុមឧក្រិដ្ឋជនបានប្រែក្លាយទៅជាទម្រង់នៃការរស់នៅដោយសារគេ គឺនៅពេលដែលពួកគេផ្តល់សំណូក និងធ្វើការត្រួតត្រាលើដែនដីមូលដ្ឋានរបស់ខ្លួន ជាមួយនឹងតម្រូវការឈ្មួញកណ្តាលសម្រាប់សេវាកម្មខុសច្បាប់ ហើយក្លាយជាក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងពេញលេញ ។ អំពើពុករលួយខាងនយោបាយដែលជួយដល់ការផ្តល់សេវាកម្ម និងទំនិញខុសច្បាប់ បានផ្តល់នូវចំណងដ៏សំខាន់ និងស្និតរមួតជាមួយអង្គការឧក្រិដ្ឋជនសម្ងាត់ ។ ដោយចេះតែកើនឡើងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង បានពង្រីកឥទ្ធិពលរបស់ខ្លួនទៅលើទីក្រុង និងតំបន់ផ្សេងៗ ហើយមានលក្ខណៈស្មើនឹងរដ្ឋ និងអាចធំជាងរដ្ឋទៀតផង ។

នៅដំណាក់កាលនៃការពឹងពាក់គ្នាទៅវិញទៅមក ចំណងនៃការរស់នៅដោយសារគេ និងមានភាពស្មើគ្នារវាងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង និងរដ្ឋ បានក្លាយជាការពឹងពាក់គ្នាទៅវិញទៅមក ។ រដ្ឋបានពឹងផ្អែកទៅលើបណ្តាញនៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ដើម្បីទ្រទ្រង់ឥទ្ធិពលរបស់ខ្លួន ។ នៅពេលដែលក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងបានឈានដល់ដំណាក់កាលនៃការពឹងពាក់គ្នាទៅវិញទៅមក វាគឺមិនគ្រាន់តែជាបញ្ហាមន្ត្រីអនុវត្តច្បាប់ប៉ុណ្ណោះទេ តែវាជាការបង្កបញ្ហាដល់សន្តិសុខជាតិ ។

## ៤. ភាពសំខាន់ៗនៃឧក្រិដ្ឋកម្មឆ្លងដែននៅអាស៊ីប៉ាស៊ីហ្វិក

សហគ្រាសឧក្រិដ្ឋកម្ម ឬឧក្រិដ្ឋកម្មមានអង្គការចាត់តាំង គឺរីករាលដាលទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក និងពាក់ព័ន្ធនៅក្នុងសកម្មភាពឧក្រិដ្ឋកម្មភាគច្រើន ដូចជា ការជួញដូរគ្រឿងញៀនខុសច្បាប់ ការសម្អាតប្រាក់ អន្តោប្រវេសន៍ខុសច្បាប់ ពេស្យាកម្មឆ្លងដែន ការក្លែងបន្លំប័ណ្ណឥណទាន ការក្លែងបន្លំឯកសារ និងអំពើពុករលួយ ។ ទោះបីជាក្រុមខ្លះដូចជា អង្គការឧក្រិដ្ឋកម្មសង្គមងងឹតចិន និងជប៉ុន Yakuzi មានរចនាសម្ព័ន្ធដូចឧក្រិដ្ឋជនមានអង្គការចាត់តាំងបែបប្រពៃណីក៏ដោយ ក្រុមផ្សេងទៀតជាច្រើនគឺមានរចនាសម្ព័ន្ធសាមញ្ញជាង និងត្រៀមរួចជាស្រេច ដើម្បីបង្កើតនូវបក្សសម្ព័ន្ធកលយុទ្ធជាមួយក្រុមផ្សេងទៀត តាមឱកាស ។

ក្រុមដែលមានប្រសិទ្ធភាព និងធំបំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក គឺអាចជាក្រុមឧក្រិដ្ឋជនចិនផ្សេងៗគ្នា ដែលមានរចនាសម្ព័ន្ធចាត់តាំង រួមមាន អង្គការឧក្រិដ្ឋកម្មសង្គមងងឹតចិន ។ សកម្មភាពនៃក្រុមទាំងនេះគឺចម្រុះគ្នា ។ វាត្រូវបានប៉ាន់ប្រមាណជាលក្ខណៈអន្តរជាតិថា មានមនុស្ស ១៧០ ០០០ នាក់ ជាសមាជិកសកម្មនៅក្នុងអង្គការឧក្រិដ្ឋកម្មសង្គមងងឹតចិន ដូចជា ក្រុម Sun Yee On ក្រុម 14K និងក្រុម Wo ដែលមានមូលដ្ឋាននៅហុងកុង ក្រុមជនពាល the United Bamboo Gang ដែលមានមូលដ្ឋាននៅតៃវ៉ាន់ និងក្រុមសមុទ្របួន (the Four Seas Band) និងក្រុមកងយក្ស (Great Circle Gang) ដែលមានមូលដ្ឋាននៅចិនដីគោក ។ ក្រុមអង្គការឧក្រិដ្ឋជនសង្គមងងឹតទាំងនេះ មានទំនាក់ទំនងទូលំទូលាយនៅបរទេស ជាពិសេសនៅអាស៊ីអាគ្នេយ៍ អឺរ៉ុប និងសហរដ្ឋអាម៉េរិក។ តែទោះជាយ៉ាងណាក៏ដោយ ក៏មានក្រុមសកម្មខ្លាំងមួយចំនួនទៀតនៅក្នុងប្រទេសភូមា និងប្រទេសថៃ Chiu Chow groups ក្រុមសង្គមសម្ងាត់ខ្លានាគ (Tiger Dragon Secret Society) នៅប្រទេសសាំងហ្គាពួរ និងក្រុម18 Gang and the Wah Kee នៅប្រទេសម៉ាឡេស៊ី ដែលមិនលេចមុខធ្វើប្រតិបត្តិការជាអង្គការឧក្រិដ្ឋកម្មសង្គមងងឹតចិនទេ ប៉ុន្តែទោះជាយ៉ាងណាក៏សកម្មខ្លាំងក្លា និងទទួលជោគជ័យក្នុងអំពើឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសក្រុមជួញដូរថ្នាំញៀនហេរ៉ូអ៊ីន ។

អង្គការឧក្រិដ្ឋកម្មសង្គមងងឹតចិន មានមូលដ្ឋានជាសំខាន់ក្នុងទីក្រុងហុងកុង បានដើរតួនាទីដ៏សំខាន់នៅក្នុងឧស្សាហកម្មជួញដូរថ្នាំញៀនហេរ៉ូអ៊ីន ។ ទោះបីជាមាននូវការពិភាក្សាក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ ថាតើអង្គការឧក្រិដ្ឋកម្មសង្គមងងឹតចិន គ្រប់គ្រងជាផ្លូវការទៅលើពាណិជ្ជកម្មថ្នាំញៀនហេរ៉ូអ៊ីននៅអាស៊ីអាគ្នេយ៍ ក៏ដូចជាប្រឆាំងនឹងក្រុមសមាជិកនីមួយៗ ដោយប្រើបណ្ដាញក្រុមទាំងនេះ និងទំនាក់ទំនងសម្រាប់ការជួញដូរក៏ដោយ ក៏ក្រុមដែលមានមូលដ្ឋាននៅហុងកុង បានផ្ដល់នូវមជ្ឈមណ្ឌលចែកចាយយ៉ាងសកម្ម ដែលអាចបញ្ជូនថ្នាំញៀនហេរ៉ូអ៊ីនទៅកាន់សហរដ្ឋអាម៉េរិក អឺរ៉ុបខាងលិច និងអូស្ត្រាលី ។

ក្រុមឧក្រិដ្ឋកម្មសង្គមងងឹតជប៉ុន Yakuzi មានសមាជិកប្រមាណ ៨៧ ០០០ នាក់នៅក្នុងបក្សសម្ព័ន្ធ ២៣០០ ។ ដោយយោងទៅតាមទីភ្នាក់ងារប៉ូលិសជាតិជប៉ុន ក្រុមនេះបានរកប្រាក់ចំណូលប្រហែល ១៤០០ ០០០ លានយ៉េន ក្នុងមួយឆ្នាំ ពីសកម្មភាពជំនួញ និងឧក្រិដ្ឋកម្មរបស់ខ្លួន ។ មុនឆ្នាំ ១៩៩២ សមាជិកភាពនៃក្រុមនេះមិនមានវិន័យតឹងរ៉ឹង ដែលត្រូវអនុវត្តទៅលើសមាជិកក្រុមនោះទេ ។

ក្រុម Yakuzi ធំសំខាន់បី គឺក្រុម Yamaguchi-gumi មានសមាជិក ២៦ ០០០ នាក់ ក្រុម Shimiyoshi-Kai មានសមាជិក៨ ០០០ នាក់ និងក្រុមInagawa-Kai មានសមាជិក ៨ ០០០នាក់ ។

សកម្មភាពចម្បងនៃក្រុម Yakuzi គឺជំនួញតូចៗ (ជាពិសេសការសាងសង់) ក្រុមហ៊ុនហិរញ្ញវត្ថុ និងលក់អចលនទ្រព្យ ការជួញដូរគ្រឿងញៀន (មេតំហ្វេតាមីនពណ៌ថ្លា ឬទឹកកក) និងរបរទុច្ចរិតជំរិតយកប្រាក់ និងការពារប្រឆាំងនឹងក្រុមជំនួញសារជីវកម្មនានា (ក្រុម Sokaiya គឺជាអ្នកប្រកបរបរទុច្ចរិត ការចងការប្រាក់ អំពើពុករលួយនៃមន្ត្រីសាធារណៈ និងអ្នកជំនួញ ពេស្យាកម្ម ការបើកបនល្បែង ឧស្សាហកម្មភាពយន្ត និងកំសាន្ត) និងនាំចូលនូវកម្មករខុសច្បាប់ចូលប្រទេសជប៉ុន ។ នៅក្រៅប្រទេស ក្រុម Yakuzi ចម្រុះ គឺសកម្មនៅក្នុងសហរដ្ឋអាម៉េរិក (ជាពិសេសនៅក្នុងរដ្ឋ Guam, the Marianas and Hawaii) ប្រទេសហ្វីលីពីន ប្រទេសផ្សេងទៀតនៅក្នុងអាស៊ីអាគ្នេយ៍ និងប្រទេសអូស្ត្រាលី ជាកន្លែងពួកគេផ្តោតទៅលើសមាជិកនៃសហគមន៍ជប៉ុនក្នុងស្រុក ឬទេសចរជប៉ុន ។

**៥. ផលប៉ះពាល់នៃឧក្រិដ្ឋកម្មមានអង្គការចាត់តាំងឆ្លងដែន**

ជាទូទៅ បញ្ហាស្ថិរភាព និងសន្តិសុខអន្តរជាតិត្រូវបានគេវិភាគថា មានជាប់ពាក់ព័ន្ធនឹងការគំរាមកំហែងផ្នែកយុទ្ធសាស្ត្រ និងយោធា ។ ខណៈដែលការគំរាមកំហែងខាងយោធាក្រៅប្រទេសនៅតែមាន គេកាន់តែយល់ស្របថែមទៀតថា ប្រទេសទាំងឡាយត្រូវតែគិតពិចារណាពីភាពផ្សេងៗគ្នាដ៏ច្រើននៃការគំរាមកំហែងទាំងនៅក្នុង និងក្រៅប្រទេស និងចំណុចខ្សោយរបស់ប្រទេសនោះដែលជាមុខព្រួញរបស់ឧក្រិដ្ឋកម្ម ។ បន្ថែមទៅលើការគំរាមកំហែងខាងយោធា សន្តិសុខរបស់ប្រទេសអាចត្រូវបានធ្វើឱ្យមានការព្រួយបារម្ភ ដោយការគំរាមកំហែងចំពោះសុខុមាលភាពសេដ្ឋកិច្ច ស្ថិរភាពនយោបាយ ភាពចុះសម្រុងក្នុងសង្គម បរិស្ថាន និងសុខភាពនៃប្រជាពលរដ្ឋរបស់ខ្លួនទៀតផង ។ ផ្តើមចេញពីទស្សនវិស័យនេះ ប្រទេសជាច្រើនបានអះអាងថា បន្ទាប់ពីរយៈពេលនៃសង្គ្រាមត្រជាក់ សន្តិសុខរួមរបស់មនុស្សជាតិ ត្រូវបានធ្វើឱ្យប៉ះពាល់ដោយវិសាលភាពសំខាន់ប្រាំ ៖

១. យោធា

២. នយោបាយ

៣. សេដ្ឋកិច្ច

៤. សង្គម

៥. បរិស្ថាន

ឧក្រិដ្ឋកម្មឆ្លងដែនមានផលប៉ះពាល់យ៉ាងខ្លាំងក្លា តាមរយៈវិសាលភាពមួយនៃវិសាលភាពទាំង ៥ នេះ ។ ទាក់ទិននឹងសន្តិសុខយោធា បទឧក្រិដ្ឋទាំងឡាយអាចមានផលប៉ះពាល់យ៉ាងហោចណាស់បី ៖

- នៅពេលដែលប្រទេសត្រូវបានគ្រប់គ្រងដោយរបបណាមួយ ដែលមានទំនាក់ទំនងរស់នៅជាមួយគ្នា និងជួយគ្នាទៅវិញទៅមក ជាមួយឧក្រិដ្ឋជនមានអង្គការចាត់តាំង យោធា និងអាជ្ញាធរអនុវត្តច្បាប់ អាចត្រូវបានប្រើសម្រាប់គោលបំណងឧក្រិដ្ឋកម្ម ឬដើម្បីការពារសហគ្រាសឧក្រិដ្ឋជន ។ ប្រភេទនេះអាចរាប់បញ្ចូលទំនាក់ទំនងរវាងអតីតក្រុមឧក្រិដ្ឋជនសូវៀត Soviet nomenklatura និង

ឧក្រិដ្ឋជនមានអង្គការចាត់តាំង ដែលត្រូវបង្កប់ចូលជារចនាសម្ព័ន្ធទៅក្នុងប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចនៃប្រទេស

- ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងមានចំណងទាក់ទង ដែលរស់នៅជាមួយគ្នា និងជួយគ្នាទៅវិញទៅមកក្នុងប្រទេស ប៉ុន្តែអាចប្រឆាំងនឹងធន្ទះ និងរចនាសម្ព័ន្ធអំណាចនៃប្រទេស ។ ពួកគេហាក់ដូចជាអ្នកធ្វើការឱ្យ ឬត្រូវជួលដោយស្ថាប័នរដ្ឋ (រួមមានប៉ូលិស និងយោធា)ដែលប្រើពួកគេដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន
- ភាពអវត្តមានសង្គមស៊ីវិល បានធ្វើមានការកើតឡើងនៃក្រុមឧក្រិដ្ឋជនឆ្លងដែន ដូចជាអតីតសហភាពសូវៀត និងអឺរ៉ុបខាងកើត ។ ក្រុមឧក្រិដ្ឋជនឆ្លងដែនក៏កើតចេញពីជម្លោះ និងកុបកម្មផងដែរ ដូចជា នៅប្រទេសស្រីលង្កា ភូមា អាហ្គានីស្ថាន ទួគី សូម៉ាលី និងបូស្នៀ ឬកើតចេញពីលក្ខខណ្ឌទាំងពីរផ្ទាល់ ។

សន្តិសុខនយោបាយ អាចត្រូវបានធ្វើឱ្យប៉ះពាល់ទាំងស្រុង ដោយផលប៉ះពាល់នៃឧក្រិដ្ឋកម្មជាពិសេសអំពើពុករលួយ ។ ឧទាហរណ៍ខាងក្រោមបង្ហាញពីរបៀបដែលអំពើពុករលួយបានប៉ះពាល់ដល់ស្ថិរភាពនយោបាយ ៖

- អតីតអគ្គលេខាធិការនៃអង្គការសន្ធិសញ្ញាអាតាឡង់ទិកខាងជើង (North Atlantic Treaty Organization-NATO) គឺលោក Willy Claes ត្រូវបានចោទប្រកាន់ថាមានអំពើពុករលួយនៅពេលដែលលោកបានធ្វើការបម្រើជារដ្ឋមន្ត្រីសេដ្ឋកិច្ចបែលហ្ស៊ិកនៅឆ្នាំ ១៩៨៨
- នៅប្រទេសជប៉ុន ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ នាយករដ្ឋមន្ត្រី ៤ នាក់នៃគណបក្សប្រជាធិបតេយ្យសេរី Liberal Democratic Party (LDP) ជាបន្តបន្ទាប់ ត្រូវបានបង្ខំឱ្យចុះចេញពីដំណែង ដោយសារតែអំពើពុករលួយដ៏ខ្លាំងក្លា ឬរឿងអាស្រូវផ្សេងទៀត
- ទំនាក់ទំនងស្រដៀងគ្នាជាមួយអង្គការចាត់តាំងជួញដូរថ្នាំញៀនហេរ៉ូអ៊ីនបានធ្វើឱ្យមានផលប៉ះពាល់ដល់ស្ថិរភាពនយោបាយនៃប្រទេសថៃ និងការចោទប្រកាន់ពីការអនុវត្តជំនួញមិនសមរម្យដោយសមាជិកនៃគ្រួសារស៊ូហាតូនៅក្នុងប្រទេសឥណ្ឌូណេស៊ី បាននាំឱ្យមានការរិះគន់ប្រឆាំងនឹងអតីតប្រធានាធិបតី ។

បញ្ហាទាំងអស់ដែលត្រូវប៉ះពាល់ក្រោយសម័យសង្គ្រាមត្រជាក់ ប្រហែលជា សន្តិសុខសេដ្ឋកិច្ចដែលជាបញ្ហាដ៏សំខាន់ ។ ឧក្រិដ្ឋកម្មមានជាប់ពាក់ព័ន្ធ ដែលមិនអាចកែប្រែបាននៅក្នុងសន្តិសុខសេដ្ឋកិច្ច ឱ្យតែមានចំនួនប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ជាប់ទាក់ទងក្នុងសកម្មភាពឧក្រិដ្ឋកម្ម ។ ផលប៉ះពាល់នោះអាចមានឥទ្ធិពលផ្ទាល់ ឬប្រយោល ។ អង្គការសហប្រជាជាតិបានប៉ាន់ប្រមាណថា ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងរកប្រាក់បាន ១ ១០០ ០០០ លានដុល្លារអាម៉េរិក ក្នុងមួយឆ្នាំ ។ តម្លៃប្រចាំឆ្នាំនៃពាណិជ្ជកម្មគ្រឿងញៀនខុសច្បាប់អន្តរជាតិ បានកើនឡើងដល់ ៤០០ ០០០ លានដុល្លារអាម៉េរិក ក្នុងមួយឆ្នាំ ។ កម្មវិធីគ្រប់គ្រងគ្រឿងញៀនអន្តរជាតិរបស់អង្គការសហប្រជាជាតិ The United Nations International Drug Control Programme (UNDCIP) បានធ្វើអត្ថាធិប្បាយថាប្រាក់ ៤០០ ០០០ លានដុល្លារអាម៉េរិកនេះ គឺប្រហែលជា ៨% នៃពាណិជ្ជកម្មអន្តរជាតិសរុប ។

ពាណិជ្ជកម្មគ្រឿងញៀនអន្តរជាតិត្រូវបានរាយការណ៍ថា លើសជាងតម្លៃនៃពាណិជ្ជកម្មប្រេងអន្តរជាតិ ហើយវាត្រូវបានលើសដោយសារតែតម្លៃនៃពាណិជ្ជកម្មសព្វាវុធអន្តរជាតិ ។

ជាចុងបញ្ចប់ ឧក្រិដ្ឋកម្មអាចមានផលប៉ះពាល់យ៉ាងខ្លាំងនៅក្នុងវិស័យសន្តិសុខបរិស្ថាន ។ ឧទាហរណ៍ដូចជា ផលប៉ះពាល់នៃការកាប់ឈើខុសច្បាប់នៅក្នុងប្រទេសថៃ ហ្វីលីពីន ម៉ាឡេស៊ី វៀតណាម កម្ពុជា និងប្រទេសនៅប៉ាស៊ីហ្វិកខាងត្បូង ។ ជាងនេះទៅទៀត ការបំពុលបរិយាកាស ដែលកើតចេញពីភ្លើងនៅក្នុងប្រទេសឥណ្ឌូនេស៊ី ហើយបានរាលដាលទៅដល់ប្រទេសសាំងហ្គាពួរ ម៉ាឡេស៊ី ប្រ៊ុយណេ តំបន់ខ្លះនៃប្រទេសថៃ និងហ្វីលីពីន គឺជាផ្នែកមួយដោយសារក្រុមហ៊ុនកាប់ឈើដែលកាប់ឆ្ការព្រៃខុសច្បាប់ និងដុតបំផ្លាញ ។

លើសពីនេះ ដី ខ្យល់ និងការបំពុលទឹកដែលជាលទ្ធផលនៃការបញ្ចេញចោលកាកសំណល់ឧស្សាហកម្មដែលចំណាយប្រាក់តិច ឬជួយសន្សំថ្លៃដើមនៃក្រុមហ៊ុនធំៗ ។ ទន្ទឹមនេះដែរ ការបញ្ចេញចោលកាកសំណល់នៅក្នុងប្រទេសឧស្សាហកម្មខ្លះ ត្រូវបានអ្នកម៉ៅការ ធ្វើការសូកប៉ាន់ និងមានវិធានការពុករលួយផ្សេងទៀត ដើម្បីជួយសម្រួលដល់ការបញ្ចេញចោលនៃកាកសំណល់ដ៏មានគ្រោះថ្នាក់សម្រាប់យកទៅរក្សាទុក ឬការបំផ្លាញនៅប្រទេសអន់ថយ ។

### ៦. តួនាទីមន្ត្រីអនុវត្តច្បាប់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក

គោលដៅសំខាន់នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់នៅអាស៊ី គួរតែបង្កើតបរិយាកាសតាមតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ក្នុងការរក្សាការពារផលប្រយោជន៍ជាតិ និងចាំបាច់ត្រូវត្រួតពិនិត្យការអនុវត្តច្បាប់ ។

ការបង្កើតនូវក្របខ័ណ្ឌមន្ត្រីអនុវត្តច្បាប់តាមតំបន់ដ៏មានប្រសិទ្ធភាព ឆ្លុះបញ្ចាំងនូវការរីកចម្រើនដែលទទួលផលប្រយោជន៍ទៅវិញទៅមក នៅក្នុងការគ្រប់គ្រងឧក្រិដ្ឋកម្ម ។ វានឹងជួយធ្វើឱ្យមន្ត្រីអនុវត្តច្បាប់ផ្តោតការយកចិត្តទុកដាក់ចំពោះឧក្រិដ្ឋជនសំខាន់ៗមាននៅលើអន្តរជាតិ ដូច្នេះធ្វើឱ្យសម្រេចនូវសេដ្ឋកិច្ចដ៏ច្រើន ឆ្លងតាមកិច្ចខិតខំប្រឹងប្រែងនៃការសម្របសម្រួលលើកិច្ចសហប្រតិបត្តិការការចែករំលែកព័ត៌មាន កាត់បន្ថយការមិនអនុវត្តច្បាប់ និងបង្កើននូវសមត្ថភាពស៊ើបការណ៍សម្ងាត់ ។ ដោយអនុវត្តតាមកិច្ចព្រមព្រៀងក្នុងលក្ខខណ្ឌនេះ មន្ត្រីអនុវត្តច្បាប់ក្នុងស្រុកនឹងមាននូវអត្ថប្រយោជន៍បង្កើតកម្លាំងរឹងមាំ តាមរយៈបណ្តុំធនធាន ការយល់ដឹងនូវវប្បធម៌ចម្រុះ និងកម្រិតការគំរាមកំហែង ។

កិច្ចសហប្រតិបត្តិការមន្ត្រីអនុវត្តច្បាប់ អាចបង្កើតវិធានការធ្វើឱ្យមានជំនឿទុកចិត្ត ដែលទាក់ទងនឹងការពិភាក្សាពីសន្តិសុខតាមតំបន់ ដោយរួមចំណែកដល់ការអភិវឌ្ឍនៃការកំណត់តាមតំបន់សហប្រតិបត្តិការ ។

### ៧. កិច្ចសហប្រតិបត្តិការតាមតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន

ប្រទេសនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក កំពុងតែប្រមូលជាបណ្តើរៗនូវធនធានរបស់ខ្លួនដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ។ ទាំងនេះត្រូវបានបង្ហាញឱ្យឃើញការអភិវឌ្ឍថ្មីៗដោយមានសន្និសីទតាមតំបន់នៅអាស៊ីប្រឆាំងនឹងសកម្មភាពចោរកម្មតាមសមុទ្រ ដែលការរៀបចំនេះឧបត្ថម្ភដោយប្រទេសជប៉ុនកាលពីខែមេសា ឆ្នាំ ២០០០ និងបានចូលរួមដោយប្រទេសចំនួន ១៥ នៅអាស៊ី

បូព៌ា ។ សន្និសីទបានអនុម័តលើគម្រោង ស្ដីពីចំណាត់ការប្រឆាំងអំពើចោរកម្មតាមសមុទ្រក្នុងតំបន់ ដោយបញ្ចូលនូវដំណោះស្រាយចំនួនបីចំណុច ដែលស្នើឡើងដោយនាយករដ្ឋមន្ត្រីជប៉ុន Keizo Obuchi ពោលគឺ ៖ ការបង្កើតគណៈបញ្ជាការកងនាវាយាមតាមឆ្នេរជលសាតាមតំបន់ ដោយពង្រឹងនូវការគាំទ្រដល់ក្រុមហ៊ុនដឹកជញ្ជូនតាមកប៉ាល់ និងការធ្វើឱ្យរីកចម្រើននូវការសម្របសម្រួលតាមតំបន់ ដើម្បីឆ្លើយតបចំពោះការវាយប្រហារ ។

កិច្ចផ្ដួចផ្ដើមតាមតំបន់អាស៊ីប្រឆាំងនឹងការជួញដូរស្ត្រីនិងកុមារ The Asian Regional Initiative Against Trafficking (ARIAT) ដែលប្រារព្ធឡើងនៅទីក្រុងម៉ានីលនៅខែមីនា ឆ្នាំ ២០០០ បានចូលរួមដោយប្រទេស ២២ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក សមាគមអឺរ៉ុប អង្គការរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលពាក់ព័ន្ធ គណៈកម្មការ និងមន្ត្រីប្រតិបត្តិនៃអង្គការសហប្រជាជាតិ ។ ជាលទ្ធផល បានសម្រេចនូវគម្រោងចំណាត់ការតាមតំបន់ប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ ។

មធ្យោបាយនៃកិច្ចសហប្រតិបត្តិការតាមតំបន់ដែលកើតមានខ្លះទៀត ជាពិសេសក្នុងវិស័យជួញដូរមនុស្សគឺ សេចក្ដីប្រកាសនិងវេទិកាសម្រាប់ចំណាត់ការនៅប៉េកាំង សេចក្ដីប្រកាសស្ដីពីទេសន្តរប្រវេសន៍មិនទៀងទាត់នៅបាងកក និងដំណើរការនេះ នៅទីក្រុងម៉ានីល ។

សមាគមនៃប្រទេសអាស៊ាន ដែលកំពុងដំណើរការបញ្ចូលជាមួយប្រទេសផ្សេងទៀតនៃអាស៊ីឧត្តរដើម្បីរាប់បញ្ចូលប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង តាមរយៈស្ថាបនាកម្មនៃដំណើរការអាស៊ានបូក ៣ បញ្ជាក់ជាឧទាហរណ៍ពីក្របខ័ណ្ឌនៃស្ថាប័ន និងច្បាប់ដ៏ជាក់លាក់ថែមទៀត ដើម្បីប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ។ ចាប់តាំងពីមានការចាប់ផ្ដើមនៃសមាគមនៅក្នុងឆ្នាំ ១៩៦៧ ប្រទេសជាសមាជិកបានជម្នះបង្កើតនូវវិធានការ ដើម្បីពង្រឹងមូលដ្ឋានគ្រឹះសម្រាប់តំបន់ដែលមានសន្តិភាព ។ នេះរួមមានការប្រកាសនៃកិច្ចព្រមព្រៀងអាស៊ានឆ្នាំ ១៩៧៦ ដោយអំពាវនាវឱ្យប្រទេសជាសមាជិក រឹតបណ្ដឹងនូវកិច្ចសហប្រតិបត្តិការប្រឆាំងនឹងគ្រឿងញៀនខុសច្បាប់ និងបានធ្វើម្ដងទៀតនៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី ៥ ឆ្នាំ១៩៩៥ នៅទីក្រុងបាងកក ដោយអំពាវនាវឱ្យអាស៊ានគ្មានគ្រឿងញៀន ។

គំនិតផ្ដួចផ្ដើមទាំងនេះ ត្រូវបានយល់ព្រមដោយប្រមុខរដ្ឋាភិបាលអាស៊ានអំឡុងកិច្ចប្រជុំកំពូលសាមញ្ញលើកទី ១ របស់ខ្លួននៅឆ្នាំ ១៩៩៦ និងលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន ASEAN Ministerial Meeting (AMM) លើកទី ២៩ និង៣០ នៅប្រទេសឥណ្ឌូនេស៊ីដែលបង្គាប់ឱ្យប្រទេសជាសមាជិកទាំងអស់ ពង្រឹងនូវធនធានរបស់ខ្លួនប្រឆាំងគ្រប់រូបភាពនៃឧក្រិដ្ឋកម្មឆ្លងដែន ហើយគំនិតផ្ដួចផ្ដើមទាំងនេះនឹងត្រូវបញ្ចូលទៅក្នុងទស្សនវិស័យអាស៊ាន ២០២០ ។ កតិកាសញ្ញានេះ ត្រូវបានតម្រូវនៅអំឡុងពេលកិច្ចប្រជុំកំពូលសាមញ្ញនៃប្រមុខរដ្ឋាភិបាលអាស៊ានលើកទី ២ ដែលប្រារព្ធនៅទីក្រុងកូឡាឡាំពួ ក្នុងឆ្នាំ ១៩៩៧ ដោយបានធ្វើគម្រោងយ៉ាងធំ មានគោលដៅដែលទទួលបាននៅក្នុងវិស័យនៃកិច្ចសហប្រតិបត្តិការទាំងអស់ដោយមានឧក្រិដ្ឋកម្មឆ្លងដែន។

ក្នុងការទទួលយកទស្សនវិស័យបែបនោះ មេដឹកនាំអាស៊ានកំពុងតែស្ថាបនានូវផែនការ កម្មវិធី និងយុទ្ធសាស្ត្របន្តបន្ទាប់គ្នា ក្នុងការធ្វើឱ្យបានសម្រេចនូវអាស៊ីអាគ្នេយ៍មួយដែលមានស្ថិរភាព ការរីកចម្រើន និងសន្តិភាព ។ គំនិតផ្ដួចផ្ដើមដំបូង គឺផែនការចំណាត់ការហាណូយ ដែលបង្កើតឡើង

អំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី ៦ ក្នុងខែធ្នូ ឆ្នាំ ១៩៩៨ ។ វាគូសបញ្ជាក់នូវអាទិភាពសង្គមសេដ្ឋកិច្ច និងនយោបាយនៃតំបន់អាស៊ីអាគ្នេយ៍ក្នុងគម្រោងដែលមានរយៈពេល ៦ឆ្នាំ ។ រដ្ឋមន្ត្រីការបរទេសអាស៊ានបានចេញនូវសេចក្តីប្រកាសរួមមួយ សម្រាប់អាស៊ានគ្មានគ្រឿងញៀននៅទីបញ្ចប់នៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើកទី ៣១ ក្នុងទីក្រុងម៉ានីល ខែកក្កដា ១៩៩៨ ។

មធ្យោបាយអនុវត្តមួយទៀតដែលយកចេញពីទស្សនវិស័យអាស៊ាន ២០២០ គឺសេចក្តីប្រកាសអាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ដែលប្រកាសនេះបង្កើតឡើងដោយបណ្តារដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងទីក្រុងម៉ានីលខែធ្នូ ១៩៩៧ ។ អាស៊ានបានប្តេជ្ញាប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងបើកផ្លូវសម្រាប់ការធ្វើឱ្យបានសម្រេចនៃគម្រោងចំណាត់ការអាស៊ានទៅលើឧក្រិដ្ឋកម្មឆ្លងដែន ។ ក្របខ័ណ្ឌស្ថាប័នមួយក៏ត្រូវបានដាក់ឱ្យដំណើរការតាមរយៈការបង្កើត និងការប្រជុំទៀងទាត់នៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន ដែលសមាជិកភាពរបស់ខ្លួនមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ វាគឺជាអង្គការបង្កើតនយោបាយដ៏ខ្លាំងមួយនៃកិច្ចសហប្រតិបត្តិការអាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ហើយដើរតួនាទីជាអង្គការសម្របសម្រួល សម្រាប់សកម្មភាពទាំងអស់នៃស្ថាប័នតាមតំបន់ដែលពាក់ព័ន្ធ ដូចជាមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីបញ្ហាគ្រឿងញៀន និងប្រធានប៉ូលិសជាតិអាស៊ាន ASEAN Chiefs of National Police (ASEANAPOL) ។

កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ត្រូវបានជួយឧបត្ថម្ភដោយកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន Senior Officials Meeting on Transnational Crime (SOMTC) ដែលដើរតួនាទីជាផ្នែកមួយនៃកម្លាំងប្រដាប់អាវុធសម្រាប់ធ្វើប្រតិបត្តិការ ។ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន រួមមានការបង្កើតនូវគណៈកម្មការបណ្តោះអាសន្ន សម្រាប់សិក្សាបញ្ហាពិសេសណាមួយ ដើម្បីប្រតិបត្តិនូវគម្រោងការ និងកម្មវិធីជាក់លាក់ ។

ជាការសាកល្បងទៅលើការប្រតិបត្តិនៃស្ថាប័ននេះ SOMTC បានប្រារព្ធនូវកិច្ចប្រជុំទៀងទាត់លើកទី ២ របស់ខ្លួនក្នុងទីក្រុងយ៉ាំងហ្គូន ប្រទេសភូមានៅថ្ងៃទី ២៣ មិថុនា ១៩៩៩ និងកែតម្រូវនូវគម្រោងចំណាត់ការអាស៊ានទៅលើឧក្រិដ្ឋកម្មឆ្លងដែន (ASEAN Plan of Action on Transnational Crime) ។ ជាគោលការណ៍ ស្នាក់ការកណ្តាលអាស៊ានសម្រាប់ប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ASEAN Center for Combating Transnational Crime (ACTC) ត្រូវបានបង្កើតឡើង ។ SOMTC ត្រូវបង្កើតក្រុមការងារដើម្បីរៀបចំរបាយការណ៍ពេញលេញ ស្តីពីលទ្ធភាពនៃការបង្កើត ACTC ។ ក្រុមការងារនេះប្រារព្ធកិច្ចប្រជុំរបស់ខ្លួននៅស្នាក់ការកណ្តាល ស្តីពីឧក្រិដ្ឋកម្មឆ្លងដែននៅហ្វីលីពីន Philippine Center on Transnational Crime (PCTC) ខែសីហា ឆ្នាំ ១៩៩៩ និងអនុម័តឱ្យបង្កើតឡើងជាផ្នែកមួយនៃ SOMTC ។

ACTC មានទស្សនវិស័យ ចែករំលែកមូលដ្ឋានទិន្នន័យតាមតំបន់រួមមួយ ក្នុងចំណោមប្រទេសអាស៊ានសម្រាប់ព័ត៌មានស្តីពីឧក្រិដ្ឋជន វិធីសាស្ត្រ ការចាប់ខ្លួន និងការផ្តន្ទាទោសទៅលើឧក្រិដ្ឋជនឆ្លងដែន ។ វានឹងត្រូវធ្វើឡើងនៅទីក្រុងម៉ានីលជាមួយមន្ត្រីដែលត្រូវចាត់តាំងពីប្រទេសជាសមាជិកអាស៊ាន ។

### ៨. កិច្ចសហប្រតិបត្តិការអន្តរជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន

ក្នុងឱកាសជាច្រើន សហគមន៍អន្តរជាតិដែលស្ថិតនៅក្រោមការទំនុកបម្រុងនៃអង្គការសហប្រជាជាតិ បានសម្តែងនូវក្តីព្រួយបារម្ភរបស់ខ្លួន អំពីការគំរាមកំហែង ដែលបង្កឡើងដោយឧក្រិដ្ឋកម្មឆ្លងដែនក្នុងគ្រប់រូបភាព ។ ផែនការមីឡង់ និងគោលការណ៍ណែនាំ សម្រាប់ច្បាប់ព្រហ្មទណ្ឌ និងការបង្ការទប់ស្កាត់ឧក្រិដ្ឋកម្ម ក្នុងបរិបទនៃការអភិវឌ្ឍ និងសណ្តាប់ធ្នាប់សេដ្ឋកិច្ចអន្តរជាតិ (Milan Plan of Action and the Guiding Principles for Crime Prevention and Criminal Justice in the Context of Development and a New International Economic Order)បានទទួលស្គាល់នូវតម្រូវការដើម្បីបង្ក្រាបការជួញដូរគ្រឿងញៀនខុសច្បាប់ និងឧក្រិដ្ឋកម្មឆ្លងដែន និងបង្កើតបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមក គឺជាមធ្យោបាយក្នុងការព្រាង និងផ្តល់សច្ចាប័ននៃមហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ ១៩៨៨ ស្តីពីការប្រឆាំងនឹងការជួញដូរថ្នាំញៀនណារកូទិក និងសារធាតុខុសច្បាប់ ធ្វើឱ្យប៉ះពាល់ដល់សកម្មភាពខួរក្បាល ដើម្បីបង្គ្រប់បន្ថែម និងពង្រឹងសន្ធិសញ្ញាដែលមានស្រាប់ ប្រឆាំងនឹងរូបភាពផ្សេងៗនៃឧក្រិដ្ឋកម្មឆ្លងដែន ។ មធ្យោបាយទាំងនេះក៏បានប្រាប់ឱ្យដឹងជាមុនផងដែរ នូវកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ ឆ្នាំ ១៩៩០ ស្តីពីការបញ្ចូលនូវសន្ធិសញ្ញាគំរូស្តីពីបត្យាប័ន ការជួយគ្នាទៅវិញទៅមក និងការផ្ទេររឿងក្តីក្នុងបញ្ហាឧក្រិដ្ឋកម្ម និងការផ្ទេរនូវការគ្រប់គ្រងជនល្មើស ដើម្បីធ្វើការកាត់ទោសតាមលក្ខខណ្ឌ ឬត្រូវដោះលែងទៅតាមលក្ខខណ្ឌ ។

ការប្រកាសខាងនយោបាយ និងផែនការសកលនៅទីក្រុង Naples អ៊ីតាលី ស្តីពីការប្រឆាំងនឹងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងឆ្លងដែន បានបញ្ជាក់ជាសំខាន់ពីតម្រូវការសម្រាប់គោលការណ៍ និងទិសដៅទូទៅ និងរបៀបវារៈប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ។ វាគឺជាការនាំមុខនៃសេចក្តីព្រាងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មមានអង្គការចាត់តាំងឆ្លងដែន ព្រមទាំងអនុស្សរណៈបន្ថែមបី ស្តីពីការជួញដូរមនុស្ស ការរត់ពន្ធជនអន្តោប្រវេសន៍ និងការផលិត និងជួញដូរសព្វាវុធខុសច្បាប់ ។

មធ្យោបាយអន្តរជាតិទាំងនេះមានគោលបំណងផ្តល់នូវក្របខ័ណ្ឌច្បាប់ ដែលដូចគ្នាទាំងអស់ក្នុងការបង្កើតយុទ្ធសាស្ត្រ ផែនការ កម្មវិធីចំណាត់ការ ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ។ សេចក្តីព្រាងអនុស្សរណៈពីរថែមទៀត ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិ ១៩៨៩ ស្តីពីសិទ្ធិកុមារដែលត្រូវបង្កើតឡើង ដើម្បីការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការបង្ខំឱ្យធ្វើសង្គ្រាម ត្រូវបានកែតម្រូវ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ ។ សន្ធិសញ្ញាអន្តរជាតិផ្សេងទៀតក៏កំពុងត្រូវបានព្រាងជាបន្តបន្ទាប់ ដើម្បីបំពេញភាពខ្វះចន្លោះនៃច្បាប់ ដែលក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងឆ្លងដែនអាចប្រើ ដើម្បីផលប្រយោជន៍របស់ខ្លួនដូចជា អនុសញ្ញាប្រឆាំងនឹងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា ដែលត្រូវស្នើឡើងដោយក្រុមប្រឹក្សាសហគមន៍អឺរ៉ុប ក្នុងកិច្ចសហប្រតិបត្តិការជាមួយសហរដ្ឋអាម៉េរិក កាណាដា ជប៉ុន និងអាហ្វ្រិកខាងត្បូង ។ វាត្រូវបានរៀបចំដើម្បីធ្វើឱ្យច្បាប់ប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិជ្ជា មានលក្ខណៈស្តង់ដា និងធានាមិនឱ្យមានការបំផ្លាញប្រព័ន្ធបច្ចេកវិជ្ជា តាមរយៈឧក្រិដ្ឋកម្មឆ្លងដែន ។

## ៩. ឧស្សនវិស័យ

• ឧក្រិដ្ឋកម្មនឹងក្លាយជាការគំរាមកំហែងដ៏ខ្លាំងក្លាថែមទៀតចំពោះសណ្តាប់ធ្នាប់ពិភពលោក ជាមួយនឹងការដួលរលំនៃសង្គ្រាមត្រជាក់ និងដោយសារតែការយល់នូវទំហំពិតប្រាកដ នៃបណ្តាញឧក្រិដ្ឋកម្មអន្តរជាតិ

• ការបន្តនូវសង្គ្រាមស៊ីវិល និងចលនាកុបកម្មក្នុងស្រុក នឹងជំរុញឱ្យក្រុមខ្លះ ចូលរួមជាមួយសកម្មភាពឧក្រិដ្ឋកម្ម (ជាពិសេសនៅក្នុងតំបន់ថ្នាំញៀនណារកូទិក ) ដើម្បីទ្រទ្រង់ចលនានយោបាយរបស់ពួកគេ (ឧទាហរណ៍ ប្រទេសអាហ្គានីស្ថាន ភូមា កូឡុំប៊ី និងប្រទេសប៉េរូ)

• ក្រុមឧក្រិដ្ឋជនឆ្លងដែនជាច្រើន នឹងបន្តប្រើប្រាស់បក្សសម្ព័ន្ធជាយុទ្ធសាស្ត្រសកល ដើម្បីសម្រួលដល់ប្រតិបត្តិការរបស់ពួកគេ

• ក្រុមឧក្រិដ្ឋជននឹងទិញអ្នកជំនាញល្បីៗ ដែលជួយឱ្យពួកគេទទួលបានផលប្រយោជន៍ក្នុងវិស័យច្បាប់ ។ គុណភាពនៃសកម្មភាពឧក្រិដ្ឋកម្មរបស់ពួកគេនឹងបានរីកចម្រើន ដោយសម្រួលនូវការវិនិយោគទុននៃមូលនិធិរបស់ខ្លួននៅក្នុងជំនួញស្របច្បាប់ ។ ពួកគេនឹងកាន់តែសកម្មថែមទៀតក្នុងការក្លែងបន្លំរូបិយប័ណ្ណ និងឯកសារនានា (ដូចជា ប្រទេសលីបង់ និងកូឡុំប៊ី ) ការឈ្លបយកការណ៍សម្ងាត់តាមអេឡិចត្រូនិករបស់រដ្ឋាភិបាល និងមន្ត្រីអនុវត្តច្បាប់ ព្រមទាំងអាចមានចំពោះលក្ខណៈនៃសង្គ្រាមព័ត៌មានទៀតផង

• ឧក្រិដ្ឋជនមានអង្គការចាត់តាំង អាចជាប់ពាក់ព័ន្ធកាន់តែខ្លាំងឡើង ក្នុងគម្រោងការ ឬពាណិជ្ជកម្មបច្ចេកវិជ្ជាគីមី ជីវសាស្ត្រ និងនុយក្លេអ៊ែរ

• តំបន់ផលិតគ្រឿងញៀន និងការធ្វើចរាចរមានការប្រែប្រួល ជាពិសេសនៅពេលដែលការផ្លាស់ប្តូរសេដ្ឋកិច្ច សង្គម នយោបាយ ។ ឧស្សាហូបនីយកម្មនៅក្នុងអាស៊ីយ៉ាងលឿននឹងបង្កើនផលិតផលក្នុងស្រុក និងភាពអាចរកបាននូវសារធាតុគីមី ។ ការប្រើប្រាស់ថ្នាំញៀនណារកូទិកនៃតំបន់នេះ មិនទំនងជាថយចុះនោះទេ ជាពិសេសថ្នាំញៀនកូកាអ៊ីន និងអំហ្វេតាមីន

• មធ្យោបាយងាយស្រួលខាងធនាគារកិច្ច និងការសម្អាតប្រាក់ នឹងអាចធ្វើបាន ។ ការចេះតែកើនឡើងនូវគំនាបសង្កត់ ទៅលើមធ្យោបាយងាយស្រួលនៃធនាគារកិច្ច នៅក្រៅប្រទេសបែបប្រពៃណី អាចជំរុញឱ្យមានចលនាមួយទៅកាន់តំបន់ថ្មីៗជាច្រើន ជាពិសេសនៅក្នុងករណីនៃប្រទេសអឺរ៉ុបខាងកើត និងអតីតសហភាពសូវៀតជាមួយនឹងក្រុមឧក្រិដ្ឋជនដែលធ្វើអាជីវកម្មលើការគ្រប់គ្រងដ៏ធូររលុង និងទាញយកប្រយោជន៍ពីតម្រូវការរូបិយប័ណ្ណនៃប្រទេសជាតិ ។ ចំនួនទឹកប្រាក់របស់ឧក្រិដ្ឋជនដែលឆ្លងកាត់ប្រព័ន្ធធនាគារអន្តរជាតិ អាចមានផលប៉ះពាល់ធ្វើឱ្យមានអស្ថិរភាពផ្នែកហិរញ្ញវត្ថុក្នុងប្រទេសមួយចំនួន ។ ភាពសកម្មនៃសេដ្ឋកិច្ចអាស៊ី អាចជាមធ្យោបាយដ៏មានប្រយោជន៍ សម្រាប់ការសម្អាតប្រាក់ ។ ការវិនិយោគទុនដែលមានទំហំធំដោយប្រទេសអាស៊ីនៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងត្បូងអាចធ្វើឱ្យមានឱកាសសម្រាប់ការធ្វើអាជីវកម្មរបស់ឧក្រិដ្ឋជន

• អតីតមន្ត្រីស៊ើបការណ៍ និងអ្នកជំនាញខាងយោធាជាច្រើន អាចជាប់ពាក់ព័ន្ធឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ដូចបានកើតឡើងចំពោះវិសាលភាពដ៏ទូលំទូលាយក្នុងអតីតសហភាពសូវៀត

- និន្នាការនេះ កាន់តែច្បាស់នៅក្នុងប្រទេសខ្លះនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ៖
  - ភាពអាចរកទិញនូវសព្វាវុធ នឹងនាំទៅដល់ការប្រើកាំភ្លើងកាន់តែច្រើនឡើង
  - ការក្លែងបន្លំប័ណ្ណឥណទាន ការក្លែងបន្លំការដាក់ប្រាក់នៅក្នុងធនាគារ
  - បច្ចេកវិជ្ជានៃទូរគមនាគមន៍ និងកុំព្យូទ័រដែលមានប្រយោជន៍គាំទ្រក្រុមឧក្រិដ្ឋជន
  - អំពើពុករលួយនៅក្នុងសកម្មភាពផ្សេងៗគ្នា នឹងបន្តគាំទ្រ និងសម្រួលដល់ឧក្រិដ្ឋកម្មនៅក្នុងតំបន់
  - មន្ត្រីអនុវត្តច្បាប់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ខ្លះ នឹងបន្តប្រឈមនឹងភាពលំបាកជាច្រើនក្នុងការដោះស្រាយជាមួយភាពជឿនលឿននៃការក្លែងបន្លំ និងឧក្រិដ្ឋកម្មសកលភាវូបនីយកម្ម
  - កិច្ចសហប្រតិបត្តិការនៃការអនុវត្តច្បាប់កាន់តែជិតស្និទ្ធក្នុងតំបន់ នឹងជួយធ្វើឱ្យមានតុល្យភាពនូវកត្តាមួយចំនួនដូចដែលបានរៀបរាប់ ។
- ចំពោះបញ្ហាដែលបានលើកឡើង ការគំរាមកំហែងដ៏ខ្លាំងបំផុតចំពោះស្ថិរភាពនិងសន្តិសុខតាមតំបន់អាចជាការអភិវឌ្ឍនូវភាពជឿនលឿន និងសកលភាវូបនីយកម្មនៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ការក្លែងបន្លំគ្រប់រូបភាព ការសម្អាតប្រាក់ បទល្មើសតាមប្រព័ន្ធបច្ចេកវិជ្ជា និងអំពើពុករលួយដែលបន្តនូវផលប៉ះពាល់ដល់សេដ្ឋកិច្ចតាមតំបន់ ការរំលោភបំពាន ការជួញដូរគ្រឿងញៀន ជាពិសេសការផលិត និងការចរាចរគ្រឿងញៀន ដើម្បីផ្តល់ហិរញ្ញវត្ថុដល់យុទ្ធនាការនយោបាយរបស់ពួកគេ
- ដោយមានភាពចម្រុះ និងការវិវត្តនៃឧក្រិដ្ឋកម្មក្នុងតំបន់ មន្ត្រីអនុវត្តច្បាប់ ទោះមានធនធានខាងកម្លាំង ឬហិរញ្ញវត្ថុក៏ដោយ អាចមិនមានតុល្យភាពជាមួយក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងនោះដែរ ។ មន្ត្រីអនុវត្តច្បាប់តាមតំបន់ អាចមានប្រៀបទៅអនាគត គឺត្រូវជ្រើសរើស ឬបណ្តុះបណ្តាលជំនាញ ដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធភាពចំពោះការគំរាមកំហែងនៃឧក្រិដ្ឋកម្មទំនើប និងដើម្បីដាក់នូវអាទិភាព ស្តីពីកិច្ចសហប្រតិបត្តិការតាមតំបន់ និងការផ្តល់នូវព័ត៌មានស៊ើបអង្កេតឧក្រិដ្ឋកម្ម ។

### ១០. ឧក្រិដ្ឋជនមានអង្គការចាត់តាំង និងគ្រឿងញៀននៅកម្ពុជា

អំឡុងឆ្នាំ២០០២ មានការកើនឡើងដ៏ខ្លាំងមួយក្នុងភាពអាចរកទិញបាននូវគ្រឿងញៀនខុសច្បាប់នៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងទីក្រុង ។ ការទាក់ទងពិសេសគឺ ភាពទូទៅនៃថ្នាំញៀនមេតំហ្វេតាមីនដែលសំដៅទៅលើឈ្មោះថៃថា ថ្នាំយ៉ាបា ដែលកំពុងតែត្រូវបានប្រើប្រាស់កាន់តែកើនឡើងដោយយុវជន ។ តែទោះជាយ៉ាងណាក៏ដោយ ការស្ទាបស្ទង់ដ៏ទូលំទូលាយនៃការប្រើគ្រឿងញៀនខុសច្បាប់ ដោយក្រុមមនុស្សធ្វើការដោយប្រចុយប្រថាន ត្រូវបានតម្រូវឱ្យមានចំណាត់ការជាបន្ទាន់ដូច្នេះ ធនធានដែលមានកម្រិតនៃរដ្ឋាភិបាល និងប្រទេសជាម្ចាស់ផ្តល់អំណោយ អាចត្រូវបានផ្តោតកាន់តែប្រសើរទៅលើអ្នកដែលត្រូវការចាំបាច់បំផុត ។

ការរឹបអូសសារធាតុជំនួយកម្លាំងថ្នាំញៀនអំហ្វេតាមីន(amphetamine-type stimulants : ATS) និងថ្នាំញៀនមេតំហ្វេតាមីន ដោយមន្ត្រីអនុវត្តច្បាប់កម្ពុជាបានកើនឡើងដល់ ៨២% ចាប់តាំងពីឆ្នាំ ២០០១ និងបង្ហាញយ៉ាងច្បាស់ថា ជាមួយឧបករណ៍សម្ភារៈ និងការបណ្តុះបណ្តាលគ្រប់គ្រាន់យើងអាចធ្វើការបង្ក្រាបទៅលើការជួញដូរគ្រឿងញៀនប្រភេទទាំងនោះ ។

លើសពីនេះទៅទៀត ការធ្លាក់ចុះយ៉ាងខ្លាំងនៃតម្លៃថ្នាំញៀនមេតំហ្វេតាមីនតាមផ្លូវ ក្នុងប្រទេសកម្ពុជា គឺជាការបញ្ជាក់ថែមទៀតថា បរិមាណដ៏ច្រើននៃថ្នាំញៀននេះ នៅតែកំពុងចរាចរលើទីផ្សារដែលមិនដឹងពីផលវិបាកមានគ្រោះថ្នាក់នៃគ្រឿងញៀន ។

ចរាចរថ្នាំញៀនហេរ៉ូអ៊ីនឆ្លងកាត់ប្រទេសកម្ពុជាក៏ទំនងជាកើនឡើងផងដែរ ។ កត្តាទាំងនេះបានផ្តល់ជាអនុសាសន៍ដ៏ខ្លាំងក្លាថា ទន្លេមេគង្គនៅក្នុងភាគខាងកើតប្រទេសកម្ពុជាកំពុងត្រូវបានប្រើប្រាស់ដោយក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ដើម្បីបញ្ជូនថ្នាំញៀនហេរ៉ូអ៊ីនពីប្រទេសឡាវចូលមកប្រទេសកម្ពុជា និងបន្ទាប់មកដឹកតាមផ្លូវគោកទៅកាន់ប្រទេសវៀតណាម ។ ការអភិវឌ្ឍនូវបច្ចេកទេសដើម្បីទប់ស្កាត់សម្រាប់មន្ត្រីអនុវត្តច្បាប់ដែលធ្វើការលើបញ្ហានេះ និងតាមបណ្តោយដងទន្លេមេគង្គ ត្រូវបានគេចាត់ទុកជាអាទិភាពខ្ពស់នៅក្នុងឆ្នាំ ២០០៣ ជាមួយនឹងជំនួយអន្តរជាតិដែលចាំបាច់ ដើម្បីផ្តល់នូវការបណ្តុះបណ្តាល និងឧបករណ៍សម្ភារៈឱ្យទូលំទូលាយដល់មន្ត្រីទាំងនោះ ។

កិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន តម្រូវឱ្យពង្រឹងនូវទំនាក់ទំនងរវាងវិស័យនគរបាលយុត្តិធម៌ និងតុលាការ ដូច្នេះ ការយល់ដឹង និងទំនាក់ទំនងសហប្រតិបត្តិការអាចត្រូវបានអភិវឌ្ឍដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ។ ការកែទម្រង់ច្បាប់គ្រប់គ្រងគ្រឿងញៀននៃប្រទេសកម្ពុជាត្រូវបានធ្វើនៅក្នុងឆ្នាំ ២០០២ ហើយផ្តោតទៅលើការផ្តន្ទាទោស ។ លើសពីនេះ ប្រទេសកម្ពុជាបានចាប់ផ្តើមដំណើរការនៃការធ្វើសច្ចាប័នលើអនុសញ្ញា ៣ ស្តីពីការគ្រប់គ្រងគ្រឿងញៀនអន្តរជាតិ នាឆ្នាំ ១៩៦១ ១៩៧១ ១៩៨៨ និងត្រូវធ្វើឱ្យសម្រេចនូវសកម្មភាពរបស់ខ្លួនត្រឹមចុងឆ្នាំ ២០០៣ ដើម្បីបង្ហាញនូវការប្តេជ្ញាដ៏ច្បាស់លាស់ ក្នុងនាមជាសមាជិកទទួលខុសត្រូវនៃការប្រយុទ្ធប្រឆាំងរបស់សហគមន៍អន្តរជាតិ ចំពោះការផលិត និងការជួញដូរគ្រឿងញៀនខុសច្បាប់ ។

## VI. ការគ្រប់គ្រងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងអំពើពុករលួយ

អំពើពុករលួយ និងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង កើតមានច្រើនជាងបទល្មើសផ្សេងៗ ។ អំពើពុករលួយ ត្រូវបានកំណត់និយមន័យយ៉ាងទូលំទូលាយថា ជាការរំលោភលើអំណាចសាធារណៈដើម្បីសម្រេចផលប្រយោជន៍ឯកជន ។ ក្នុងអំឡុងទសវត្សឆ្នាំ ១៩៩០ មន្ត្រីអនុវត្តច្បាប់ទាំងឡាយនៅក្នុងទ្វីបអឺរ៉ុបបានកំណត់និយមន័យមួយចំនួននៃវាក្យស័ព្ទ "ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង" ដែលស្របទៅនឹងកត្តាសំខាន់ៗដូចខាងក្រោម ៖

- ក្រុមមួយបែបដែលមានរចនាសម្ព័ន្ធចាត់តាំង
- មានលក្ខណៈជាអចិន្ត្រៃយ៍
- ប្រើប្រាស់អំពើហិង្សា
- ការសូកប៉ាន់មន្ត្រី
- ការសម្អាតប្រាក់ដែលជាប្រាក់ចំណូលបានមកពីឧក្រិដ្ឋកម្ម និងវិនិយោគស្របច្បាប់ ។

ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង គឺជាក្រុមដែលមានរចនាសម្ព័ន្ធចាត់តាំងប្រព្រឹត្តិឧក្រិដ្ឋកម្មធ្ងន់ធ្ងរដើម្បីប្រាក់ចំណេញ ។ និយមន័យដ៏ទូលំទូលាយនេះ ត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីជាលក្ខណៈប្រភេទ

ធម្មតានៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងមានន័យរួម ដូចជា ការជួញដូរគ្រឿងញៀន ការជួញដូរសព្វាវុធ ការជួញដូរមនុស្ស អំពើចោរកម្មរថយន្ត ឬសម្បត្តិបេតិកភណ្ឌជាតិ និងអំពើភេរវកម្ម (សេចក្តីសម្រេចនៃមហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥៥/២៥ ឧបសម្ព័ន្ធ១)។

**១. កត្តាសេដ្ឋកិច្ច-សង្គម**

នៅក្នុងករណីជាច្រើនដូចជា ភាពក្រីក្រ និងភាពអត់ការងារធ្វើ ផ្តល់នូវការផ្គត់ផ្គង់ដ៏ធំមួយដល់ពលកម្មខុសច្បាប់ដ៏មានសក្តានុពល សម្រាប់ប្រព្រឹត្តិសកម្មភាពឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងបង្កើតបរិយាកាសអំណោយផលដល់ក្រុមឧក្រិដ្ឋជន ធ្វើអាជីវកម្មលើរចនាសម្ព័ន្ធសង្គមនៃបណ្តាប្រទេសទាំងឡាយ ដែលជាមូលដ្ឋានគ្រឹះមួយសម្រាប់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង មានសមត្ថភាពទាញយកសារប្រយោជន៍ពីលក្ខខណ្ឌសង្គមក្រីក្រ និងសេដ្ឋកិច្ចអន់ថយនៅក្នុងប្រទេស ។

ប្រព័ន្ធពន្ធដារគឺជាទិដ្ឋភាពសេដ្ឋកិច្ចដ៏សំខាន់មួយ ដែលមានឥទ្ធិពលយ៉ាងខ្លាំងដល់សកម្មភាពរបស់អង្គការចាត់តាំងឧក្រិដ្ឋជន ។ អំពើគេចពន្ធនៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងបានគាំទ្រដល់ការសម្អាតប្រាក់ឱ្យទទួលបានផលប្រយោជន៍ច្រើន ។ រចនាសម្ព័ន្ធរូបិយវត្ថុ និងហិរញ្ញវត្ថុរបស់ប្រទេសមានឥទ្ធិពលប៉ះពាល់ដល់អត្រាគ្រោះថ្នាក់របស់ប្រទេស និងពាក់ព័ន្ធទៅនឹងសន្ទស្សន៍ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។

**២. បរិយាកាសនយោបាយ**

ការវិភាគពីទំនាក់ទំនងរវាងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង និងរដ្ឋប្រជាធិបតេយ្យ យល់ថា កំណើននៃឧក្រិដ្ឋកម្មមានអង្គការចាត់តាំងធ្វើឱ្យមានការថយចុះនូវបទឧក្រិដ្ឋដទៃទៀត ។ ដូច្នេះការពង្រឹងលទ្ធិប្រជាធិបតេយ្យត្រូវធ្វើឱ្យបានព្រមគ្នាទៅតាមកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលបង្អាក់នូវកំណើនក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ តាមធម្មតា មធ្យោបាយរបស់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងដើម្បីជ្រៀតចូលក្នុងស្ថាប័នរដ្ឋ គឺតាមរយៈការបោះឆ្នោតជ្រើសតាំងសមាជិកស្ថាប័នសាធារណៈ ។

**៣. ប្រព័ន្ធយុត្តិធម៌**

ប្រព័ន្ធយុត្តិធម៌ គឺជាកត្តាគន្លឹះក្នុងការវិភាគប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋ ដើម្បីឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ។ ផ្តើមចេញពីការវិភាគនេះគឺ ចំនួនមន្ត្រីដែលបានធ្វើការនៅក្នុងប្រព័ន្ធយុត្តិធម៌ ត្រូវមានតុល្យភាពទៅនឹងកម្រិតនៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ នៅក្នុងប្រទេសជាច្រើនដែលមានអត្រាបទល្មើសខ្ពស់ ការឆ្លើយតបដំបូងរបស់រដ្ឋ គឺត្រូវតែបង្កើនចំនួនមន្ត្រីនគរបាលយុត្តិធម៌ឱ្យបានច្រើន ដើម្បីដោះស្រាយបញ្ហា ។ ជាទូទៅ និន្នាការនោះត្រូវបានអះអាងថាធនធានហិរញ្ញវត្ថុប្រើប្រាស់នៅក្នុងប្រព័ន្ធយុត្តិធម៌ ត្រូវយកមកពិចារណា ។ ទំហំនៃបៀវត្សរ៍ និងប្រាក់ចំណាយលើប្រព័ន្ធយុត្តិធម៌ ជាប់ពាក់ព័ន្ធទៅនឹងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។

លទ្ធផលរំពឹងទុកក្នុងការចំណាយទៅលើប្រព័ន្ធយុត្តិធម៌ ពឹងផ្អែកលើការបណ្តុះបណ្តាលមន្ត្រីជំនាញឯកទេស ដែលជួយកាត់បន្ថយឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ។

### ៤. អភិបាលកិច្ចផ្នែកឯកជន

កង្វះខាតអភិបាលកិច្ចផ្នែកឯកជនផ្តល់នូវមូលដ្ឋានបង្អែក ដើម្បីបង្កើនក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង រួមមាន៖

- ទស្សនវិស័យទីមួយគឺ សំដៅលើប្រសិទ្ធភាព និងតម្លាភាពរបស់ប្រព័ន្ធធនាគារ ហើយចំពោះអាជីវកម្ម ថាតើវាផ្តល់លទ្ធភាពបែបណា ដើម្បីឈានចូលដល់ការគ្រប់គ្រងសេវាកម្មហិរញ្ញវត្ថុនៅក្នុងក្របខ័ណ្ឌ ដែលចែងដោយបញ្ញត្តិ ។ ប្រសិនបើសេវាកម្មខ្ចីប្រាក់មានការលំបាក អ្នកជំនួញអាចឈានទៅពឹងផ្អែកលើប្រភពខុសច្បាប់ខ្លះ
- ទស្សនវិស័យទីពីរ គឺសំដៅលើកង្វល់អំពីអភិបាលកិច្ចផ្នែកហិរញ្ញវត្ថុ និងសាជីវកម្មនានាដែលកំពុងផ្តោតលើការសម្អាតប្រាក់ រួមជាមួយនឹងក្របខ័ណ្ឌប្រកបដោយបញ្ញត្តិច្បាប់ និងប្រតិបត្តិការត្រួតត្រាលើការគ្រប់គ្រងធនាគារ ។

### ៥. អភិបាលកិច្ចផ្នែកសាធារណៈ

ការទិញទឹកចិត្ត គឺជាលក្ខខណ្ឌចាំបាច់មួយសម្រាប់កំណើនក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ ដើម្បីវាស់ស្ទង់កម្រិតដែលអាចធ្វើឱ្យមានអំពើពុករលួយក្នុងវិស័យសាធារណៈ រដ្ឋត្រូវកំណត់ការវាស់វែងលើអភិបាលកិច្ចផ្នែកសាធារណៈ ។ លើសពីនេះ មន្ត្រីរាជការ ត្រូវបានរកឃើញថា កម្រិតអន្តរាគមន៍កាន់តែខ្ពស់នៅក្នុងការតែងតាំង ការចាត់បញ្ជូន ការដាក់ទណ្ឌកម្ម ការជ្រើសរើស និងការដំឡើងឋានៈតួនាទី អាចផ្តល់ឱកាសកាន់តែខ្លាំង គាំទ្រដល់សកម្មភាពក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។

### ៦. ឯករាជ្យភាព និងសុចរិតភាពរបស់តុលាការ

ឯករាជ្យភាពរបស់តុលាការ អាចមានឥទ្ធិពលទៅលើក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ លើសពីនេះ កង្វះខាតលទ្ធភាពនៃការគ្រប់គ្រងរបស់តុលាការ ក៏ជាប់ពាក់ព័ន្ធនឹងអំពើពុករលួយរបស់ខ្លួន និងសកម្មភាពរបស់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងផងដែរ ។ ដោយឯករាជ្យ វិសាលភាពនៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង កើនឡើងកាន់តែខ្លាំងនៅក្នុងបណ្តាប្រទេសដែលការអនុវត្តច្បាប់របស់មន្ត្រីនគរបាលមានប្រសិទ្ធភាពតិចតួច ។

### ៧. បញ្ហានីតិបញ្ញត្តិ និងឧបករណ៍ស៊ើបអង្កេត

#### ក. កំណែទម្រង់ប្រព័ន្ធយុត្តិធម៌

ដើម្បីអនុវត្តប្រកបដោយជោគជ័យនូវគោលនយោបាយស្តីពីកំណែទម្រង់ផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ប្រឆាំងនឹងសម្ព័ន្ធភាពនៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង និងអំពើពុករលួយនៅក្នុងផ្នែកសាធារណៈ រដ្ឋត្រូវតែធានាជាដំបូងឱ្យមានលិខិតុបករណ៍សមស្រប ។ នៅក្នុងវិស័យផ្នែកច្បាប់ប្រទេសមួយចំនួនបានធ្វើការអនុម័តលើវិធានការស្របច្បាប់ដែលចាត់ទុកការសមគំនិត ដូចជាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែរ ។ បណ្តាប្រទេសផ្សេងទៀតបានដាក់ទណ្ឌកម្មសមាជិកភាព ឬអ្នកចូលរួមនៅក្នុងបណ្តាសហគ្រាសឧក្រិដ្ឋកម្ម ។ ការចូលរួមខុសច្បាប់ ឬការពាក់ព័ន្ធនឹងអំពើខុសច្បាប់ជាទម្រង់មួយនៃសកម្មភាពបទឧក្រិដ្ឋ មានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌជាច្រើនជុំវិញពិភពលោក ជា

ពិសេសនៅក្នុងប្រទេសបារាំង អ៊ីតាលី អេស្ប៉ាញ និងរដ្ឋក្នុងទ្វីបអាម៉េរិកឡាទីន ។ ប្រទេសដទៃទៀត បានចាត់ទុកថា ជាបទល្មើសព្រហ្មទណ្ឌចំពោះជនដែលបានប្រព្រឹត្តបទល្មើសជាក្រុម ។ នៅក្នុងប្រទេសអ៊ីតាលី គេហៅថា បទល្មើសព្រហ្មទណ្ឌពាក់ព័ន្ធគ្នា ឬបទល្មើសព្រហ្មទណ្ឌប្រភេទម៉ាហ្វីយ៉ា ។

នៅក្នុងក្របខ័ណ្ឌច្បាប់ទាំងនេះ ប្រទេសមួយចំនួនកំពុងបង្កើតនូវគោលនយោបាយប្រឆាំងនឹងពួកម៉ាហ្វីយ៉ា បានធ្វើឱ្យប្រសើរឡើងផងដែរ នូវសមត្ថភាពប្រតិបត្តិការរបស់ពួកគេសម្រាប់ការប្រមូល និងវិភាគវត្ថុដែលជាភស្តុតាងស្មុគស្មាញ បន្ថែមលើបច្ចេកទេសស៊ើបអង្កេតតាមទម្លាប់ ។ បច្ចេកទេសទំនើបបែបហ្នឹង រួមមានឧបករណ៍ស៊ើបអង្កេតបំពាក់ដោយកាមេរ៉ា ខ្សែអាត់បង្កប់ ឧបករណ៍ត្រួតពិនិត្យសារលិខិត ការត្រួតពិនិត្យតាមអេឡិចត្រូនិក និងការធ្វើបន្ទាល់ដែលទទួលបានមកពីសាក្សីទាំងឡាយតាមរយៈសំណើអភ័យឯកសិទ្ធិ ឬគ្រឿងលើកទឹកចិត្តផ្សេងទៀត រួមជាមួយកិច្ចការពារគាំពារដល់សាក្សីទាំងឡាយ ។ លើសពីនេះទៅទៀត បទពិសោធន៍អន្តរជាតិនៅក្នុងការវាយប្រហារប្រឆាំងនឹងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង បង្ហាញឱ្យឃើញថា មន្ត្រីអនុវត្តច្បាប់ត្រូវមានការស្រាវជ្រាវ និងការវិភាគលើសមត្ថភាព លទ្ធភាពដែលគាំទ្រដល់ការស៊ើបអង្កេត និងការចោទប្រកាន់នានាដោយកំណត់ឱ្យច្បាស់នូវ ៖

- របនាសម្ព័ន្ធ សមាសភាព និងសកម្មភាពចម្បងៗនៃបណ្ដាញឧក្រិដ្ឋជន
- បែបផែន ឧបាយកល និងសកម្មភាពរបស់ពួកគេ (រួមមានផលិតកម្ម ទីផ្សារ និងភស្តុការហិរញ្ញវត្ថុ)
- ទាក់ទងជាមួយបរិយាកាសស្របច្បាប់ និងមិនស្របច្បាប់ និង
- ការកំណត់ឱ្យបានច្បាស់លាស់នូវលក្ខណៈយុទ្ធសាស្ត្រទប់ស្កាត់ ឬបង្ការជាមុន ។

### ខ. ការចូលរួមរបស់សង្គមស៊ីវិល

ប្រព័ន្ធយុត្តិធម៌ដែលកាន់តែមានប្រសិទ្ធភាព នៅក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងអំពើពុករលួយនៅក្នុងផ្នែកសាធារណៈ តាមធម្មតា អាចពឹងផ្អែកលើសុឆន្ទៈប្រជាពលរដ្ឋ ចូលរួមសហការជាមួយមន្ត្រីអនុវត្តច្បាប់ ដើម្បីសម្រេចឱ្យបានមធ្យោបាយប្រតិបត្តិការមួយ ។ ការបង្កើតជំនឿទុកចិត្តដល់សាធារណជន នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ តម្រូវឱ្យមានការបង្ហាញជាដំបូងដល់លទ្ធផលប្រកបដោយជោគជ័យជាក់ស្ដែងរបស់សង្គមស៊ីវិល ។ លើសពីនេះ ថ្នាក់ដឹកនាំមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការគ្រប់កម្រិត ត្រូវបង្កើតគំរូល្អដោយការអនុម័តយកស្តង់ដាក្រមសីលធម៌ និងការបង្កើតនូវនីតិវិធី ដើម្បីធានាថា រឿងក្ដីត្រូវឱ្យតាមនីតិវិធី ។

កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងប្រទេស មិនទទួលផល បើគ្មានជំនួយ និងការគាំទ្រពីស្ថាប័នផ្សេងៗ ។ កត្តានយោបាយត្រូវបានតម្រូវឱ្យពង្រឹងនូវប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឯករាជ្យមួយ ដោយមានសមត្ថភាពបង្ក្រាបក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង និងអំពើពុករលួយផ្នែកសាធារណៈ ។ សង្គមស៊ីវិលក៏ដូចជាសមាគមវិជ្ជាជីវៈមេធាវី និងសាលាច្បាប់ដែរ អាចដើរតួនាទីដ៏សំខាន់មួយនៅក្នុងដំណើរការកំណែទម្រង់នោះ ។

### គ. គោលនយោបាយនៅក្នុងវិស័យហិរញ្ញវត្ថុ និងវិស័យសេដ្ឋកិច្ច-សង្គម

នៅក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រឆាំងនឹងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង រួមមានកិច្ចសហប្រតិបត្តិការដ៏ល្អដូចជា ៖

- ការកាត់បន្ថយភាពក្រីក្រ និងបង្កើននូវកម្រិតប្រាក់បៀវត្សរ៍ សម្រាប់មន្ត្រីរាជការដើម្បីទប់ស្កាត់អំពើពុករលួយ
- ការកាត់បន្ថយសកម្មភាព និងទីផ្សារងងឹតដែលផ្តល់នូវធនធាន សម្រាប់ប្រតិបត្តិ និងលទ្ធផលនៃសេដ្ឋកិច្ចសម្រាប់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង
- ការធ្វើឱ្យប្រសើរឡើងដល់ការចែកចាយប្រាក់ចំណូល និងទ្រព្យសម្បត្តិ
- ការកាត់បន្ថយឧបសគ្គចំពោះការដោះដូរទំនិញ និងសេវាកម្មអន្តរជាតិ
- ការអនុម័ត និងការអនុវត្តលិខិតបទដ្ឋានហិរញ្ញវត្ថុ ដែលមានភាពស៊ីគ្នាច្រើន ដែលត្រូវបានអនុវត្តដោយស្ថានប័នរដ្ឋដែលមានជំនាញឯកទេសគ្រប់គ្រង ដោយទទួលខុសត្រូវចំពោះការស៊ើបអង្កេតខាងហិរញ្ញវត្ថុ ។

នៅក្នុងវិស័យខាងលិខិតបទដ្ឋានហិរញ្ញវត្ថុ បទពិសោធន៍របស់បណ្តាប្រទេសទាំងឡាយដែលអនុវត្តកិច្ចសហប្រតិបត្តិការដ៏ប្រសើរបំផុតបានបង្ហាញថា សមត្ថកិច្ចរបស់រដ្ឋដើម្បីតាមដានកំណត់អត្តសញ្ញាណ ត្រួតពិនិត្យ ដណ្តើមយក និងរឹបអូសយករាល់ទ្រព្យសម្បត្តិខាងហិរញ្ញវត្ថុនិងប្រភេទលទ្ធផលផ្សេងទៀត ដែលទទួលបានមកពីឧក្រិដ្ឋកម្ម គឺជាកត្តាសំខាន់នៅក្នុងកម្មវិធីត្រួតត្រាក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ នេះបានតម្រូវឱ្យមានហេដ្ឋារចនាសម្ព័ន្ធសកលមួយផ្នែកច្បាប់ដែលបង្ហាញនូវការរឹបអូសយកទ្រព្យសម្បត្តិដែលបានមកពីឧក្រិដ្ឋកម្ម ។

## VII. ការចោទប្រកាន់ចំពោះក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង

បទពិសោធន៍នៃប្រទេសជាច្រើនក្នុងពិភពលោកបានបង្ហាញឱ្យឃើញថា នីតិវិធីនៃដំណើរការបទល្មើសព្រហ្មទណ្ឌដែលអនុញ្ញាតឱ្យមន្ត្រីស៊ើបអង្កេត និងតុលាការ អនុវត្តនូវការស៊ើបអង្កេតដោយមានប្រសិទ្ធភាព និងសមស្រប ក្នុងដំណាក់ការជម្រះក្តីរបស់តុលាការក្នុងករណីបទល្មើសព្រហ្មទណ្ឌបានដើរតួនាទីដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។

### ១. ការចោទប្រកាន់

ការជំនុំជម្រះក្តីព្រហ្មទណ្ឌតម្រូវតាមច្បាប់ និងធន្ទានុសិទ្ធិ ។ ត្រូវតែមានភស្តុតាងពិតប្រាកដក្នុងក្របខ័ណ្ឌច្បាប់ នៃដំណើរការព្រហ្មទណ្ឌ ក្នុងការប្រយុទ្ធប្រឆាំងនឹងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ ក្នុងប្រទេសភាគច្រើន ព័ត៌មានដែលទទួលបានដោយមានជំនួយពីការត្រួតពិនិត្យតាមប្រព័ន្ធបច្ចេកវិជ្ជា ភ្នាក់ងារសម្ងាត់ បន្ទាល់នៃអ្នកសមគំនិត និងព័ត៌មានដែលទទួលបានតាមរយៈប្រអប់សំបុត្រ ត្រូវប្រើយ៉ាងជោគជ័យចំពោះការស៊ើបអង្កេតរឿងក្តី ដែលពាក់ព័ន្ធក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។

តាមគំនិតផ្តួចផ្តើមរបស់ខ្លួន វិធីសាស្ត្រនៃការត្រួតពិនិត្យតាមប្រព័ន្ធបច្ចេកវិជ្ជា គឺល្អបំផុត

ហើយមានប្រសិទ្ធភាពខ្ពស់ ។ ការលួចស្ដាប់ការសន្ទនារបស់ជនសង្ស័យ គឺត្រូវបានធ្វើដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

ការទទួលព័ត៌មានតាមរយៈភ្នាក់ងារសម្ងាត់ និងប្រអប់សំបុត្រ មានភាពខុសគ្នាក្នុងបទប្បញ្ញត្តិនៃនីតិវិធីទាំងនេះ ដើម្បីទទួលបានភស្តុតាងក្នុងប្រទេសផ្សេងៗគ្នា ។ តែទោះជាយ៉ាងណាក៏ដោយ ក្នុងការប្រយុទ្ធប្រឆាំងនឹងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង នីតិកម្ម និងការអនុវត្តនៃអង្គនីតិបញ្ញត្តិនៃប្រទេសមួយចំនួន អនុញ្ញាតឱ្យមានការផ្ដល់បន្ទាល់ ។

**២. កិច្ចសហប្រតិបត្តិការអន្តរជាតិ**

កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង បានរីកលូតលាស់អស់រយៈពេលពីរទសវត្សកន្លងមក ។ ស្របពេលជាមួយគ្នានេះដែរ បញ្ហាជាច្រើននៅតែមិនទាន់បានដោះស្រាយនៅឡើយ ហើយមានឧបសគ្គធ្ងន់ធ្ងរ និងការរារាំងជាច្រើនទៀត ។ សមត្ថភាពនៃរដ្ឋ ឬរដ្ឋាភិបាលតែមួយ មិនអាចប្រយុទ្ធប្រឆាំងនឹងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងឆ្លងដែន ឱ្យមានប្រសិទ្ធភាពបានឡើយ ហេតុនេះត្រូវមានកិច្ចសហប្រតិបត្តិការអន្តរជាតិ ។ ក្រុមអង្គការទាំងនេះកំពុងតែមានឥទ្ធិពលជាសកល និងមានការវិវត្តកាន់តែខ្លាំងឡើង ។

- ភាពខ្វះខាតនៃមធ្យោបាយ និងធនធានសម្ភារៈរបស់រដ្ឋនីមួយៗ មិនអាចបង្ក្រាបសកម្មភាពរបស់ពួកឧក្រិដ្ឋជនបានទេ ។ នោះហើយជាបញ្ហា ជាពិសេសចាប់តាំងពីក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងឆ្លងដែន យល់ដឹងពីស្ថានភាពនេះយ៉ាងច្បាស់ ហើយជ្រើសរើសប្រទេសណាដែលមានប្រព័ន្ធយុត្តិធម៌ទន់ខ្សោយ និងពុករលួយ ជាទីកន្លែងជ្រកកោន និងធ្វើសកម្មភាពចម្បងរបស់ពួកគេ ។ ក្នុងករណីដែលពួកគេជួបប្រទះសម្ពាធខ្លាំងពីមន្ត្រីអនុវត្តច្បាប់ ក្រុមអង្គការនេះផ្លាស់ប្ដូរទីកន្លែងនៃបណ្ដាញរបស់ខ្លួន ទៅកាន់ប្រទេសដែលមាន "បរិយាកាស" អនុគ្រោះខ្លាំង
- ការទំនាក់ទំនងនយោបាយរវាងប្រទេស និងប្រទេស ភាពខុសគ្នាក្នុងមនោគមវិជ្ជា និងគោលនយោបាយរបស់ខ្លួនចំពោះការអនុវត្តសិទ្ធិមនុស្ស
- ប្រទេសខ្លះមិនមានឆន្ទៈធ្វើបត្យាប័នប្រជាពលរដ្ឋរបស់ខ្លួន ទៅកាន់អំណាចច្បាប់នៃប្រទេសមួយផ្សេងទៀតទេ បើទោះបីជាមានហេតុផលដ៏ខ្លាំងសម្រាប់ការចោទប្រកាន់ឧក្រិដ្ឋជនរបស់ពួកគេដោយនីតិកម្មនៃប្រទេសនោះក៏ដោយ
- ប្រទេស និងប្រទេស មិនចូលរួមក្នុងកិច្ចសហប្រតិបត្តិការ និងមានអំពើពុករលួយ ទាក់ទងនឹងសកម្មភាពក្រុមឧក្រិដ្ឋជន
- មន្ត្រីអនុវត្តច្បាប់ខ្លះ មិនមានឆន្ទៈចូលរួមក្នុងប្រតិបត្តិការរួម ជាមួយសហសេវិករបស់ពួកគេពីប្រទេសផ្សេងៗទៀត ។

**៣. វិធីសាស្ត្រជាក់លាក់នៃកិច្ចសហប្រតិបត្តិការ**

កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ត្រូវអនុវត្តនៅកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ៖

- ការចូលរួមរបស់មន្ត្រីអនុវត្តច្បាប់

- ការធ្វើបត្យាប័ន ៖ កិច្ចព្រមព្រៀងគំរូស្តីពីការធ្វើបត្យាប័នឧក្រិដ្ឋជន ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ គឺជាវិធានការមួយទៀតដើម្បីកែលម្អដល់ស្ថានភាពក្នុងវិស័យនេះ ដែលកិច្ចព្រមព្រៀងជាសកលនៃសមាជិករបស់សហគមន៍ពិភពលោកត្រូវបានសម្រេច
- លទ្ធភាពដើម្បីទទួលបានភស្តុតាង រួមទាំងបន្ទាល់របស់សាក្សីពីប្រទេសផ្សេងទៀត គឺសំខាន់ណាស់សម្រាប់ការប្រយុទ្ធប្រឆាំងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងឆ្លងដែន
- ការរក្សាទុក និងការរឹបអូសទ្រព្យសម្បត្តិជាអត្ថប្រយោជន៍នៃរដ្ឋដែលកំពុងស្នើសុំ
- ការរៀបចំអនុសញ្ញាអន្តរជាតិស្តីពីការគ្រប់គ្រងឧក្រិដ្ឋជនមានអង្គការចាត់តាំងឆ្លងដែន
- ការបង្កើតប្រព័ន្ធប្រមូលផ្តុំ ការវិភាគ និងការផ្លាស់ប្តូរព័ត៌មាន អំពីសកម្មភាពខុសច្បាប់នៃរចនាសម្ព័ន្ធក្រុមឧក្រិដ្ឋជនឆ្លងដែន ។

## VIII. ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា

ក្រុមនេះសំដៅធ្វើសកម្មភាពរកប្រាក់ចំណេញ និងត្រូវបន្តជំនួញដោយមធ្យោបាយឧក្រិដ្ឋកម្ម ។ សហគ្រាសឧក្រិដ្ឋកម្មនឹងអភិវឌ្ឍដូចគ្នាទៅនឹងសហគ្រាសស្របច្បាប់ តាមប្រព័ន្ធបច្ចេកវិជ្ជា ដើម្បីចាប់ឱកាសក្នុងការស្វែងរកប្រាក់ចំណេញ ។ ក្រុមអង្គការឧក្រិដ្ឋជនដើរតួនៅក្នុងទីផ្សារខុសច្បាប់ និងប្រកួតប្រជែងដោយការគំរាមកំហែងនូវអំពើហិង្សាមានរចនាសម្ព័ន្ធចាត់តាំង ។

ទន្ទឹមនឹងនេះដែរ ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងមិនចាំបាច់អភិវឌ្ឍជំនាញបច្ចេកទេសប្រព័ន្ធអ៊ិនធឺណិតទេ ប៉ុន្តែពួកគេអាចជួល ឬសហការជាមួយអ្នកជំនាញ តាមរយៈការឱ្យរង្វាន់ និង/ឬការគំរាមកំហែងឱ្យធ្វើក្នុងកិច្ចការរបស់ខ្លួនដោយមានប្រសិទ្ធភាព និងទទួលបានលទ្ធផល ។

ជាទូទៅ ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងមានទីតាំងជាមូលដ្ឋានមួយក្នុងរដ្ឋអន់ថយ ដែលផ្តល់នូវសុវត្ថិភាពដើម្បីជាជម្រកសម្រាប់ពួកគេប្រតិបត្តិការឆ្លងដែន ។ ជាលទ្ធផល នេះផ្តល់នូវកម្រិតការពារបន្ថែមទៀតប្រឆាំងនឹងអ្នកអនុវត្តច្បាប់ និងអនុញ្ញាតឱ្យពួកគេប្រតិបត្តិដោយមានគ្រោះថ្នាក់តិចបំផុត ។ ប្រព័ន្ធអ៊ិនធឺណិតផ្ទាល់ក៏ផ្តល់នូវឱកាសជាច្រើនសម្រាប់ប្រភេទផ្សេងៗគ្នានៃចោរកម្ម ចាប់ពីធនាគារតាមប្រព័ន្ធអ៊ិនធឺណិត ឬកម្មសិទ្ធិបញ្ញា ។ ប៉ុន្តែវាក៏ផ្តល់ផងដែរនូវមធ្យោបាយថ្មីៗនៃការប្រព្រឹត្តឧក្រិដ្ឋកម្មចាស់ ដូចជាការក្លែងបន្លំ និងបង្កគ្រោះថ្នាក់ថ្មីៗថែមទៀត ដែលពាក់ព័ន្ធនឹងទិន្នន័យ សម្រាប់ការគំរាមកំហែង ដែលមានសារៈសំខាន់យ៉ាងខ្លាំងដល់ក្រុមនេះ ។

អនាមិកភាពនៃប្រព័ន្ធបច្ចេកវិជ្ជា ក៏ជាបណ្តាញ និងឧបករណ៍ដ៏សំខាន់សម្រាប់សកម្មភាពរបស់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ ជាធម្មតា ភាពសម្ងាត់នៃប្រព័ន្ធបច្ចេកវិជ្ជា គឺជាផ្នែកដ៏សំខាន់នៃវិធីរបស់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ដោយពួកគេប្រើប្រព័ន្ធនេះដើម្បីបម្រើឱ្យសកម្មភាពរបស់ខ្លួន ។ សកម្មភាពជាច្រើនអាចត្រូវបានលាក់កំបាំង ក្រោមរូបភាព ជាកាហ្វេអ៊ិនធឺណិត អ៊ិនធឺណិត ២៤ ម៉ោង ដែលមាននៅគ្រប់ទីកន្លែង ដើម្បីបិទបាំងការបញ្ជូនតាមប្រព័ន្ធអ៊ិនធឺណិត ។

ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងតែងតែជ្រើសរើសឧស្សាហកម្មពិសេសជាច្រើន សម្រាប់ការជ្រៀតចូល និងការប្រើប្រាស់ឥទ្ធិពលខុសច្បាប់ ។ ក្នុងអតីតកាល ទាំងនេះបានរួមបញ្ចូលទាំងឧស្សាហ

កម្មជីកសំរាម ឧស្សាហកម្មសំណង់ កាកសំណល់ជាតិពុល និងធនាគារកិច្ច ជាដើម ។

ប្រព័ន្ធអ៊ិនធឺណិត និងការរីកចម្រើននៃពាណិជ្ជកម្មអេឡិចត្រូនិក បង្ហាញនូវគោលដៅមួយចំនួនសម្រាប់ការជ្រៀតចូល និងការប្រើប្រាស់ឥទ្ធិពលរបស់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ដែលជាទស្សនវិស័យមួយបង្ហាញពីបច្ចេកវិជ្ជាប្រព័ន្ធអ៊ិនធឺណិត និងក្រុមហ៊ុនសេវាកម្មប្រព័ន្ធអ៊ិនធឺណិត គួរតែប្រុងប្រយ័ត្នជាពិសេសអំពីដៃគូអនាគត និងអ្នកផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ ។

សរុបសេចក្តីមក លទ្ធផលរួមគ្នារវាងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង និងប្រព័ន្ធបច្ចេកវិជ្ជាមិនមែនគ្រាន់តែសាមញ្ញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចរីកដុះដាល និងអភិវឌ្ឍថែមទៀតក្នុងពេលអនាគត ។ ប្រព័ន្ធបច្ចេកវិជ្ជាផ្តល់នូវគោលដៅជាច្រើន សម្រាប់ឧក្រិដ្ឋកម្ម ហើយធ្វើឱ្យពួកគេធ្វើអាជីវកម្មសម្រាប់ការចំណេញយ៉ាងច្រើនដោយមានគ្រោះថ្នាក់តិចតួចបំផុត ។ ដូច្នេះវាមានសារៈសំខាន់ណាស់ ដើម្បីកំណត់វិធីសាស្ត្រដែលក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង កំពុងតែគ្រួតត្រាបន្ថែមទៀតជាមួយនឹងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា ។

- ការឆ្លើយតបចំពោះការគ្រួតត្រាបន្ថែមទៀត ដែលកាន់តែកើនឡើង រវាងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង និងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា ទាមទារនូវយុទ្ធសាស្ត្រទូលំទូលាយ ។ មានអាទិភាព និងគំរូជាច្រើនដើម្បីឆ្លើយតបបញ្ហានេះ ដែលអាចជួយជាពិសេស និងធ្វើឱ្យការអនុវត្តច្បាប់មានតុល្យភាព ។ ការឆ្លើយតបនៃសហគមន៍អន្តរជាតិចំពោះក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងឆ្លងដែន និងការសម្អាតប្រាក់ អាចជួយជាគំរូមួយដ៏ល្អ
- ក្រុមការងារចំណាត់ការហិរញ្ញវត្ថុ The Financial Action Task Force (FATF) ជាអង្គការដែលបង្កើតឡើងដោយក្រុមប្រទេសឧស្សាហកម្មទាំង ៧ (Canada, France, Germany, Italy, Japan, the United Kingdom, and the United States) មានគោលបំណងបង្កើតបទដ្ឋាន និងស្តង់ដាសម្រាប់ឱ្យរដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុជាច្រើនធ្វើតាមក្នុងការអភិវឌ្ឍបទប្បញ្ញត្តិ និងយន្តការអនុវត្តច្បាប់ថ្នាក់ជាតិ ។ អំឡុងពេលដែលយុទ្ធនាការរបស់ FATF ឈានដល់កម្រិតខ្ពស់បំផុតនៃកិច្ចខិតខំប្រឹងប្រែង ១០ ឆ្នាំ វាផ្តល់គោលវិធីមួយដែលអាចត្រូវយកមកអនុវត្តដោយសហគមន៍អន្តរជាតិ នៅពេលដែលខ្លួនចាប់ផ្តើមប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា
- ការគាំទ្រអនុសញ្ញានេះគឺជាការទទួលស្គាល់ជាមូលដ្ឋាននៃតម្រូវការ ដើម្បីធ្វើឱ្យច្បាប់ជាតិចុះសម្រុងគ្នា ។ ថ្មីៗនេះ កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការអនុវត្តច្បាប់បានទទួលជោគជ័យ តាមរយៈការធ្វើបត្យាប័នជាបន្តបន្ទាប់ និងសន្ធិសញ្ញាជំនួយច្បាប់ទៅវិញទៅមក ដែលអនុញ្ញាតឱ្យរដ្ឋាភិបាលជាច្រើនចែករំលែកព័ត៌មាន និងភស្តុតាងឱ្យគ្នាទៅវិញទៅមក ។ តែទោះជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឱ្យសន្ធិសញ្ញាជំនួយច្បាប់ទៅវិញទៅមក និងសន្ធិសញ្ញាធ្វើបត្យាប័នចូលជាធរមានទាល់តែមានឧក្រិដ្ឋកម្មមួយក្នុងដែនសមត្ថកិច្ចពីរ ។ ទន្ទឹមនេះដែរ កិច្ចសហប្រតិបត្តិការអន្តរជាតិត្រូវបានសម្របសម្រួលយ៉ាងខ្លាំង ដោយការរួមគ្នានូវអ្វីដែលត្រូវបានធ្វើទៅជារឿងព្រហ្មទណ្ឌក្នុងដែនសមត្ថកិច្ចជាតិ
- ការចុះសម្រុងគ្នា គឺចាំបាច់ណាស់សម្រាប់ច្បាប់សារជាតុ ឬច្បាប់សារវិជ្ជមាន ( ច្បាប់

ដែលបង្កើតឱ្យនិយមន័យ និងកំណត់សិទ្ធិ និងករណីកិច្ចរបស់ភាគីផ្សេងៗ និងដែលផ្តល់ដើមហេតុនៃបណ្តឹង) និងក្រមនីតិវិធីព្រហ្មទណ្ឌ ។ ប្រទេសទាំងអស់ ត្រូវតែវាយតម្លៃជាថ្មី និងបន្ថែមនូវវិធាននៃភស្តុតាង ការស្វែងរក និងការរឹបអូស ការលួចស្តាប់ព័ត៌មានសម្ងាត់តាមអេឡិចត្រូនិក និងសកម្មភាពស្រដៀងគ្នាដទៃទៀត ដើម្បីការពារព័ត៌មានដែលទទួលបានតាមរយៈប្រព័ន្ធកុំព្យូទ័រ ទំនាក់ទំនង និងលក្ខណៈសកលនៃប្រព័ន្ធអ៊ិនធឺណិត ។ ការសម្របសម្រួលដ៏ខ្លាំងក្លានៃក្រមនីតិវិធីព្រហ្មទណ្ឌជួយដល់កិច្ចសហប្រតិបត្តិការក្នុងការស៊ើបអង្កេតដែលការពារដល់ដែនសមត្ថកិច្ចជាច្រើន

- បន្ថែមទៅលើច្បាប់ រដ្ឋាភិបាល និងមន្ត្រីអនុវត្តច្បាប់ត្រូវអភិវឌ្ឍនូវសមត្ថភាព ដើម្បីអនុវត្តច្បាប់ទាំងនេះ ។ នេះតម្រូវឱ្យមានការអភិវឌ្ឍនៃកោសលវិច័យក្នុងវិស័យនៃឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា ក៏ដូចជាព័ត៌មានដ៏មានប្រសិទ្ធភាពដែលចែករំលែកឱ្យគ្នា តាមរយៈសមត្ថកិច្ចជំនាញក្នុងប្រទេស និងឆ្លងដែន ។ វាក៏សំខាន់ផងដែរដើម្បីបង្កើតអង្គភាពអនុវត្តច្បាប់ថ្នាក់ជាតិ ដែលមានជំនាញដើម្បីដោះស្រាយជាមួយបញ្ហាឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា ។ អង្គភាពបែបនេះ អាចផ្តល់មូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិជាផ្លូវការ និងមិនផ្លូវការដោយផ្អែកលើបណ្តាញឆ្លងដែនគួរឱ្យទុកចិត្តក្នុងចំណោមមន្ត្រីអនុវត្តច្បាប់
- សមាសភាពសំខាន់ផ្សេងទៀតនៃយុទ្ធសាស្ត្រ ដើម្បីប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា គឺភាពជាដៃគូរវាងរដ្ឋាភិបាល និងឧស្សាហកម្ម ជាពិសេសផ្នែកបច្ចេកវិជ្ជាព័ត៌មាន
- ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងវិស័យទាំងនេះក៏ដោយ ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង និងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា នឹងបន្តរីករាលដាលដដែល ។ ប្រសិនបើវិធានការបង្កើតឡើងក្នុងទិសដៅទាំងនេះ យ៉ាងហោចណាស់ក៏មាននូវឱកាសខ្លះដែលឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា អាចត្រូវបានបង្ក្រាប និងមិនធ្វើឱ្យអន្តរាយដល់ជំនឿទុកចិត្តក្នុងពាណិជ្ជកម្មអេឡិចត្រូនិក ។ វានឹងមិនបង្កើនក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងទៀតទេ ដែលពួកគេអាចគំរាមកំហែង និងធ្វើឱ្យរដ្ឋាភិបាលពុករលួយ ។ ដូចនេះ អ្នកឈ្នះខ្លាំងជាងគេពីការរីកចម្រើននៃប្រព័ន្ធបច្ចេកវិជ្ជា គឺមិនមែនជាក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងនោះទេ ។

## IX. ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងក្នុងការជួញដូរមនុស្ស

### ១. ទិដ្ឋភាពទូទៅ

ការជួញដូរស្ត្រី គឺជាអាជីវកម្មបែបថ្មីមួយ និងជាប្រភពថាមពលសម្រាប់ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ។ ជាទូទៅ វិសាលភាពពេញលេញនៃក្រុមឧក្រិដ្ឋជន និងអាជីវកម្មលួចលាក់ មានចាប់ពីក្រុមអង្គការចាត់តាំងឧក្រិដ្ឋជនធំៗ រហូតដល់ ក្រុមជនពាល ក្រុមរត់ពន្ធ និងក្រុមបណ្តាញផ្សេងទៀត ។ ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងធំៗ ជាពិសេសនៅប៉ែកអឺរ៉ុបខាងកើត និងអាស៊ី មានការពាក់ព័ន្ធយ៉ាងខ្លាំងក្នុងការជួញដូរ ។ លើសពីនេះ ការជួញដូរត្រូវបានប្រព្រឹត្តដោយក្រុមឧក្រិដ្ឋជនដ៏ច្រើនដែលមានការពាក់ព័ន្ធទូលំទូលាយ ផ្តោតលើទិដ្ឋភាពផ្សេងៗគ្នានៃដំណើរការជួញដូរកំពុងធ្វើឱ្យមានការលំបាកដល់ការស៊ើបអង្កេត និងការបង្ក្រាបរបស់មន្ត្រីអនុវត្តច្បាប់ ដោយសារតែបទល្មើសនេះ

មានភាពអាចកំកំបាំង ។ គួបផ្សំនឹងការគំរាមកំហែងថ្មីៗនេះ មន្ត្រីអនុវត្តច្បាប់បានរកឃើញថា ការជួញដូរនៅក្នុងឧស្សាហកម្មស្ត្រីមានជាប់ពាក់ព័ន្ធគ្នាយ៉ាងស្អិតរមួតជាមួយសកម្មភាពឧក្រិដ្ឋកម្មពាក់ព័ន្ធដទៃទៀត ដូចជាការកំហែងយក ការរកស៊ីបរទុច្ចរិត ការសម្អាតប្រាក់និងការសូកប៉ាន់ដល់មន្ត្រីសាធារណៈ ការប្រើប្រាស់គ្រឿងញៀន ការក្លែងបន្លំឯកសារលិខិតបទដ្ឋាន និងការបើកបនល្បែង ...។ ក្រៅពីការកេងប្រវ័ញ្ចផលប្រយោជន៍ពីស្ត្រី ក្រុមជួញដូរក៏ស្វះស្វែងគំរាមយកផលប្រយោជន៍ពីអតិថិជនផងដែរ ។

ការិយាល័យស៊ើបអង្កេតសហព័ន្ធសហរដ្ឋអាម៉េរិក The United States Federal Bureau of Investigation (FBI) បានរាយការណ៍ថា ក្រុមសហគ្រាសឧក្រិដ្ឋកម្មអាស៊ីបានជាប់ពាក់ព័ន្ធក្នុងការរត់ពន្ធមនុស្សទៅកាន់សហរដ្ឋអាម៉េរិក ចែកចេញជាប្រភេទ៖ ៤៥% ជាជនជាតិចិន ២៩% ជាជនជាតិវៀតណាម ៧,៣% ជាជនជាតិកូរ៉េ ជប៉ុន ហ្វីលីពីន ថៃ ឡាវ កម្ពុជា និងផ្សេងទៀតជាជនជាតិ Polynesian ។ ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងអាស៊ីបានដើរតួនាទីជាផ្នែកដ៏ស្មុគស្មាញមួយនៅក្នុងការរត់ពន្ធស្ត្រីអាស៊ីទៅកាន់សហរដ្ឋអាម៉េរិក និងក្នុងការគ្រប់គ្រងផ្ទះបននានា ហើយអាចធ្វើជាម្ចាស់ផ្ទះបន អ្នកជំរិត ឬជាអ្នកការពារ ។ ការស៊ើបអង្កេតរបស់ទីភ្នាក់ងារអន្តោប្រវេសន៍ និងសញ្ជាតូបនីយកម្ម (Immigration and Naturalization Service-INS) បានលាតត្រដាងនូវចំណងទាក់ទងជាច្រើននៅក្នុងទីក្រុងខ្លះ ក្នុងផ្ទះបន ក្រុមជនពាលតាមផ្លូវ និងមេខ្លោងនៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងនៅអាស៊ី ។ ក្រុមជនពាល និងក្រុមឧក្រិដ្ឋជនសង្គមងងឹតចិនបានជាប់ពាក់ព័ន្ធក្នុងការរត់ពន្ធមនុស្ស និងពេស្យាកម្មអស់រយៈពេលជាច្រើនឆ្នាំ ហើយពួកគេកំពុងតែរៀបចំការជ្រើសរើស និងការរត់ពន្ធស្រីពេស្យាមកពីបរទេសកាន់តែខ្លាំងឡើង ។

## ២. ការជាប់ទាក់ទងនឹងទេសន្តរប្រវេសន៍ខុសច្បាប់

បញ្ហានៃទេសន្តរប្រវេសន៍ខុសច្បាប់ជាប់ពាក់ព័ន្ធកាន់តែខ្លាំងឡើង ជាមួយក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ដែលបច្ចុប្បន្ននេះ គ្រប់គ្រងយ៉ាងទូលំទូលាយលើការជួញដូរ និងរត់ពន្ធមនុស្ស ។ ក្រុមជួញដូរ និងរត់ពន្ធមនុស្ស រកប្រាក់ចំណេញបានច្រើនសន្ធឹកសន្ធាប់ ។ ពួកគេមានទំនាក់ទំនងជាមួយបណ្តាញឧក្រិដ្ឋជនឆ្លងដែនដទៃទៀត ដែលបានពាក់ព័ន្ធក្នុងការជួញដូរថ្នាំញៀនណារកូទិក ការជួញដូរសព្វាវុធ ការសម្អាតប្រាក់ និងការក្លែងបន្លំឯកសារលិខិតបទដ្ឋាន ហើយផ្តល់មូលនិធិចាំបាច់ដើម្បីទិញគ្រឿងបរិក្ខារទំនើបៗ និងទិញទឹកចិត្តអាជ្ញាធរមានសមត្ថកិច្ច ។ សកម្មភាពរបស់ពួកគេពឹងផ្អែកលើហេដ្ឋារចនាសម្ព័ន្ធដ៏ស្មុគស្មាញ ហើយរដ្ឋជាច្រើនត្រូវតែចាត់វិធានការកាន់តែខ្លាំងថែមទៀតទៅលើក្រុមទាំងនោះ ។

ក្រុមរត់ពន្ធមនុស្សត្រូវការប្រាក់ដ៏ច្រើនសម្រាប់ផ្តល់ឱ្យមន្ត្រីអនុវត្តច្បាប់ ក្នុងការដោះដូរនឹងការចូលដោយខុសច្បាប់របស់ពួកគេទៅក្នុងប្រទេសថ្មីមួយ ។ តាមធម្មតា ពួកគេផ្តល់មធ្យោបាយដឹកជញ្ជូន លិខិតឆ្លងដែនក្លែងក្លាយ ទីស្នាក់អាស្រ័យបណ្តោះអាសន្ន និងការឆ្លងកាត់ព្រំដែននានា ។ ជាញឹកញាប់ការពង្រឹងនីតិវិធីអន្តោប្រវេសន៍នៅក្នុងប្រទេសម្ចាស់ផ្ទះ បានបង្ខំអ្នកដែលប្រាថ្នាចង់គៀសខ្លួនគេចចេញពីបញ្ហាក្រីក្រ ឬជម្លោះក្នុងស្រុក ដើម្បីពឹងផ្អែកលើសេវាកម្មដែលមានតម្លៃខ្ពស់ និងប្រកបដោយគ្រោះថ្នាក់ទាំងនេះ ។ ជនអន្តោប្រវេសន៍ដែលគ្មានលិខិតស្នាម ត្រូវបង់ថ្លៃខ្ពស់សម្រាប់សិទ្ធិឆ្លងកាត់

បន្ទាប់ពីការទៅដល់របស់ពួកគេ ។ ដោយសារមិនអាចទូទាត់នូវបំណុលរបស់ពួកគេ អ្នកទាំងនោះចាប់ផ្តើមធ្វើការឱ្យក្រុមជនពាលនៅក្នុងការងារដែលមានជំនាញទាប ដូចជា ឧស្សាហកម្មផ្លូវភេទ និងឧក្រិដ្ឋកម្ម ។ ហេតុដូច្នេះ ក្រុមជនពាលអាចជាប់ពាក់ព័ន្ធនៅក្នុងការរត់ពន្ធ និងការធ្វើអាជីវកម្មលើពលករខុសច្បាប់ ។ ក្រុមជួញដូរមនុស្សប្រើល្បិចដាក់អន្ទាក់ភាគច្រើនជាកុមារ និងស្ត្រីក្មេងៗ ឱ្យចូលទៅបម្រើការ ឬធ្វើពេស្យាចារតាមរយៈការប្រើប្រាស់កម្លាំងបង្ខិតបង្ខំ ឬការបោកបញ្ឆោត ។ ពួកគេចុងបញ្ចប់ធ្លាក់ខ្លួនក្លាយជាទាសករផ្លូវភេទ ពលករដោចថ្លៃ និងជាកម្មករដែលទទួលកម្រៃទាប បន្ទាប់ពីត្រូវបានសន្យាថា ផ្តល់ការងារល្អឱ្យធ្វើ ។ ជាទូទៅ លិខិតឆ្លងដែនត្រូវបានរឹបអូស ហើយស្ថានភាពខុសច្បាប់របស់ពួកគេធ្វើឱ្យមានការលំបាកកាន់តែខ្លាំងថែមទៀត ដើម្បីចាប់ផ្តើមរកផ្លូវដោះស្រាយជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងស្រុក ។ នៅពេលធ្វើបែបនេះ ពួកគេផ្សងគ្រោះថ្នាក់នឹងការផាកពិន័យលក្ខខណ្ឌកំណត់ឱ្យជាប់ពន្ធនាគារ និងការនិរទេស ។

ក្រុមកម្មករដែលគ្មានលិខិតស្នាមជាច្រើននៅក្នុងអាស៊ី បានពឹងផ្អែកលើពួកអ្នករត់ពន្ធមនុស្ស ដើម្បីចូលទៅដល់ទិសដៅចុងក្រោយរបស់ពួកគេដោយខុសច្បាប់ ។ បច្ចុប្បន្ន ភាគច្រើននៃជនអន្តោប្រវេសន៍ខុសច្បាប់ទាំងនេះ ជាស្ត្រីដែលជាញឹកញាប់ធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ក្រុមជួញដូរមនុស្ស។ តាមការប៉ាន់ប្រមាណរបស់អង្គការសហប្រជាជាតិបញ្ជាក់ថា ស្ត្រីចំនួន ២០០ ០០០ នាក់ត្រូវបានជួញដូរនៅក្នុងទ្វីបអាស៊ីអាគ្នេយ៍ក្នុងមួយឆ្នាំៗ ។ ស្ត្រីរាប់ពាន់នាក់មកពីប្រទេសចិន ឡាវ និងភូមា ធ្វើជាស្រីពេស្យានៅក្នុងប្រទេសថៃ ។ កុមារីជនជាតិវៀតណាមត្រូវបានជួញដូរផងដែរ ទៅកាន់ប្រទេសកម្ពុជា ដើម្បីផ្គត់ផ្គង់ការជួញដូរផ្លូវភេទ និងទៅកាន់ប្រទេសចិន និងតៃវ៉ាន់តាមរយៈអាពាហ៍ពិពាហ៍ ។ ពាណិជ្ជកម្មស្ត្រីខុសច្បាប់ បានក្លាយជាប្រភពចំណូលដ៏ច្រើនសម្រាប់ក្រុមជួញដូរមនុស្ស និងនៅតែមានការលំបាកដើម្បីធ្វើការចាប់ខ្លួន ដោយសារតែត្រូវបានលាក់បំពួននៅក្នុងទេសន្តរប្រវេសន៍ ដែលគ្មានលិខិតស្នាមដ៏ទូលំទូលាយ ។ វិបត្តិហិរញ្ញវត្ថុនៅទ្វីបអាស៊ីឆ្នាំ ១៩៩៧-៩៨ និងផលវិបាកខាងសេដ្ឋកិច្ចចេះតែបន្តដែលត្រូវបានប្រឈមដោយប្រទេសឥណ្ឌូនេស៊ី និងប្រទេសក្នុងតំបន់ផ្សេងទៀត បានបង្កើនដល់ការជួញដូរស្ត្រីនៅអាស៊ីអាគ្នេយ៍ ។ ភាពក្រីក្រ កង្វះខាតការអប់រំ និងឱកាសការងារសម្រាប់ស្ត្រី គឺជាប្រភពឫសគល់ដែលបង្កឱ្យមានបញ្ហានេះ ។

## ៣. ភាពលំបាកដែលប្រឈមនឹងមន្ត្រីអនុវត្តច្បាប់

បញ្ហាប្រឈមនឹងឧក្រិដ្ឋកម្មឆ្លងដែននៅអាស៊ីអាគ្នេយ៍ បណ្តាលមកពីកត្តាក្នុងស្រុកជាច្រើនរួមមាន អំពើពុករលួយ ធនធានមានកម្រិត និងជម្លោះផលប្រយោជន៍ ។ ទំនាក់ទំនងរវាងអស្ថិរភាព ភាពក្រីក្រក្នុងប្រទេស និងឧក្រិដ្ឋកម្មឆ្លងដែន ចាំបាច់ត្រូវតែដោះស្រាយ ។ ប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើន នៅតែជាប្រទេសទន់ខ្សោយ ដោយសារស្ថាប័នមួយចំនួនក្នុងប្រទេស មិនរឹងមាំ និងមានបញ្ហាវិបត្តិសង្គម-សេដ្ឋកិច្ច ។ អំពើពុករលួយ និងកង្វះហិរញ្ញវត្ថុសម្រាប់កិច្ចប្រតិបត្តិការ បានធ្វើឱ្យអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងក្នុងប្រទេស ដើម្បីប្រឆាំងនឹងក្រុមជនពាលមានអង្គការចាត់តាំង ។ វិសមភាពសេដ្ឋកិច្ច និងភាពក្រីក្រដែលបន្តនៅមានក្នុងតំបន់ ជះឥទ្ធិពលដល់លទ្ធភាពដើម្បីដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសបញ្ហាជួញដូរ និងរត់ពន្ធមនុស្ស ។

ប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនយឺតយ៉ាវ ក្នុងការដាក់ឱ្យនៅក្រៅច្បាប់នូវទិដ្ឋភាពនៃឧក្រិដ្ឋកម្មឆ្លងដែន ដោយសារតែកត្តាក្នុងស្រុកមួយចំនួនដែលបានរៀបរាប់ដូចខាងលើ ។ នេះត្រូវបានបកស្រាយនៅក្នុងការពិតដែលពួកគេមិនបានសម្រេចកំណត់ពីនីតិកម្មចាំបាច់ ដើម្បីចោទប្រកាន់ប្រភេទឧក្រិដ្ឋកម្មជាក់លាក់ ។ ហេតុដូច្នេះ ពួកគេផ្តល់នូវបរិយាកាសល្អប្រសើរទៅដល់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ។ ប្រទេសនៅអាស៊ីអាគ្នេយ៍ខ្លះ ជួបនូវការបរាជ័យនៅក្នុងការដាក់ឱ្យនៅក្រៅច្បាប់ចំពោះឧក្រិដ្ឋកម្មឆ្លងដែនថ្នាក់ជាតិ ដែលបញ្ហានេះធ្វើឱ្យស្មុគស្មាញដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីឆ្លើយតបទៅនឹងសកម្មភាពទាំងនោះនៅតាមតំបន់ ។ ប្រទេសកម្ពុជាបានឈានឡើងមួយកម្រិតទៀត ដោយរដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០០៧ ដែលមានលក្ខណៈប្រសើរជាងច្បាប់ចាស់ ។

បញ្ហាឧក្រិដ្ឋកម្មឆ្លងដែនទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងបញ្ហាអធិបតេយ្យភាពជាតិ ។ ផ្ទុយទៅវិញ សកម្មភាពឧក្រិដ្ឋកម្មឆ្លងដែនតំណាងការគំរាមកំហែងចំពោះអធិបតេយ្យជាតិ និងបូរណភាពរបស់រដ្ឋឯករាជ្យ ហើយបង្កគ្រោះថ្នាក់ដល់ការរស់រានមានជីវិតនៃរដ្ឋាភិបាលរបស់រដ្ឋនោះទៀតផង ។ ជាយូរមកហើយ ប្រទេសអាស៊ីអាគ្នេយ៍ គឺជាអ្នកការពារដ៏រឹងមាំនៃភាពមិនអាចរំលោភបានចំពោះអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី ។

## X. ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងភេរវកម្ម

ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងភេរវកម្មមិនមែនជាបញ្ហាថ្មីទេ ។ អ្វីដែលថ្មី គឺមូលដ្ឋានដែលអំណោយផលសម្រាប់ការរីកលូតលាស់យ៉ាងឆាប់រហ័ស និងប្រតិបត្តិការថ្មី ដែលពិភពលោកនៃសកលភាវូបនីយកម្ម បានផ្គត់ផ្គង់ដល់ពួកគេ ។ សកលភាវូបនីយកម្មកំពុងផ្តល់នូវកាលានុវត្តភាពកាន់តែប្រសើរឡើង សម្រាប់ពាណិជ្ជកម្មអន្តរជាតិ គមនាគមន៍ ការធ្វើដំណើរ និងការបណ្តុះបណ្តាលបញ្ញវន្ត។ នៅក្នុងការវិវត្តដែលពុំអាចស្មានដល់នៃជោគវាសនាសកលភាវូបនីយកម្ម កំពុងតែផ្តល់ឱកាសផងដែរដល់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង ដើម្បីពង្រីកខ្លួន ប្រតិបត្តិកាន់តែមានប្រសិទ្ធភាព កាន់តែរលូន និងសម្រាប់ក្រុមភេរវជនទទួលបានអាវុធយុទ្ធភ័ណ្ឌ ពង្រីកនូវគោលបំណងរបស់ពួកគេ និងគេចចេញពីអាជ្ញាធរអនុវត្តច្បាប់ ។

### ១. និន្នាការ

ឧក្រិដ្ឋកម្មសកលទំនងនៅតែបន្តទទួលផលប្រយោជន៍ពីសកលភាវូបនីយកម្ម ដោយលើកកម្ពស់នូវសមាហរណកម្មសេដ្ឋកិច្ច ពាណិជ្ជកម្មសេរី និងបច្ចេកវិទ្យាជឿនលឿនឱ្យបានយូរអង្វែង ជាញឹកញាប់ មុនពេលសហគ្រាសស្របច្បាប់នានាត្រូវបានបង្ខំឱ្យធ្វើទៅតាមកម្រិតស្តង់ដា និងបទប្បញ្ញត្តិអន្តរជាតិ ។ ដូចនេះ ខណៈពេលដែលនិន្នាការសកលភាវូបនីយកម្មទាំងនេះ បានប្រាប់ឱ្យដឹងជាមុននូវចលនាកើនឡើងដ៏ខ្លាំងក្លានៃប្រជាជន និងពាណិជ្ជកម្ម ថ្មីៗនេះពួកគេបានដើរតួនាទីដ៏សំខាន់នៅក្នុងការជួយដល់ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងក្រុមភេរវជនអន្តរជាតិ ដើម្បីពង្រីកខ្លួន និងធ្វើឱ្យអាជ្ញាធរអន្តរជាតិមិនអាចចាប់ពួកគេបាន នៅក្នុងសង្គមគួរឱ្យខ្លាចនៃសកលភាវូបនីយកម្ម ។

### ២. ភេរវកម្ម

ភេរវកម្មអាចមានការគំរាមកំហែងតិចតួចជាងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ប៉ុន្តែវាត្រូវបានគេស្គាល់ជាយូរមកហើយ ។ វប្បធម៌ ប្រពៃណី និងតម្លៃនានា ត្រូវបានធ្វើពលិកម្មក្នុងរដ្ឋជាច្រើន ដោយសារតែសកលភាវូបនីយកម្ម ។ គមនាគមន៍ និងការធ្វើដំណើរសកលដែលបានកើនឡើង គួបផ្សំនឹងបណ្ដាញព័ត៌មានដែលគ្របដណ្ដប់លើពិភពលោក បានធ្វើសមាហរណកម្មវប្បធម៌ជាតិពាសពេញពិភពលោក ជាញឹកញាប់ធ្វើឱ្យមានភាពមិនច្បាស់លាស់ ។ និន្នាការនេះ មានផលវិបាកធ្ងន់ធ្ងរ ដែលនាំឱ្យក្រុមខ្លះបានត្រឡប់ទៅរកវិធីសាស្ត្រភេរវកម្ម ដើម្បីសម្រេចឱ្យបាននូវគោលបំណងរបស់ខ្លួន ។ បញ្ហានេះ បានកើតឡើងនៅក្នុងប្រទេសមួយចំនួន ដែលមានឃាតកម្មនយោបាយជាច្រើន ចំពោះទេសចរត្រូវបានធ្វើក្នុងនាមបង្ហាញភាពបរិសុទ្ធខាងសាសនា ដែលបានបំផ្លាញយ៉ាងជាក់ស្ដែងដល់ផ្នែកនៃសេដ្ឋកិច្ចមួយចំនួន ។

សកលភាវូបនីយកម្មធ្វើឱ្យប្រឈមបូកប្រឡប់ពិបាកគ្រប់គ្រងដល់ក្រុមភេរវជន ។ នៅក្នុងអំឡុងពេលសង្គ្រាមត្រជាក់ ក្រុមភេរវជនបែបប្រពៃណី ជាញឹកញាប់ត្រូវបានដឹកនាំដោយរដ្ឋាភិបាលបរទេស ហើយពួកគេផ្ដោតលើកម្លាំងជំរុញទឹកចិត្តខាងមនោគមន៍វិជ្ជា និងនយោបាយជាក់លាក់ ។ នេះធ្វើឱ្យមន្ត្រីអនុវត្តច្បាប់កាន់តែងាយស្រួល ដើម្បីកំណត់អត្តសញ្ញាណ និងគោលដៅ ។ ក្រុមភេរវជនដែលបានលេចរូបឡើងនៅពេលបច្ចុប្បន្ននេះ ខ្វះខាតនូវឧត្តមគតិយល់ដឹងទូលំទូលាយ ពឹងផ្អែកយ៉ាងខ្លាំងលើកម្លាំងជំរុញទឹកចិត្តខាងសាសនា ត្រូវបានរៀបចំមិនសូវល្អ និងមានទំនាក់ទំនងតិចតួច ឬមានសេចក្ដីស្មោះត្រង់តិចតួចចំពោះរដ្ឋណាមួយ ប្រសិនជាមាន ។ រចនាសម្ព័ន្ធកាន់តែរីកធំ និងមិនច្បាស់លាស់របស់ពួកគេ ធ្វើឱ្យមន្ត្រីអនុវត្តច្បាប់កាន់តែលំបាក ដើម្បីរកឱ្យឃើញ និងទប់ស្កាត់ ។ ក្រុមអ្នកនិយមជ្រុល ដែលមានលក្ខណៈអាចកំបាំង គ្មានគោលដៅមនោគមន៍វិជ្ជាច្បាស់លាស់ ជាមួយនឹងមនុស្សរងប់នឹងសាសនា បានបង្ហាញឱ្យឃើញនូវសមាសភាព កាន់តែគ្រោះថ្នាក់ខ្លាំងក្លាថែមទៀត នៅក្នុងភាពរីករវនៃអំពើភេរវកម្ម ដែលជាមហិច្ឆតាមួយ ដើម្បីប្រើប្រាស់អំពើហិង្សាប្រឆាំងនឹងតម្លៃរបស់សកលភាវូបនីយកម្ម និងមនុស្សជាតិនៃប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ។

## XI. ការឆ្លើយតបចំពោះការគំរាមកំហែងនៃឧក្រិដ្ឋកម្មអន្តរជាតិ

ហេដ្ឋារចនាសម្ព័ន្ធអេឡិចត្រូនិកទំនើបរបស់យើងដែលជាប្រព័ន្ធព័ត៌មានវិទ្យា គ្រប់គ្រងអ្វីៗទាំងអស់ តាំងពីប្រព័ន្ធអំណាចរបស់យើង រហូតដល់ផ្សារភាគហ៊ុន គឺជាគោលដៅដ៏មានសក្ដានុពលសម្រាប់ការវាយប្រហារ ដោយអ្នកលួចចូលប្រព័ន្ធបច្ចេកវិជ្ជា (Hacker) និងសហគ្រាសឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ។ ការវាយប្រហារបែបនោះធ្វើឱ្យមានការគំរាមកំហែងដោយត្រង់ៗ ចំពោះសន្តិសុខរបស់ប្រទេស ។ ជាមួយឧបករណ៍បច្ចេកវិជ្ជាទំនើប ក្រុមឧក្រិដ្ឋជនជុំវិញពិភពលោក អាចលួចប្រាក់រាប់លានដុល្លារពីធនាគារ និងសម្អាតប្រាក់ដោយមិនបាច់ឈានជើងចូលក្នុងប្រទេសនោះឡើយ។ បច្ចេកវិជ្ជាដូចគ្នាទាំងនេះ អនុញ្ញាតឱ្យឧក្រិដ្ឋជនមានអង្គការចាត់តាំងដែលមានស្រាប់ បង្កើតនូវបណ្ដាញថ្មីជុំវិញពិភពលោកដ៏ទូលំទូលាយ ដើម្បីរត់ពន្ធគ្រឿងញៀន និងសព្វាវុធខុសច្បាប់ ព្រមទាំង

អាវុធប្រល័យលោកទៀតផង ។ ក្រុមឧក្រិដ្ឋជនក៏អាចប្រើប្រាស់នូវបច្ចេកវិជ្ជាថ្មីនេះផងដែរ ដើម្បីធ្វើអាជីវកម្មលើកុមារ ដោយប្រើប្រាស់ឧបករណ៍បច្ចេកវិជ្ជាផ្ទាល់ខ្លួន ដើម្បីមើល ផ្ញើរូបភាពអាសអាភាសកុមារ និងដើម្បីទាក់ទាញអនីតិជនឱ្យចូលរួមក្នុងពេស្យាកម្មកុមារ ។

**១. គោលបំណង**

មន្ត្រីអនុវត្តច្បាប់អន្តរជាតិ ត្រូវតែត្រៀមរួចជាស្រេច ដើម្បីប្រឈមនឹងការប្រកួតប្រជែងថ្មីៗដែលបង្កឡើងដោយការគំរាមកំហែងនៃឧក្រិដ្ឋកម្មដែលកំពុងកើតឡើង ។ យើងតែងតែទទួលយកគោលវិធីដែលមានលក្ខណៈជាច្រើន ដើម្បីប្រឈមនឹងឧក្រិដ្ឋកម្មស្មុគស្មាញ ដូចជាការជួញដូរមនុស្ស និងសកម្មភាពនៃបណ្តាញក្រុមឧក្រិដ្ឋជន ។ អំឡុងពេលដែលមានតួនាទីសំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ សម្រាប់មន្ត្រីអនុវត្តច្បាប់បែបប្រពៃណី លក្ខណៈ និងភាពស្មុគស្មាញនៃបញ្ហាដែលកំពុងកើតឡើងទាំងនេះ នាំឱ្យមានការពាក់ព័ន្ធដល់ផ្នែកឯកជនដ៏ច្រើនកើតឡើងផងដែរ ។ នៅពេលណាដែលមានលទ្ធភាព យើងត្រូវតែដឹកនាំវិធានការតបតជាមុន ដោយរៀបចំខ្លួនសម្រាប់ប្រឆាំងសកម្មភាពឧក្រិដ្ឋកម្ម មុនសកម្មភាពទាំងនេះកើតឡើង និងកាត់បន្ថយនូវចំណុចខ្សោយរបស់យើង ។ គោលបំណងនៃចំណាត់ការអនុវត្តច្បាប់ទាំងនេះមាន ៖

- ទប់ស្កាត់សកម្មភាពថ្មីៗនៃក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងអន្តរជាតិ
- បង្កើនកិច្ចខិតខំប្រឹងប្រែងស៊ើបការណ៍ប្រឆាំងនឹងសហគ្រាសឧក្រិដ្ឋកម្ម ដើម្បីចែករំលែកព័ត៌មានឱ្យបានទាន់ពេលវេលា អំពីការផ្លាស់ប្តូរ និងកលល្បិចរបស់ពួកគេ
- កាត់បន្ថយការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មលើកុមារ
- បង្កើនកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា
- ស្វែងរកជាប្រចាំ និងធ្វើឱ្យមានភាពប្រសើរឡើង ចំពោះចំណុចខ្សោយរបស់ហេដ្ឋារចនាសម្ព័ន្ធដែលប្រើបច្ចេកវិជ្ជាក្នុងទូរគមនាគមន៍ កិច្ចការជំនួញហិរញ្ញវត្ថុ និងវិស័យបច្ចេកវិជ្ជាផ្សេងទៀត ។

**២. កម្មវិធី និងការផ្តួចផ្តើម**

ការវិវត្តដែលគំរាមកំហែងខ្លាំងបំផុត ចំពោះមន្ត្រីអនុវត្តច្បាប់លើពិភពលោក គឺការពង្រីកចូលទៅក្នុងតំបន់ភូមិសាស្ត្រថ្មីៗ និងសកម្មភាពខុសច្បាប់ដោយក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងជឿនលឿនក្នុងប្រទេសមួយចំនួន ។

ការស៊ើបការណ៍បង្ហាញថា ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងជាច្រើន ប្រតិបត្តិស្រដៀងនឹងសហគ្រាសឧក្រិដ្ឋកម្មមានអង្គការចាត់តាំងបែបម៉ាហ្វីយ៉ា និងបែបប្រពៃណី ។ ជាញឹកញាប់ ក្រុមសមាជិកមានជាតិសាសន៍ និងវប្បធម៌ដូចគ្នា ហើយមកពីសន្តានគ្រួសារ ឬទីក្រុងជាមួយគ្នា ។ ភក្តីភាព និងភាពសម្ងាត់ ត្រូវបានបង្ខំឱ្យអនុវត្តតាមរយៈអំពើហិង្សា និងការបំភិតបំភ័យ ។ មន្ត្រីអនុវត្តច្បាប់ មិនងាយជ្រៀតចូលទៅក្នុងក្រុមដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នាទាំងនេះទេ ។ ហេតុនេះមន្ត្រីអនុវត្តច្បាប់ត្រូវតែពឹងផ្អែកលើបច្ចេកទេសស៊ើបអង្កេតទំនើបជាង ។

ទោះបីជាក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងទាំងនេះ ជួនកាលមាននូវលក្ខណៈពិសេសដែលមានរចនាសម្ព័ន្ធចាត់តាំងរួមគ្នាក៏ដោយ ក៏សកម្មភាពឧក្រិដ្ឋកម្មរបស់ពួកគេមិនដូចគ្នាដែរ ។

ជាទូទៅ ក្រុមជំនួញឧក្រិដ្ឋកម្មអន្តរជាតិមានចំណុចខ្សោយជាច្រើន ដូចគ្នានឹងក្រុមឧក្រិដ្ឋជនអន្តរជាតិដែរ ។ ការបដិសេធផ្តល់ជម្រកសុវត្ថិភាពឱ្យក្រុមឧក្រិដ្ឋជនអន្តរជាតិ ការបំផ្លាញទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់ពួកគេ និងការការពារកុំឱ្យពួកគេធ្វើអាជីវកម្មតាមព្រំដែន អាចកាត់បន្ថយផលប៉ះពាល់ដល់ជីវិតមនុស្សដែលគ្មានកំហុស សហគមន៍នានា ហិរញ្ញវត្ថុ និងសន្តិសុខ ។

ដើម្បីឆ្លើយតបចំពោះការវិវត្តដ៏គួរឱ្យព្រួយបារម្ភ ត្រូវមានកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ក្រុមជំនួញឧក្រិដ្ឋកម្មអន្តរជាតិ និងជួយដល់ដៃគូអន្តរជាតិ ដោយផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេស ។

**៣. ការស៊ើបការណ៍**

ដើម្បីផ្តល់ព័ត៌មានទាន់ពេលវេលានៃការផ្លាស់ប្តូរក្នុងក្រុមឧក្រិដ្ឋជន និងកលល្បិចឧក្រិដ្ឋកម្ម ការប្រមូល ការវិភាគ និងចែករំលែកព័ត៌មានស៊ើបការណ៍ គឺជាចំណុចសំខាន់ ដើម្បីវាយប្រហារប្រភពនៃឧក្រិដ្ឋកម្មអន្តរជាតិ ។ ការស៊ើបការណ៍ត្រូវចំណាយនូវធនធានដ៏ច្រើន ដើម្បីកំណត់អត្តសញ្ញាណ និន្នាការរបស់សកម្មភាពឧក្រិដ្ឋជនអន្តរជាតិ និងតាមរកបណ្តាញ រចនាសម្ព័ន្ធ សកម្មភាព និងចំណុចខ្សោយនៃក្រុមឧក្រិដ្ឋជនអន្តរជាតិ ។ យន្តការនិងវិធានការ ដើម្បីធានាដល់កិច្ចខិតខំប្រឹងប្រែងស៊ើបការណ៍ ត្រូវដឹកនាំឆ្ពោះទៅកាន់ការបំពេញតម្រូវការជាអាទិភាពនៃគោលនយោបាយ និងមន្ត្រីអនុវត្តច្បាប់ ។ ក្រុមស៊ើបការណ៍នឹងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្តល់ព័ត៌មាន ពីស្ថានការណ៍ និងទាន់ពេលវេលាទៅឱ្យមន្ត្រីអនុវត្តច្បាប់ ដើម្បីជួយទប់ស្កាត់ឧក្រិដ្ឋកម្មអន្តរជាតិ និងបំផ្លាញក្រុមឧក្រិដ្ឋជន ។

**៤. ការកាត់បន្ថយអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មលើកុមារ**

ដោយសារតែប្រាក់ចំណេញដ៏ច្រើន និងគ្រោះថ្នាក់តិចបំផុត ក្រុមឧក្រិដ្ឋជនធ្វើការជួញដូរស្ត្រី និងកុមារ ឆ្លងកាត់ព្រំដែនអន្តរជាតិសម្រាប់ការធ្វើអាជីវកម្មផ្លូវភេទ និងពលកម្មដោយបង្ខំ តាមរយៈការក្លែងបន្លំធ្វើជាជំនួញស្របច្បាប់ ដូចជាក្រុមហ៊ុនបង្ហាញម៉ូដ ក្រុមហ៊ុនស្វែងរកការងារ ក្រុមហ៊ុនជ្រើសរើសគូស្រករអន្តរជាតិ ឬអង្គការផ្លាស់ប្តូរវប្បធម៌ ក្រុមឧក្រិដ្ឋជនផ្តល់សេចក្តីសង្ឃឹមនៃការងារ និងអាពាហ៍ពិពាហ៍ទៅឱ្យស្ត្រីទាំងនេះ ។ តាមពិត ជាញឹកញាប់ ពួកគេធ្វើការសន្យាដោយបោកបញ្ឆោត នាំទៅដល់ទាសភាពបំណុល ការគំរាមកំហែងដល់ក្រុមគ្រួសាររបស់ស្ត្រីទាំងនោះ និងអំពើហិង្សា ។

**ក. កិច្ចខិតខំប្រឹងប្រែង**

ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរស្ត្រី និងកុមារ កិច្ចខិតខំប្រឹងប្រែងបង្ការទប់ស្កាត់ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអនុវត្ត ត្រូវធ្វើឡើងដើម្បីកាត់បន្ថយបទល្មើសនេះ ។ វិធានការទប់ស្កាត់ រួមមានការស្រាវជ្រាវ លើកកម្ពស់កម្រិតយល់ដឹងជាសាធារណៈ ការអនុវត្តច្បាប់និងការបណ្តុះបណ្តាលផ្នែកជំនាញ និងជំនួយសម្ភារៈបច្ចេកទេស ។ វិធានការអនុវត្ត រួមមាន ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិប្រឆាំងការជួញដូរមនុស្ស ការធ្វើវិសោធនកម្មច្បាប់ និងការបង្កើតបន្ថែមច្បាប់ថ្មី ការកំណត់ទោសបញ្ញត្តិឱ្យបានធ្ងន់ធ្ងរ សម្រាប់ការជួញដូរមនុស្ស និងការបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ។ វិធានការការពារ រួមមាន ត្រួតពិនិត្យការផ្តល់ទិដ្ឋាការឱ្យបានល្អ ការការពារសាក្សីជាជនរងគ្រោះ ក៏ដូចជាផ្តល់ទីស្នាក់អាស្រ័យ ជម្រើសសេដ្ឋកិច្ច និងការពិគ្រោះផ្តល់យោបល់ផ្នែកច្បាប់ និងការព្យាបាល ។

**ខ. ឧក្រិដ្ឋកម្មលើកុមារ**

ក្រុមឧក្រិដ្ឋជនផលិតរូបអាសអាភាសកុមារ គឺកំពុងតែប្រតិបត្តិការក្នុងប្រទេសជាច្រើន តាមរយៈប្រព័ន្ធអ៊ិនធឺណិត និងបណ្ដាញចែកចាយផ្សេងៗទៀត ។ បច្ចេកវិជ្ជាថ្មីអនុញ្ញាតឱ្យឧក្រិដ្ឋជនទាំងនេះ រក្សាទុកនូវចំនួនរូបថតឌីជីថលដ៏ច្រើនសន្ធឹកសន្ធាប់ នៅលើឧបករណ៍តូចៗ ដែលធ្វើឱ្យយើងកាន់តែពិបាកថែមទៀត ដើម្បីរកឱ្យឃើញនូវចំណាត់ការឆ្លងកាត់ព្រំដែនអន្តរជាតិរបស់ពួកគេ ។

**គ. ការធ្វើអាជីវកម្មលើពលកម្មកុមារ**

កុមារត្រូវបានធ្វើអាជីវកម្ម ក្នុងរោងចក្រជុំវិញពិភពលោក សម្រាប់ពលកម្មតម្លៃថោក ។ ទីភ្នាក់ងារអនុវត្តច្បាប់សហព័ន្ធបានផ្ដួចផ្ដើម នូវកម្មវិធីមួយរួមគ្នាជាមួយនឹងអ្នកតំណាងពាណិជ្ជកម្មសហរដ្ឋអាម៉េរិកឧស្សាហកម្មក្នុងស្រុក និងអង្គការសង្គមស៊ីវិលដែលមានការពាក់ព័ន្ធដើម្បីប្រយុទ្ធប្រឆាំង នឹងការនាំចូលនូវទំនិញដែលផលិតដោយពលកម្មកុមារដោយបង្ខំ ។ កម្មវិធីអនុវត្តដ៏ខ្លាំងក្លានេះ ត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់នូវការនាំចូលនៃទំនិញដែលផលិតឡើងដោយកុមារដែលត្រូវគេធ្វើអាជីវកម្ម និងដើម្បីចោទប្រកាន់នីតិបុគ្គលដែលបាននាំចូលដោយចេតនានូវសម្ភារៈត្រូវហាមឃាត់ ។

## ៥. កិច្ចខិតខំប្រឹងប្រែងប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា

**ក. ការរីកចម្រើនខាងទូរគមនាគមន៍ និងឧក្រិដ្ឋកម្មពាក់ព័ន្ធ**

ការងាររបស់អ្នកជំនាញជាច្រើន គឺផ្ដោតទៅលើការអភិវឌ្ឍឧបករណ៍ ដែលក្រុមអាជ្ញាធរអនុវត្តច្បាប់ ត្រូវការដើម្បីរកឱ្យឃើញ និងកំណត់អត្តសញ្ញាណក្រុមឧក្រិដ្ឋជនតាមប្រព័ន្ធបច្ចេកវិជ្ជា និងដើម្បីប្រមូលភស្តុតាងនៃឧក្រិដ្ឋកម្ម ក្នុងការនាំឧក្រិដ្ឋជនទៅផ្ដន្ទាទោស ។ ប្រទេសជាច្រើនក៏កំពុងតែត្រួតពិនិត្យឡើងវិញនូវច្បាប់របស់ខ្លួន ដើម្បីធានាថា ការបំពាននៃបច្ចេកវិជ្ជាទូរគមនាគមន៍ត្រូវបានដាក់ទណ្ឌកម្មគ្រប់គ្រាន់ ។

កិច្ចខិតខំប្រឹងប្រែងទាំងនេះ បានឈានដល់កម្រិតកំពូលក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីយុត្តិធម៌ និងមហាផ្ទៃនៃក្រុមប្រទេសឧស្សាហកម្មទាំង ៨ ដែលកិច្ចខិតខំប្រឹងប្រែងជាសំខាន់ គឺដើម្បីបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិថ្មីៗ ស្ដីពីឧក្រិដ្ឋកម្មដែលមានបច្ចេកវិជ្ជាខ្ពស់ ។ ក្រុមរដ្ឋមន្ត្រីបានយល់ព្រមចំពោះផែនការចំណាត់ការ ដែលបានរួមបញ្ចូលការប្ដេជ្ញាដើម្បី ៖

- ធានាថា មន្ត្រីអនុវត្តច្បាប់ និងសម្ភារៈបច្ចេកទេស ត្រូវមានគ្រប់គ្រាន់ និងទទួលការបណ្ដុះបណ្ដាល ដើម្បីត្រៀមបម្រុង ធ្វើការងារប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានបច្ចេកវិជ្ជាខ្ពស់
- បង្កើតបណ្ដាញទំនាក់ទំនងមានបច្ចេកវិជ្ជាខ្ពស់ ដែលអាចធ្វើការ ២៤ ម៉ោងក្នុងមួយថ្ងៃ ដើម្បីឆ្លើយតបក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្មដែលមានបច្ចេកវិជ្ជាខ្ពស់
- ជំរុញការអភិវឌ្ឍថែមទៀត ដើម្បីតាមដានការវាយប្រហារតាមប្រព័ន្ធបច្ចេកវិជ្ជា ។

**ខ. នីតិកម្មថ្មី**

ឧបករណ៍នីតិកម្មថ្មីៗក៏ចាំបាច់ផងដែរ ដើម្បីប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជាដែលមានបច្ចេកទេសខ្ពស់ និងឧក្រិដ្ឋកម្មហិរញ្ញវត្ថុ ។ ច្បាប់ត្រូវបានស្នើឡើង និងផ្ដល់អំណាចឱ្យប្រើប្រាស់ការឈ្លបយកការណ៍តាមអេឡិចត្រូនិក ដែលឥឡូវត្រូវបានកំហិតចំពោះបទល្មើសទាំងឡាយ

ដូចជាការជួញដូរគ្រឿងញៀន និងឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយអ្នកជំនួញ ឬមន្ត្រីការិយាល័យ នៅក្នុងការស៊ើបអង្កេតលើបទល្មើសតាមប្រព័ន្ធបច្ចេកវិជ្ជា ។

**គ. ការប្រឈមនឹងបញ្ហានៃការដាក់លេខសម្ងាត់**

ការប្រើប្រាស់ដ៏ទូលំទូលាយនៃការដាក់លេខសម្ងាត់ដោយក្រុមឧក្រិដ្ឋជន បង្កើតជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ដល់សុវត្ថិភាពសាធារណៈ ។ ការដាក់លេខសម្ងាត់អាចត្រូវការប្រើប្រាស់ ដោយក្រុមឧក្រិដ្ឋជន ទាក់ទងអំពីគោលបំណងឧក្រិដ្ឋកម្ម និងរក្សាភស្តុតាងឧក្រិដ្ឋរបស់ពួកគេ ដែលត្រូវរក្សាទុកដោយប្រព័ន្ធអេឡិចត្រូនិក ក្នុងទម្រង់មួយដែលរារាំងដល់ការស្វែងរក ។

**៦. ការស្រាវជ្រាវបញ្ហាដែលកំពុងកើតឡើង**

ការរីកចម្រើនខាងបច្ចេកវិជ្ជា រួមមានប្រព័ន្ធផ្សព្វផ្សាយ សម្រាប់ធ្វើកិច្ចការជំនួញហិរញ្ញវត្ថុតាមប្រព័ន្ធអេឡិចត្រូនិក ដូចជា ប័ណ្ណឥណទាន (Smart card) ។ សព្វថ្ងៃ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាឧស្សាហកម្មដែលបានចំណូលប្រហែល ៤០០ លានដុល្លារអាម៉េរិក ក្នុងមួយឆ្នាំ ប៉ុន្តែត្រឹមឆ្នាំ ២០០០ វាអាចកើនឡើងដល់ ៣ ០០០ ពាន់លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ ។ បច្ចេកវិជ្ជា Smart card នឹងអាចរក្សាតម្លៃរូបិយប័ណ្ណដ៏ច្រើននៅលើកាតមួយ ហើយអាចផ្ទេរទៅកាន់កាតមួយទៀត ឬជុំវិញពិភពលោក តាមរយៈកុំព្យូទ័រ ឬទូរស័ព្ទ ។ បច្ចេកវិជ្ជានេះ កំពុងតែមានលក្ខណៈស្តង់ដាយ៉ាងលឿន សម្រាប់សេវាកម្មទូរគមនាគមន៍ និងហិរញ្ញវត្ថុ ។ ការផ្លាស់ប្តូរពីក្រដាសប្រាក់ទៅជាប្រាក់តាមអេឡិចត្រូនិក នឹងបង្ហាញនូវការប្រកួតប្រជែងអន្តរជាតិថ្មីសម្រាប់មន្ត្រីអនុវត្តច្បាប់ ក្នុងការប្រឆាំងការសម្អាតប្រាក់ និងឧក្រិដ្ឋកម្មក្លែងបន្លំ ដោយសារតែចំនួនប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានរក្សាទុកនៅលើ Smart card ។

មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីសន្តិសុខជាតិ បានកំពុងតែពិភាក្សាគ្នាជាមួយសមភាគីរបស់ខ្លួនក្នុងការរៀបចំភាពបន្ទាន់នៃឧស្សាហកម្មទូរគមនាគមន៍ ចំណុចខ្សោយរបស់ប្រព័ន្ធ និងបញ្ហាដែលទាក់ទងផ្សេងទៀត ។ ភាពជាដៃគូរដ្ឋ-ឯកជន ដែលសំដៅទប់ស្កាត់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិជ្ជា និងការពារហេដ្ឋារចនាសម្ព័ន្ធក៏មានសារៈសំខាន់ផងដែរ ។ ផ្នែកឯកជន និងមន្ត្រីអនុវត្តច្បាប់ បានសហការជាមួយគ្នាក្នុងការធ្វើសន្និសីទ ស្តីពីឧក្រិដ្ឋកម្មដែលមានបច្ចេកវិជ្ជាខ្ពស់ ។

## XII. គោលការណ៍ផ្សេងៗដើម្បីប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង

ប្រទេសជាច្រើន បានផ្តល់នូវប្រាក់រាប់កោដិដុល្លារអាម៉េរិក ដើម្បីប្រយុទ្ធប្រឆាំងក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំង តាមរយៈគោលការណ៍ច្បាប់ព្រហ្មទណ្ឌ ដែលមានស្រាប់ ។ ការកើនចំនួនថវិកាអនុវត្តច្បាប់ ត្រូវរួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេតដ៏ខ្លាំងក្លា ការស៊ើបការណ៍ និងកិច្ចខិតខំប្រឹងប្រែងគំហាត់ (ការដកសិទ្ធិមិនឱ្យធ្វើតាមអំពើចិត្ត) ច្បាប់ថ្មីដ៏មានឥទ្ធិពល និងឧបករណ៍ច្បាប់ ។ ទោះបីជាមានការពង្រីក និងការធ្វើឱ្យរឹតតែខ្លាំងឡើងនៃកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ និងសមិទ្ធិកម្មនៃជោគជ័យរាប់មិនអស់ដោយរួមទាំងការដាក់ពន្ធនាគារនូវ ឧក្រិដ្ឋជនគ្រឿងញៀន ការរឹបអូសទ្រព្យធំនៃទំនិញរត់ពន្ធ និងការបំផ្លាញក្រុមអង្គការឧក្រិដ្ឋជន និងការកាត់បន្ថយការប្រកបបរទុច្ចរិត

ផ្តាច់មុខនៃក្រុមឧក្រិដ្ឋជនក៏ដោយ គោលការណ៍អនុវត្តច្បាប់ដែលមានជាយូរមកហើយ នៅតែមិនទាន់ទៅដល់គោលដៅរបស់ខ្លួននៃការបង្ក្រាបសកម្មភាពក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងនៅឡើយទេ ។

ចំពោះការប្រឈមដែលបង្កើតឡើងដោយលក្ខណៈស្មុគស្មាញ និងទំហំកាន់តែកើនឡើងរបស់ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងឆ្លងដែន គួបផ្សំនឹងការអនុវត្តច្បាប់ជាយូរមកហើយ នៅមានកម្រិតមន្ត្រីអនុវត្តច្បាប់ចាំបាច់ស្វែងរកជម្រើស និងគោលការណ៍ថ្មីៗ ដោយកំណត់លក្ខណៈដូចខាងក្រោម ៖

- គោលការណ៍គ្រឹះដែលបានដាក់ឱ្យអនុវត្ត មានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ជាពិសេសសម្រាប់មន្ត្រីអនុវត្តច្បាប់ និងស្ថាប័នអយ្យការ
- គោលការណ៍អនុវត្តយុទ្ធសាស្ត្រឆ្លើយតប តាមស្ថានភាពជាក់ស្តែង
- ភាពម្ចាស់ការនៃកិច្ចប្រតិបត្តិការរបស់មន្ត្រីអនុវត្តច្បាប់ ក្នុងដែនសមត្ថកិច្ច
- ការចោទប្រកាន់ និងស៊ើបអង្កេតបែបប្រពៃណី( គំហាត់ យុទ្ធវិធីស៊ើបការណ៍ ប្រតិបត្តិការសម្ងាត់ ភ្នាក់ងារផ្តល់ព័ត៌មាន ការរឹបអូសភស្តុតាង...)
- ទំនុកចិត្តទៅលើ( គំរូផ្តន្ទាទោស ) ទណ្ឌកម្មដល់ឧក្រិដ្ឋជន ដោយសង្កត់ធ្ងន់លើការដាក់ទណ្ឌកម្ម និងការដាក់ពន្ធនាគារ ។

ដោយសារតែឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ប៉ះពាល់ស្ទើរតែគ្រប់ផ្នែកទាំងអស់នៃសង្គម ការរិះរកវិធានផ្សេងៗគ្នា ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម ។ ជាទូទៅ គោលការណ៍ច្បាប់ព្រហ្មទណ្ឌបែបថ្មីដែលពីមុនមិនត្រូវបានប្រើ ឥឡូវត្រូវបានប្រើដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ៖

- សហគមន៍ ៖ ការទប់ស្កាត់ឧក្រិដ្ឋកម្ម
- ការចូលរួមរបស់ប្រជាពលរដ្ឋដោយប្រយោល ៖ ការចែករំលែកព័ត៌មាន ការអប់រំ ការលើកកម្ពស់កម្រិតយល់ដឹង និងទូរស័ព្ទប្រើក្នុងពេលមានអាសន្ន
- ការចូលរួមរបស់ប្រជាពលរដ្ឋដោយផ្ទាល់ ៖ បណ្តឹងរដ្ឋប្បវេណី មេធាវី ចៅក្រម
- ការធ្វើគោលនយោបាយសហគមន៍ គោលនយោបាយសាធារណៈ ផ្នែកឯកជន ការអប់រំ កម្មវិធី និងដំណោះស្រាយក្រៅប្រព័ន្ធច្បាប់ ៖
  - គោលនយោបាយបទប្បញ្ញត្តិ កម្មវិធី និងមន្ត្រី
  - ការរាយការណ៍ពីរូបិយប័ណ្ណ និងសកម្មភាពគួរឱ្យសង្ស័យ
  - កម្មវិធី និងគោលនយោបាយសារពើពន្ធ
  - ការពិន័យរដ្ឋប្បវេណី
  - កងកម្លាំងប្រដាប់អាវុធ
  - គោលនយោបាយ និងកម្មវិធីការបរទេស
  - គណៈកម្មការរបស់រដ្ឋាភិបាល
  - ក្រុមហ៊ុននីមួយៗ
  - សមាគមអ្នកមានអាជីព និងឧស្សាហកម្ម
  - កម្មវិធីប្រឆាំងនឹងការក្លែងបន្លំ និងការសម្អាតប្រាក់

- ការធ្វើគោលនយោបាយឯកជន និងគណនេយ្យ ដែលសម្រាប់អនុវត្តតាមច្បាប់
- មជ្ឈមណ្ឌលស្រាវជ្រាវ និងក្រុមជំនាញគោលនយោបាយសាធារណៈ កិច្ចសហប្រតិបត្តិការពហុផ្នែក និងពហុដែនសមត្ថកិច្ច
- ភាពជាដៃគូសម្រាប់អនុវត្តក្នុងប្រទេស
- មជ្ឈការនៃអំណាច
- ភាពជាដៃគូសម្រាប់អនុវត្តក្នុងកម្រិតអន្តរជាតិ
- ការចែករំលែកព័ត៌មានស៊ើបការណ៍
- ភាពជាដៃគូផ្នែកឯកជន និងរដ្ឋ ។

៙៙៙ ✸ ៚៚៚

# ឯកសារយោង


• ឯកសារមេរៀនរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ២០០៣

- Bourg, Wendy et al; *A Child Interviewer's Guidebook*, Thousand Oaks, CA: Sage Publications, 1999
- Goodman, Gail; Bottoms, Bette; *Child Victims, Child Witnesses: Understanding and Improving Testimony*, New York, NY: The Guilford Press, 1993
- Mapes, Bruce; *Child Eyewitness Testimony in Sexual Abuse Investigations*, Brandon, VT: Clinical Psychology Publishing Co., 1995
- Milne, Rebecca; Bull, Ray; *Investigative Interviewing: Psychology and Practice*, Chichester, West Sussex, UK: John Wiley & Sons Press, 1999
- Morgan, Marcia; *How to Interview Sexual Abuse Victims Including the Use Of Anatomical Dolls*, Thousand Oaks, CA: Sage Publications, 1995
- Poole, Debra A; *Investigative Interviews of Children: A Guide for Helping Professionals*, Washington, DC: American Psychological Association, 1998
- Schafer, John; Navarro, Joe; *Advanced Interviewing Techniques: Proven Strategies for Law Enforcement, Military, and Security Personnel*, Springfield. IL: Thomas Books, 2003
- Shuy, Roger W.; *The Language of Confession, Interrogation, and Deception*, Thousand Oaks, CA: Sage Publications, 1998
- Swanson, Charles R. et al; *Criminal Investigation*, Boston, MA: McGraw Hill Publications, 2003, 8th edition
- Yeschke, Charles; *The Art of Investigative Interviewing: A Human Approach to Testimonial Evidence*, Boston, MA: Butterworth-Heinemann Press, 1997

**MANUALS USED**

- Faller, Kathleen C.; *Child Sexual Abuse: Intervention and Treatment Issues*, U.S. Department of Health and Human Services Administration for Children and Families, McLean, VA: The Circle, Inc, 1993
- Ministry of Interior, General Director of National Police, Kingdom of Cambodia; *Understanding and Investigating Child Sexual Exploitation*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2000
- Ministry of Interior, General Director of National Police, Kingdom of Cambodia; *Training Document on Child Victim Sensitivity*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2003
- Sas, Louise; *The Interaction Between Children's Developmental Capabilities and the Courtroom Environment: The Impact on Testimonial Competency*, Report prepared for the Department of Justice Canada, 2002

**OTHER MATERIALS USED**

- U. S. Department of State Trafficking in Persons Report, 2004

**WEB SITES USED**

- HTTP://www.childdevelopmentinfo.com/development/language_development.shtml
- HTTP://www.families.qld.gov.au/projectaxis/orgbooklet/development.html
- HTTP://danenet.wicip.org/dcccrsa/saissues/parent/1.html
- HTTP://www.aacap.org/publications/factsfam/develop.htm
- HTTP://www.secasa.com.au/index.php/family/12/120
- HTTP://www.earlychildhoodbehavioralhealth.com/ChildDev/sexdevelop.htl
- HTTP://www.ces.perdue.edu/providerparent/Child%20Growth-Development/SexualDEV.htm
- HTTP://www.state.gov/g/tip/rls/tiprpt/2004/34021pf.htm